ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា



# ផែនការយុទ្ធសាស្ត្រវិស័យអប់រំ
# ឆ្នាំ២០២៤-២០២៨

ខែមិថុនា ឆ្នាំ២០២៤

# អារម្ភកថា

ក្នុងរយៈពេល១០ឆ្នាំ នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ និង២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធបានរួមគ្នាសម្រេចកិច្ចការធំៗគួរឱ្យកត់សម្គាល់ដូចជា ការបង្កើនការចូលរៀនប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ននៅគ្រប់ភូមិសិក្សា ការពង្រឹងអភិបាលកិច្ចនៅតាមគ្រឹះស្ថានសិក្សា ការយកចិត្តទុកដាក់លើគ្រូបង្រៀន និងការដោះស្រាយការខាតបង់ការសិក្សាក្នុងបរិបទកូវីដ-១៩។ ក្រសួងបានសម្រួចវិធានការពាក់ព័ន្ធក្នុងគោលដៅលើកកម្ពស់គុណភាព និងភាពឆ្លើយតបរបស់សេវាអប់រំ តាមរយៈការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន ការលើកទឹកចិត្តបុគ្គលិកអប់រំ ការបង្កើនស្វ័យភាព គណនេយ្យភាព និងភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសេវាអប់រំនៅគ្រប់លំដាប់ថ្នាក់។ ជាមួយគ្នានេះ ក្រសួងក៏បានឆ្លើយតបនឹងការអនុវត្តកំណែទម្រង់របស់រាជរដ្ឋាភិបាលសំខាន់ៗ ដូចជាកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការកសាងសមត្ថភាពស្ថាប័នផងដែរ។

យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល អាណត្តិទី៧នៃរដ្ឋសភា បានកំណត់មនុស្ស ជាអាទិភាពទីមួយ និងនៅក្នុងបញ្ចកោណទី ១ បានលើកឡើងអំពី "ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា"។ ឈរលើមូលដ្ឋាននេះ ក្រសួងបានកំណត់អាទិភាពចំនួនប្រាំបី៖ ១).ការពង្រឹងអភិបាលកិច្ចសាលារៀន, ២).ការពិនិត្យ និងកែសម្រួលកម្មវិធីសិក្សា និងសកម្មភាពបន្ថែមក្រៅម៉ោងសិក្សាស្របតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងអាកប្បកិរិយារបស់សិស្ស, ៣).ការថែរក្សាសុខភាពសិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភរបស់កុមារ និងការគ្រប់គ្រងគុណភាពអាហារនៅតាមសាលារៀន, ៤).ការជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមពីមាតាបិតា អាណាព្យាបាល និងសហគមន៍ក្នុងវិស័យអប់រំ ស្របពាក្យស្លោកភាពជាដៃគូរដ្ឋ និងសហគមន៍ក្នុងការអប់រំ, ៥).ការពង្រឹងការអប់រំឌីជីថល, ៦). ការជំរុញមជ្ឈមណ្ឌលឧត្តមភាពក្នុងការអប់រំឧត្តមសិក្សា, ៧).ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព, និង៨).ការអភិវឌ្ឍការអប់រំកាយ និងកីឡា។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០២៤-២០២៨ ត្រូវបានរៀបចំឡើង ដើម្បីប្រែក្លាយអាទិភាពដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១, កំណែទម្រង់វិស័យអប់រំ, និងគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព ស្តីពីការអប់រំ ឆ្នាំ២០៣០ ឱ្យទៅជាការអនុវត្តជាក់ស្តែង និងនាំទៅរកសមិទ្ធកម្មពិតប្រាកដ ប្រកបដោយការទទួលខុសត្រូវ និងគណនេយ្យភាពរបស់អង្គភាពគ្រប់កម្រិត រួមទាំងគ្រឹះស្ថានសិក្សា។

ក្រសួងបានបង្រួមខ្លឹមសារគោលនយោបាយអប់រំឱ្យនៅតែមួយ «**ធានាឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត**»។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០២៤-២០២៨ បន្តផ្តោតលើការធ្វើកំណែទម្រង់អប់រំនៅគ្រប់កម្រិត និងគ្រប់ផ្នែក ជាពិសេសកំណែទម្រង់សាលារៀនឆ្ពោះទៅសម្រេចស្តង់ដាសាលារៀនគំរូ និងកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០២៤-២០២៨ ផ្តោតលើការអនុវត្តអភិក្រមនៃការគ្រប់គ្រងរចនាសម្ព័ន្ធតាមរយៈកម្មវិធី និងអនុកម្មវិធី ដោយបានកែសម្រួលវត្ថុបំណង ក្របខណ្ឌយុទ្ធសាស្ត្រ សកម្មភាពចម្បង និងតម្រូវការធនធាន ព្រមទាំងរៀបចំក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃ និងយន្តការផ្តល់ព័ត៌មានត្រឡប់ និងការពិនិត្យឡើងវិញ ដើម្បីធានាបាននូវការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម។

ក្រសួងអប់រំ យុវជន និងកីឡាសូមថ្លែងអំណរគុណចំពោះបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងក្រុមការងារវិស័យអប់រំ ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣ និងកំណែទម្រង់វិស័យ ប្រកបដោយលទ្ធផលជាផ្លែផ្កា និងជាមូលដ្ឋានសម្រាប់ការអនុវត្តបន្តនៅឆ្នាំ ២០២៤-២០២៨។ ក្រសួងសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០២៤-២០២៨ និងការផ្តល់ធាតុចូលសព្វបែបយ៉ាងពីគ្រប់ភាគី។ ក្រសួងនឹងបន្តកិច្ចសហការជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០២៤-២០២៨ ឱ្យទទួលបានសមិទ្ធផលតាមការគ្រោងទុក។

ថ្ងៃសុក្រ ៧រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# មាតិកា


**ជំពូកទី១៖ ការវិភាគការបំពេញការងារ ២០១៩-២០២៣** ........ ១

១.១ បរិបទសង្គម-សេដ្ឋកិច្ច និងនិន្នាការប្រជាសាស្ត្រ ........ ១

១.២ សមិទ្ធផលនៃកំណែទម្រង់អប់រំ (២០១៤-២០២៣) ........ ៤

១.៣ ការវិភាគសមិទ្ធផលតាមអនុវិស័យ ........ ៩

១.៤ ការវិភាគសមត្ថភាព និងការគ្រប់គ្រង ........ ៣០

**ជំពូកទី២៖ ក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍវិស័យអប់រំឆ្នាំ២០២៤-២០២៨** ៣៨

២.១ របៀបវារៈការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ........ ៣៨

២.២ ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា ........ ៤១

២.៣ អាទិភាពឆ្លើយតបនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ (២០២៤-២០២៨) ........ ៤២

២.៤ គោលការណ៍ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ ........ ៥៤

**ជំពូកទី ៣៖ ផែនការតាមកម្មវិធី និងអនុកម្មវិធី២០២៤-២០២៨** ........ ៥៨

៣.១ រចនាសម្ព័ន្ធកម្មវិធីអាទិភាព អនុកម្មវិធី និងលទ្ធផលរំពឹងទុក ........ ៥៩

៣.២ សូចនាករសមិទ្ធកម្មគន្លឹះ និងចំណុចដៅសម្រាប់ឆ្នាំ ២០២៤-២០២៨ ........ ៦០

៣.៣ កម្មវិធីអាទិភាព១៖ កំណែទម្រង់សាលារៀនដើម្បីការចូលរៀនមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន ........ ៦១

៣.៤ កម្មវិធីអាទិភាពទី២៖ ការកែលម្អការចូលរៀន គុណភាព និងឆ្លើយតបនៃការអប់រំឧត្តមសិក្សា និងការស្រាវជ្រាវ និងនវានុវត្តន៍ ........ ៩៧

៣.៥ កម្មវិធីអាទិភាពទី៣៖ ការលើកកម្ពស់ជំនាញសតវត្សរ៍ទី២១ សម្រាប់យុវជន ........ ១១២

៣.៦ កម្មវិធីអាទិភាពទី ៤៖ ការអភិវឌ្ឍសកម្មភាពហាត់ប្រាណ ការអប់រំកាយ និងកីឡា ........ ១២៥

៣.៧ កម្មវិធីអាទិភាពទី៥៖ ការលើកកម្ពស់ការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ........ ១៣៥

**ជំពូកទី៤៖ ការគណនាតម្រូវការ ការព្យាករថវិកា និងជម្រើសហិរញ្ញប្បទាន** ........ ១៧៤

៤.១ ការព្យាករតម្រូវការថវិកានៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ........ ១៧៥

៤.២ ការព្យាករថវិកាសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ........ ១៨១

៤.៣ គម្លាតថវិកា និងយុទ្ធសាស្ត្រកៀរគរធនធាន ........ ១៨៥

**ជំពូកទី៥៖ ក្របខ័ណ្ឌការពិនិត្យតាមដាន និងវាយតម្លៃ** ........ ១៨៩

៥.១ ដំណើរការ ........ ១៨៩

៥.២ តួអង្គពាក់ព័ន្ធ ........ ១៩៣

៥.៣ សូចនាករពិនិត្យតាមដាន និងវាយតម្លៃ ........ ១៩៦

**ជំពូកទី៦៖ ការកំណត់ហានិភ័យចម្បងៗ និងជម្រើសកាត់បន្ថយ** ........ ១៩៧

៦.១ ហានិភ័យខាងក្រៅដែលជះឥទ្ធិពលដល់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ........ ១៩៧



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

៦.២ ហានិភ័យខាងក្នុងដែលជះឥទ្ធិពលដល់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងការរៀបចំយុទ្ធសាស្ត្រក្នុងការអនុវត្ត ........ ១៩៩

**តារាងឧបសម្ព័ន្ធ** ........ ២០៣

តារាងឧបសម្ព័ន្ធទី១៖ សូចនាករសមិទ្ធកម្មគន្លឹះ ........ ២០៣

តារាងឧបសម្ព័ន្ធទី២៖ សូចនាករផលសម្រេច ........ ២០៦

តារាងឧបសម្ព័ន្ធទី៣៖ សូចនាករលទ្ធផល ........ ២១៣

តារាងឧបសម្ព័ន្ធទី៤៖ ចំណោលចំនួនសិស្ស និងតម្រូវការអប់រំ ........ ២៤០

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ជំពូកទី១៖ ការវិភាគការបំពេញការងារ ២០១៩-២០២៣

## ១.១ បរិបទសង្គម-សេដ្ឋកិច្ច និងនិន្នាការប្រជាសាស្ត្រ

ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ សេដ្ឋកិច្ចកម្ពុជា បានផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ពីសេដ្ឋកិច្ចដែលពឹងផ្អែកខ្លាំងលើកសិកម្មទៅជាសេដ្ឋកិច្ចឧស្សាហកម្ម និងការនាំចេញ។ វិស័យឧស្សាហកម្មបានកើនយ៉ាងឆាប់រហ័សពី ២២,០ ភាគរយ នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០០០ ដល់ ៤១,០ ភាគរយ ក្នុងឆ្នាំ២០២២។ ទន្ទឹមនឹងនេះ វិស័យកសិកម្មបានធ្លាក់ចុះពី ៣៦,០ ភាគរយ នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០០០ មកនៅត្រឹម ១៧,០ ភាគរយ នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០២២។ វិស័យនានាក៏បានផ្លាស់ប្តូរយ៉ាងឆាប់រហ័សក្នុងរយៈពេលនេះ។ គំរូកំណើនដែលផ្លាស់ប្តូរនេះ បានបង្ហាញឱ្យឃើញជាក់ស្តែងនូវភាពជឿនលឿននៃការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា និងបានឈានដល់ដំណាក់កាលនៃការអភិវឌ្ឍជាបន្តបន្ទាប់។

បន្ទាប់ពីរងផលប៉ះពាល់ដោយសារវិបត្តិជំងឺកូវីដ-១៩ សេដ្ឋកិច្ចកម្ពុជាបានបង្ហាញពីសញ្ញាវិជ្ជមាននៃការងើបឡើងវិញ និងភាពធន់ ដោយមានកំណើនសេដ្ឋកិច្ច ៥,១ ភាគរយ នៅឆ្នាំ២០២២ និង ៥,០ ភាគរយ នៅឆ្នាំ២០២៣ (ផលិតផលក្នុងស្រុកសរុបឆ្នាំគោល ២០១៤)។ កំណើននៅឆ្នាំ២០២៣ បានធ្លាក់ចុះបន្តិចមកវិញដោយសារតែការធ្លាក់ចុះនៃតម្រូវការខាងក្រៅ ដែលបណ្តាលឱ្យវិស័យកាត់ដេរមានការធ្លាក់ចុះ ខណៈពេលដែលការផលិតក្រៅពីវិស័យកាត់ដេរបន្តមានសន្ទុះខ្លាំង ព្រមទាំងការងើបឡើងវិញនៃវិស័យទេសចរណ៍។ នៅឆ្នាំ២០២៤ សេដ្ឋកិច្ចត្រូវបានព្យាករណ៍ថា នឹងកើនឡើងក្នុងរង្វង់ ៦,០ ភាគរយ និងជាមធ្យម ៦,៥ ភាគរយ សម្រាប់រយៈពេលមធ្យម (២០២៥-២០២៧)។ ទោះជាយ៉ាងណាក៏ដោយ ហានិភ័យ និងភាពមិនប្រាកដប្រជានៅតែមានកម្រិតខ្ពស់ ហើយសេដ្ឋកិច្ចកម្ពុជានៅតែងាយប៉ះទង្គិចពីកត្តាខាងក្រៅខ្លាំង ខណៈដែលបញ្ហារចនាសម្ព័ន្ធជាច្រើននៅតែបន្តកើតមាន ជាពិសេសការពឹងផ្អែកលើកម្លាំងពលកម្មជំនាញទាប និងការនាំចេញមានតម្លៃបន្ថែមទាប ដើម្បីប្រកួតប្រជែងក្នុងទីផ្សារពិភពលោក ព្រមទាំងដំណើរការធ្វើពិពិធកម្មយឺត។

ក្នុងរយៈពេលមធ្យម និងវែង ការរក្សាបាននូវភាពប្រកួតប្រជែង និងការបង្កើនការធ្វើពិពិធកម្ម គឺជាទិសដៅគោលនយោបាយដ៏សំខាន់ ដូចមានចែងក្នុង «យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១» ស្តីពីការអភិវឌ្ឍមូលធនមនុស្ស៖ មុំទី១) ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលជាកត្តាគន្លឹះដើម្បីរក្សាចីរភាពនៃកំណើន និងការពង្រឹងភាពធន់សង្គម-សេដ្ឋកិច្ច។ ការអភិវឌ្ឍមូលធនមនុស្សនឹងត្រូវគិតគូរពិចារណាក្នុងទិដ្ឋភាពសំខាន់ៗដូចខាងក្រោម៖

- ការរៀបចំជំនាញឡើងវិញ និងការបង្កើនជំនាញ ដោយផ្អែកលើ «ការសិក្សាពេញមួយជីវិត» ដើម្បីធានាបាននូវភាពបត់បែន និងការឆ្លើយតបបរិវត្តកម្មសង្គម-សេដ្ឋកិច្ច ព្រមទាំងសមត្ថភាពគ្រប់គ្រាន់ក្នុងការចាប់យកឱកាសថ្មីៗ
- ការកសាងប្រព័ន្ធគាំពារសង្គម ដែលឆ្លើយតបទៅនឹងការផ្លាស់ប្តូរសង្គម-សេដ្ឋកិច្ច ក្នុងគោលបំណងបង្កើត និងបង្កើនបណ្តាញសន្តិសុខសង្គម ដើម្បីលើកកម្ពស់ការគាំពារសង្គម ជាពិសេសក្រុមងាយរងគ្រោះ

➢ ការដាក់បញ្ចូលការប្រើប្រាស់ឌីជីថលក្នុងការអប់រំ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការសិក្សា និងសមត្ថភាពក្នុងការចាប់យកអ្វីដែលថ្មី ដែលជាមូលដ្ឋានគ្រឹះក្នុងការបង្កើត និងបង្កើនភាពធន់ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃសង្គម-សេដ្ឋកិច្ច។

ការទទួលស្គាល់ពីសារៈសំខាន់នៃការអភិវឌ្ឍធនធានមនុស្សតាមរយៈការលើកកម្ពស់គុណភាព និងការវាយតម្លៃការអប់រំ និងការអភិវឌ្ឍជំនាញ ក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម២០២៥-២០២៧ [1] រាជរដ្ឋាភិបាលកម្ពុជាបានកំណត់អាទិភាពលើវិស័យសង្គម ដែលក្នុងនោះមានវិស័យសុខាភិបាល និងវិស័យអប់រំ ជាវិស័យអាទិភាពនៅក្នុងការវិភាជន៍ថវិកា។ ការចំណាយលើវិស័យសង្គម ត្រូវបានគ្រោងទុកក្នុងរង្វង់ ៥,២៧ ភាគរយ នៃផលិតផលក្នុងស្រុកសរុបជាមធ្យមសម្រាប់រយៈពេលមធ្យម (២០២៥-២០២៧) ស្មើនឹងអត្រាកំណើនប្រចាំឆ្នាំជាមធ្យម ១១,១ ភាគរយ ក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំ និងការអភិវឌ្ឍជំនាញដែលឆ្លើយតបនឹងទីផ្សារ ការពង្រីកវិសាលភាពនៃការទទួលបានការថែទាំសុខភាព ឆ្ពោះទៅរកភាពគ្របដណ្តប់សុខភាពជាសកល និងជំរុញការអនុវត្តកម្មវិធីជាតិគាំពារសង្គម និងគោលនយោបាយអាទិភាពផ្សេងទៀត។

តួនាទីសំខាន់នៃការអប់រំ ដើម្បីសម្រេចបាននូវស្ថិរភាពនៃកំណើន និងបរិយាបន្ន គឺជាភស្តុតាងជាក់ស្តែងនៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់កម្ពុជា ដែលជាការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការធានាគុណភាពអប់រំមូលដ្ឋានថ្នាក់ទី៩ ដល់កុមារ និងយុវជនកម្ពុជាទាំងអស់នៅឆ្នាំ២០៣០។

រចនាសម្ព័ន្ធប្រជាសាស្ត្របច្ចុប្បន្ន នាំឱ្យមានការវិនិយោគលើការអប់រំ និងជំនាញសម្រាប់កុមារដែលដល់វ័យអាយុចូលរៀន ដើម្បីបង្កើននិរន្តរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ក្នុងរយៈពេលមធ្យម និងវែង។ អត្រាអ្នកនៅក្នុងបន្ទុកមានកម្រិតទាបនៅពេលបច្ចុប្បន្ន ៦០,០ ភាគរយ ក្នុងឆ្នាំ២០២៣ (មានន័យថា ៦០ នាក់ ក្នុង១០០នាក់ នៅក្នុងបន្ទុក) ត្រូវបានព្យាករណ៍ថា នឹងធ្លាក់ចុះបន្ថែមទៀតនៅប៉ុន្មានឆ្នាំខាងមុខនេះ។ នៅឆ្នាំ២០៥០ ដោយសារចំនួនប្រជាជនមានវ័យចំណាស់ អត្រាអ្នកនៅក្នុងបន្ទុកនឹងចាប់ផ្តើមកើនឡើងលើសពីកម្រិតនាពេលបច្ចុប្បន្ននេះ ដែលត្រូវបានព្យាករណ៍ថាមាន ៦៣,០ ភាគរយ ក្នុងឆ្នាំ២០៥០ ជាមួយនឹងអត្រាកុមារក្នុងបន្ទុកធ្លាក់ចុះដល់ ២៥,២ ភាគរយ (បច្ចុប្បន្ន ៤៣,៩ ភាគរយ ក្នុងឆ្នាំ២០២៣) និងអត្រាប្រជាជនវ័យចំណាស់ក្នុងបន្ទុកកើនដល់ ៣៧,៨ ភាគរយ (បច្ចុប្បន្ន ១៦,២ ភាគរយ)។ ប្រជាជនវ័យចំណាស់មានការកើនឡើង ផ្អែកតាមការព្យាករក្នុងរយៈពេលជាច្រើនទសវត្សរ៍ខាងមុខ ដែលនឹងនាំឱ្យកើនឡើងនូវចំណាយសន្តិសុខសង្គម ដោយរាជរដ្ឋាភិបាលគួរតែកាត់បន្ថយការចំណាយសាធារណៈ ការបង្កើនផលិតភាពមនុស្សវ័យជំទង់នាពេលអនាគត តាមរយៈការវិនិយោគប្រកបដោយប្រសិទ្ធភាពក្នុងវិស័យអប់រំបច្ចុប្បន្ននេះ គឺជាកត្តាគន្លឹះក្នុងការទទួលបាននិរន្តរភាពហិរញ្ញវត្ថុក្នុងរយៈពេលមធ្យម និងវែង។

ចំនួនប្រជាជនដល់អាយុចូលរៀននឹងស្ថិតនៅថេរក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ដែលជាឱកាសល្អសម្រាប់លើកកម្ពស់ការទទួលបានសេវាអប់រំ ដើម្បីសម្រេចការអប់រំមូលដ្ឋានជាសកលនៅឆ្នាំ២០៣០។ នៅឆ្នាំ

[1] ការធ្វើចំណោលផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ បង្ហាញនៅក្នុងជំពូកទី៤ ផ្អែកលើក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម២០២៥-២០២៧ ជាព័ត៌មានដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយនៅខែមេសា ឆ្នាំ២០២៤

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

២០១៩ ដល់ ២០៣០ ប្រជាជនដែលមានអាយុចូលរៀន (អាយុ៣-១៧ ឆ្នាំ) ត្រូវបានព្យាករណ៍នៅថេរខណៈដែលប្រជាជនដែលមានអាយុលើសពី ១៧ ឆ្នាំ រំពឹងថានឹងកើនឡើងដល់ ២៩,០ ភាគរយ (តារាង ១.១)។ និន្នាការផ្ទុយគ្នានេះ មានភាពពាក់ព័ន្ធពីរចំណុចសំខាន់ដល់គោលនយោបាយអប់រំ។ ទីមួយ គឺមានភាពងាយស្រួលក្នុងការលើកកម្ពស់ការទទួលបានការអប់រំមូលដ្ឋាន ជាពិសេសការអប់រំនៅកម្រិតនីមួយៗ និងទីពីរ តម្រូវការសម្រាប់ឱកាសសិក្សាពេញមួយជីវិត និងការអប់រំនៅឧត្តមសិក្សាក្នុងរយៈពេលមធ្យម និងទៅអនាគត យុវជនជំនាន់ក្រោយរំពឹងថា នឹងទទួលបានការអប់រំកាន់តែច្រើនឡើង។

**តារាង១.១ ៖ ការវិវត្ត និងការព្យាករចំនួនប្រជាជនក្នុងវ័យសិក្សា ឆ្នាំ២០០៨-២០៣០ (គិតជាពាន់នាក់)**

| ប្រជាជនតាមក្រុមអាយុ | ២០០៨ | | ២០១៩ | | ២០២៥ | | ២០៣០ | |
|---|---|---|---|---|---|---|---|---|
| | សរុប | ភាគរយ | សរុប | ភាគរយ | សរុប | ភាគរយ | សរុប | ភាគរយ |
| ០-២ | ៨០៦ | ៦,០% | ៨០៨ | ៥,២% | ៩២៦ | ៥,៣% | ៨៦២ | ៤,៦% |
| ៣-៥ (មត្តេយ្យសិក្សា) | ៨៦០ | ៦,៤% | ៩៤៧ | ៦,១% | ៩៥៤ | ៥,៤% | ៩២៥ | ៤,៩% |
| ៦-១១ (បឋមសិក្សា) | ១ ៧៨៦ | ១៣,៣% | ១ ៨២៩ | ១១,៨% | ១ ៨៤៣ | ១០,៥% | ១ ៨៨៤ | ១០,១% |
| ១២-១៤ (មធ្យមសិក្សាបឋមភូមិ) | ១ ០៦៤ | ៧,៩% | ៩៨៨ | ៦,៤% | ៩១៩ | ៥,២% | ៩២៧ | ៤,៩% |
| ១៥-១៧ (មធ្យមសិក្សាទុតិយភូមិ) | ៩៧៤ | ៧,៣% | ៨៤០ | ៥,៤% | ១ ០១២ | ៥,៨% | ៨៩៥ | ៤,៨% |
| ១៨-២៣ (ឧត្តមសិក្សា) | ២ ០១៦ | ១៥,១% | ១ ៨២៥ | ១១,៧% | ២ ១៧៨ | ១២,៤% | ២ ៣០១ | ១២,៣% |
| ២៥-៦៤ (ការរៀនពេញមួយជីវិត) | ៥ ៣២៥ | ៣៩,៨% | ៧ ៤០៤ | ៤៧,៦% | ៨ ៤៩៧ | ៤៨,៣% | ៩ ២៩០ | ៤៩,៦% |
| ៦៥+ | ៥៦៥ | ៤,២% | ៩១២ | ៥,៩% | ១ ២៥០ | ៧,១% | ១ ៦៥២ | ៨,៨% |
| ចំនួនប្រជាជនសរុប | ១៣ ៣៩៦ | ១០០% | ១៥ ៥៥២ | ១០០% | ១៧ ៥៧៨ | ១០០% | ១៨ ៧៣៦ | ១០០% |

ប្រភព៖ ជំរឿនប្រជាជននៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៨ និងឆ្នាំ២០១៩ និងរបាយការណ៍ស្តីពីការព្យាករចំនួនប្រជាជន NIS ឆ្នាំ២០១៩

ប្រជាជនកម្ពុជារស់នៅជនបទបានធ្វើចំណាកស្រុកមកទីប្រជុំជនកាន់តែកើនឡើង ដោយសារការប្រមូលផ្តុំនៃវិស័យការងារឧស្សាហកម្ម និងសេវាកម្មនៅទីប្រជុំជន។ យោងតាមជំរឿនប្រជាជនឆ្នាំ២០១៩ ប្រជាជន ៦០,៦ ភាគរយ រស់នៅតាមតំបន់ជនបទ បានធ្លាក់ចុះជិត ២០,០ ភាគរយ នៅចន្លោះឆ្នាំ២០០៨ និង ២០១៩។ ដូចគ្នានេះដែរ អត្រាកំណើនជាមធ្យមប្រចាំឆ្នាំសម្រាប់ប្រជាជននៅទីប្រជុំជនបានកើនឡើងពី ២,០ ភាគរយ នៅចន្លោះឆ្នាំ១៩៩៨ និងឆ្នាំ២០០៨ ដល់ ៧,៨ ភាគរយ នៅចន្លោះឆ្នាំ២០០៨ និងឆ្នាំ២០១៩ ដែលបង្ហាញអំពីការធ្វើចំណាកស្រុកពីជនបទទៅទីប្រជុំជនកើនឡើងគួរឱ្យកត់សម្គាល់។ ចំណែកឯ នៅតំបន់ជនបទ អត្រាកំណើនប្រជាជនបានធ្លាក់ចុះពី ១,៣ ភាគរយ ទៅ ១,២ ភាគរយ ជាមធ្យមក្នុងមួយឆ្នាំសម្រាប់ រយៈពេលដូចគ្នានេះ។ រាជធានីភ្នំពេញដែលជាទីក្រុងដ៏សំខាន់របស់ប្រទេសកម្ពុជា មានអត្រាកំណើនខ្ពស់បំផុត ជាមួយនឹងចំនួនប្រជាជនកើនឡើងជាមធ្យម ៤,៩ ភាគរយ នៅចន្លោះឆ្នាំ២០០៨ និង២០១៩ រហូតដល់ ២,៣ លាននាក់ ដែលស្មើនឹង ១៤,៧ ភាគរយ នៃចំនួនប្រជាជនសរុប។ ការផ្លាស់ប្តូរទីលំនៅប្រជាជនពីតំបន់កណ្តាលរាជធានីភ្នំពេញទៅកាន់តំបន់ជាយក្រុង ធ្វើឱ្យចំនួនសិស្សមានចំនួនច្រើនក្នុងមួយថ្នាក់ និងខ្វះគ្រូបង្រៀន។ នៅតំបន់ភាគខាងជើង និងភាគខាងលិចនៃប្រទេស មានចំនួនប្រជាជនកើនឡើង ដែលនាំឱ្យមានការកើនឡើងសាលារៀនពេញដោយលបណ្តោះអាសន្នចំនួនប្រមាណជា ៣០០ ដែលធ្វើឱ្យស្ថានភាពអប់រំនៅទីនោះមានការអភិវឌ្ឍតិចតួច។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ១.២ សមិទ្ធផលនៃកំណែទម្រង់អប់រំ (២០១៤-២០២៣)

ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្ដើមកំណែទម្រង់វិស័យអប់រំក្នុងឆ្នាំ២០១៤ ស្របតាមគោលនយោបាយរយៈពេលមធ្យមពីរគឺ គោលនយោបាយទី១៖ ធានាឱ្យការចូលរៀនមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និងគោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

កំណែទម្រង់នេះត្រូវបានអនុវត្តជាបួនដំណាក់កាលបន្តបន្ទាប់ប្រកបដោយជោគជ័យ ដូចខាងក្រោម៖

- **ដំណាក់កាលទី១៖ កំណែទម្រង់ថ្នាក់ជាតិ (ឆ្នាំ២០១៤)៖** ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញ និងអនុវត្តនូវអាទិភាពកំណែទម្រង់ ៨ចំណុច ដែលមានគោលបំណងបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់កំណែទម្រង់វិស័យអប់រំ។ សមិទ្ធផលសំខាន់ៗក្នុងដំណាក់កាលនេះរួមមាន៖
  - **ការកែលម្អប្រសិទ្ធភាពនៃសេវាអប់រំ៖** គោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្ដីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចត្រូវបានអនុម័ត។ សាលារៀនជំនាន់ថ្មីបានបង្កើតឡើងនៅវិទ្យាល័យព្រះស៊ីសុវត្ថិ និងកម្មវិធីអាហារូបករណ៍សិស្សក្រីក្រនៅមធ្យមសិក្សា ត្រូវបានបង្កើន
  - **កំណែទម្រង់ការគ្រប់គ្រងបុគ្គលិក៖** ការបង្កើនបៀវត្សដល់បុគ្គលិកអប់រំជាបន្តបន្ទាប់ និងការផ្ដល់មូលនិធិដំណើរការសាលារៀន ដោយបានបញ្ចូលទៅក្នុងគណនីរបស់សាលារៀនដោយផ្ទាល់តាមរយៈប្រព័ន្ធធនាគារ
  - **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖** ការបង្កើនថវិកាដំណើរការសាលារៀន ដោយផ្អែកលើប្រកាសអន្តរក្រសួងលេខ ៥០៨ ស្ដីពីការចាប់ផ្ដើមផ្ទេរភារកិច្ចទៅមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត សម្រាប់ការរៀបចំ និងអនុវត្តថវិកាឆ្នាំ២០១៥ ការបង្កើតអង្គភាពលទ្ធកម្ម
  - **កំណែទម្រង់ការប្រឡង៖** ក្រសួងអប់រំ យុវជន និងកីឡា បានផ្ទេរការទទួលខុសត្រូវការប្រឡងថ្នាក់ទី៩ ដល់ថ្នាក់ក្រោមជាតិ និងបានចាប់ផ្ដើមអនុវត្តកំណែទម្រង់ការប្រឡងថ្នាក់ទី១២។ ការប្រឡងជ្រើសរើសគ្រូបង្រៀន ត្រូវបានលើកទឹកចិត្តសិស្សពូកែឱ្យធ្វើជាគ្រូបង្រៀន
  - **ជំនាញសម្រាប់យុវជន៖** ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍយុវជន បានផលិតឯកសារ និងបណ្ដុះបណ្ដាលជំនាញនៅតាមមជ្ឈមណ្ឌលយុវជន
  - **កំណែទម្រង់ឧត្តមសិក្សា៖** ក្រសួងអប់រំ យុវជន និងកីឡា បានផ្ទេរសិទ្ធិឱ្យគ្រឹះស្ថានឧត្តមសិក្សាទទួលខុសត្រូវលើការចេញសញ្ញាបត្រ និងផ្អាកការបង្កើតគ្រឹះស្ថានឧត្តមសិក្សាថ្មី លើកលែងតែគ្រឹះស្ថានឧត្តមសិក្សា ដែលផ្ដោតលើមុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ គំនិតផ្ដួចផ្ដើមសម្រាប់ការអនុវត្ត ដើម្បីពង្រឹងសមត្ថភាពរបស់គ្រឹះស្ថានឧត្តមសិក្សាដែលមានស្រាប់
  - **កំណែទម្រង់អប់រំកាយ និងកីឡាឆ្ពោះទៅស៊ីហ្គេមឆ្នាំ២០២៣៖** គោលនយោបាយអប់រំកាយ និងកីឡាត្រូវបានអនុម័ត និងគណៈកម្មាធិការគ្រប់គ្រងពហុកីឡដ្ឋានជាតិអូឡាំពិកត្រូវបានបង្កើតឡើង ព្រមទាំងការជួសជុលពហុកីឡដ្ឋានជាតិអូឡាំពិកត្រូវបានចាប់ផ្ដើម។ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី** បានធានានូវការ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

លើកទឹកចិត្តបន្ថែមទៀតដល់ការលេងកីឡាគ្រប់ប្រភេទ ជាពិសេសតាមរយៈការបង្កើនប្រាក់លើកទឹកចិត្ត និងប្រាក់រង្វាន់ដល់អត្តពលិកដែលទទួលបានជ័យលាភីមេដាយ

- **ការបង្កើតធនាគារខួរក្បាលសម្រាប់វិស័យអប់រំ៖** ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតក្រុមប្រឹក្សាស្រាវជ្រាវអប់រំ និងលេខាធិការដ្ឋាន។

- **ដំណាក់កាលទី២៖ កំណែទម្រង់ផ្តោតលើសសរស្តម្ភ ៥ (២០១៥ ដល់ ២០១៨)៖** ផ្អែកលើសមិទ្ធផលក្នុងកំណែទម្រង់ដំណាក់កាលទី១ និងលទ្ធផលនៃការប្រឡងថ្នាក់ទី១២ ក្នុងឆ្នាំ២០១៤ (មានបេក្ខជនត្រឹមតែ ២៥,៧ ភាគរយ បានប្រឡងជាប់លើកទី១ និង ១៧,៩ ភាគរយ បានប្រឡងជាប់លើកទី២) ក្រសួងបានដាក់ចេញអាទិភាពកំណែទម្រង់ ១៥ ចំណុច ដោយឈរលើមូលដ្ឋានគ្រឹះសសរស្តម្ភ៥គឺ ១) ការអនុវត្តផែនការសកម្មភាពគោលនយោបាយ គ្រូបង្រៀន ២) ការងារអធិការកិច្ច ៣) វាយតម្លៃលទ្ធផលសិក្សា ៤) ការអភិវឌ្ឍកម្មវិធីសិក្សា និង៥) កំណែទម្រង់ឧត្តមសិក្សា។ សមិទ្ធផលសំខាន់ៗនៃកំណែទម្រង់ដំណាក់កាលទី២ រួមមាន៖
  - **កំណែទម្រង់ទី១៖ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖** បានបង្កើតអង្គភាពថវិកាចំនួន ៣៩ នៅថ្នាក់ជាតិ និង ២៥ នៅថ្នាក់រាជធានី-ខេត្ត ដូច្នេះអង្គភាពនីមួយៗមានទាំងផែនការសកម្មភាព និងថវិកាដើម្បីអនុវត្ត និងពង្រឹងភាពជាម្ចាស់លើគោលនយោបាយជាតិ ក៏ដូចជាពង្រឹងសមត្ថភាពបុគ្គលិកអប់រំ។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការ ជាលទ្ធផលនាំឱ្យមានការបង្កើនថវិកាដំណើរការដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងមូលនិធិដំណើរការសាលារៀន និងការទិញបរិក្ខារកុំព្យូទ័រសម្រាប់សាលារៀន
  - **កំណែទម្រង់ទី២៖ ការពង្រាយគ្រូបង្រៀន៖** គោលការណ៍ស្តីពីការគ្រប់គ្រងធនធានមនុស្សត្រូវបានរៀបចំឡើង និងគោលការណ៍ណែនាំស្តីពី និយាមប្រើប្រាស់បុគ្គលិកបានចាប់ផ្តើមអនុវត្ត ដែលធ្វើឱ្យការពង្រាយគ្រូបង្រៀនមានការកែលម្អ ដើម្បីដោះស្រាយបញ្ហាលើសនិងខ្វះគ្រូបង្រៀន។ គ្រូបង្រៀនខ្មែរឥស្លាមចំនួន ១ ៤៤១នាក់ និងគ្រូបង្រៀនជនជាតិដើមភាគតិចចំនួន ២០នាក់ ត្រូវបានបញ្ចូលក្នុងក្របខ័ណ្ឌរដ្ឋ
  - **កំណែទម្រង់ទី៣៖ កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូ៖** ប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងបាត់ដំបង ទៅជាវិទ្យាស្ថានគរុកោសល្យ និងដំឡើងកម្រិតបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានពី១២+២ ទៅ ១២+៤ និងបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស
  - **កំណែទម្រង់ទី៤៖ ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន៖** បានបង្កើតគណៈកម្មការអភិវឌ្ឍធនធានគ្រូបង្រៀន និងអនុវត្តប្រព័ន្ធក្រេឌីតសម្រាប់វាយតម្លៃសមត្ថភាពបុគ្គលិកអប់រំ កែលម្អលក្ខខណ្ឌជ្រើសរើសបេក្ខជនគ្រូបង្រៀន ដោយផ្តល់អាទិភាពដល់បេក្ខជនដែលមាននិទ្ទេស A, B, C និងបំប៉នគ្រូបង្រៀនថ្នាក់ទី១២ មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រទូទាំងប្រទេស

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- **កំណែទម្រង់ទី៥៖ ការងារអធិការកិច្ច៖** បានអនុម័តបញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា និងសេចក្តីណែនាំស្តីពីការអនុវត្តការងារអធិការកិច្ចធានាគុណភាពអប់រំសម្រាប់រាជធានី-ខេត្ត។ បានរៀបចំរចនាសម្ព័ន្ធអធិការកិច្ចនៅថ្នាក់ក្រោមជាតិ ជាតំបន់អធិការកិច្ច ៨តំបន់
- **កំណែទម្រង់ទី៦៖ វង្វាយតម្លៃលទ្ធផលសិក្សា៖** បានរៀបចំក្របខ័ណ្ឌវង្វាយតម្លៃលទ្ធផលសិក្សា និងនីតិវិធីវាស់ស្ទង់សមត្ថភាពកម្រិតសមមូល ការធ្វើតេស្តវង្វាយតម្លៃថ្នាក់ជាតិថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា និងផ្សព្វផ្សាយលទ្ធផល និងបានចូលរួមអនុវត្ត និងផ្សព្វផ្សាយកម្មវិធីតេស្តវង្វាយតម្លៃកម្រិតអន្តរជាតិសម្រាប់ការអភិវឌ្ឍ
- **កំណែទម្រង់ទី៧៖ កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ៖** បានបង្កើតនាយកដ្ឋានកិច្ចការប្រឡង និងបន្តអនុវត្តកំណែទម្រង់ការប្រឡង ដោយឈរលើគោលការណ៍ច្បាប់ យុត្តិធម៌ តម្លាភាព និងលទ្ធផលទទួលយកបាន ស្របតាមពាក្យស្លោក «អ្នកចេះគឺជាប់»
- **កំណែទម្រង់ទី៨៖ កំណែទម្រង់កម្មវិធីសិក្សានិងសៀវភៅសិក្សា៖** បានអនុម័តក្របខ័ណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស ពីមត្តេយ្យសិក្សាដល់មធ្យមសិក្សា និងកម្មវិធីសិក្សាលម្អិតបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ គ្រប់មុខវិជ្ជាគ្រប់កម្រិតថ្នាក់
- **កំណែទម្រង់ទី៩៖ ការសាងសង់អគារសិក្សានិងការជួសជុល៖** អគារសិក្សា មត្តេយ្យសិក្សា ធនធាន និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ
- **កំណែទម្រង់ទី១០៖ ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា៖** បានវាយតម្លៃការទទួលស្គាល់គុណភាព អប់រំឧត្តមសិក្សា និងបានអនុវត្តការធានាគុណភាពអប់រំ តាមស្តង់ដាធានាគុណភាពអប់រំផ្ទៃក្នុងសម្រាប់គ្រឹះស្ថានឧត្តមសិក្សា
- **កំណែទម្រង់ទី១១៖ ការលើកកម្ពស់វិស័យកីឡា៖** បានបង្កើនការវិនិយោគលើការហ្វឹកហ្វឺនក្រុមជម្រើសជាតិ និងផ្តល់រង្វាន់ដល់ម្ចាស់ជ័យលាភី កំណត់គោលការណ៍រៀបចំប្រកួតកីឡាជាតិដោយប្រព្រឹត្តទៅរៀងរាល់ពីរឆ្នាំម្តង ធ្វើវិមជ្ឈការថវិកាដល់សហព័ន្ធកីឡាជាតិ និងជួសជុលពហុកីឡដ្ឋានជាតិអូឡាំពិក អនុម័តកម្មវិធីសិក្សាអប់រំកាយនៅកម្រិតមធ្យមសិក្សាបឋមភូមិ និងកសាងហេដ្ឋារចនាសម្ព័ន្ធកីឡានៅក្នុងគ្រឹះស្ថានសិក្សា។ ការសម្រេចរបស់ **សម្តេចតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី ក្នុងការសាងសង់ពហុកីឡដ្ឋានមរតកតេជោ សម្រាប់ការប្រកួតកីឡាអាស៊ីហ្គេមលើកទី៣២ និងអាស៊ាន ប៉ារ៉ាហ្គេមលើកទី១២ គឺជាមរតកដែលមិនអាចកាត់ថ្លៃបានសម្រាប់ការអភិវឌ្ឍវិស័យកីឡានៅកម្ពុជា
- **កំណែទម្រង់ទី១២៖ ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន៖** ការបង្កើតនាយកដ្ឋានសហប្រតិបត្តិការកាយរឹទ្ធិ ការបើកដំណើរការមជ្ឈមណ្ឌលព័ត៌មានទីផ្សារក្នុងខេត្តមួយចំនួន ការបង្កើតកម្មវិធីអប់រំសមមូលកម្រិតមូលដ្ឋាន ការអនុវត្តកម្មវិធីអភិវឌ្ឍសហគ្រាសសហគមន៍ និងកម្មវិធីអប់រំសហគ្រិនភាពនៅតាមវិទ្យាល័យ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- **កំណែទម្រង់ទី១៣៖ ការអប់រំបច្ចេកទេស៖** បានអនុម័តលើផែនការគោល និងផែនការសកម្មភាពការអប់រំបច្ចេកទេសសម្រាប់មធ្យមសិក្សា អនុម័តកម្មវិធីសិក្សានិងសៀវភៅសិក្សាលើ ៥ មុខជំនាញ និងបង្កើតវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល និងកំពង់ស្ពឺ
- **កំណែទម្រង់ទី១៤៖ ការបង្កើតសាលារៀនជំនាន់ថ្មី៖** ការបង្កើតសាលារៀនជំនាន់ថ្មីចំនួន ១១ រួមមាន សាលាបឋមសិក្សាចំនួន ៤ និងមធ្យមសិក្សាចំនួន ៧
- **កំណែទម្រង់ទី១៥៖ ការរៀបចំគន្លងអាជីព និងការបណ្តុះបណ្តាលនាយកសាលា៖** បានអនុម័តក្របខ័ណ្ឌគោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន និងរៀបចំក្របខ័ណ្ឌផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន។

- **ដំណាក់កាលទី៣៖ កំណែទម្រង់សាលារៀន (២០១៩ ដល់ ២០២២)៖** ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកំណែទម្រង់សាលារៀន រួមមានសាលារៀនជំនាន់ថ្មីនៅឆ្នាំ២០១៦ សាលារៀនមានប្រសិទ្ធភាពនៅឆ្នាំ២០១៧ និងកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ។ លទ្ធផលសំខាន់ៗក្នុងកំណែទម្រង់អប់រំដំណាក់កាលទី៣ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ រួមមាន៖
  - ចំនួនសាលារៀនជំនាន់ថ្មីបានកើនដល់ ១១ (បឋមសិក្សា ៤ និងមធ្យមសិក្សា ៧)។ ការបង្កើតសាលារៀនជំនាន់ថ្មី មានគោលបំណងផ្តល់ស្វ័យភាពក្នុងការអនុវត្តកម្មវិធីសិក្សា ដើម្បីបណ្តុះធនធានមនុស្សមានបំណិនសតវត្សរ៍ទី២១
  - ក្រសួងបានសាកល្បងសាលារៀនមានប្រសិទ្ធភាពចំនួន ១០០ ដែលផ្តួចផ្តើមដោយគម្រោងកែលម្អការអប់រំមធ្យមសិក្សា និងមានផលជះដល់សាលារៀនចំនួន ៥០០ ផ្សេងទៀតដែលនៅក្បែរនោះ។ នៅឆ្នាំ២០១៧ ការគ្រប់គ្រងតាមសាលារៀន ត្រូវបានពង្រឹងដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស និងផ្លាស់ប្តូរវប្បធម៌សាលារៀន
  - ក្រសួងបានធ្វើកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ កែលម្អកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន។ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋាន (១២+២) តាមប្រព័ន្ធក្រេឌីតត្រូវបានដាក់ឱ្យដំណើរការ។ កញ្ចប់អំណាន និងគណិតវិទ្យាថ្នាក់ដំបូង ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបឋមសិក្សា។ ក្របខ័ណ្ឌនៃកម្មវិធីបណ្តុះបណ្តាលគ្រូវិទ្យាល័យ (បរិញ្ញាបត្រ+២) ត្រូវបានអនុម័ត និងសៀវភៅណែនាំស្តីពី ការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ត្រូវបានរៀបចំឡើង
  - ផ្តល់អាទិភាពខ្ពស់ដល់ការពង្រឹងគុណភាពនៃការអប់រំបឋមសិក្សា ដោយការលើកកម្ពស់កញ្ចប់អំណាន និងគណិតវិទ្យាថ្នាក់ទី១ និងទី២។ ការកែលម្អការជ្រើសរើស និងការពង្រាយគ្រូបង្រៀនភាសាខ្មែរ និងគណិតវិទ្យា។ ការបង្កើត «សាលាគំរូអំណាន និងគណិតវិទ្យាថ្នាក់ដំបូង» និងការអនុវត្តការគ្រប់គ្រងតាមសាលារៀន។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- **ដំណាក់កាលទី៤៖ ការអនុវត្តស្តង់ដាសាលារៀនគំរូ (២០២៣-បច្ចុប្បន្ន)៖** ក្រសួងបានដាក់ចេញនូវស្តង់ដាសាលារៀនគំរូ ចាប់ពីការអប់រំកុមារតូចរហូតដល់ការអប់រំមធ្យមសិក្សា ដោយផ្តោតលើ៖ ១) លទ្ធផលសិក្សារបស់សិស្ស ២) ការបង្រៀននិងរៀន ៣) ការចូលរួមរបស់សហគមន៍ ៤) ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន និង៥) គណនេយ្យភាពរបស់សាលារៀន។ សាលារៀនគំរូទទួលបានការគាំទ្រយ៉ាងខ្លាំងពីប្រមុខរាជរដ្ឋាភិបាល ដើម្បីដាក់ឱ្យអនុវត្ត «**ស្តង់ដាសាលារៀនគំរូ**» និង «**ពានរង្វាន់សាលារៀនគំរូសម្តេចមហាបវរធិបតី**» ព្រមទាំងយន្តការសាលារៀនគ្មានសំរាមនៅទូទាំងប្រទេស ដែលមានគោលដៅធ្វើកំណែទម្រង់សាលារៀនឆ្ពោះទៅកាន់ឧត្តមភាព។ ក្រសួងបានចេញសេចក្តីណែនាំ និងផ្សព្វផ្សាយដល់គ្រប់សាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ឱ្យដំណើរការគ្រឹះស្ថានសិក្សាក្នុងក្របខ័ណ្ឌនៃស្តង់ដាសាលារៀនគំរូផងដែរជាមួយគ្នានោះដែរ ក្រសួងបានបង្កើតយន្តការផ្ទៃក្នុង ដើម្បីគាំទ្ររាល់ការអនុវត្តនេះ រួមមាន៖ គណៈកម្មការពង្រឹងអភិបាលកិច្ចសាលារៀន អនុគណៈកម្មការបច្ចេកទេសការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំមធ្យមសិក្សា ការលើកកម្ពស់សុខភាពសិក្សា និងការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា ក្នុងការជំរុញអនុវត្តសាលារៀនគំរូ និងយន្តការចុះជួយសាលារៀន។ ក្រសួងក៏បានបង្កើតក្រុមការងារវាយតម្លៃសាលារៀន ដោយប្រើប្រាស់ស្តង់ដា និងសូចនាករដែលបានរៀបចំក្នុងគោលដៅផ្តល់ការគាំទ្រ និងការចុះជួយតាមសាលារៀនគោលដៅដែលមិនទាន់សម្រេចតាមស្តង់ដា និងរៀបចំការលើកទឹកចិត្តដល់សាលារៀនដែលសម្រេចបានស្តង់ដា។ ក្នុងនោះ នៅមត្តេយ្យសិក្សា ក្រសួងនឹងផ្តោតលើការគាំពារ និងអភិវឌ្ឍកុមារតូចជាពិសេសសារៈសំខាន់នៃ ១០០០ ថ្ងៃដំបូង និងការចូលរៀនមត្តេយ្យសិក្សា។ ចំណែកឯ អាទិភាពនៅបឋមសិក្សាផ្តោតលើការពង្រឹងនិងពង្រីកការអនុវត្តកម្មវិធីអំណាន និងគណិតវិទ្យានៅថ្នាក់ដំបូងដែលជាបំណិនមូលដ្ឋានគ្រឹះ។ ស្របជាមួយគ្នានេះ អាទិភាពនៅមធ្យមសិក្សាផ្តោតលើ ការពង្រឹងការបង្រៀនមុខវិជ្ជាស្ទែម និងភាសាបរទេស ជាពិសេសការអនុវត្តវិធីសាស្ត្របង្រៀនថ្មីតាមបែបស្ថាបនានិយម បំណិនរៀនដើម្បីចេះរៀនដោយខ្លួនឯង ដើម្បីបណ្តុះបំណិនសតវត្សរ៍ទី២១ លើកកម្ពស់អក្ខរកម្មឌីជីថល និងការសិក្សាពេញមួយជីវិត។ ក្រសួងបន្តលើកកម្ពស់ការបង្រៀនមុខវិជ្ជាឌីជីថល ដូចជា ការសរសេរកូដ ការផលិតមនុស្សយន្ត។ល។ សហគ្រិនភាព ការប្រឹក្សាអាជីពនៅតាមសាលារៀនជំនាន់ថ្មី វិទ្យាល័យធនធាន វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស និងវិទ្យាល័យដែលមានសក្តានុពលដោយសហការជាមួយគ្រឹះស្ថានឧត្តមសិក្សា និងផ្នែកឯកជន។ សាលារៀនគំរូត្រូវផ្តោតលើការអប់រំចរិយាធម៌ និងការបង្កើនម៉ោងសិក្សា។ ការអប់រំត្រូវផ្តោតលើសមធម៌ និងបរិយាបន្ន ដោយផ្តល់ប្រឹក្សាដល់ក្រុមកុមារ និងយុវជនដែលប្រឈមនឹងការបោះបង់ការសិក្សា និងក្រុមសិស្សងាយរងគ្រោះពីគ្រោះធម្មជាតិ និងបញ្ហាចំណាកស្រុក ការលើកកម្ពស់ការអប់រំសម្រាប់កុមារមានពិការភាព ការអប់រំពហុភាសាសម្រាប់ជនជាតិដើមភាគតិច ការពង្រឹងគុណភាពសាលាមត្តេយ្យសិក្សាសហគមន៍ និងទារកដ្ឋានសម្រាប់កម្មការិនីរោងចក្រ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ១.៣ ការវិភាគសមិទ្ធផលតាមអនុវិស័យ

## ១.៣.១ ការអប់រំកុមារតូច

### ការចូលរៀនប្រកបដោយសមធម៌

អត្រារួមនៃការសិក្សាកុមារអាយុ ៥ ឆ្នាំ គ្រប់រូបភាព បានបង្ហាញពីវឌ្ឍនភាពក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ។ កុមារអាយុ ៥ ឆ្នាំ បានចុះឈ្មោះចូលរៀនក្នុងការអប់រំកុមារតូចគ្រប់រូបភាព បានកើនឡើងពី ៥៩,៩ ភាគរយ ក្នុងឆ្នាំសិក្សា២០១៣-២០១៤ ដល់ ៦៤,៨ ភាគរយ ក្នុងឆ្នាំសិក្សា២០២២-២០២៣។ ដូចបានបញ្ជាក់ក្នុងរបាយការណ៍ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា អត្រាចូលរៀនមានវឌ្ឍនភាពនៅចន្លោះឆ្នាំ២០១៥ និង២០១៩។ ទោះជាយ៉ាងណា មានការកត់សម្គាល់ឃើញថា អត្រាចូលរៀនបានធ្លាក់ចុះក្នុងរយៈពេល ៣ឆ្នាំ ជាប់ៗគ្នា ពីឆ្នាំ២០១៩ ដល់ ២០២២ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។

**រូបភាព ១.១៖ អត្រាចូលរៀនកុមារអាយុ ៥ឆ្នាំ (ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣)**




អត្រារួមនៃការសិក្សារបស់កុមារអាយុ៣-៥ឆ្នាំ បានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេល ១០ ឆ្នាំកន្លងមកនេះ បានកើនឡើងពី ៣៣,៤ ភាគរយ ក្នុងឆ្នាំសិក្សា២០១៣-២០១៤ ដល់ ៣៧,១ ភាគរយ ក្នុងឆ្នាំសិក្សា២០២២-២០២៣។ និន្នាការនេះ បានបង្ហាញថាអត្រារួមនៃការសិក្សាបានកើនឡើង ៣,៧ ភាគរយ។ អត្រារួមនៃការសិក្សាជិតសម្រេចចំណុចដៅដែលបានកំណត់នៅក្នុងរបាយការណ៍ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ ៣៧,៤ ភាគរយ ក្នុងឆ្នាំសិក្សា២០២២-២០២៣។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## រូបភាព ១.២៖ អត្រារួមនៃការសិក្សាកុមារអាយុ ៣-៥ ឆ្នាំ (ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣)




សាលាមត្តេយ្យសិក្សាសហគមន៍បានបំពេញតាមស្តង់ដាអប្បបរមា គឺជាសូចនាករដ៏សំខាន់មួយក្នុងការវាស់វែងគុណភាពនៃសេវាអប់រំកុមារតូច។ សាលាមត្តេយ្យសិក្សាសហគមន៍បានបំពេញតាមស្តង់ដាអប្បបរមា បានកើនឡើងពី ៦០០ ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ ដល់ ១ ៣០៥ ក្នុងឆ្នាំសិក្សា ២០២២-២០២៣ ស្មើ ៤០,៦ ភាគរយ ធៀបទៅនឹងសាលាមត្តេយ្យសិក្សាសហគមន៍ទាំងអស់នៅទូទាំងប្រទេស។

ក្រសួងបានលើកទឹកចិត្តឱ្យបង្កើតទារកដ្ឋាននៅតាមរោងចក្រ។ រហូតមកដល់ពេលនេះ មានមត្តេយ្យសិក្សាសហគមន៍ ឬទារកដ្ឋាននៅតាមរោងចក្រចំនួន ១៣ កន្លែង ដែលក្នុងនោះមាន ១០ នៅក្នុងខេត្តកំពង់ស្ពឺ និង ៣ទៀត នៅខេត្តកំពង់ចាម។

ក្រសួងក៏មានគំនិតផ្តួចផ្តើមផ្សេងៗ ក្នុងគោលបំណងលើកកម្ពស់ការចូលរៀនក្នុងការអប់រំកុមារតូចសម្រាប់កុមារជនជាតិដើមភាគតិច ដែលភាគច្រើនមានទីតាំងនៅតំបន់ភាគឦសាន។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ បានដាក់បញ្ចូលការណែនាំឱ្យប្រើប្រាស់កម្មវិធីអប់រំពហុភាសានៅក្រុង ស្រុក ចំនួន ១៩ ដោយផ្តោតលើសាលាមត្តេយ្យសិក្សាចំនួន ១៣៣ (ភាគច្រើនជាមត្តេយ្យសិក្សាសហគមន៍)។ នៅឆ្នាំ ២០២២ កុមារចំនួន ២ ៦២៥ នាក់ បានចូលរៀនកម្មវិធីអប់រំពហុភាសារបស់រដ្ឋ ស្មើនឹង ០,៦៩ ភាគរយ នៃការចូលរៀនសរុបនៅក្នុងការអប់រំកុមារតូច។

ការកែលម្អហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត អនាម័យ ឱ្យមានគុណភាព ជាកត្តាវិជ្ជមានក្នុងការជំរុញដល់ការចុះឈ្មោះចូលរៀន។ ភាគរយនៃសាលាមត្តេយ្យសិក្សាអនុវត្តស្តង់ដា អប្បបរមាបានកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ។ វិធានការនេះ បានជំរុញមួយផ្នែកបន្ទាន់ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលបង្កឡើងដោយជំងឺកូវីដ-១៩ ដែលនាំឱ្យសាលាមត្តេយ្យសិក្សា ៧៥,០ ភាគរយ ធ្លាក់ចុះក្នុងចំណាត់ថ្នាក់កម្រិត១ កម្រិត២ ឬកម្រិត៣ នៅឆ្នាំសិក្សា ២០២២-២០២៣។ តាមរយៈកម្មវិធីផ្តល់អាហារដល់សាលារៀនផ្ទះបាយសម្រាប់ផ្តល់អាហារជាង ៣៥០ កន្លែង ត្រូវបានសាងសង់ឡើង ឆ្លើយតបទៅនឹងការរីករាលដាលនៃជំងឺកូវីដ-១៩។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ការបង្កើនគុណវុឌ្ឍិគ្រូបង្រៀនមត្តេយ្យសិក្សាត្រូវបានយកចិត្តទុកដាក់ ទោះបីជាសមត្ថភាពបណ្តុះបណ្តាលនៅមានកម្រិតក៏ដោយ។ ចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩ គ្រូបង្រៀនមត្តេយ្យសិក្សា តម្រូវឱ្យបញ្ចប់ការអប់រំថ្នាក់ទី១២ និងឆ្លងកាត់កម្មវិធីបណ្តុះបណ្តាលរយៈពេល ២ ឆ្នាំ នៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម។ បច្ចុប្បន្ននេះ គ្រូបង្រៀនមត្តេយ្យសិក្សាសាធារណៈ ៧៥,០ ភាគរយ បានបំពេញតាមស្តង់ដាថ្នាក់ជាតិ ១២+២ និងមានសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម តែមួយគត់សម្រាប់បណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា ដែលអាចទទួលបេក្ខជនអតិបរមាត្រឹមតែ ២០០ នាក់ប៉ុណ្ណោះ ក្នុងមួយឆ្នាំ។ ស្តង់ដាគុណវុឌ្ឍិគ្រូបង្រៀនជាផ្នែកមួយដ៏សំខាន់សម្រាប់ជំរុញការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនបន្ថែមទៀត។

### ១.៣.២ ការអប់រំនៅបឋមសិក្សា

#### ការអប់រំប្រកបដោយសមធម៌

ការអប់រំបឋមសិក្សានៅកម្ពុជាស្ទើរតែសម្រេចបានជាសកល។ អត្រាពិតនៃការសិក្សានៅបឋមសិក្សាបានថយចុះជាបន្តបន្ទាប់ពី ៩៨,២ ភាគរយ ក្នុងឆ្នាំសិក្សា២០១៣-២០១៤ មកនៅត្រឹម ៩៥,៨ ភាគរយក្នុងឆ្នាំសិក្សា២០២២-២០២៣។ ការធ្លាក់ចុះនេះ ដោយសារទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ដែលនាំឱ្យសាលារៀនត្រូវផ្អាកដំណើរការជាបណ្តោះអាសន្ន។

**រូបភាព ១.៣ ៖ អត្រាពិតនៃការសិក្សានៅបឋមសិក្សា (ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣)**




ចាប់ពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ឆ្នាំសិក្សា២០២២-២០២៣ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាថយចុះ ២,១ ភាគរយ ប្រុសថយចុះ ២,៥ ភាគរយ និងស្រី ថយចុះ ០,៨ ភាគរយ។ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាមានការថមថយបន្តិចបន្តួចក្នុងរយៈពេល១០ឆ្នាំ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

## រូបភាព ១.៤៖ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា (ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣)




តាមការសង្កេតបង្ហាញថា អត្រាគង់វង្សនៅឆ្នាំសិក្សាកន្លងមក មានការថយចុះពី ៧៩,៩ ភាគរយ ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ មកនៅត្រឹម ៦៩,៥ ភាគរយ ក្នុងឆ្នាំសិក្សា២០២២-២០២៣។ អត្រាគង់វង្សរបស់សិស្សប្រុសមានការកើនឡើងពី ៧៦,៥ ភាគរយ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ ដល់ ៨០,៣ ភាគរយ ក្នុងឆ្នាំសិក្សា២០២២-២០២៣។ ផ្ទុយទៅវិញ អត្រាគង់វង្សរបស់សិស្សស្រីមានការថយចុះពី ៨៣,៥ ភាគរយ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ មកនៅត្រឹម ៦០,៤ ភាគរយ ក្នុងឆ្នាំសិក្សា២០២២-២០២៣ ដែលនិន្នាការនេះបង្ហាញថា ការរក្សាសិស្សឱ្យនៅបន្តការសិក្សាក្នុងបឋមសិក្សានៅមិនទាន់មានភាពល្អប្រសើរ។

## រូបភាព ១.៥៖ អត្រាគង់វង្សក្នុងការអប់រំបឋមសិក្សា (ឆ្នាំសិក្សា២០១៧-២០១៨ ដល់ ២០២២-២០២៣)




ការកើនឡើងនៃប្រសិទ្ធភាពផ្ទៃក្នុង មានទំនាក់ទំនងទៅនឹងការថយចុះនៃចំនួនសិស្សដែលចូលរៀនលើសអាយុនៅថ្នាក់ទី១ ចាប់តាំងពីឆ្នាំ២០១៧។ និន្នាការវិជ្ជមាននេះ បានបង្ហាញឱ្យឃើញថាសិស្សចូលរៀនត្រឹមត្រូវតាមអាយុមានកាន់តែច្រើនឡើង ដោយមូលហេតុនៃការថយចុះចំនួនសិស្សចូលរៀនលើសអាយុនៅថ្នាក់ទី១ និង២ ចាប់តាំងពីឆ្នាំ២០១៤-២០១៦។ ទោះយ៉ាងណា នៅឆ្នាំ២០២០-២០២២ សិស្សចូលរៀនថ្នាក់ទី១ ប្រមាណ ២០ ភាគរយ នៅតែបន្តលើសអាយុ ៦ ឆ្នាំ ខណៈដែលមានសិស្ស ៩,០ ភាគរយ លើសអាយុ ២ ឆ្នាំ នៃអាយុតាមផ្លូវការ។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

អត្រាបោះបង់ការសិក្សានៅបឋមសិក្សា បានថយចុះពី ៨,៣ ភាគរយ នៅឆ្នាំសិក្សា ២០១៣-២០១៤ មកត្រឹម ៧,៥ ភាគរយ នៅឆ្នាំសិក្សា២០២២-២០២៣។ អត្រាបោះបង់ការសិក្សារបស់សិស្សប្រុសបានថយចុះបន្តិចម្តងៗពី ៩,៤ ភាគរយ នៅឆ្នាំសិក្សា ២០១៣-២០១៤ មកត្រឹម ៨,៦ ភាគរយ នៅឆ្នាំសិក្សា ២០២១-២០២២ និងសិស្សប្រុសធ្លាក់ចុះយ៉ាងគំហុកមកត្រឹម ៥,៥ ភាគរយ នៅឆ្នាំសិក្សា២០២២-២០២៣។ ផ្ទុយទៅវិញ ការបោះបង់ការសិក្សារបស់សិស្សស្រីបានថយចុះពី ៧,២ ភាគរយ មកនៅត្រឹម ៥,៧ ភាគរយ នៅឆ្នាំសិក្សា ២០២១-២០២២ និងកើនមកវិញ ៩,៥ ភាគរយ នៅឆ្នាំសិក្សា២០២២-២០២៣។ អត្រាបោះបង់ការសិក្សាមានការកើនឡើងរយៈពេល ៣ ឆ្នាំ ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩។

## រូបភាព ១.៦៖ អត្រាបោះបង់ការសិក្សានៅបឋមសិក្សា (ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣)




អត្រាត្រួតថ្នាក់ បានកើនឡើងពី ៤,៨ ភាគរយ នៅឆ្នាំសិក្សា២០១៣-២០១៤ ដល់ ៥,៩ ភាគរយ នៅឆ្នាំសិក្សា ២០២២-២០២៣។ អត្រាត្រួតថ្នាក់របស់សិស្សប្រុសកើនពី ៦,០ ភាគរយ នៅឆ្នាំសិក្សា២០១៣-២០១៤ មកត្រឹម ៧,៥ ភាគរយ នៅឆ្នាំសិក្សា២០២២-២០២៣ ខណៈដែលសិស្សស្រីបង្ហាញនូវវឌ្ឍនភាពតិចតួចនៅទសវត្សរ៍ចុងក្រោយ(៤,១ ភាគរយ នៅឆ្នាំសិក្សា២០១៣-២០១៤ មកត្រឹមតែ ៤,២ ភាគរយ នៅឆ្នាំសិក្សា ២០២២-២០២៣)។ លទ្ធផលនេះ លើសពីចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំកន្លងមក និងមិនសម្រេចបានតាមចំណុចដៅឆ្នាំ២០២៣ នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣។ សិស្សប្រុសនៅតែមានលទ្ធផលការសិក្សាមិនទាន់បានល្អជៀបនឹងសិស្សស្រី។

## រូបភាព ១.៧៖ អត្រាត្រួតថ្នាក់នៅបឋមសិក្សា (ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣)



## គុណភាពនៃការបង្រៀន និងរៀន

អំណាន និងគណិតវិទ្យាថ្នាក់ដំបូង គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់សិស្សរៀននៅសាលាបឋមសិក្សា។ ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងលើកកម្ពស់ «អំណានថ្នាក់ដំបូង» និង «គណិតវិទ្យាថ្នាក់ដំបូង» ជាពិសេស ការបណ្តុះបណ្តាលគ្រូបង្រៀន និងការពង្រីកការអនុវត្តនៅទូទាំងប្រទេស ក្នុងគោលបំណងបង្កើនលទ្ធផលសិក្សារបស់សិស្ស គឺកុមារកម្ពុជាអាចអាន និងសរសេរបាន។

ក្រសួងបានសហការជាមួយដៃគូអភិវឌ្ឍ ដើម្បីអនុវត្តសម្ភារអំណានថ្នាក់ដំបូងនៅសាលាបឋមសិក្សានៅក្នុងរាជធានីខេត្តចំនួន២២ អំណានថ្នាក់ទី២ នៅក្នុងខេត្តចំនួន១៩ និងអំណានថ្នាក់ទី៣ នៅក្នុងខេត្តកំពង់ឆ្នាំង។ កញ្ចប់គណិតវិទ្យាថ្នាក់ដំបូង បានអនុវត្តនៅក្នុងខេត្ត៨ ហើយកញ្ចប់គណិតវិទ្យាថ្នាក់ទី២ បានអនុវត្តនៅក្នុងខេត្ត៦។ ក្រសួងបានដាក់បញ្ចូលអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូងទៅក្នុងការបណ្តុះបណ្តាលគ្រូបង្រៀននៅសាលាគរុកោសល្យ។

គុណភាពនៃបរិស្ថានសិក្សានៅថ្នាក់បឋមសិក្សា នៅពុំទាន់មានភាពល្អប្រសើរនៅឡើយទេ ចំពោះតម្រូវការ និងការផ្គត់ផ្គង់ដល់គ្រូ និងសិស្សក្នុងថ្នាក់រៀន ដោយសារសិស្សក្នុងថ្នាក់មានចំនួនច្រើននៅតំបន់ទីប្រជុំជន ក៏ដូចជាតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច និងតំបន់សេដ្ឋកិច្ច។ នៅតំបន់ជាយក្រុងរាជធានីភ្នំពេញ ចំនួនសិស្សមានប្រមាណ ៧០ នាក់ ក្នុងមួយថ្នាក់ និងប្រឈមនឹងការខ្វះគ្រូបង្រៀន។

លើសពីនេះ កង្វះគ្រូបង្រៀនក៏នៅតែជាបញ្ហាប្រឈមក្នុងតំបន់ជនបទ។ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងបានជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ប្រើថ្នាក់ពីរវេន និងថ្នាក់គួប ព្រមទាំងជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ១៣ ២៥៦ នាក់ និងគ្រូបង្រៀនពីរថ្នាក់ពីរពេលចំនួន ៨ ៧០៧ នាក់ និងគ្រូបង្រៀនថ្នាក់គួប ២ ៤៣០ នាក់ ត្រូវបានប្រើប្រាស់ក្នុងឆ្នាំសិក្សា ២០២៣-២០២៤។

ចំនួនសាលាបឋមសិក្សាដែលបង្រៀន និងរៀនមួយវេន បានកើនឡើងពី ២ ៣៣៥ ស្មើនឹង ៣២,៣ ភាគរយ និង ១៣ ៤០៩ បន្ទប់ ក្នុងឆ្នាំសិក្សា ២០១៨-២០១៩ ដល់ ២ ៨៥៤ ស្មើនឹង ៣៨,៩ ភាគរយ និង ១៧ ៧៣៣ បន្ទប់ ក្នុងឆ្នាំសិក្សា ២០២២-២០២៣។ អន្តរាគមន៍នេះ បង្ហាញពីលទ្ធភាពលើផ្នែកហេដ្ឋារចនាសម្ព័ន្ធក្នុងការអនុវត្តការបង្រៀន និងរៀនពេញមួយថ្ងៃនៅក្នុងសាលាបឋមសិក្សាមួយចំនួន។

គ្រូបង្រៀនចំនួន ៣ ៥០០ នាក់ បានជ្រើសរើសប្រចាំឆ្នាំ ប៉ុន្តែប្រមាណជា ១ ៩០០ នាក់ សម្រាប់ការជំនួសឱ្យអត្រាវិចរិល រួមមាន ការចូលនិវត្តន៍ មរណភាព និងហេតុផលផ្សេងទៀត។

គ្រូបង្រៀន កំពុងទទួលបានការអភិវឌ្ឍគុណវុឌ្ឍិប្រសើរជាងមុន។ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់យ៉ាងទូលំទូលាយលើកម្មវិធីសិក្សាគរុកោសល្យ និងបង្កើនគុណវុឌ្ឍិគ្រូឧទ្ទេស។ តម្រូវការបេក្ខជនសម្រាប់បណ្តុះបណ្តាលជាគ្រូបង្រៀន ដែលបច្ចុប្បន្ននេះ តម្រូវឱ្យបេក្ខជនត្រូវបញ្ចប់ថ្នាក់ទី១២ យ៉ាងតិចនិងបរិញ្ញាបត្រ ដោយប្រើរូបមន្ត ១២+៤ ។ ភាគរយនៃគ្រូបឋមសិក្សាសាធារណៈ ដែលមានគុណវុឌ្ឍិ (មានសញ្ញាបត្រថ្នាក់ទី១២ និងខ្ពស់ជាងនេះ ប៉ុន្តែមិនចាំបាច់មានបរិញ្ញាបត្រទេ) បានបង្ហាញពីភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ ដែលកើនពី ៧៣ ភាគរយ ក្នុងឆ្នាំសិក្សា២០១៨-២០១៩ ដល់ ៨៤,៤ ភាគរយ ក្នុងឆ្នាំសិក្សា២០២២-២០២៣។ គ្រូបង្រៀនមានសញ្ញាបត្របរិញ្ញាបត្រ មានការកើនឡើងគួរឱ្យកត់សម្គាល់

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ពីមិនមានគ្រូបង្រៀនមានសញ្ញាបត្របរិញ្ញាបត្រនៅក្នុងឆ្នាំសិក្សា២០១៧-២០១៨ បើធៀបនឹងឆ្នាំសិក្សា ២០២២-២០២៣ មានចំនួន ២២,៣ ភាគរយ ទោះបីជាមានវិសមភាពរវាងខេត្តក៏ដោយ។

បរិស្ថានសិក្សាមានសុវត្ថិភាព និងបំពាក់សម្ភារបានល្អជាងមុន។ នៅឆ្នាំសិក្សា២០២២-២០២៣ សាលាបឋមសិក្សា ៨៤,០ ភាគរយ បានប្រកាន់ខ្ជាប់តាមស្តង់ដា ទឹកស្អាត អនាម័យ គួរឱ្យកត់សម្គាល់ និង កើនឡើង ១៥,០ ភាគរយ ក្នុងរយៈពេល ៤ ឆ្នាំកន្លង។ លើសពីនេះ ការវិនិយោគសំខាន់ៗជាច្រើន បានធ្វើឡើង ដើម្បីធានាឱ្យសាលាបឋមសិក្សាមានអគ្គិសនីប្រើប្រាស់។ នៅឆ្នាំសិក្សា២០២២-២០២៣ សាលារៀន ៩ ក្នុងចំណោម ១០ មានអគ្គិសនីប្រើប្រាស់ បើធៀបនឹងសាលារៀន ៥០,០ ភាគរយ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ មានអគ្គិសនីប្រើប្រាស់។ ទោះយ៉ាងណាក៏ដោយ ការប្រើប្រាស់អ៊ីនធឺណិតនៅមានកម្រិតនៅឡើយ ជាពិសេសសាលារៀននៅតំបន់ជនបទ។ ផែនការគោលបច្ចេកវិទ្យាព័ត៌មានវិទ្យា ផ្តោតលើតម្រូវការក្នុងការ បំពាក់ឧបករណ៍ឌីជីថលនៅតាមសាលារៀន សម្រាប់ក្នុងការអប់រំឌីជីថលប្រកបដោយសមធម៌។

សិស្សថ្នាក់ទី ៦ មានលទ្ធផលសិក្សាទាបជាងកម្រិតមូលដ្ឋាន ផ្អែកតាមការវាយតម្លៃការសិក្សាថ្នាក់ជាតិ សម្រាប់មុខវិជ្ជាទាំងអស់នៅចន្លោះឆ្នាំ២០១៦-២០២១ ជាពិសេសលទ្ធផលគណិតវិទ្យាដែលលទ្ធផលសិក្សា របស់សិស្ស ៧៤,៣ ភាគរយ ស្ថិតនៅក្រោមកម្រិតមូលដ្ឋាន ក្នុងឆ្នាំ២០២១ (៥៣,២ ភាគរយ ក្នុងឆ្នាំ២០១៦)។ លទ្ធផលនេះ បានរងផលប៉ះពាល់ពីការពន្យាពេលនៃការបិទសាលារៀន ដែលបណ្តាលមកពីការរីករាលដាល នៃជំងឺកូវីដ-១៩។ កត្តាដែលរារាំងដល់ការសិក្សាពីចម្ងាយរបស់សិស្សមិនបានពេញលេញក្នុងអំឡុងពេលបិទ សាលារៀន គឺសមត្ថភាពក្នុងប្រើប្រាស់បច្ចេកវិទ្យាទាំងគ្រូនិងសិស្ស។

លទ្ធផលនៃការសិក្សាខុសគ្នា គឺបង្ហាញតាមរយៈភាពខុសគ្នានៃស្ថានភាពសង្គម-សេដ្ឋកិច្ច និងទីតាំង ភូមិសាស្ត្រ។ ជាការកត់សម្គាល់ សិស្សភាគច្រើនដែលមកពីតំបន់ជួបការលំបាក មានលទ្ធផលសិក្សាទាប លើផ្នែកអំណាន សំណេរ និងគណិតវិទ្យា ប្រៀបធៀបនឹងសិស្សដែលរស់នៅតំបន់ជនបទ ឬធៀបនឹងសិស្ស នៅទីប្រជុំជន។ វិសមភាពយេនឌ័រ បង្ហាញឱ្យឃើញ ជាពិសេសនៅក្នុងផ្នែកអំណាន និងសំណេរ ដែលសិស្ស ថ្នាក់ទី៦ សិស្សស្រីប្រសើរជាងសិស្សប្រុស។ កម្មវិធីផ្តល់អាហារតាមសាលារៀនអាចរួមចំណែកកាត់បន្ថយ ភាពខុសគ្នានៃលទ្ធផលសិក្សា។

### ១.៣.៣ ការអប់រំមធ្យមសិក្សា

**ការអប់រំប្រកបដោយសមធម៌**

អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិកើនពី ៥៣,៣ ភាគរយ (ស្រី ៥៤,៥ ភាគរយ ប្រុស ៥២,១ ភាគរយ) នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៦៤,៨ ភាគរយ (ស្រី ៦៩,៤ ភាគរយ ប្រុស ៦០,៦ ភាគរយ) នៅឆ្នាំសិក្សា២០២២-២០២៣។ កំណើននេះ បង្ហាញពីការយកចិត្តទុកដាក់របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការប្រមូលកុមារចូលរៀននៅតាមសាលារៀន មានភាពល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ ស្របតាមស្ថានភាពសុវត្ថិភាពសង្គម។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## រូបភាព ១.៨៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣)




t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិកើនពី ២៤,៩ ភាគរយនៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៤៤,២ ភាគរយ នៅឆ្នាំសិក្សា ២០២២-២០២៣ (ស្រី ២៤,៦ ភាគរយ ទៅ ៤៩,២ ភាគរយ និង ប្រុស ២៥,២ ភាគរយ ទៅ ៣៩,៣ ភាគរយ នៅឆ្នាំសិក្សា ២០២២-២០២៣)។ កំណើននេះ បង្ហាញពីការយកចិត្តទុកដាក់ក្នុងការប្រមូលកុមារចូលរៀននៅតាមសាលារៀន មានភាពល្អប្រសើរក្នុងមួយទសវត្សរ៍ចុងក្រោយនេះ ដោយសារកំណែទម្រង់ប្រព័ន្ធអប់រំមានប្រសិទ្ធភាព និងជីវភាពប្រជាជនមានការកើនឡើង។

## រូបភាព ១.៩៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ (ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣)




អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ បានកើនឡើងពី ៣៩,១ ភាគរយ(ស្រី ៤០,០ ភាគរយ ប្រុស ៣៨,៣ ភាគរយ) នៅឆ្នាំសិក្សា ២០១៣-២០១៤ មកដល់ ៥៩,៧ ភាគរយ (ស្រី ៦៤,៥ ភាគរយ ប្រុស ៥៤,៩ ភាគរយ) នៅឆ្នាំសិក្សា ២០២២-២០២៣។ កំណើនជាមធ្យមក្នុងមួយឆ្នាំរង្វង់ ២,១ ភាគរយ

ស្រី ២,៥ ភាគរយ និងប្រុស ១,៧ ភាគរយ។ ទោះបីយ៉ាងណា អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ សិស្សស្រីខ្ពស់ជាងសិស្សប្រុស។

### រូបភាព ១.១០៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣)




អត្រាគង់វង្សនៅមធ្យមសិក្សាបឋមភូមិក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ បានបង្ហាញនូវលទ្ធផលថយចុះជាមធ្យមក្នុងមួយឆ្នាំវង្វង់ ១,៧៦ ភាគរយ ស្រី ៣,៦៨ ភាគរយ ប្រុស ០,២៦ ភាគរយ ។ ប្រការនេះ បង្ហាញនូវការព្រួយបារម្ភ ដែលតម្រូវឱ្យគ្រប់ភាគីពាក់ព័ន្ធចូលរួមយកចិត្តទុកដាក់ និងគាំទ្រដល់ដំណើរការបង្រៀន និងរៀន។

### រូបភាព ១.១១៖ អត្រាគង់វង្សនៅមធ្យមសិក្សាបឋមភូមិ (ឆ្នាំសិក្សា២០១៨-២០១៩ ដល់ ២០២២-២០២៣)




បញ្ហាប្រឈមក្នុងការរក្សាសិស្សឱ្យនៅបន្តការសិក្សា និងការកាត់បន្ថយការបោះបង់ការសិក្សានៅមធ្យមសិក្សា។ អត្រាបោះបង់នៅមធ្យមសិក្សាបឋមភូមិមានវឌ្ឍនភាពតិចតួចក្នុងរយៈពេល ១០ ឆ្នាំ។ អត្រានេះបានថយចុះពី ២១,២ ភាគរយ (ប្រុស ១៦,៦ ភាគរយ និងស្រី ២០,៩ ភាគរយ) នៅឆ្នាំសិក្សា ២០១៣-២០១៤ មកនៅត្រឹម ១៥,៤ ភាគរយ (ប្រុស ១៧,៦ ភាគរយ ស្រី ១៤,២ ភាគរយ) នៅឆ្នាំសិក្សា ២០១៧-២០១៨ និងបានកើនឡើងវិញដល់ ១៨,២ ភាគរយ (ប្រុស ១៩,២ ភាគរយ ស្រី១៧,២ ភាគរយ) នៅឆ្នាំសិក្សា ២០២២-២០២៣។ ការកាត់បន្ថយការបោះបង់ការសិក្សានៅដើមឆ្នាំសិក្សា នៅមធ្យមសិក្សាបឋមភូមិនៅតែជាបញ្ហាប្រឈម ជាពិសេសបន្ទាប់ពីការរីករាលដាលនៃជំងឺកូវីដ-១៩។ ការរក្សាសិស្សឱ្យនៅបន្តការសិក្សា

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

នៅកម្រិតមធ្យមសិក្សាបឋមភូមិ មានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់នៅចន្លោះឆ្នាំសិក្សា ២០១៧-២០១៨ និងឆ្នាំសិក្សា ២០១៨-២០១៩ ដោយសិស្សស្ទើរតែ ៨០ ភាគរយ បានចូលរៀនថ្នាក់ទី៧ និងបានបន្តរៀនដល់ថ្នាក់ចុងក្រោយនៃកម្រិតនេះ។ ការលើកកម្ពស់នេះត្រូវបានដាក់ចេញដើម្បីកែលម្អស្ថានភាពថ្មីៗ បន្ទាប់ពីរងផលប៉ះពាល់ដោយការរីករាលដាលនៃជំងឺកូវីដ-១៩។ ទោះបីយ៉ាងណាក៏ដោយ អត្រាចូលរៀនថ្នាក់ទី៧ បានបង្ហាញថាមានការថយចុះគួរឱ្យកត់សម្គាល់ពី ៨០,០ ភាគរយ នៅឆ្នាំសិក្សា២០២១-២០២២ មកនៅត្រឹម ៦៧,០ ភាគរយ នៅឆ្នាំសិក្សា ២០២២-២០២៣។

**រូបភាព ១.១២៖ អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ (ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២១-២០២២)**




អត្រាត្រួតថ្នាក់នៅមធ្យមសិក្សាបឋមភូមិ បានកើនឡើងបន្តិចពី ១,៨ ភាគរយ នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ២,០ ភាគរយ នៅឆ្នាំសិក្សា ២០២១-២០២២។ ជាការកត់សម្គាល់អត្រានេះបានធ្លាក់ចុះយ៉ាងគំហុកមកត្រឹម ០,៤ ភាគរយ នៅឆ្នាំសិក្សា ២០១៩-២០២០ ក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩ នៅពេលសាលាបិទទ្វារ។ លើសពីនេះ អត្រាត្រួតថ្នាក់សិស្សប្រុសបានកើនឡើងធំជាងសិស្សស្រីប្រហែល ១,៨ ភាគរយ។

**រូបភាព ១.១៣៖ អត្រាត្រួតថ្នាក់នៅមធ្យមសិក្សាបឋមភូមិ (ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២១-២០២២)**






youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

កត្តាដែលរារាំងដល់វឌ្ឍនភាពនៃការអប់រំមធ្យមសិក្សានៅកម្ពុជា រួមមាន ភាពក្រីក្រ ឱកាសសេដ្ឋកិច្ច ការទទួលបានការអប់រំ និងចំនួនសាលារៀនមិនទាន់គ្របដណ្តប់។ សិស្សមួយចំនួនប្រឈមនឹងការសម្រេចចិត្ត រវាងការស្វែងរកឱកាសរកប្រាក់ចំណូល និងការសិក្សា ដែលជាមូលហេតុនាំឱ្យអត្រាចូលរៀនមានការប្រែប្រួល។ តម្រូវការកម្លាំងពលកម្មយុវជន និងអត្រាការងារនៅក្នុងប្រទេស និងការមិនទាន់យល់ដឹងច្បាស់ពីទំនាក់ទំនង រវាងស្ថានភាពទីផ្សារការងារ និងការអប់រំ ជាមូលហេតុនៃការអូសទាញសិស្សឱ្យឈប់រៀន ដើម្បីបានការងារធ្វើ។

បណ្តាខេត្តដែលប្រឈមនឹងការប្រែប្រួលអាកាសធាតុខ្ពស់ មានការប៉ះពាល់ដល់លទ្ធផលសិក្សា។ ការប៉ះពាល់មានដូចជា ការបិទសាលារៀនបណ្តោះអាសន្ន ការខូចខាតហេដ្ឋារចនាសម្ព័ន្ធ អវត្តមានគ្រូ និងសិស្ស។ ដើម្បីដោះស្រាយបញ្ហាស្មុគស្មាញនេះ តម្រូវឱ្យមានការរៀបចំគោលនយោបាយ ដើម្បីដោះស្រាយបញ្ហាគ្រប់កាលៈទេសៈទាំងអស់នេះ។

## គុណភាពបង្រៀន និងរៀន

ចំនួនសិស្សលើសនិយាមនៅក្នុងថ្នាក់ នាំឱ្យមានការលំបាកក្នុងការអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ។ លើសពីនេះ កង្វះគ្រូបង្រៀននៅតែជាបញ្ហាប្រឈមលើមុខវិជ្ជាមួយចំនួន ជាពិសេស មុខវិជ្ជាដែលទាក់ទងនឹងការអប់រំស្ទែម។ ការអនុវត្តម៉ោងបង្រៀននិងរៀននៅពេលបច្ចុប្បន្ន មិនអាចធានាបានលទ្ធផលសិក្សាល្អប្រសើរទេ គឺត្រូវទាមទារឱ្យមានការបង្កើនម៉ោងសិក្សាបន្ថែមនៅតាមសាលារៀន។

ក្នុងឆ្នាំ២០១៦ ក្រសួងបានដាក់ឱ្យអនុវត្តសាលារៀនជំនាន់ថ្មី ក្នុងគោលបំណងបង្កើនស្វ័យភាពសាលារៀន ដើម្បីលើកកម្ពស់គុណភាពអប់រំ។ សាលារៀនជំនាន់ថ្មី គឺជាសាលារៀនគំរូសម្រាប់អប់រំសិស្ស ឱ្យមានចំណេះដឹង ជំនាញ សមត្ថភាព និងភាពជាពលរដ្ឋល្អ ដើម្បីបំពេញតម្រូវការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចក្នុងសតវត្សទី២១ តាមរយៈការលើកកម្ពស់វិធីសាស្ត្របង្រៀននិងរៀន ការពង្រឹងស្វ័យភាព គណនេយ្យភាព និងការចូលរួមរបស់សហគមន៍ ។ សាលារៀនជំនាន់ថ្មីក៏ជាសាលារៀនគំរូសម្រាប់គ្រឹះស្ថានអប់រំផ្សេងទៀត។

នៅឆ្នាំ២០១៨ ក្រសួងបានអនុវត្តគម្រោងកែលម្អការអប់រំមធ្យមសិក្សា នៅតាមសាលារៀនគោលដៅចំនួន ១០០ នៅទូទាំង ២៥ រាជធានី-ខេត្ត ដោយផ្តោតលើការពង្រឹងការគ្រប់គ្រងតាមសាលារៀន ការផ្តល់មូលនិធិសម្រាប់កែលម្អសាលារៀន ការលើកកម្ពស់គុណវុឌ្ឍិគ្រូនៅមធ្យមសិក្សាបឋមភូមិ និងការគ្រប់គ្រងថ្នាក់រៀន និងសម្ភារឧបទេស។ នៅឆ្នាំ២០២២ គម្រោងកែលម្អការអប់រំមធ្យមសិក្សាចំណេះទូទៅបានបន្តអនុវត្តតាមសាលារៀនគោលដៅចំនួន ១ ៦៣៣ ក្នុងនោះសាលាមត្តេយ្យសិក្សាសាធារណៈចំនួន ២១៣ សាលាបឋមសិក្សាសាធារណៈចំនួន ១ ០០០ និងមធ្យមសិក្សាបឋមភូមិសាធារណៈ ៤២០ នៅតាមក្រុង ស្រុក ខណ្ឌ ចំនួន ២០៣ ក្នុង ២៥ រាជធានី-ខេត្ត ក្នុងគោលបំណងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សទាំងគុណភាព និងសមធម៌សម្រាប់ការអប់រំចំណេះទូទៅ ដើម្បីសម្រេចបានស្តង់ដាអប្បបរមា។

ឆ្នាំសិក្សា២០២២-២០២៣ គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ៨៩,៦ ភាគរយ មានសញ្ញាបត្រក្រោយមធ្យមសិក្សា និង ៦៤,៥ ភាគរយ មានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រខ្ពស់ជាងនេះ។ ទោះជាយ៉ាងណា ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន គុណវុឌ្ឍិគ្រូបង្រៀនតម្រូវឱ្យបញ្ចប់ថ្នាក់ទី១២យ៉ាងតិច និងបរិញ្ញាបត្រ។ គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ តម្រូវឱ្យបញ្ចប់បរិញ្ញាបត្រ និងទទួលការបណ្តុះបណ្តាលគរុកោសល្យរយៈពេលមួយឆ្នាំនៅវិទ្យាស្ថានជាតិអប់រំ។ ជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡា មានផែនការដំឡើងកម្រិតគុណវុឌ្ឍិនៃការបណ្តុះបណ្តាលគ្រូបង្រៀនដល់ ១២+៤ ។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

តាមរយៈរង្វាយតម្លៃលទ្ធផលសិក្សាថ្នាក់ជាតិសិស្សថ្នាក់ទី៨ លទ្ធផលផ្នែកសំណេរបានបង្ហាញថា ៧៨,៧ ភាគរយ សិស្សថ្នាក់ទី៨ ទទួលបានលទ្ធផលក្រោមកម្រិតសមត្ថភាពមូលដ្ឋាន (រូបវិទ្យា ៦៨,៤ ភាគរយ គណិតវិទ្យា ៤៣,២ ភាគរយ និងអំណាន ១៧,៣ ភាគរយ)។ សិស្សប្រុសភាគច្រើនទទួលបានលទ្ធផលទាបជាងកម្រិតសមត្ថភាពមូលដ្ឋានលើផ្នែកសរសេរ និងអំណាន។ ជាមួយគ្នានេះ កត្តាសង្គម-សេដ្ឋកិច្ចនៅទីប្រជុំជន និងជនបទ មានឥទ្ធិពលទៅលើលទ្ធផលនៃការសិក្សាផងដែរ។ ស្របពេលដែលការរីករាលដាលនៃជំងឺកូវីដ-១៩ មិនទាន់មានភាពប្រសើរឡើង លទ្ធផលរង្វាយតម្លៃការសិក្សាថ្នាក់ជាតិ បង្ហាញនូវលទ្ធផលពុំទាន់ល្អប្រសើរ នៅចន្លោះឆ្នាំ ២០១៧ និង២០២២។

ប្រទេសកម្ពុជាបានចូលរួមជាផ្លូវការ ក្នុងកម្មវិធីអន្តរជាតិតេស្តរង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ក្នុងឆ្នាំ ២០២២ ដែលជាសមិទ្ធផលថ្មីមួយទៀត និងប្រើប្រាស់លទ្ធផលដើម្បីកែលម្អការបង្រៀននិងរៀន។ ការប្រៀបធៀបលទ្ធផលឆ្នាំ២០១៧ និង២០២២ បានបង្ហាញថា សិស្សទទួលបានលទ្ធផលសិក្សាកម្រិត២ ឬខ្ពស់ជាង មានសមត្ថភាពអំណានកើនឡើង ០,៤ ពិន្ទុ ពោលគឺកើនពី ៧,៥ ភាគរយ ដល់ ៧,៩ ភាគរយ។ មុខវិជ្ជាគណិតវិទ្យាកើនឡើង ២,១ ពិន្ទុ គឺកើនពី ៩,០ ភាគរយ ដល់១២ ភាគរយ។ មុខវិជ្ជាវិទ្យាសាស្ត្រកើនឡើងពី ៥,២ ភាគរយ ដល់ ១០,៤ ភាគរយ។ គម្លាតនៃលទ្ធផលរបស់សិស្សផ្នែកអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្ររវាងសាលារៀនទីប្រជុំជន និងជនបទ ត្រូវបានកាត់បន្ថយប្រមាណជា ១ដង។ ទោះបីលទ្ធផលដែលកម្ពុជាទទួលបានមានការកើនឡើង ប៉ុន្តែបើប្រៀបធៀបជាមួយបណ្ដាប្រទេសអាស៊ាន និងអង្គការសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ដែលមានការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្រិតខ្ពស់ គឺកម្ពុជាស្ថិតនៅក្រោមមធ្យមភាគនៅឡើយ។ បញ្ហាប្រឈម រួមមាន កត្តាម៉ោងសិក្សា កត្តាសិស្ស កត្តាគ្រូបង្រៀន កត្តាសាលារៀន រួមទាំងកម្មវិធីសិក្សាផងដែរ។

ក្រសួងនឹងដាក់ចេញនូវសកម្មភាពជាអាទិភាព ដើម្បីបង្កើនគុណភាពនៃការអប់រំ ដែលនឹងត្រូវឆ្លុះបញ្ចាំងក្នុងជំហានបន្ទាប់នៃកម្មវិធីរង្វាយតម្លៃអន្តរជាតិ តាមរយៈ ១) ការអនុវត្តនូវសកម្មភាពជា អាទិភាព ៤ ចំណុចរបស់រាជរដ្ឋាភិបាល ២)ការអនុវត្តកំណែទម្រង់កម្រិតសាលារៀន ៣) ការអភិវឌ្ឍគ្រូបង្រៀន តាមរយៈការកែទម្រង់សាលាគរុកោសល្យ ៤) ការពិនិត្យឡើងវិញនូវសៀវភៅសិក្សាគោល និងវិធីសាស្ត្របង្រៀន ៥) ការចូលរួមរបស់សហគមន៍ ៦) ការលើកកម្ពស់អភិបាលកិច្ច និងការគាំទ្រសាលារៀន ៧) ការអភិវឌ្ឍកម្មវិធីសិក្សា ៨) ការលើកកម្ពស់សុខភាពសិក្សា និង៩) ការគាំទ្រសិស្ស។

### ការអប់រំបច្ចេកទេស

### ការចូលរៀន

ការអប់រំបច្ចេកទេសកំពុងទាក់ទាញសិស្សកាន់តែច្រើន ប៉ុន្តែការផ្ដល់ជំនាញត្រូវឆ្លុះបញ្ចាំងពីគម្លាតយេនឌ័រ ដែលជំនាញសម្រាប់សិស្សស្រីនៅតែមានចំនួនតិចជាងសិស្សប្រុស។ ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ នេះត្រូវបានសង្កេតឃើញថា ការចុះឈ្មោះចូលរៀនផ្នែកអប់រំបច្ចេកទេស សមាមាត្រសិស្សប្រុស និងសិស្សស្រីនៅតែទាប សិស្សស្រី ១ នាក់ សិស្សប្រុស ២ នាក់។ មុខវិជ្ជាសិក្សាដែលសិស្សប្រុសបានជ្រើសរើស រួមមាន ជំនាញអគ្គិសនី អេឡិចត្រូនិក មេកានិក និងការរចនាប្រព័ន្ធផ្សព្វផ្សាយឌីជីថល។ ចំពោះសិស្សស្រី មានការសិក្សាលើមុខជំនាញ ដូចជា ជំនាញកសិកម្ម ជំនាញចិញ្ចឹមសត្វ ជំនាញកុំព្យូទ័រ ជំនាញកែច្នៃ



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ចំណីអាហារ ជំនាញគណនេយ្យ និងទេសចរណ៍។ ភាគច្រើនសិស្សស្រីចូលចិត្តជំនាញកសិកម្ម ឧស្សាហកម្ម កម្រិតទាប និងមធ្យម ការងារស្មៀន និងសេវាកម្មផ្សេងៗ ដែលជាឱកាសអាទិភាពក្នុងតម្រូវការទីផ្សារការងារ។

ក្នុងរយៈពេល ១២ ឆ្នាំ នេះ ការផ្តល់សេវាអប់រំបច្ចេកទេសកម្រិតមធ្យមសិក្សាទុតិយភូមិ (៩+៣) ត្រូវបានពង្រីកពី ២ សាលា រហូតដល់ ២១ សាលា និងពី ៤ មុខជំនាញ រហូតដល់ ១២ មុខជំនាញ ក្នុងឆ្នាំ ២០២៤ ដែលក្នុងគ្រឹះស្ថានចំនួន ១២ បានពង្រីកជំនាញបន្ថែម។ សិស្សកើនពី ៦១១ នាក់ ស្រី ១៨០ នាក់ ក្នុងឆ្នាំ ២០១២ មានដល់ ៣ ៥១២ នាក់ ស្រី ១ ២៤៦ នាក់ ក្នុងឆ្នាំ ២០២៤។ សាលារៀនមធ្យមសិក្សាចំនួន ៨៤៨ បាននិងកំពុងដំណើរការបង្រៀននិងរៀនកម្មវិធីអប់រំបំណិនជីវិត ដោយផ្តោតលើបំណិនសតវត្សទី២១ បំណិនសហគ្រិនភាព និងបំណិនបុរេវិជ្ជាជីវៈ។

ក្រសួងបានបង្កើតកម្មវិធីមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សានៅកម្រិតសាលារៀន ដើម្បីជួយសិស្សក្នុងការអភិវឌ្ឍការអប់រំ ការអភិវឌ្ឍអាជីព និងការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់សិស្ស។ ឆ្នាំសិក្សា ២០២៣-២០២៤ សិស្សទទួលផលពីកម្មវិធីចំនួន ១៦០ ៩៩១ នាក់ ស្រី ៩០ ៦០០ នាក់ ស្មើនឹង ៥៦,៤៥ ភាគរយ និងប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍បានទទួលផល សរុប ៧ ២៩៦ នាក់ ស្រី ៤ ៤៦៦ ស្មើនឹង ៦១,២១ ភាគរយ។ សាលារៀនចាប់ផ្តើមផ្តល់អន្តរាគមន៍ដល់ក្រុមសិស្សងាយរងគ្រោះ តាមរយៈការផ្តល់សេវាប្រឹក្សាដោយផ្ទាល់ និងការងារបណ្តាញចំនួន ១ ៥៥៥ នាក់ ស្រី ៨២៦ នាក់។ សាលារៀនបានផ្សព្វផ្សាយព័ត៌មានអំពីការសិក្សារបស់សិស្សជូនសហគមន៍ មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស ដែលជាសញ្ញានៃការចាប់ផ្តើមបណ្តុះទម្លាប់កសាងកិច្ចសហការគ្នាទៅវិញទៅមករវាងសាលារៀន និងមាតាបិតា និងអ្នកអាណាព្យាបាលសិស្ស ដោយបានរៀបចំកម្មវិធីជំនួបមាតាបិតាសិស្សៗ ដែលមានអ្នកចូលរួមចំនួន ៦ ៨៤៨ នាក់ ស្រី ៤ ២២១ នាក់។ ក្រសួងបានផ្សព្វផ្សាយ និងបណ្តុះគំនិតផែនការអាជីវកម្ម និងបំណិនរកប្រាក់ចំណូលដល់ក្រុមសិស្សដែលមានឧបនិស្ស័យផ្នែកសហគ្រិនភាពចំនួន ៩១ នាក់ ស្រី ៣២ នាក់។ ក្រសួងបានបំផុសសមត្ថភាពសិក្សា គំនិតច្នៃប្រឌិត ស្មារតីក្រុម កិច្ចសហការ ទំនាក់ទំនង តាមរយៈសកម្មភាពក្លឹបសិក្សា ដែលមានសិស្សចូលរួមចំនួន ១ ២៤៣ នាក់ ស្រី ៨១៣ នាក់ និងបង្កើតការងារគម្រោងសរុបចំនួន ៤៥ នាក់ ស្រី ១៥ នាក់។ សាលារៀនមានបំណិនក្នុងការពង្រឹងភាពជាដៃគូរវាងសាលារៀន និងវិស័យឯកជន ដើម្បីអភិវឌ្ឍសាលារៀន រៀបចំព្រឹត្តិការណ៍នានាក្នុងសាលារៀន ដូចជា អញ្ជើញវាគ្មិនពីខាងក្រៅមកចែករំលែកបទពិសោធការងារដល់សិស្ស ផ្តល់ទីតាំងសម្រាប់ឱ្យសិស្សទស្សនកិច្ចសិក្សា ចុះសង្កេតការងារ និងឧបត្ថម្ភធនធានសម្រាប់អភិវឌ្ឍសាលារៀន។

## គុណភាពបង្រៀន និងរៀន

ឆ្នាំសិក្សា២០២៣-២០២៤ គ្រូបង្រៀនអប់រំបច្ចេកទេស មានចំនួន ២៥២ នាក់ ស្រី ៦៤ នាក់ ដែលគ្រូបង្រៀនអគ្គិសនីចំនួន ៧៣ នាក់ ស្រី ០៦ នាក់ គ្រូបង្រៀនអេឡិចត្រូនិកចំនួន ២៨ នាក់ ស្រី ០៥ នាក់ គ្រូបង្រៀនចិញ្ចឹមសត្វចំនួន ៣៣ នាក់ ស្រី ១១ នាក់ គ្រូបង្រៀនផ្នែកកសិកម្ម ៤១ នាក់ ស្រី ១៦ នាក់ គ្រូបង្រៀនផ្នែកមេកានិក ២៣ នាក់ ស្រី ០១ នាក់ បុគ្គលិកការិយាល័យជួរមុខមានចំនួន ០៣ នាក់ ស្រី ០២ នាក់ គ្រូបង្រៀនកុំព្យូទ័រ ១៤ នាក់ ស្រី ០៣ នាក់ គ្រូបង្រៀនគណនេយ្យ ០៧ នាក់ ស្រី ០៣ នាក់ គ្រូបង្រៀនកែច្នៃចំណីអាហារ ១៦ នាក់ ស្រី ១២ នាក់ គ្រូបង្រៀនរៀបចំប្រព័ន្ធផ្សព្វផ្សាយឌីជីថលមានចំនួន ០២ នាក់ ស្រី

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

០១ នាក់ គ្រូបង្រៀនកសិកម្មមានចំនួន ១០ នាក់ ស្រី ០៤ នាក់ និងគ្រូបង្រៀនវិស្វកម្មសំណង់ស៊ីវិលចំនួន ០២ នាក់ ស្រី ០១ នាក់។

### ១.៣.៤ ការអប់រំឧត្តមសិក្សា

#### ការចូលរៀន

អត្រារួមនៃការសិក្សានៅឧត្តមសិក្សាត្រូវបានវាស់វែងលើអត្រារួមនៃការអប់រំពាក់ព័ន្ធនឹងប្រជាជនដែលមានអាយុចាប់ពី ១៨ឆ្នាំ ដល់ ២២ឆ្នាំ។ អត្រានេះបានកើនឡើងពី ៩,៩ ភាគរយ (ប្រុស ១០,៣ ភាគរយ ស្រី ៩,៣ ភាគរយ) ក្នុងឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ១៧,៩ ភាគរយ (ប្រុស ១៦,៥ ភាគរយ និងស្រី ១៩,៣ ភាគរយ) ក្នុងឆ្នាំសិក្សា ២០២២-២០២៣។ អត្រារួមនៃការសិក្សាបានកើនឡើងជាមធ្យម ០,៨ ភាគរយ ប្រុស ០,៦ ភាគរយ និងស្រី ១,០ ភាគរយ ក្នុងមួយឆ្នាំ ។

**រូបភាព ១.១៤៖ អត្រារួមនៃការសិក្សាអាយុ ១៨-២២ឆ្នាំ (ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២០២២-២០២៣)**




ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ មានការកើនឡើងគួរឱ្យកត់សម្គាល់នៃសមភាពយេនឌ័រនៅឧត្តមសិក្សា។ ជាក់ស្តែងអត្រាចុះឈ្មោះចូលរៀននៅក្នុងឆ្នាំសិក្សា ២០២២-២០២៣ និស្សិតស្រីមានរហូតដល់ ១៩,៣ ភាគរយ លើសនិស្សិតប្រុស ២,៨ ភាគរយ និងកើនឡើងជាង ២ដង បើប្រៀបធៀបទៅអត្រាចូលរៀនរបស់និស្សិតស្រីក្នុងឆ្នាំសិក្សា ២០១៣-២០១៤។ទោះបីជាយ៉ាងណា ភាពខុសគ្នាចំពោះយេនឌ័រ នៅតែកើតមានសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត ដែលចំនួននិស្សិតស្រីនៅតែតិចជាងនិស្សិតប្រុស។ ជារួម ចំនួននិស្សិតស្រីក្នុងកម្មវិធីថ្នាក់បណ្ឌិតបានកើនឡើងជិត ២ ដង ក្នុងរយៈពេល ១០ ឆ្នាំ ចុងក្រោយនេះ ចំណែកនិស្សិតប្រុស នៅតែមានចំនួនលើសលប់ដល់ជិត ៩០ ភាគរយ នៃចំនួនចុះឈ្មោះចូលរៀនសរុប។

ការចុះឈ្មោះចូលរៀនក្នុងកម្មវិធីការអប់រំស្វែម នៅឧត្តមសិក្សាមានការកើនឡើង ប៉ុន្តែការចុះឈ្មោះចូលរៀនរបស់និស្សិតស្រីនៅតែមានកម្រិតទាប។ ភាគរយនៃការចុះឈ្មោះចូលរៀនក្នុងកម្មវិធីការអប់រំស្វែមកម្រិតបរិញ្ញាបត្របានកើនឡើងពី ១៩,៦ ភាគរយ ក្នុងឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៣១,២ ភាគរយ ក្នុងឆ្នាំ ២០២២-២០២៣ ប៉ុន្តែការចុះឈ្មោះចូលរៀនរបស់និស្សិតស្រីក្នុងកម្មវិធីអប់រំស្វែម នៅតែមានកម្រិតទាបជាងនិស្សិតប្រុស ហើយគម្លាតយេនឌ័រនេះនឹងកាន់តែកើនឡើង។ និស្សិតប្រុសបានចុះឈ្មោះចូលរៀនក្នុង



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

កម្មវិធីបរិញ្ញាបត្រនៃការអប់រំស្ទែមច្រើនជាងពីរដងនៃនិស្សិតស្រីក្នុងឆ្នាំសិក្សា ២០១៣-២០១៤។ នៅចន្លោះឆ្នាំ ២០១៩-២០២១ មាននិស្សិតប្រុសច្រើនជាង ២,៥ ដង លើសនិស្សិតស្រីដែលជ្រើសរើសមុខវិជ្ជាស្ទែម។

**រូបភាព ១.១៥៖ ភាគរយនិស្សិតចូលរៀនក្នុងកម្មវិធីការអប់រំស្ទែម (ឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ២០២២-២០២៣)**




ចំនួននិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់បានកើនឡើងពី ១៨ ០១០ នាក់ ស្រី ៣ ៧៧២ នាក់ ស្មើនឹង ២០,៩៤ ភាគរយ ក្នុងឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ១៣ ០០៨ នាក់ ស្រី ៤ ៥១៤ នាក់ ស្មើនឹង ៤៣,៣៩ ភាគរយ ក្នុងឆ្នាំសិក្សា ២០២២-២០២៣។ ចំនួននិស្សិតថ្នាក់បណ្ឌិតបានកើនឡើងពី ១ ១៨១ នាក់ ស្រី ៦០ នាក់ ស្មើនឹង ៥,០៨ ភាគរយ ក្នុងឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ១ ៣៣០ នាក់ ស្រី ១៣៩ នាក់ ស្មើនឹង ១០,៩៦ ភាគរយ ក្នុងឆ្នាំសិក្សា ២០២១-២០២២។

ក្នុងរយៈពេល ជាង ១០ ឆ្នាំ កន្លងមក ក្រសួងបានបញ្ជូននិស្សិតខ្មែរទៅសិក្សានៅបរទេសក្នុងរូបភាពអាហារូបករណ៍ចំនួន ៦ ២៥៣ នាក់ ស្រី ១ ៩៩២ នាក់ ស្មើនឹង ៣១,៨៦ ភាគរយ ក្នុងនោះ នៅប្រទេសថៃចំនួន ១ ៦០៧ នាក់ ស្រី ៦៣៨ នាក់ ប្រទេសចិនចំនួន ១៥៥៣ នាក់ ស្រី ៣៩១ នាក់ ប្រទេសវៀតណាមចំនួន ១ ០៧៣ នាក់ ស្រី ២៦៦ នាក់ ប្រទេសឡាវចំនួន ១០៩ នាក់ ស្រី ៣៧ នាក់ ប្រទេសជប៉ុន ៦៣៣នាក់ ស្រី ១៦៨ នាក់ ប្រទេសអូស្ត្រាលី ៤០១ នាក់ ស្រី ១៨៩ នាក់ នៅសហព័ន្ធរុស្ស៊ី ៩៦ នាក់ ស្រី ២៣ នាក់ ប្រទេសហុងគ្រីចំនួន ១២៨ នាក់ ស្រី ៤៩ នាក់ ប្រទេសនូវែលសេឡង់ ២៥៨ នាក់ ស្រី ១១១ នាក់ ចក្រភពអង់គ្លេសមានចំនួន ៩៩ នាក់ ស្រី ៣៥ នាក់ ប្រទេសគុយបា ០៨ នាក់ សាធារណរដ្ឋឆេក ៥៤ នាក់ ស្រី ២៣ នាក់ ហ្វីលីពីន ២៥ នាក់ (ស្រី ៦នាក់) សឹង្ហបុរី ៣២ នាក់ ស្រី ១១ នាក់ និងឥណ្ឌូនេស៊ី ៧៥ នាក់ ស្រី ២២ នាក់។ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំអន្តេវាសិកដ្ឋានសម្រាប់និស្សិតស្រីស្នាក់នៅចំនួន ៥ ៣៣០ នាក់ និងសម្រាប់និស្សិតស្រីបរទេសចំនួន ៥៥០ នាក់។ រាជរដ្ឋាភិបាលកម្ពុជា និងបារាំងបានផ្តល់អាហារូបករណ៍ដល់និស្សិតថ្នាក់បណ្ឌិតផ្នែកវិទ្យាសាស្ត្រចំនួន ២៧ នាក់ ទៅសិក្សានៅប្រទេសបារាំង។ លើសពីនេះ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់អាហារូបករណ៍បរទេសចំនួន ១ ៤០៨ នាក់ ស្រី ៥៥០ នាក់ មកសិក្សានៅកម្ពុជា

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ក្នុងនោះមាននិស្សិតជនជាតិវៀតណាម ៨២១ នាក់ ស្រី ២៤៥ នាក់ ឡាវ ៤៦២ នាក់ ស្រី ១៨៥ នាក់ និង ចិន ១២៥ នាក់ ស្រី ១២០ នាក់។

ដើម្បីពង្រឹងប្រតិបត្តិការមជ្ឈមណ្ឌលឧត្តមភាព ក្រសួងនឹងបន្តអនុវត្តសកម្មភាពបន្ថែមដោយផ្តោតលើ៖ ១) ការពង្រឹងសមត្ថភាពមជ្ឈមណ្ឌលឧត្តមភាពនីមួយៗ តាមលក្ខណៈវិនិច្ឆ័យនៃប្រភេទមជ្ឈមណ្ឌលឧត្តមភាព ២) រៀបចំវេទិកាផ្សព្វផ្សាយផលប៉ះពាល់របស់មជ្ឈមណ្ឌលឧត្តមភាពជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍវិស័យឯកជន វិស័យឧស្សាហកម្ម និងផែនការអាជីវកម្មរបស់មជ្ឈមណ្ឌលសម្រាប់ការរកប្រាក់ចំណូលសម្រាប់និស្សិត សាស្ត្រាចារ្យ និងសាលាគរុកោសល្យ ៣) ការអនុវត្តប្រព័ន្ធលើកទឹកចិត្តសម្រាប់អ្នកស្រាវជ្រាវ ឬអ្នកជំនាញ។

ក្រសួងបានអនុវត្តបណ្តាញសាកលវិទ្យាល័យសាយប័រ នៅតាមគ្រឹះស្ថានឧត្តមសិក្សាគោលដៅ និងពង្រីកវិសាលភាពនៃបណ្តាញដល់គ្រឹះស្ថានឧត្តមសិក្សានៅតាមបណ្តាខេត្ត ដើម្បីលើកកម្ពស់ការអប់រំឌីជីថល។

## គុណភាពបង្រៀន និងរៀន

មជ្ឈមណ្ឌលឧត្តមភាពចំនួន៤ បានបង្កើតនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដើម្បីលើកកម្ពស់សមត្ថភាពបង្រៀននិងរៀន ការស្រាវជ្រាវនិងនវានុវត្តន៍ និងការអភិវឌ្ឍសមត្ថភាពគ្រឹះស្ថាន ក្នុងនោះមាន៖ ១) មជ្ឈមណ្ឌលឧត្តមភាពសម្រាប់នវានុវត្តន៍ការបង្រៀននិងរៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ២) មជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្មនិរន្តរភាព និងអាហារូបត្ថម្ភនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ៣) មជ្ឈមណ្ឌលឧត្តមភាព សម្រាប់ការស្រាវជ្រាវប្រព័ន្ធជលសាស្ត្រនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និង ៤) មជ្ឈមណ្ឌលឧត្តមភាពនៃការស្រាវជ្រាវ ការអភិវឌ្ឍនិងនវានុវត្តន៍ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។ តាមរយៈការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនេះ សមិទ្ធផលសំខាន់ៗដែលសម្រេចបានរួមមាន៖ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជនចំនួន ១១ បានកែលម្អការរៀបចំកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និងវិធីសាស្ត្រវាយតម្លៃ និងលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងបុគ្គលិកកម្រិតអនុបណ្ឌិត និងបណ្ឌិត ជាមួយគ្រឹះស្ថានឧត្តមសិក្សា ដៃគូនៅក្រៅប្រទេស និងគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេស ក្នុងនោះកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រ ចំនួន ៧៩ បានបង្កើតថ្មី និងកែលម្អ និងកម្មវិធីចំនួន ៦៧ បានធ្វើការវាយតម្លៃដោយអ្នកជំនាញការបរទេស និងអ្នកជំនាញការក្នុងប្រទេស។ ការធ្វើទំនើបកម្មកម្មវិធីអប់រំ តាមរយៈការរៀបចំក្របខ័ណ្ឌអភិវឌ្ឍកម្មវិធីអប់រំតាមបែបការអប់រំផ្អែកលើលទ្ធផល និងគោលការណ៍ណែនាំពាក់ព័ន្ធរួមមាន៖ ការអភិវឌ្ឍកម្មវិធីសិក្សា ការរៀបចំវិធីសាស្ត្របង្រៀន និងវិធីសាស្ត្រវាយតម្លៃលទ្ធផលសិក្សា បាននិងកំពុងរៀបចំ ដើម្បីជួយគ្រឹះស្ថានឧត្តមសិក្សាក្នុងការពង្រឹងប្រសិទ្ធភាពបង្រៀននិងរៀន។ គ្រឹះស្ថានឧត្តមសិក្សារដ្ឋចំនួន ៦ បាននិងកំពុងអនុវត្តបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា និងមានគ្រឹះស្ថានឧត្តមសិក្សាឯកជនចំនួន ២ បានចូលរួមជាសមាជិក ដើម្បីផ្តល់ការអប់រំបែបឌីជីថល។ កម្មវិធីភាពជាដៃគូក្នុងស្រុកសម្រាប់ការអប់រំស្វែមដើម្បីផ្សារភ្ជាប់គ្នា រវាងអនុវិស័យមធ្យមសិក្សា និងឧត្តមសិក្សាបាននិងកំពុងអនុវត្តតាមរយៈកិច្ចសហការរវាងគ្រឹះស្ថានឧត្តមសិក្សារដ្ឋ ៦ ជាមួយសាលារៀនមធ្យមសិក្សា ១០២ ដើម្បីបង្កើតកម្មវិធី

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

បង្រៀនសិស្សឱ្យមានបំណិនរកប្រាក់ចំណូលលើមុខជំនាញកសិកម្មនិងបច្ចេកវិទ្យា និងលើកកម្ពស់លទ្ធផលនៃការសិក្សារបស់សិស្ស តាមរយៈការបង្រៀនបែបគម្រោង ឬបែបចម្រុះមុខវិជ្ជា។

ក្រសួងបាននិងកំពុងបន្តផ្តល់អាហារូបករណ៍ដល់និស្សិតចូលរៀនថ្នាក់បរិញ្ញាបត្រ មិនបង់ថ្លៃសិក្សា ១០០ ភាគរយ នៅតាមគ្រឹះស្ថានឧត្តមសិក្សា ដោយក្នុងនោះមានកំណត់ និស្សិតអាទិភាពទូទៅ អាទិភាពនារី អាទិភាពក្រីក្រ អាទិភាពតំបន់ដាច់ស្រយាល អាទិភាពសិស្សមានពិការភាព និងសិស្សពូកែទូទាំងប្រទេស។ ក្រសួងអប់រំ យុវជន និងកីឡា បានចូលជាសមាជិកពេញសិទ្ធិទី១០ ក្នុងកម្មវិធីចល័តនិស្សិតអន្តរជាតិនៅអាស៊ីនៅឆ្នាំ ២០២៣។ តាមរយៈកម្មវិធីនេះក្រសួងបានបញ្ជូននិស្សិតមកពីគ្រឹះស្ថានឧត្តមសិក្សាសាធារណៈទៅចូលរួមកម្មវិធីផ្លាស់ប្តូរការសិក្សារយៈពេល ១ ឆមាស នៅតាមគ្រឹះស្ថានឧត្តមសិក្សាដៃគូ ដែលស្ថិតក្រោមកម្មវិធីវិធីចល័តនិស្សិតអន្តរជាតិនៅអាស៊ី នៅបណ្តាប្រទេសនៅក្នុងតំបន់អាស៊ាន រួមទាំងប្រទេសជប៉ុន និងប្រទេសកូរ៉េខាងត្បូង។

ក្រសួងក៏បានយកចិត្តទុកដាក់ក្នុងការលើកកម្ពស់អភិបាលកិច្ច និងការអភិវឌ្ឍសមត្ថភាពស្ថាប័នតាមរយៈការរៀបចំផែនការសកម្មភាពដើម្បីអភិវឌ្ឍអនុវិស័យឧត្តមសិក្សា ២០២៥-២០២៩ ដើម្បីឆ្លើយតបទៅនឹងទិសដៅអាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំ ២០២៤-២០២៨។ ក្រសួងក៏បានរៀបចំ និងអនុវត្តប្រព័ន្ធគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្ររបស់គ្រឹះស្ថានឧត្តមសិក្សាក៏ដូចជាយុទ្ធសាស្ត្ររបស់អនុវិស័យផងដែរក្នុងនោះមាន៖ ១) ប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង ២) ប្រព័ន្ធគ្រប់គ្រងទិន្នន័យឧត្តមសិក្សា ៣)ប្រព័ន្ធការតាមដានការងាររបស់និស្សិតនៅតាមគ្រឹះស្ថានឧត្តមសិក្សា ៤) ប្រព័ន្ធសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជនក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ៥) ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ៦) ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ៧) ប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សានិង ៨) ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ។ ការអនុវត្តប្រព័ន្ធ ធានាគុណភាពអប់រំផ្ទៃក្នុងត្រូវបានយកចិត្តទុកដាក់ ដើម្បីធានាបាននូវគុណភាពនៃការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានឧត្តមសិក្សា។ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជនចំនួន ៤៨ បានស្ម័គ្រចិត្តចូលរួមអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង ដោយបានរៀបចំរបាយការណ៍ស្វ័យវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងកម្រិតកម្មវិធីអប់រំ និងបានយកលទ្ធផលនៃការរកឃើញពីការធ្វើស្វ័យវាយតម្លៃនេះទៅកែលម្អកម្មវិធីផងដែរ។

## ការស្រាវជ្រាវ និងនវានុវត្តន៍

ការលើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ។ គម្រោងស្រាវជ្រាវជាច្រើន បាននិងកំពុងអនុវត្តនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន ក្នុងនោះក៏មានគម្រោងស្រាវជ្រាវផ្សារភ្ជាប់ជាមួយឧស្សាហកម្មផងដែរ។ តាមរយៈគម្រោងស្រាវជ្រាវទាំងនេះ អត្ថបទស្រាវជ្រាវជាច្រើនបានបោះពុម្ពផ្សាយនៅកម្រិតជាតិ និងនៅកម្រិតអន្តរជាតិ។ ផលិតផល និងផលិតផលគំរូកសិកម្ម និងបច្ចេកវិទ្យា ត្រូវបានផលិត ចេញពីគម្រោងស្រាវជ្រាវ។ ក្រសួងក៏បានអភិវឌ្ឍសមត្ថភាពអ្នកស្រាវជ្រាវ តាមរយៈការផ្តល់ឱកាសចូលរួមអនុវត្តគម្រោងស្រាវជ្រាវ អនុវត្តសកម្មភាពពិសោធន៍ផ្សេងៗដោយប្រើប្រាស់ឧបករណ៍ និងសម្ភារពិសោធន៍ទំនើបៗ និងសរសេរអត្ថបទ

បោះពុម្ពក្នុងទស្សនាវដ្ដីស្រាវជ្រាវជាតិ និងអន្តរជាតិ។ ទស្សនាវដ្ដីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម បានដាក់ឱ្យដំណើរការតាមរយៈការបោះពុម្ពអត្ថបទជាភាសាខ្មែរ។ ទស្សនាវដ្ដីនេះបានទទួលលេខស៊េរីស្តង់ដាអន្តរជាតិ ISSN ៣០០៥-២២៩៧ (អនឡាញ) ពីមជ្ឈមណ្ឌលអន្តរជាតិនៃលេខស៊េរីស្តង់ដា និង បានទទួលលេខ DOI សម្រាប់សម្គាល់អត្ថបទស្រាវជ្រាវក្នុងប្រព័ន្ធអនឡាញពីក្រុមហ៊ុន CROSSREF នៅចុងឆ្នាំ ២០២៣។ សៀវភៅណែនាំស្ដីពីការគ្រប់គ្រងការស្រាវជ្រាវសម្រាប់គ្រឹះស្ថានឧត្តមសិក្សា បានរៀបចំដោយក្រសួង និងដាក់ឱ្យប្រើប្រាស់ផ្ទៃក្នុងគ្រឹះស្ថានសិក្សា ដើម្បីពង្រឹងការគ្រប់គ្រងការស្រាវជ្រាវ នៅតាមគ្រឹះស្ថានឧត្តមសិក្សា។ វេទិកាឧត្តមសិក្សាប្រចាំឆ្នាំបានរៀបចំ ដើម្បីប្រមូលផ្ដុំអ្នកបង្កើតគោលនយោបាយ អ្នករៀបចំកម្មវិធីសិក្សា អ្នកស្រាវជ្រាវ អ្នកសិក្សា និស្សិត សហគ្រិន និងសាធារណជន ក្នុងការចែករំលែក ពិភាក្សា និងផ្ទៀងផ្ទាត់លទ្ធផលស្រាវជ្រាវ ឬនវានុវត្តន៍ និងរបកគំហើញ ឬគំនិតបង្កើតថ្មីៗ ដែលត្រូវបានបង្កើតឡើងចេញពីគម្រោងស្រាវជ្រាវ និងការស្រាវជ្រាវនានា។ ក្រសួងបានធ្វើការវាយតម្លៃ និងផ្ដល់ឋានៈសាស្ត្រាចារ្យដល់បុគ្គលិកអប់រំ ៣២៨ នាក់ នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ក្នុងនោះឋានៈសាស្ត្រាចារ្យ ៣២ នាក់ សាស្ត្រាចារ្យរង ៥៨ នាក់ និងសាស្ត្រាចារ្យជំនួយ ២៣៨ នាក់។

ការសិក្សាស្រាវជ្រាវមានការវិវត្តគួរឱ្យកត់សម្គាល់ក្នុងអំឡុងពេលប្រមាណ ១០ឆ្នាំ កន្លងមកនេះ។ ជាឧទាហរណ៍ ចំនួននៃការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវនៅក្នុងទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រ ដែលមានការទទួលស្គាល់ដោយស្កូភើស (Scopus) ដែលជាមូលដ្ឋានទិន្នន័យធំបំផុតរបស់ពិភពលោក បានកើនឡើងគួរឱ្យកត់សម្គាល់ពីចំនួន ២៧៧ អត្ថបទ នៅឆ្នាំ២០១៣ ដល់ចំនួន ៨៥៣ អត្ថបទ នៅឆ្នាំ២០២៣។ ចំនួនទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រក្នុងស្រុក ក៏មានកើនឡើងពីចំនួន ១៣ នៅឆ្នាំ២០១២ ដល់ចំនួន ៥២ ក្នុងពាក់កណ្ដាលឆ្នាំ២០២៤ ក្នុងនោះក៏មានកំណើនទស្សនាវដ្ដីស្រាវជ្រាវដែលបោះពុម្ពជាភាសាខ្មែរផងដែរ។ លើសពីនេះ ទស្សនាវដ្ដីស្រាវជ្រាវក្នុងស្រុកចំនួន ២ ត្រូវបានទទួលស្គាល់ដោយលិបិក្រមអាស៊ាន។

តាមរយៈមូលនិធិស្រាវជ្រាវ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមន្ទីរពិសោធន៍ទំនើបៗ កសិដ្ឋាន និងផលិតផលស្រាវជ្រាវគំរូជាច្រើន ជាពិសេសក្នុងវិស័យស្ទែម និងកសិកម្ម និងអនុវត្តការជ្រើសរើស និងផ្ដល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំជាលើកដំបូង រៀបចំប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវ រៀបចំវេទិកាស្រាវជ្រាវថ្នាក់ជាតិប្រចាំឆ្នាំ បង្កើតថ្នាលឌីជីថលសម្រាប់ចែករំលែកនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ និងថ្នាក់បណ្ឌិត និងកសាងសមត្ថភាពអ្នកស្រាវជ្រាវ និងនិស្សិតថ្នាក់ក្រោយបរិញ្ញាបត្រ តាមរយៈការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍ស្រាវជ្រាវ។

ទោះបីជាមានការវិវត្តយ៉ាងណាក៏ដោយ ការស្រាវជ្រាវ និងការអភិវឌ្ឍនៅឧត្តមសិក្សាកម្ពុជាមានបញ្ហាប្រឈម ដូចជា ចំនួនអ្នកស្រាវជ្រាវមានសញ្ញាបត្របណ្ឌិតនៅមានចំនួនតិច សមត្ថភាពស្រាវជ្រាវរបស់គ្រឹះស្ថានឧត្តមសិក្សានៅមានកម្រិត ការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវក្នុងតំបន់ឈរលំដាប់លេខរៀងទី៨ និងការស្រាវជ្រាវមិនទាន់ផ្សារភ្ជាប់ទៅនឹងតម្រូវការទីផ្សារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។

ដើម្បីពង្រឹងប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា ក្រសួងនឹងបន្តអនុវត្តយុទ្ធសាស្ត្របង្កើនគុណវុឌ្ឍិគ្រូបង្រៀនថ្នាក់បណ្ឌិត ពង្រីកការអនុវត្តមូលនិធិស្រាវជ្រាវ បន្តពង្រឹងគុណភាពទស្សនាវដ្ដី

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ស្រាវជ្រាវ និងការបោះពុម្ពផ្សាយ និងបន្តអនុវត្តភាពជាដៃគូរវាងគ្រឹះស្ថានឧត្តមសិក្សា និងវិស័យឯកជន ដើម្បីលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យា និងការវិនិយោគពីវិស័យឯកជន។

### ១.៣.៥ ការអប់រំក្រៅប្រព័ន្ធ

#### លទ្ធភាពការចូលរៀន

កម្មវិធីអប់រំក្រៅប្រព័ន្ធផ្តល់ការអប់រំក្នុងរូបភាពចម្រុះ ប៉ុន្តែការចូលរួមនៅមានកម្រិត ហើយកម្មវិធីសិក្សាភាគច្រើនបានថយចុះ។ កម្មវិធីអប់រំក្រៅប្រព័ន្ធភាគច្រើន ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងអប់រំ យុវជន និងកីឡា ទាំងកុមារ យុវជន និងមនុស្សពេញវ័យ។ កម្មវិធីនីមួយៗ មានលក្ខណៈខុសៗគ្នា ដូចជាការផ្តល់បំណិនមូលដ្ឋាន (កម្មវិធីអក្ខរកម្ម) ការបញ្ជូនកុមារ និងយុវជនទៅក្នុងការអប់រំជាផ្លូវការ (កម្មវិធីចូលរៀនឡើងវិញ) កម្មវិធីបំពេញបន្ថែម (កម្មវិធីបំពេញវិជ្ជា និងកម្មវិធីសមមូល) ឬការផ្តល់បំណិនមូលដ្ឋានដល់អ្នកគ្មានការងារធ្វើ (កម្មវិធីបង្កើនប្រាក់ចំណូល)។ នៅចន្លោះឆ្នាំ ២០១៤-២០១៥ សង្កេតឃើញថាចំនួនអ្នកសិក្សាក្នុងកម្មវិធីសមមូល និងកម្មវិធីបង្កើនប្រាក់ចំណូលមានការកើនឡើង ខណៈដែលចំនួនអ្នកសិក្សាក្នុងប្រព័ន្ធមានការធ្លាក់ចុះ។ នៅឆ្នាំ ២០២១-២០២២ ចំនួនអ្នកសិក្សាក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធមានចំនួន ៥០ ២៥៥ នាក់ ស្រី ២៦ ៦៧៧ នាក់ និងបានបញ្ចប់ការសិក្សា ៣៨ ៨០០ នាក់ ស្រី ២១ ៦១៤ នាក់។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យអប់រំក្រៅប្រព័ន្ធកំពុងដាក់អនុវត្ត ដែលនឹងគាំទ្រដល់ការប្រមូលទិន្នន័យពីរាជធានី-ខេត្តទាំង២៥ ប្រកបដោយប្រសិទ្ធភាព ដើម្បីជួយអ្នកគ្រប់គ្រងក្នុងការវិភាគអំពីការចូលរៀន និងការរៀបចំកម្មវិធីអប់រំក្រៅប្រព័ន្ធឱ្យមានភាពទាក់ទាញ។

កម្មវិធីការអប់រំក្រៅប្រព័ន្ធ ផ្តោតតែទៅលើយុវជន និងមនុស្សពេញវ័យដែលមិនទទួលបានការអប់រំមួយផ្នែកប៉ុណ្ណោះ។ ផ្អែកតាមការប៉ាន់ស្មាន អត្រាគ្របដណ្តប់ (ប្រៀបធៀបអ្នកទទួលផលពីកម្មវិធីអប់រំក្រៅប្រព័ន្ធជាក់ស្តែងទៅនឹងចំនួនប្រជាជនដែលមានតម្រូវការកម្មវិធីទាំងនេះ) នៅពេលបច្ចុប្បន្ន ធ្លាក់ចុះទាបជាងការរំពឹងទុក នៅចន្លោះពី ០,២ ភាគរយ ទៅ ២,០ ភាគរយ។ អត្រាទាំងនេះ បង្ហាញពីបញ្ហាក្នុងការពង្រីកកម្មវិធីអប់រំក្រៅប្រព័ន្ធ។ កម្មវិធីបង្កើនប្រាក់ចំណូលមិនរាប់បញ្ចូលនៅក្នុងអត្រាគ្របដណ្តប់ប៉ាន់ស្មាននៃកម្មវិធីអប់រំក្រៅប្រព័ន្ធ ដែលបង្ហាញពីការចុះឈ្មោះចូលរៀនប្រចាំឆ្នាំប្រមាណជា ១,៥ ដង នៃទំហំប៉ាន់ស្មានប្រជាជនជាអ្នកទទួលផល (ប្រជាជនគ្មានការងារធ្វើអាយុ ១៥ឆ្នាំ ទៅ ២៤ឆ្នាំ ទទួលបានការអប់រំក្រោមកម្រិតមូលដ្ឋាន)។

ក្រសួងអប់រំ យុវជន និងកីឡា បានប្រែក្លាយមជ្ឈមណ្ឌលសិក្សាសហគមន៍ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ដែលមានការកើនឡើងពី ៥ កន្លែង នៅឆ្នាំ ២០១៩ ដល់ ៣៣កន្លែង នៅឆ្នាំ ២០២៣ ក្នុងខេត្តចំនួន ៧។ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ផ្តល់ឱកាសដល់អ្នកសិក្សាតាមសហគមន៍ ដោយផ្តល់នូវការអប់រំដ៏សម្បូរបែបនៃចំណេះដឹង បំណិនជីវិត និងជំនាញអាជីវកម្មបែបសាមញ្ញ ដើម្បីចូលរួមក្នុងការអភិវឌ្ឍសហគមន៍ ក៏ដូចជាលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់សហគមន៍។ ឧទាហរណ៍៖ អង្គការឌីវីវីអន្តរជាតិ (DVV) នៅកម្ពុជាបានជ្រើសរើស «មជ្ឈមណ្ឌលសិក្សាសហគមន៍ស្រែក្នុង» ជាគម្រោងសាកល្បង ដើម្បីក្លាយជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### ១.៣.៦ ការអភិវឌ្ឍយុវជន

**កម្មវិធី និងរចនាសម្ព័ន្ធ**

ក្នុងមួយទសវត្សរ៍កន្លងមកនេះ ក្រសួងបានខិតខំអនុវត្តការងារដោយសម្រេចបានលទ្ធផលគួរជាទីមោទនៈ ផ្អែកលើគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្ត ដូចជា យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥ គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា២០២២-២០២៦ និងផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០១៩-២០២៣។

ក្រសួងបានផ្សព្វផ្សាយ និងជ្រើសរើសយុវជន និងកុមារ តាមប្រព័ន្ធផ្សព្វផ្សាយផ្លូវការរបស់ក្រសួង ដោយការធ្វើតេស្តចំណេះដឹងមូលដ្ឋាន និងជំនាញស្តីពីប្រធានបទពាក់ព័ន្ធកម្មវិធីផ្លាស់ប្តូរទំនាក់ទំនងអន្តរជាតិនីមួយៗ វប្បធម៌ខ្មែរ និងភាសាអង់គ្លេស ដើម្បីបំប៉នត្រៀមមុនបញ្ជូនទៅចូលរួម តាមការអញ្ជើញរបស់ប្រទេសដៃគូ មានដូចជា ជប៉ុន ចិន កូរ៉េ ឥណ្ឌា ប្រទេសសមាជិកអាស៊ាន។ល។ យុវជន និងកុមារ ទទួលបានចំណេះដឹង និងបទពិសោធន៍បន្ថែមទៀតលើការសិក្សាក្នុងសាលារៀន និងអភិវឌ្ឍជំនាញស្មើគ្នានៅលើឆាកអន្តរជាតិ។ ការចូលរួមកម្មវិធីអន្តរជាតិរបស់យុវជន កុមារ និងមន្ត្រី ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ បានប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យជាផ្លែផ្កា ផ្អែកលើស្មារតីចូលរួមចំណែកពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រតិភូនៃបណ្តាប្រទេសចូលរួម។ ជារួម ប្រតិភូកម្ពុជាបានចូលរួមគ្រប់សកម្មភាពនៃកម្មវិធី ដោយបានខិតខំការពារ និងដាក់ផលប្រយោជន៍កម្ពុជាជាធំ ជាពិសេសកិត្យានុភាព និងកិត្តិនាមកម្ពុជាជាអាទិភាព ក៏ដូចជាការផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីទេសចរណ៍ និងវប្បធម៌កម្ពុជាទៅកាន់អ្នកចូលរួមទាំងអស់។

កម្មវិធីជាច្រើនបានរៀបចំឡើងដើម្បីលើកកម្ពស់ជំនាញសតវត្សរ៍ទី២១ សម្រាប់យុវជន ដូចជា ការគិតបែបត្រិះរិះពិចារណា ការធ្វើការងារជាក្រុម ការច្នៃប្រឌិត ការដោះស្រាយបញ្ហា ភាពជាអ្នកដឹកនាំ ការប្រាស្រ័យទាក់ទង ការងារស្ម័គ្រចិត្ត ជំនាញភាសា អក្ខរកម្មឌីជីថល ជំនាញសារព័ត៌មាន និងភាពជាសហគ្រិន ដែលមានគោលដៅលើកកម្ពស់ទំនួលខុសត្រូវរបស់ពលរដ្ឋ ការបណ្តុះស្មារតីស្នេហាជាតិ សាមគ្គីភាព និងការដឹងគុណចំពោះសន្តិភាព និងការអភិវឌ្ឍសង្គមក្នុងចំណោមយុវជនកម្ពុជា។

ជាលទ្ធផល អនុវិស័យការអភិវឌ្ឍយុវជន បានបណ្តុះបំណិនសតវត្សរ៍ទី២១ ដល់យុវជន និងកុមារ តាមរយៈកម្មវិធីសំខាន់ៗ ដូចជា ១) កម្មវិធីជជែកដេញដោល យុវជនថ្នាក់ជាតិ ២) កម្មវិធីយុវជន២១ «សហគ្រិនបែបឌីជីថល» ៣)កម្មវិធីធុរកិច្ចជាតិសម្រាប់យុវជន ៤) កម្មវិធីអ្នកនាំសារសន្តិភាពដើម្បីសហគមន៍ខ្ញុំ ៥) សិក្ខាសាលាផ្លាស់ប្តូរបទពិសោធន៍លើបំណិនបច្ចេកវិទ្យាព័ត៌មាននិងឌីជីថល (JoTa-JoTi) ៦) អ្នកនាំសារសន្តិភាពដើម្បីសហគមន៍ខ្ញុំ ៧) កម្មវិធីស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ ៨) កម្មវិធីការប្រកួតប្រជែងផែនការអាជីវកម្ម និង ៩) កម្មវិធីអប់រំសេមមូលកម្រិតមូលដ្ឋាន។

ក្នុងក្របខ័ណ្ឌអាស៊ាន ក្រសួងបានផ្តួចផ្តើមរៀបចំ "សេចក្តីថ្លែងការណ៍រួមរបស់ថ្នាក់ដឹកនាំអាស៊ានស្តីពីឆ្នាំនៃយុវជនអាស៊ាន" ដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២ និងបានរៀបចំ កម្មវិធីយុវជនចំនួន៥ ដូចជា៖ (១) កិច្ចសន្ទនាយុវជនអាស៊ានលើកទី១ (២) ការប្រកួតវីដេអូយុវជនអាស៊ានលើកទី៦ (៣) ការប្រកួតរូបថតយុវជនអាស៊ាន (៤)

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ការប្រកួតជជែកដេញដោលយុវជនអាស៊ាន និង (៥) ជំនួបថ្នាក់ដឹកនាំកំពូលអាស៊ានជាមួយតំណាងយុវជនអាស៊ាន ដែលនឹងរួមចំណែកយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍបំណិនសតវត្សរ៍ទី២១ ដល់យុវជនកម្ពុជា និងតំបន់។

នៅចន្លោះឆ្នាំ ២០១៤-២០២៣ ក្រសួងអប់រំ យុវជន និងកីឡាបានលើកកម្ពស់ជំនាញសតវត្សរ៍ទី២១ សម្រាប់យុវជន និងកុមារចំនួន ៤៨ ៥៦៧ នាក់ ក្នុងនោះមានស្រី ៤៩ ភាគរយ បានពង្រឹងក្រុមប្រឹក្សាកុមារកម្ពុជា នៅគ្រឹះស្ថានសិក្សាចំនួន ៨ ៩៥៤ និងក្រុមប្រឹក្សាយុវជនកម្ពុជាចំនួន ៥៩៣ គ្រឹះស្ថានសិក្សា លើកកម្ពស់ចលនាប្រកួតប្រជែងកុមារ ៣ល្អ «កូនល្អ សិស្សល្អ មិត្តល្អ» ពានរង្វាន់ផ្ទើមប្រចាំឆ្នាំសម្រាប់យុវជន និងកុមារចំនួន ១ ៦៩៦ នាក់ ស្រី ៤៩ ភាគរយ និង ព្រមទាំងបានបង្កើតក្លឹបសកម្មភាព យុវជន និងក្លឹបសិក្សា ដើម្បីត្រៀមជួយដល់សិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ លើសពីនេះ ការចូលរួមក្នុងកម្មវិធីកាយរឹទ្ធិបានបង្ហាញពីការរីកចម្រើន ក្រោមការចង្អុលបង្ហាញ និងការខិតខំប្រឹងប្រែងរបស់ក្រសួង ដើម្បីអភិវឌ្ឍគំនិតផ្តួចផ្តើមទាំងនេះ ព្រមទាំងការពង្រីកសមាជិកកាយរឹទ្ធិជាតិកម្ពុជាដល់ ១៧៥ ០០០ នាក់ ស្រី ៤៩ ភាគរយ នៅតាមគ្រឹះស្ថានសិក្សាសាធារណៈឯកជន និងសហគមន៍។

ក្រសួងអប់រំ យុវជន និងកីឡា បានពង្រឹងសមត្ថភាព និងបង្កើនការយល់ដឹងរបស់យុវជនឱ្យចេះសរសេរ និងអនុវត្តគម្រោងចំនួន ២ ៤៣៧ ផ្តល់ឱកាសដល់យុវជនចំនួន ៤១ ៤៦៩ នាក់ ស្រី ៤៧,៥ ភាគរយ ដើម្បីគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច និងការពារាល់សមិទ្ធផលនានារបស់រាជរដ្ឋាភិបាល។ ការបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអ្នកស្ម័គ្រចិត្តសម្រាប់សហគមន៍ខ្ញុំ កម្មវិធីផ្ញើសារសន្តិភាពសម្រាប់សហគមន៍ខ្ញុំ ជំរំយុវជនសកល និងជំរំកាយរឹទ្ធិ។

### ១.៣.៧ ការអប់រំកាយ និងកីឡា

ចាប់ពីឆ្នាំ២០១៤ មក ភាគរយនៃសាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ដែលអនុវត្តកម្មវិធីអប់រំកាយ និងកីឡា មានការកើនឡើងពី ៥០ ទៅ ៧០ ភាគរយ។ ការកើនឡើងនេះ អាចកំណត់បានថាមកពីការដាក់ឱ្យប្រើប្រាស់កម្មវិធីអប់រំកាយក្នុងម៉ោងសិក្សានៅតាមសាលារៀនសាធារណៈ ដើម្បីបង្កើនការយល់ដឹង និងធានាគុណភាពនៃការអប់រំកាយ កម្មវិធីអប់រំកាយ និងកីឡា ចាំបាច់ត្រូវពង្រីក និងពង្រឹងដល់គ្រឹះស្ថានសិក្សាសាធារណៈ និងកន្លែងហាត់ប្រាណទាំងអស់។

គោលការណ៍ណែនាំលើគុណភាពនៃការអប់រំកាយ និងកីឡា ត្រូវបានលើកកម្ពស់នៅគ្រប់កម្រិតសាលារៀន។ គ្រូអប់រំកាយ និងកីឡា ៦០ ភាគរយ បានទទួលអត្ថប្រយោជន៍ជាច្រើនពីការបណ្តុះបណ្តាលបន្ថែមតាំងពីឆ្នាំ២០១៤។ ការកែលម្អសៀវភៅណែនាំគ្រូសម្រាប់ការអប់រំកាយ និងកីឡា នៅតាមគ្រឹះស្ថានសិក្សាត្រូវបានពង្រឹងផងដែរ។

ទោះបីជាមានការកើនឡើង ក៏កម្មវិធីសិក្សាបន្ថែមសម្រាប់សកម្មភាពកីឡានៅតែមានកម្រិត ជាពិសេសនៅតាមបណ្តាខេត្តមួយចំនួន។ អ្នកលេងកីឡាមានអាយុពី ៧ឆ្នាំ ដល់ ២៤ឆ្នាំ បានចូលរួមក្នុងសកម្មភាពអប់រំកាយ និងកីឡានៅខាងក្រៅសាលា មានកំណើន ៦,០ ភាគរយ ដោយចំនួនបុរស និងស្ត្រីស្មើគ្នា សរុប ១៨,២ ភាគរយ នៃចំនួនប្រជាជន។ លទ្ធផលនេះ ជាគំនិតផ្តួចផ្តើមដើម្បីលើកកម្ពស់វិស័យកីឡា។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

កំណែទម្រង់កីឡាបានចាប់ផ្តើមនៅឆ្នាំ២០១៥ ស្របពេលដែលមានការដួសដុលពហុកីឡដ្ឋានជាតិអូឡាំពិកទៅជាទីលានបាល់ទាត់ស្តង់ដារបស់សហព័ន្ធកីឡាបាល់ទាត់ពិភពលោក (ហ្វីហ្វា) កំណែទម្រង់កីឡាផ្តោតលើ៖ ១) ការយកចិត្តទុកដាក់ និងការចូលរួមរបស់រដ្ឋ៖ ប្រមុខរាជរដ្ឋាភិបាលបានរៀបចំការលើកទឹកចិត្តដល់កីឡាករជារៀងរាល់ឆ្នាំតាមគ្រប់រូបភាពមុនការចេញប្រកួតនៅក្រៅប្រទេស និងការផ្តល់រង្វាន់ដល់ជ័យលាភី ២) ការកែលម្អហេដ្ឋារចនាសម្ព័ន្ធកីឡាស្របតាមស្តង់ដាអន្តរជាតិ ៣) ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ៖ បង្កើនប្រាក់រង្វាន់សម្រាប់ទទួលជ័យលាភី និងបង្កើនប្រាក់ឧបត្ថម្ភអាហារប្រចាំខែ ៤) ការពង្រឹងសមត្ថភាពសហព័ន្ធកីឡា៖ ការផ្តល់មូលនិធិប្រតិបត្តិការដល់សហព័ន្ធកីឡាស្តង់ដា ៥) ការបណ្តុះបណ្តាល និងកិច្ចសហប្រតិបត្តិការល្អជាមួយគណៈកម្មាធិការជាតិអូឡាំពិក៖ ក្រសួងអប់រំ យុវជន និងកីឡា ទទួលបន្ទុកបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស។ ឆ្នាំ២០២៣ កម្ពុជាទទួលបានលទ្ធផល ដោយដណ្តើមបានមេដាយសរុប ២៨២ គ្រឿង ក្នុងនោះមេដាយមាស ៨១ ក្នុងការប្រកួតកីឡាស៊ីហ្គេម ។ កម្ពុជាជាប់ចំណាត់ថ្នាក់លេខ៤ ក្នុងចំណោមប្រទេសអាស៊ីអាគ្នេយ៍ទាំង១១ បូកនឹងទីម័រឡេស្តេ។ ក្នុងរយៈពេល ១០ឆ្នាំ មកនេះ ក្រសួងអប់រំ យុវជន និងកីឡា បានសហការរៀបចំការប្រកួតកីឡាអន្តរជាតិក្នុងប្រទេស ដោយដណ្តើមបានមេដាយចំនួន ២០១ គ្រឿង ក្នុងនោះមេដាយមាស ៦៨ ប្រាក់ ៥៧ និងសំរឹទ្ធ ៧៦។

ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងអនុវត្តកម្មវិធីអប់រំកាយ និងកីឡា ២ម៉ោង ក្នុងមួយសប្តាហ៍ ក្នុងសាលារៀនចំនួន ២ ៧៨៦។ ក្រសួងក៏បានការរៀបចំឱ្យមានការប្រកួតកីឡាតាមថ្នាក់រាជធានី-ខេត្ត ដើម្បីជ្រើសរើសសិស្សបឋមសិក្សា និងមធ្យមសិក្សាក្នុងកម្រិតថ្នាក់ជាតិ។

## ១.៤ ការវិភាគសមត្ថភាព និងការគ្រប់គ្រង

### ១.៤.១ សមត្ថភាព

ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តផែនការគោលស្តីពីការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំឆ្នាំ ២០២០-២០២៤ ក្នុងវត្ថុបំណងធានាបាននូវភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃបុគ្គលិកអប់រំនៅគ្រប់លំដាប់ថ្នាក់ តាមរយៈអតិក្រមអភិវឌ្ឍន៍សមត្ថភាព ដែលដឹកនាំដោយក្រសួងផ្អែកលើតម្រូវការ មានលក្ខណៈគ្រប់ជ្រុងជ្រោយ ជាប្រព័ន្ធ និងនិរន្តរភាព។ ដើម្បីសម្រេចបាននូវគោលដៅ ក្រសួងបានផ្តោតលើ៖ ១) ការបង្កើតគោលនយោបាយផ្អែកលើភស្តុតាង ការស្រាវជ្រាវ និងកិច្ចសន្ទនាពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយ ២) ការរៀបចំគោលនយោបាយ និងផែនការផ្អែកលើលទ្ធផល និងការអនុវត្តការពិនិត្យតាមដាន និងវាយតម្លៃ និងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំនៅគ្រប់កម្រិត ៣) ការផ្តល់ថវិការបស់រដ្ឋាភិបាល ផ្អែកលើសមធម៌ និងគុណភាព ដោយធានានូវគណនេយ្យភាពហិរញ្ញវត្ថុកាន់តែទូលំទូលាយ ៤) ការពង្រាយគ្រូ និងការគ្រប់គ្រងបុគ្គលិកឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈយន្តការអភិវឌ្ឍសមត្ថភាពជាប្រព័ន្ធ ៥)ការលើកកម្ពស់សមធម៌ក្នុងការផ្តល់សេវាអប់រំប្រកបដោយគុណភាព ព្រមទាំងការអភិវឌ្ឍយុវជន និងកីឡា និង៦) សមត្ថភាពនៃអធិការកិច្ចសាលា និងការវាយតម្លៃការសិក្សារបស់សិស្ស។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## គម្លាតសមត្ថភាពស្ថាប័ន

ក្រសួងនឹងពិនិត្យឡើងវិញលើច្បាប់ស្តីពីការអប់រំ ការពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នកម្មគោលនយោបាយអប់រំ ការរៀបចំក្របខ័ណ្ឌច្បាប់និងឯកសារគតិយុត្ត ឆ្លើយតបនឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រដ្ឋបាលសាធារណៈ និងវិមជ្ឈការនិងវិសហមជ្ឈការ ការរៀបចំផែនការអភិវឌ្ឍធនធានមនុស្ស កម្មវិធីបណ្តុះបណ្តាល ការជ្រើសរើសមន្ត្រីជំនាញមានសមត្ថភាពខ្ពស់ ការរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្ម ការរៀបចំប្រព័ន្ធគ្រប់គ្រងបុគ្គលិកនិងអភិវឌ្ឍសមត្ថភាព។

## គម្លាតសមត្ថភាពរបស់អង្គភាព

ក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់ត្រូវការបង្កើតអភិក្រមបណ្តុះបណ្តាលមានលក្ខណៈជាប្រព័ន្ធ និងកម្មវិធីជាក់លាក់ ដោយផ្តោតទៅលើ៖ ការប្រមូលនិងវិភាគស្ថិតិ ការវិភាគស្ថានភាពអប់រំ ការរៀបចំគោលនយោបាយ ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ការគ្រោងថវិកានិងការគ្រប់គ្រងហិរញ្ញវត្ថុ ការតាក់តែងកម្មវិធីសិក្សា អធិការកិច្ច និងវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ចិត្តគរុកោសល្យនិងវិធីសាស្ត្របង្រៀន ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ការបណ្តុះបណ្តាលគ្រូបង្រៀន និងការគ្រប់គ្រងសាលារៀន។ ដើម្បីធានាប្រសិទ្ធភាពនៃការអភិវឌ្ឍសមត្ថភាពមានផលជះរយៈពេលវែង ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ទាមទារឱ្យមានថវិកាគ្រប់គ្រាន់ ការបណ្តុះបណ្តាលឱ្យចំក្រុមគោលដៅ មានលក្ខណៈជាប្រព័ន្ធ និងកម្មវិធីជាក់លាក់ ។

## គម្លាតសមត្ថភាពបុគ្គល

លទ្ធផលសិក្សារបស់សិស្ស-និស្សិតនៅតាមគ្រឹះស្ថានសិក្សា មិនត្រឹមតែអាស្រ័យលើសកម្មភាពបង្រៀន និងរៀននោះទេ ការរៀបចំគោលនយោបាយ ផែនការ ការអភិវឌ្ឍកម្មវិធីសិក្សា វគ្គបណ្តុះបណ្តាល និងសកម្មភាពគាំទ្រផ្សេងទៀត ក៏ចូលរួមចំណែកដល់សមិទ្ធផលទាំងនោះ។ បច្ចុប្បន្ននេះ អ្នកឯកទេសវិជ្ជាជីវៈជាន់ខ្ពស់នៅមានចំនួនតិចតួច មិនទាន់ឆ្លើយតបទៅនឹងតម្រូវការនាពេលបច្ចុប្បន្ន និងទៅអនាគត។

## គម្លាតសមត្ថភាពរបស់អ្នកឯកទេសក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន

**ការអប់រំកុមារតូច៖** ក្រសួងអប់រំ យុវជន និងកីឡាចាំបាច់បង្កើនចំនួនគ្រូបង្រៀន និងបុគ្គលិកអប់រំដែលមានវិញ្ញាបនបត្រ/សញ្ញាបត្រ និងអភិវឌ្ឍកម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់លើជំនាញការអប់រំកុមារតូច។ ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអប់រំកុមារតូច ចាំបាច់ត្រូវកែលម្អឱ្យមានភាពស៊ីចង្វាក់គ្នា និងភាពត្រឹមត្រូវ ដើម្បីធានាបានការគ្រប់គ្រងផ្អែកសមិទ្ធកម្ម។ ក្រសួងកំពុងរៀបចំក្របខ័ណ្ឌគតិយុត្តក្នុងការគ្រប់គ្រងមត្តេយ្យសិក្សាឯកជន។

**ការអប់រំបឋមសិក្សា៖** ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំ និងដាក់ឱ្យអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនពហុភាសាជនជាតិដើមភាគតិចនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគឦសានខេត្តស្ទឹងត្រែង ដើម្បីធានាបានការអប់រំដល់កុមារជនជាតិដើមភាគតិច។ ដូចគ្នានេះដែរ ការអភិវឌ្ឍសមត្ថភាពកម្រិតអង្គភាព គឺត្រូវការជាចាំបាច់ក្នុងការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន កម្មវិធីសិក្សា និងកម្មវិធីផ្សេងៗទៀត ដើម្បីគាំទ្រ



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដល់ការអនុវត្តផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន។ ការអភិវឌ្ឍសមត្ថភាពភាសាខ្មែរ និងគណិតវិទ្យានៅថ្នាក់ដំបូង គឺត្រូវការជាចាំបាច់នៅកម្រិតបឋមសិក្សា។ ក្រសួងកំពុងរៀបចំក្របខ័ណ្ឌគតិយុត្តក្នុងការគ្រប់គ្រងបឋមសិក្សាឯកជន។

**ការអប់រំមធ្យមសិក្សា និងការអប់រំបច្ចេកទេស៖** ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងយកចិត្តទុកដាក់អភិវឌ្ឍសមត្ថភាពគ្រូបង្រៀនស្តីពីវិធីសាស្ត្របង្រៀនបែបទំនើប និងផ្តល់សេវាអប់រំឱ្យបានគ្របដណ្តប់នៅតាមតំបន់ជួបការលំបាក។ ក្រសួងក៏បានយកចិត្តទុកដាក់ទៅលើការកាត់បន្ថយអត្រាបោះបង់ការសិក្សាដោយរៀបចំប្រព័ន្ធរំលឹកជាមុន ការប្រឹក្សា និងកិច្ចសហការជាមួយសហគមន៍និងអាជ្ញាធរមូលដ្ឋាន ដើម្បីផ្តល់ការគាំទ្រដល់សិស្សដែលងាយបោះបង់ការសិក្សា ឬសិស្សដែលមានតម្រូវការពិសេស។ ការគ្រប់គ្រងតាមសាលារៀនជាអាទិភាពមួយ ដើម្បីពង្រឹងភាពជាអ្នកដឹកនាំ និងគ្រប់គ្រងដែលបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០។

**ការអប់រំក្រៅប្រព័ន្ធ៖** ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងពង្រឹងសមត្ថភាពដល់ការអនុវត្តក្របខ័ណ្ឌបណ្តុះបណ្តាល និងកម្មវិធីសិក្សាសមមូល និងអភិវឌ្ឍសមត្ថភាពភាពជាអ្នកដឹកនាំនិងគ្រប់គ្រងជំនាញកំព្យូទ័រ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ភាសាអង់គ្លេស និងរដ្ឋបាលអប់រំ ដល់មន្ត្រីអប់រំក្រៅប្រព័ន្ធសម្រាប់គ្រប់គ្រងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។

**ការអប់រំឧត្តមសិក្សា៖** សកម្មភាពសិក្សាស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សានៅមានកម្រិត។ ការរៀបចំឱ្យមានស្ថាប័នភាវូបនីយកម្មនៃគោលការណ៍ណែនាំ និងស្តង់ដាស្រាវជ្រាវ ការលើកកម្ពស់គុណវុឌ្ឍិបុគ្គលិកសិក្សា និងមន្ត្រីគ្រប់គ្រងរដ្ឋបាលគ្រឹះស្ថានឧត្តមសិក្សា រួមមាន មុខជំនាញឯកទេស និងមុខជំនាញវិទ្យាសាស្ត្របច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា អភិបាលកិច្ច ផែនការ ការធានាគុណភាព ការគ្រប់គ្រងធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស គឺចាំបាច់ដើម្បីលើកកម្ពស់វប្បធម៌ និងគុណភាពនៃការស្រាវជ្រាវ។

**ការអភិវឌ្ឍយុវជន៖** សកម្មភាពសម្រាប់ការអភិវឌ្ឍយុវជនមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ប៉ុន្តែអនុកម្មវិធីនេះមិនទាន់មានធនធានមនុស្សគ្រប់គ្រាន់ក្នុងការរៀបចំកម្មវិធី បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងយន្តការសម្របសម្រួលសម្រាប់សកម្មភាពថ្នាក់ក្រោមជាតិនៅឡើយ។

**ការអប់រំកាយ និងកីឡា៖** ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងកីឡា គោលនយោបាយ និងក្របខ័ណ្ឌបច្ចេកទេសសម្រាប់ការអប់រំកាយ និងកីឡា។ សកម្មភាពអប់រំកាយ និងកីឡាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ប៉ុន្តែអនុកម្មវិធីមិនទាន់មានធនធានមនុស្សគ្រប់គ្រាន់ ជាពិសេស គ្រូបង្វឹក អាជ្ញាកណ្តាល ចៅក្រមសម្រាប់ការប្រកួតលក្ខណៈអន្តរជាតិ គ្រូឧទ្ទេសនៅកម្រិតឧត្តមសិក្សា និង បុគ្គលិកឯកទេសផ្នែកវិទ្យាសាស្ត្រកីឡា និងវេជ្ជសាស្ត្រកីឡា។ ក្រសួងត្រូវការអតិក្រមប្រកបដោយសមធម៌ដើម្បីធានាឱ្យមានការចូលរួមរបស់ស្ត្រីក្នុងគ្រប់សកម្មភាពកីឡា។

### ១.៤.២ ការគ្រប់គ្រង

នៅថ្នាក់ជាតិ គណៈកម្មការគ្រប់គ្រងកម្មវិធីបានជួបប្រជុំជាប្រចាំ ដើម្បីពិនិត្យវឌ្ឍនភាពនៃវិស័យអប់រំតាមរយៈការរៀបចំសន្និបាតអប់រំប្រចាំឆ្នាំ។ គណៈកម្មការនេះ បានធ្វើការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ឆ្នាំ២០២១ នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដោយកែសម្រួលគោលនយោបាយអប់រំរយៈពេលមធ្យមមកត្រឹមពីរ ដើម្បីឱ្យស្របនឹងផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤។ ក្រសួងបានកែសម្រួលយុទ្ធសាស្ត្រ ចំណុចដៅ និងសូចនាករព្យាករណ៍ដល់ឆ្នាំ២០២៤។ គណៈកម្មការបានប្រមូលធនធាន និងតម្រឹមជាមួយកំណែទម្រង់អាទិភាព។

**រចនាសម្ព័ន្ធអនុវិស័យ** ត្រូវបានរៀបចំឡើងដើម្បីសម្របសម្រួលដោយរៀបចំផែនការ ការគ្រប់គ្រង និងការពិនិត្យតាមដាន។ ជាងនេះទៅទៀត ការរៀបចំផែនការអនុវិស័យត្រូវបានបន្សុំជាមួយនឹងផែនការយុទ្ធសាស្ត្រថវិកា ផែនការប្រតិបត្តិប្រចាំឆ្នាំ និងថវិកាកម្មវិធី។ ការគ្រប់គ្រង និងការពិនិត្យតាមដានត្រូវបានធ្វើឡើងតាមរយៈការពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិ និងសន្និបាតអប់រំប្រចាំឆ្នាំ ។ ការគ្រប់គ្រងកម្មវិធីថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាប់ទាក់ទងនឹងអង្គភាពថវិកាទាំងពីរកម្រិត។

## វិមជ្ឈការ និងវិសហមជ្ឈការ

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺចាំបាច់ដើម្បីជានាប្រសិទ្ធភាព និងការឆ្លើយតបទៅនឹងអាទិភាពការផ្ដល់សេវាសាធារណៈ ជាពិសេសក្នុងវិស័យអប់រំ។ ការវិភាគមុខងារ និងការពិនិត្យឡើងវិញមុខងារត្រូវបានរៀបចំឡើងសម្រាប់មុខងារ និងមុខងាររងចំនួន ៥៧៣ និងគោលនយោបាយស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងវិស័យអប់រំត្រូវបានរៀបចំឡើង ។ តាមរយៈការពិនិត្យឡើងវិញមុខងារ និងធនធានក្នុងវិស័យអប់រំ អនុលោមតាមគោលការណ៍ណែនាំរបស់រដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំមុខងារ និងភារកិច្ចរបស់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើប្រតិភូកម្ម និងផ្ទេរមុខងារទៅឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌ។

រាជរដ្ឋាភិបាលកម្ពុជា បានចេញអនុក្រឹត្យលេខ ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពី «ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ» ដើម្បីផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅទូទាំងប្រទេស។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានប្រគល់មុខងារបីក្នុងវិស័យអប់រំ រួមមាន ១) មុខងារគ្រប់គ្រងការអប់រំកុមារតូច ២) មុខងារគ្រប់គ្រងការអប់រំបឋម និង ៣) មុខងារគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ។

លើសពីនេះ ក្រសួងអប់រំ យុវជន និងកីឡា បន្តធ្វើប្រតិភូកម្មមុខងារគាំទ្រផ្នែករដ្ឋបាលលើវិស័យអប់រំ យុវជន និងកីឡា រួមមាន ១) មុខងាររដ្ឋបាលសម្រាប់គាំទ្រមុខងារសាលាមធ្យមសិក្សាចំណេះទូទៅ ២) មុខងាររដ្ឋបាលសម្រាប់គាំទ្រការអភិវឌ្ឍយុវជន និង ៣) មុខងាររដ្ឋបាលសម្រាប់គាំទ្រការអប់រំកាយ និង កីឡា។

## កំណែទម្រង់មុខងារសាធារណៈ

**កំណែទម្រង់មុខងារសាធារណៈក្នុងវិស័យអប់រំ៖** ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំកំណែទម្រង់ការគ្រប់គ្រងបុគ្គលិកអប់រំ ដើម្បីឆ្លើយតបនឹងកម្មវិធីកំណែទម្រង់មុខងារសាធារណៈរបស់រាជរដ្ឋាភិបាល។ ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ កម្មវិធីជាតិនៃការអនុវត្ត និងកំណែទម្រង់បានបង្កើនប្រសិទ្ធភាពនៃការផ្ដល់សេវាអប់រំនៅគ្រប់កម្រិតអប់រំ។ កំណែទម្រង់នេះត្រូវលើកទឹកចិត្ត ដោយរាជរដ្ឋាភិបាល រួមមាន ការបើកបៀវត្ស

របស់មន្ត្រីជាទៀងទាត់តាមរយៈប្រព័ន្ធធនាគារ ។ ការកើនឡើងបីដងនៃបៀវត្ស ដំឡើងបៀវត្សអប្បបរមាពី ៣១០ ០០០ រៀល ក្នុងឆ្នាំ២០១៣ ដល់ ១ ២០០ ០០០ រៀល នៅឆ្នាំ២០១៩ ការបង្កើនប្រាក់ឧបត្ថម្ភទ្វេដង សម្រាប់បុគ្គលិកអប់រំនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក និងប្រាក់ឧបត្ថម្ភទ្វេដងសម្រាប់ម៉ោងបង្រៀនបន្ថែម។ ក្រសួងអប់រំ យុវជន និងកីឡាបានពង្រឹងការគ្រប់គ្រងបុគ្គលិកអប់រំ គ្រូបង្រៀន និងគ្រូបង្រៀនជាប់កិច្ចសន្យា ហើយបន្តអនុវត្តការដាក់ពង្រាយគ្រូបង្រៀនពីសាលារៀនដែលមានគ្រូបង្រៀនលើសទៅសាលារៀនដែលខ្វះគ្រូបង្រៀន ។

នៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់មុខងារសាធារណៈ ក្រសួងបានធ្វើការវិភាគមុខងារបែបស៊ីជម្រៅតាមស្មារតីនៃការធ្វើវិចារណកម្ម ដោយបានកាត់ចោលមុខងារត្រួតស៊ីគ្នាក្នុងការអនុវត្តភារកិច្ច និងបានកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួន ឱ្យស្របទៅនឹងកម្មវិធីកំណែទម្រង់វិស័យអប់រំនិងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា។ ការកែសម្រួលរចនាសម្ព័ន្ធនេះ បានធ្វើឡើងក្នុងគោលបំណងដើម្បីអនុវត្តកំណែទម្រង់វិស័យអប់រំឱ្យកាន់តែមានប្រសិទ្ធភាព និងការរៀបចំផែនការអភិវឌ្ឍបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពមន្ត្រីរាជការ ក្នុងគោលដៅសម្រេចចក្ខុវិស័យឆ្នាំ២០៣០ និងឆ្នាំ២០៥០ ខាងមុខ។ ក្រសួងបានពិនិត្យ និងកាត់បន្ថយនាយកដ្ឋានចំនួន ៤ និងការិយាល័យចំនួន ៣៤ និងបានប្រែក្លាយអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ទៅជាអគ្គលេខាធិការដ្ឋាន ដើម្បីសម្របសម្រួលការងារ ព្រមទាំងបង្កើតអគ្គនាយកដ្ឋានថ្មីមួយ គឺអគ្គនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ។

**កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ**

ទាក់ទងនឹងសមត្ថភាពក្នុងការផ្តល់ថវិកាសម្រាប់សេវាអប់រំ ថវិកាដែលបានវិភាជន៍ដល់វិស័យអប់រំបានកើនឡើងនៅចន្លោះឆ្នាំ២០១៧ និង២០២០ ប៉ុន្តែថវិកាអប់រំបានធ្លាក់ចុះចាប់តាំងពីពេលនោះមកដោយសារផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩។ នៅចន្លោះឆ្នាំ២០១៧ និង ២០២២ ថវិកាដែលបានវិភាជន៍សម្រាប់វិស័យអប់រំ បានកើនឡើងជាង ៤០ ភាគរយ ក្នុងលក្ខខណ្ឌធម្មតា ដែលស្មើ ២៣ ភាគរយ នៅក្នុងលក្ខខណ្ឌជាក់ស្តែង ចាប់តាំងពីឆ្នាំ២០១៧ ។ ចាប់តាំងពីឆ្នាំ២០២០ មកថវិកាអប់រំសរុបបានធ្លាក់ចុះ។ នៅឆ្នាំ២០២២ កម្រិតនៃការវិនិយោគ គឺប្រហាក់ប្រហែលនឹងឆ្នាំ២០១៨។

ថវិកាចំណាយសាធារណៈត្រូវបានបែងចែកទៅក្រសួងអប់រំ។ នៅឆ្នាំ២០២២ ថវិការដ្ឋាភិបាលដែលបានផ្តល់ឱ្យវិស័យអប់រំគឺ ២,៦ ភាគរយ នៃផលិតផលក្នុងស្រុកសរុប។ ទាក់ទងនឹងកិច្ចខិតខំប្រឹងប្រែងរបស់វិស័យសាធារណៈ ថវិកាអប់រំក្នុងឆ្នាំ២០២២ ជិតស្មើ ១២ ភាគរយ នៃការចំណាយសាធារណៈសរុប ដោយឡែកការចំណាយបច្ចុប្បន្ននៃវិស័យអប់រំជិតស្មើ ១៥ ភាគរយ។ សេចក្តីថ្លែងការណ៍ទីក្រុងអ៊ិនឆន សាធារណរដ្ឋកូរ៉េ ឆ្នាំ២០១៥ ផ្តល់អនុសាសន៍ឱ្យរដ្ឋាភិបាលនៃប្រទេសនីមួយៗវិភាជន៍ថវិកាឱ្យបានយ៉ាងហោចណាស់ ១៥ ដល់ ២០ ភាគរយ នៃការចំណាយសាធារណៈសរុបសម្រាប់ការអប់រំ និង ៤ ដល់ ៦ ភាគរយ នៃផលិតផលក្នុងស្រុកសរុប។ ប៉ុន្តែការចំណាយសម្រាប់វិស័យអប់រំបានធ្លាក់ចុះក្នុងរយៈពេលនេះ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## រូបភាព ១.១៦៖ ភាគរយចំណាយសម្រាប់វិស័យអប់រំ ឆ្នាំ២០១៧ ដល់ ២០២៥




ថវិកាអប់រំភាគច្រើន បានចំណាយទៅលើបៀវត្សបុគ្គលិកអប់រំ ក្រៅពីនេះសម្រាប់កម្មវិធីគាំទ្រ និងអភិវឌ្ឍនានា។ ថវិកាភាគច្រើនរបស់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបែងចែកទៅលើការចំណាយប្រតិបត្តិការ ៩៨,០ ភាគរយ ក្នុងឆ្នាំ២០២៣ ក្រៅពីនេះចំណាយទៅលើការវិនិយោគ និងការអភិវឌ្ឍ។ ថវិកាចំណាយមូលធនមានដែលនៅមានកម្រិត បានធ្លាក់ចុះចាប់តាំងពីឆ្នាំ២០១៨ ស្មើ ១៥,៥ ភាគរយ។ ផ្អែកតាមការវិភាជន៍ថវិកាកម្មវិធីសម្រាប់ការអប់រំ កម្មវិធីទី៥របស់ក្រសួង ដែលរួមបញ្ចូលទាំងបៀវត្សគ្រូបង្រៀនស្រូបយកអស់ ៨៩,០ ភាគរយ នៃថវិកាសរុប ដែលធ្វើឱ្យវាមានការលំបាកក្នុងការពិនិត្យតាមដានការចំណាយនៅទូទាំងអនុវិស័យ។

មូលនិធិដំណើរការសាលារៀនសាធារណៈបង្កើនស្វ័យភាពកម្រិតសាលារៀន ប៉ុន្តែមានបញ្ហាប្រឈមមួយចំនួនចំពោះសាលារៀន និងការគ្រប់គ្រង។ មូលនិធិដំណើរការសាលារៀនសាធារណៈបានចាប់ផ្តើមក្នុងឆ្នាំ២០១៥ មានកញ្ចប់ថវិកាពីរដ្ឋាភិបាល និងការរួមចំណែកដោយដៃគូអភិវឌ្ឍនិងសហគមន៍។ មូលនិធិទាំងនេះត្រូវបានផ្ទេរដោយផ្ទាល់ទៅគណនីរបស់សាលារៀនរដ្ឋ។ បរិមាណនៃការបែងចែកមូលនិធិដំណើរការសាលារៀនសាធារណៈ គឺផ្អែកលើកម្រិតភូមិសិក្សា ចំនួនសិស្សនៅក្នុងសាលារៀន សាលារៀនស្ថិតនៅតំបន់ដាច់ស្រយាល ឬតំបន់ជួបការលំបាក។ នៅឆ្នាំ២០២២ មូលនិធិដំណើរការសាលារៀនមានចំនួន ៤,៦ ភាគរយនៃថវិកាអប់រំសរុប។

អត្រាទូទាត់ថវិកាដំណើរការសាលារៀនសាធារណៈខ្ពស់ ដែលមានដល់ ៩៨,៤ ភាគរយ ក្នុងឆ្នាំ២០១៩ ហើយមានកម្រិតប្រហាក់ប្រហែលគ្រប់អនុវិស័យលើកលែងតែវិទ្យាល័យមធ្យមសិក្សា និងបច្ចេកទេស (៩៣,៩ ភាគរយ)។ បញ្ហាប្រឈមដែលបានកត់សម្គាល់នៅក្នុងរបាយការណ៍ថវិការបស់នាយកដ្ឋានហិរញ្ញវត្ថុឆ្នាំ២០២០ រួមមានចំណេះដឹងរបស់សាលារៀនសាធារណៈនៅមានកម្រិតលើនីតិវិធីហិរញ្ញវត្ថុ និងការអនុវត្ត ដែលត្រូវការអភិវឌ្ឍសមត្ថភាពបន្ថែមជាពិសេសនៅសាលាបឋមសិក្សា និងពង្រឹងការពិនិត្យតាមដាននៃការអនុវត្តមូលនិធិដំណើរការសាលារៀនសាធារណៈ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ការចំណាយរបស់គ្រួសារសិស្សលើការអប់រំនៅតែមាន ហើយការចំណាយកាន់តែច្រើនជាបន្ទុកគ្រួសារ នៅពេលកូនរៀននៅថ្នាក់កាន់តែខ្ពស់។ ចំនួនទឹកប្រាក់ដែលគ្រួសារចំណាយលើការសិក្សារបស់កូន នៅតែមិនប្រែប្រួល លើកលែងតែការធ្លាក់ចុះយ៉ាងខ្លាំងក្នុងឆ្នាំ២០២១ ដែលអាចមកពីវិបត្តិកូវីដ-១៩ ដែលប្រការនេះអាចជាការធ្លាក់ចុះក្នុងរយៈពេលខ្លី។ ការចំណាយលើការអប់រំរបស់គ្រួសារសិស្ស បានរកឃើញថានឹងកើនឡើងជាមួយនឹងកម្រិតនៃការអប់រំកាន់តែខ្ពស់ និងការចំណាយខ្ពស់បំផុតនៅកម្រិតការអប់រំឧត្តមសិក្សា តាមរយៈការសង្កេតជាសកល។ ការចំណាយលើការអប់រំរបស់គ្រួសារសិស្សនៅតាមទីប្រជុំជននៅតែខ្ពស់ជាងទីជនបទ ជាពិសេសនៅរាជធានីភ្នំពេញ ការចំណាយលើការអប់រំពឹងផ្អែកទៅលើប្រាក់ចំណូលគ្រួសារសិស្ស។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

### ១.៤.៣ ថ្នាលប្រព័ន្ធព័ត៌មានគ្រប់គ្រង

ក្រសួង បានពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងក្នុងវិស័យអប់រំ ទាំងប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្នាក់ជាតិ និងសាលារៀន ដើម្បីបង្កើនប្រសិទ្ធភាពនៃការរៀបចំផែនការ ការពិនិត្យតាមដាន និងវាយតម្លៃ និងធ្វើរបាយការណ៍។ រហូតមកដល់ពេលនេះ ក្រសួងមានប្រព័ន្ធព័ត៌មានជាច្រើនដូចជា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធព័ត៌មានសាលារៀន សាលាឌីជីថល។ល។ ក្រសួងមានវត្តុបំណងកែលម្អ និងធ្វើសុខដុមនីយកម្មជាមួយគ្នាទាំងព័ត៌មានគ្រូបង្រៀន ព័ត៌មានសិស្ស និងការគ្រប់គ្រងសាលារៀនជាទូទៅ ដើម្បីធានាឱ្យបានភាពត្រឹមត្រូវនៃទិន្នន័យ ការវិភាគទិន្នន័យ និងការប្រើប្រាស់ទិន្នន័យសម្រាប់ការសម្រេចចិត្តគោលនយោបាយ ដើម្បីសម្រួលដល់ការកំណត់សាលារៀនអាទិភាពដែលត្រូវការគាំទ្រពីក្រសួង ឬគម្រោង និងដើម្បីដោះស្រាយបញ្ហាប្រឈមរបស់សាលារៀន។

### ១.៤.៤ ការបណ្តុះបណ្តាលគ្រូបង្រៀន

ក្រសួងបានធ្វើកំណែទម្រង់សាលាគរុកោសល្យដោយផ្តោតលើ (១) ការកែលម្អកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន (២) ការអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសលើខ្លឹមសារមេរៀន គរុកោសល្យនិងវិធីសាស្ត្របង្រៀនសម្បូរបែប និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន (៣) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្របតាមបច្ចេកវិទ្យាថ្មី បណ្ណាល័យ និងសម្ភារឧបទេសទំនើបសម្បូរបែប (៤) ការអភិវឌ្ឍភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង (៥) ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តកម្មសិក្សាគរុកោសល្យ និង (៦) ការធានាគុណភាពនៃការបណ្តុះបណ្តាល។

នាពេលខាងមុខ ក្រសួងនឹង (១) បន្តអនុវត្តកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ តាមរយៈ (i) ការបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+៤ ឬបរិញ្ញាបត្រ+១ និងគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិតាមប្រព័ន្ធ បរិញ្ញាបត្រ+២ (ii) ការកែលម្អការបណ្តុះបណ្តាលគ្រូបង្រៀនស្របតាម «ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន» និង (iii) ការផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (២) អនុវត្តអាជ្ញាប័ណ្ណវិជ្ជាជីវៈគ្រូបង្រៀន (គ្រូបង្រៀនកិច្ចសន្យា និងគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន) (៣) អនុវត្តវិធីសាស្ត្របង្រៀនថ្មីសម្រាប់ការអប់រំមធ្យមសិក្សាស្របតាមកម្មវិធីតេស្តវាយតម្លៃអន្តរជាតិ ជាពិសេសផ្តោតលើចំណេះដឹង និងបំណិនសតវត្សរ៍ទី២១ ដូចដែលបានអនុវត្តនៅសាលារៀនជំនាន់ថ្មី និងអនុវត្តអំណាន និងគណិតវិទ្យាថ្នាក់ដំបូងនៅថ្នាក់បឋមសិក្សា (៤) អនុវត្តវិធីសាស្ត្រថ្មីនៃការបង្រៀន និងរៀន និងវិធីសាស្ត្រវាយតម្លៃ

ការសិក្សាដែលអាចឱ្យសិស្សអភិវឌ្ឍបំណិនការគិតត្រិះរិះពិចារណា និងដោះស្រាយបញ្ហាទាក់ទងនឹងជីវិតប្រចាំថ្ងៃ (៥) លើកកម្ពស់ការអប់រំឌីជីថល និងវេទិកាសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីចែករំលែកឧត្តមានុវត្តន៍ដល់គ្រូបង្រៀន និង (៦) ការផ្តល់ឋានៈវិជ្ជាជីវៈដល់គ្រូឧទ្ទេស។

## ១.៤.៥ ការប្រែប្រួលអាកាសធាតុ

ការប្រែប្រួលអាកាសធាតុ បណ្តាលឱ្យប្រទេសកម្ពុជាមានបាតុភូតធម្មជាតិកើតឡើងជាញឹកញាប់ ដូចជា ខ្យល់ព្យុះ និងទឹកជំនន់ធ្វើឱ្យខូចខាត ឬបំផ្លាញអគារសិក្សា រំខានដល់ការសិក្សា និងប៉ះពាល់ដល់សុវត្ថិភាពសិស្ស និងគ្រូបង្រៀន។ លើសពីនេះ គ្រោះរាំងស្ងួត និងកំណើនសីតុណ្ហភាពខ្ពស់ បានបង្កបញ្ហាដល់ការសិក្សា និងជះឥទ្ធិពលអវិជ្ជមានដល់សុខុមាលភាពទូទៅរបស់សិស្ស។ ការប្រែប្រួលអាកាសធាតុបានជះឥទ្ធិពលផ្ទាល់ និងប្រយោលជាច្រើនលើវិស័យអប់រំ ប៉ះពាល់ដល់ទាំងហេដ្ឋារចនាសម្ព័ន្ធអប់រំ និងគុណភាពនៃការអប់រំ រួមមាន ១) ការរំខានដល់ការសិក្សា ២) ការខូចខាតហេដ្ឋារចនាសម្ព័ន្ធ ៣) ហានិភ័យសុខភាព និង ៤) កង្វះធនធាន។

ដើម្បីគាំទ្រដល់ការបន្តការអប់រំក្នុងអំឡុងពេលមានគ្រោះមហន្តរាយ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការត្រៀមបម្រុងឆ្លើយតបគ្រោះអាសន្ន នៅឆ្នាំ២០១៩ ដោយផ្តល់ការណែនាំអំពីការបង្កើតរចនាសម្ព័ន្ធសិក្សាបណ្តោះអាសន្នសម្រាប់ប្រើប្រាស់ ជាពិសេសក្នុងគ្រោះមហន្តរាយទឹកជំនន់។ ក្នុងឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការសង្គ្រោះកុមារ បានបង្កើតគោលការណ៍ណែនាំថ្មីស្តីពីការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ការរួមបញ្ចូលគោលគំនិតការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ គោលការណ៍ណែនាំនេះ រួមបញ្ចូលគំនិតទាំងនេះ នៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គមសម្រាប់សិស្សថ្នាក់ទី៤ ទី៥ និងទី៦ ។ នៅឆ្នាំ២០១៩ កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ បានគាំទ្រដល់អង្គភាពគ្រប់គ្រងគ្រោះមហន្តរាយនៃក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំកម្មវិធីសិក្សាស្តង់ដាសម្រាប់កម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលស្តីពីសុវត្ថិភាពសាលារៀន និងការត្រៀមរៀបចំសម្រាប់គ្រោះមហន្តរាយនៅកម្ពុជា។ សិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូជាង ១៤ ០០០ នាក់ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ។

នៅឆ្នាំ២០២៣ ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយអង្គការ ផ្លែនអន្តរជាតិ និងមូលនិធិសិទ្ធិកុមារ បានរៀបចំសិក្ខាសាលាថ្នាក់ជាតិមួយសម្រាប់ដាក់ឱ្យដំណើរការនូវគោលការណ៍ណែនាំអំពីប្រតិបត្តិការប្រកបដោយសុវត្ថិភាពនៃសាលារៀន។ គោលការណ៍ណែនាំមានវត្ថុបំណងបី៖ ដើម្បីការពារសិស្ស និងបុគ្គលិកអប់រំពីគ្រោះថ្នាក់ និងការពារហេដ្ឋារចនាសម្ព័ន្ធអប់រំ ការរៀបចំផែនការអប់រំដ៏រឹងមាំ ធានាបាននូវការសិក្សាគ្មានការរំខាន ខណៈពេលមានការគំរាមកំហែងផ្សេងៗ និងដើម្បីបង្កើនចំណេះដឹងរបស់សិស្ស និងអ្នកពាក់ព័ន្ធ ព្រមទាំងលើកកម្ពស់ការកាត់បន្ថយហានិភ័យ ភាពធន់ និងកំណើនប្រកបដោយនិរន្តរភាព។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ជំពូកទី២៖ ក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍវិស័យអប់រំឆ្នាំ២០២៤-២០២៨

## ២.១ របៀបវារៈការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា

### យុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល

យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ សម្រាប់កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព៖ កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដែលបានប្រកាសដាក់ឱ្យប្រើប្រាស់កាលពីខែសីហា ឆ្នាំ២០២៣ បានបង្ហាញពីរបៀបវារៈអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលសម្រាប់រយៈពេលមួយទសវត្សរ៍ខាងមុខ។ យុទ្ធសាស្ត្រនេះ បានរៀបចំឡើងបន្ទាប់ពីយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាល ដោយគូសបញ្ជាក់ពីតួនាទីនៃការអប់រំក្នុងការសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាល។ យុទ្ធសាស្ត្របញ្ចកោណនឹងអនុវត្តជា៥ដំណាក់កាលក្នុងរយៈពេល ២៥ឆ្នាំខាងមុខ។ រចនាសម្ព័ន្ធនៃយុទ្ធសាស្ត្របញ្ចកោណ មាន៖ ១) ស្នូលនៃយុទ្ធសាស្ត្រគឺ៖ ការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច ២) បរិស្ថានគ្របដណ្តប់សម្រាប់ធានាបរិយាកាសអំណោយផលដល់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល និង ៣) បញ្ចកោណយុទ្ធសាស្ត្រសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គម។

ស្នូលនៃយុទ្ធសាស្ត្រផ្តោតលើការពង្រឹងអភិបាលកិច្ច និងការធ្វើទំនើបកម្មស្ថាប័នរដ្ឋ ព្រមទាំងការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងប្រសិទ្ធភាពនៃការអនុវត្តការងារ, ការលើកកម្ពស់ និងពង្រឹងគណនេយ្យភាព និងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ, ការពង្រឹងប្រសិទ្ធភាពនៃយន្តការអធិការកិច្ច និងសវនកម្ម, ការពង្រឹងយន្តការការគ្រប់គ្រងនិងផ្តល់សេវាសាធារណៈ និងការលើកទឹកចិត្តផ្អែកលើគុណសម្បត្តិ។ ដោយរួមបញ្ចូលទាំងការងារគ្រប់គ្រងបរិស្ថាននៅក្នុងនោះផងដែរ និងការបន្តកសាងភាពជាដៃគូប្រកបដោយប្រសិទ្ធភាពសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍ។

តួនាទីស្នូលនៃការអប់រំត្រូវបានឆ្លុះបញ្ចាំង ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១៖

**បញ្ចកោណទី១៖ ការអភិវឌ្ឍមូលធនមនុស្ស**

- មុំទី១៖ ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- មុំទី២៖ ការបណ្តុះបណ្តាលជំនាញបច្ចេកទេស
- មុំទី៣៖ ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន
- មុំទី៤៖ ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង
- មុំទី៥៖ ការពង្រឹងគុណភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន

### យុទ្ធសាស្ត្រ និងកម្មវិធីសម្រាប់វិស័យអប់រំ នៅក្នុងយុទ្ធសាស្ត្របញ្ចកោណ

បញ្ចកោណទី១ កំណត់វត្ថុបំណងពីរ យុទ្ធសាស្ត្រមួយចំនួន និងកម្មវិធី ឬអន្តរាគមន៍ជាច្រើន ដែលត្រូវយកមកពិចារណាដាក់បញ្ចូលនៅក្នុងកម្មវិធីរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

មុំទី១៖ ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

- ការបន្តពង្រឹងគុណភាពអប់រំ និងការបណ្តុះបណ្តាលគ្រប់កម្រិត ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សានៅគ្រប់កម្រិត និងបង្កើតបរិយាកាសល្អសម្រាប់ការសិក្សាពេញមួយជីវិត
- ការបន្តអនុវត្តកំណែទម្រង់សាលារៀន ដោយផ្តោតលើការពង្រឹងសមិទ្ធផលដែលមានស្រាប់ ការជំរុញការបង្កើតសាលារៀនជំនាន់ថ្មី និងសាលារៀនគំរូ ការពង្រឹងអភិបាលកិច្ច និងប្រសិទ្ធភាពគ្រប់គ្រងនៅមន្ទីរអប់រំ យុវជន និងកីឡា ព្រមទាំងការជំរុញការចូលរួម និងភាពជាម្ចាស់ របស់មាតាបិតា សហគមន៍ និងវិស័យឯកជន
- ការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន និងវិធីសាស្ត្របង្រៀន ព្រមទាំងការបន្តលើកកម្ពស់ជីវភាព និងគុណតម្លៃបុគ្គលិកសិក្សាគ្រប់កម្រិត
- ការបន្តលើកកម្ពស់ការអប់រំឌីជីថល ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលតាមសាលារៀន និងការជំរុញចាប់យកនូវមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា
- ការលើកកម្ពស់សុខភាពសិក្សា និងការបង្កើនអាហារូបករណ៍សម្រាប់សិស្ស-និស្សិតក្រីក្រ និងងាយរងគ្រោះ
- ការពង្រឹងអភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា ការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍ និងនវានុវត្តន៍ និងការជំរុញភាពជាដៃគូរដ្ឋ និងឯកជន
- ការលើកកម្ពស់វិស័យកីឡាផ្សារភ្ជាប់នឹងការអប់រំ និងការបន្តជំរុញចលនា «**យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត**»។

**អាទិភាពជាតិ ដើម្បីបរិវត្តកម្មវិស័យអប់រំនៅកម្ពុជា**

បន្ថែមពីអ្វីដែលមាននៅក្នុងយុទ្ធសាស្ត្របញ្ចកោណ កម្ពុជាបានប្តេជ្ញាចិត្តមួយចំនួនទៀតក្នុងការធ្វើបរិវត្តកម្មវិស័យអប់រំ រួមមាន៖

**១) សេចក្តីថ្លែងការណ៍ជាតិនៃការប្តេជ្ញាចិត្តធ្វើបរិវត្តកម្មប្រព័ន្ធអប់រំនៅកម្ពុជា**

សេចក្តីថ្លែងការណ៍ជាតិនេះ បានធ្វើឡើងនៅក្នុងឱកាសនៃ «កិច្ចប្រជុំកំពូលស្តីពីបរិវត្តកម្មការអប់រំ» នៅខែសីហា ឆ្នាំ២០២២។ ការប្តេជ្ញាចិត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងខែកញ្ញា ឆ្នាំ២០២២ បានគូសបញ្ជាក់ពីតម្រូវការសម្រាប់ «បរិវត្តកម្មប្រព័ន្ធអប់រំឆ្ពោះទៅការអប់រំប្រកបដោយ គុណភាព សមធម៌ និងបរិយាបន្ន ភាពពាក់ព័ន្ធ និងភាពធន់ ដើម្បីដោះស្រាយបញ្ហានៃការសិក្សារៀនសូត្រ និងកសាងសង្គមប្រកបដោយសមធម៌ បរិយាបន្ន ចីរភាព និងផ្អែកលើចំណេះដឹង ស្របតាមសេចក្តីប្រាថ្នារបស់កម្ពុជា»។ ដើម្បីសម្រេចបានការប្តេជ្ញាចិត្តនេះ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់អាទិភាពចំនួន៨។ អាទិភាពទីមួយផ្តោតលើបរិបទក្រោយកូវីដ-១៩ ការបើកសាលារៀនឡើងវិញដោយសុវត្ថិភាព និងធានាការស្តារការសិក្សាឡើងវិញ និងការបន្តការសិក្សា និងអាទិភាពផ្សេងទៀតស្របតាមយុទ្ធសាស្ត្របញ្ចកោណ និងរបៀបវារៈកំណែទម្រង់ឆ្នាំ២០២៣-២០២៨។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ២) អាទិភាពនៃភាពជាដៃគូអប់រំនៅកម្ពុជា និងមូលនិធិភាពជាដៃគូសកលសម្រាប់អប់រំ

អាទិភាពនៃភាពជាដៃគូអប់រំនៅកម្ពុជា និងមូលនិធិភាពជាដៃគូសកលសម្រាប់អប់រំ គឺជាឯកសារគន្លឹះដែលរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍចាត់ទុកជាអាទិភាពនៃការផ្លាស់ប្តូរដ៏សំខាន់។ អាទិភាព គឺ «ការកែលម្អលទ្ធផលសិក្សារបស់សិស្ស» រួមបញ្ចូលអាទិភាពបីគឺ «សមភាពយេនឌ័រ» «ការរៀនប្រកបដោយគុណភាព» និង «ការបង្រៀនប្រកបដោយគុណភាព»។ ការកែលម្អលទ្ធផលសិក្សារបស់សិស្ស គឺអាចធ្វើបានតាមរយៈអន្តរាគមន៍សំខាន់ៗចំនួនបីដោយផ្អែកលើភស្តុតាងអន្តរជាតិ រួមមាន៖ គរុកោសល្យការបង្រៀនត្រូវតាមកម្រិត និងការបំប៉នបន្ថែម។ ការអនុវត្តជោគជ័យ ទាមទារឱ្យមានកំណែទម្រង់ក្នុងកម្រិតផ្សេងៗ រួមទាំងការគាំទ្រដែលផ្តល់ដោយប្រព័ន្ធជាតិដល់សាលារៀន និងគ្រូបង្រៀន (ដូចជាមូលនិធិដំណើរការសាលារៀន) ការរៀបចំការគ្រប់គ្រងតាមសាលារៀនទូទាំងប្រទេស តាមរយៈការដឹកនាំសាលាប្រកបដោយប្រសិទ្ធភាព ការវាយតម្លៃថ្នាក់រៀន និងការវិភាគស្វែងរកឧត្តមានុវត្តន៍ និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។

## ៣) របាយការណ៍ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ បានពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិក្នុងឆ្នាំ ២០២១ ដោយបានព្យាករណ៍ឡើងវិញនៅក្នុងរបាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ និងបានព្យាករណ៍រហូតដល់ឆ្នាំ២០២៥។ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ បានកែសម្រួលអាទិភាពគោលនយោបាយអប់រំ៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យ កីឡា និងពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

## ៤) គោលនយោបាយស្តីពីគ្រូបង្រៀន២០១៣ និងផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន ២០២៤-២០៣០

គោលនយោបាយ ស្តីពីគ្រូបង្រៀន បានរៀបចំឡើងក្នុងឆ្នាំ២០១៣ បានកំណត់មធ្យោបាយអភិវឌ្ឍគ្រូបង្រៀនប្រកបដោយគុណភាព សមត្ថភាព និងស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ក៏ដូចជាផ្តល់បរិយាកាសការងារប្រកបដោយជោគជ័យ និងប្រសិទ្ធភាព និងមានការទទួលស្គាល់ពីសង្គម។ វត្ថុបំណងសំខាន់ដែលបានកំណត់គឺ៖ ទាក់ទាញ និងលើកទឹកចិត្តអ្នកដែលមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន ធានាការបណ្តុះបណ្តាលប្រកបដោយគុណភាពមុនពេលបម្រើការងារជាគ្រូបង្រៀន ធានាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនក្នុងការបម្រើការងារជាប់ជាប្រចាំ និងធានាលក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ ដើម្បីសម្រេចវត្ថុបំណងទាំងនេះ ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន២០១៥-២០២០ បានរៀបចំ និងអនុវត្ត និងផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន ២០២៤-២០៣០ថ្មី បានរៀបចំឡើង ដែលគ្របដណ្តប់លើយុទ្ធសាស្ត្រ៤៖ ១) ការគ្រប់គ្រងគ្រូបង្រៀន ២) បរិវត្តកម្មភាពជាអ្នកដឹកនាំ ៣) ការអប់រំគ្រូបង្រៀន និង៤)អត្តសញ្ញាណ និងការអភិវឌ្ឍគ្រូបង្រៀន។ ផែនការ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

យុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨ បានដាក់បញ្ចូលយុទ្ធសាស្ត្រនៃផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន២០២៤-២០៣០ និងស្របតាមវត្ថុបំណងនៃគោលនយោបាយស្តីពីគ្រូបង្រៀន។

## ២.២ ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា

ឯកសារគោលនយោបាយ និងសេចក្តីប្រកាសផ្សេងៗគ្នាទាំងនេះ បង្ហាញពីរបៀបវារៈគោលនយោបាយទូលំទូលាយ និងធាតុចូលផ្សេងៗគ្នាជាច្រើននៃប្រព័ន្ធអប់រំ។ របៀបវារៈនេះ បានកំណត់លក្ខណៈនៃការបន្តកំណែទម្រង់មួយចំនួន ក៏ដូចជាគំនិតផ្តួចផ្តើមថ្មីៗ។

ខណៈពេលដែលគិតពិចារណាលើផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងសេចក្តីប្រកាសគោលនយោបាយផ្សេងៗគ្នា បង្ហាញពីទិដ្ឋភាពទូទៅ និងការរៀបចំគោលដៅ និងវត្ថុបំណងគោលនយោបាយ និងរបៀបអនុវត្តៈ

- ការឯកភាពលើចក្ខុវិស័យ និងគោលដៅរយៈពេលវែង និងការជ្រើសរើសអាទិភាពគោលនយោបាយសម្រាប់វិស័យអប់រំក្នុងអំឡុងពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- ការរៀបចំកម្មវិធីអាទិភាពសម្រាប់អនុវត្ត ដើម្បីសម្រេចអាទិភាពគោលនយោបាយ។

ចក្ខុវិស័យ និងបេសកកម្មរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ បង្ហាញអំពីអនាគតវែងឆ្ងាយនៃប្រព័ន្ធអប់រំ ដោយបានគោរពតាមយុទ្ធសាស្ត្របញ្ចកោណ និងរបៀបវារៈនៃបរិវត្តកម្មវិស័យអប់រំ។

ចក្ខុវិស័យផែនការយុទ្ធសាស្ត្រវិស័យអប់រំ គឺជានាការផ្សារភ្ជាប់រវាងការអភិវឌ្ឍប្រព័ន្ធអប់រំ និងចក្ខុវិស័យអភិវឌ្ឍជាតិៈ

| |
|---|
| **ចក្ខុវិស័យក្រសួងអប់រំ យុវជន និងកីឡាៈ** ប្រជាជនកម្ពុជា «**មានចំណេះដឹងខ្ពស់ និងជំនាញមួយយ៉ាងតិចប្រចាំជីវិត**» ប្រកបដោយអំណត់ធន់ សហគ្រិនភាព នវានុវត្តន៍ និងសីលធម៌ប្រពៃ ដោយរដ្ឋធានាផ្តល់សេវាអប់រំជាមូលដ្ឋានសម្រាប់ទាំងអស់គ្នាយ៉ាងតិចត្រឹមថ្នាក់ទី៩ បំពាក់ជំនាញ និងបច្ចេកវិទ្យាដែលជាតម្រូវការទីផ្សារការងារ និងធុរកិច្ច ពង្រឹងការបណ្តុះបណ្តាល និងផ្លាស់ប្តូរជំនាញ ស្របនឹងតម្រូវការទីផ្សារការងារ ពង្រឹងគុណភាពវិស័យឧត្តមសិក្សាឱ្យក្លាយជាមណ្ឌលមូលធនបញ្ញាជាតិ និងឃ្លាំងពុទ្ធិសកល និងយកចិត្តទុកដាក់លើជីវភាពគ្រូបង្រៀន បុគ្គលិកសិក្សា និងសាស្ត្រាចារ្យ។ |

បេសកកម្មគ្របដណ្តប់លើបរិវត្តកម្មដែលប្រព័ន្ធនឹងដំណើរការ ដើម្បីសម្រេចចក្ខុវិស័យ ដែលសង្កត់ធ្ងន់លើលក្ខណៈ ដែលជាបេះដូងផែនការយុទ្ធសាស្ត្រវិស័យអប់រំៈ ការសង្កត់ធ្ងន់លើសមធម៌ ផ្តោតលើគុណភាព និងការសិក្សា ការទទួលស្គាល់តម្រូវការសម្រាប់ភាពធន់ និងនិរន្តរភាព និងទំនាក់ទំនងតួនាទីនៃការអប់រំក្នុងការផ្លាស់ប្តូរសង្គម។

| |
|---|
| **បេសកកម្មក្រសួងអប់រំ យុវជន និងកីឡាៈ** ការធ្វើបរិវត្តកម្មប្រព័ន្ធអប់រំឆ្ពោះទៅរកការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន ភាពពាក់ព័ន្ធ និងភាពធន់ ដើម្បីដោះស្រាយបញ្ហាការសិក្សា និងកសាងសង្គមប្រកបដោយសមធម៌ បរិយាបន្ន ចីរភាព និងសង្គមផ្អែកលើពុទ្ធិ ស្របតាមបំណងប្រាថ្នាប្រទេសកម្ពុជា។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ២.៣ អាទិភាពឆ្លើយតបនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ (២០២៤-២០២៨)

យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល បានប្រែក្លាយជាអាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

| យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល | អាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា |
|---|---|
| **អាទិភាពទី១៖ ការពង្រឹងអភិបាលកិច្ចសាលារៀន** | **ការអនុវត្តស្តង់ដាសាលារៀនគំរូ៖** កិច្ចខិតខំប្រឹងប្រែងឆ្ពោះទៅរកការផ្តល់សិទ្ធិអំណាចដល់ការគ្រប់គ្រងសាលារៀន ដើម្បីដឹកនាំនិងគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព និងជំរុញការយល់ដឹងឱ្យបានទូលំទូលាយពីអាទិភាពវិស័យអប់រំដល់ភាគីពាក់ព័ន្ធទាំងអស់។ វត្ថុបំណងសំខាន់ គឺលើកកម្ពស់គុណភាពការបង្រៀន និងរៀននៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។ ការអន្តរាគមន៍ផ្សេងទៀតរួមមានការអនុវត្តស្តង់ដាសាលារៀនគំរូ ការផ្លាស់ប្តូរវប្បធម៌សាលារៀន ដើម្បីបំពេញតម្រូវការសិក្សារបស់សិស្ស និងការវាយតម្លៃលទ្ធផលសិក្សា ដោយប្រើតេស្តវាយតម្លៃថ្នាក់តំបន់ អន្តរជាតិ និងស្តង់ដាសាលារៀនគំរូមាន ៥ រួមមាន៖ (១) លទ្ធផលសិក្សារបស់សិស្ស (២) ការបង្រៀននិងរៀន (៣) ការចូលរួមរបស់សហគមន៍ (៤) ដំណើរប្រតិបត្តិការនិងរដ្ឋបាលសាលារៀន (៥) គណនេយ្យភាពរបស់សាលារៀន។ |
| **អាទិភាពទី២៖ ពិនិត្យ និងកែសម្រួលកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សា** | កិច្ចខិតខំប្រឹងប្រែងនឹងធានាថាសិស្សទទួលបានការអប់រំទូលំទូលាយ តាមរយៈមុខវិជ្ជាគោលដូចជាការអាន ការសរសេរ និងគណិតវិទ្យា និងសកម្មភាពក្រៅម៉ោងសិក្សាដែលលើកកម្ពស់ការអប់រំកាយ កីឡា និងអាកប្បកិរិយាវិជ្ជមាន។ ការបង្កើនយ៉ាងតិច ២ម៉ោងក្នុងមួយសប្តាហ៍លើសកម្មភាពក្រៅម៉ោងសិក្សា ដើម្បីលើកកម្ពស់ការសិក្សាមូលដ្ឋាន រួមមានការអាន និងគណិតវិទ្យា ការប្រឹក្សាអាជីព កម្មវិធីអភិវឌ្ឍយុវជន កម្មវិធីអប់រំបរិយាធម៌។ល។ ក្រសួងនឹងលើកកម្ពស់សមត្ថភាពគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិក្នុងការប្រើប្រាស់ និងចែករំលែកបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ និងឌីជីថលនៅក្នុងថ្នាក់រៀន និងលើកកម្ពស់ជំនាញសតវត្សទី២១ សម្រាប់យុវជន។ លទ្ធផលនៃតេស្តវាយតម្លៃថ្នាក់តំបន់ និងអន្តរជាតិនឹងវិភាគ ដើម្បីផ្សព្វផ្សាយដល់ការអភិវឌ្ឍកម្មវិធីសិក្សាបន្ថែមទៀត។ ការណែនាំឱ្យសាលារៀនអនុវត្តកម្មវិធីក្រៅម៉ោងសិក្សាក្នុងគោលដៅបង្កើន២ម៉ោងសិក្សា ក្នុង១ថ្ងៃយ៉ាងតិច។ |
| **អាទិភាពទី៣៖ ការលើកកម្ពស់សុខភាពសិក្សា** | អាទិភាពនេះ នឹងលើកកម្ពស់ការចូលរៀន តាមរយៈការផ្តល់សេវាសុខភាពមូលដ្ឋាន និងសម្ភារបរិក្ខារ ទឹកស្អាត និងអនាម័យនៅសាលារៀន លើកកម្ពស់បរិស្ថានបៃតង និងការអនុវត្តកម្មវិធីអាហារតាមសាលារៀន និងអាហារូបករណ៍។ ការដាក់បញ្ចូលការអប់រំសុខភាពទៅក្នុងកម្មវិធីសិក្សា ដើម្បីលើកកម្ពស់សុវត្ថិភាពសង្គម សមធម៌ សុខភាព ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ និងការកាត់បន្ថយភាពក្រីក្រ។ |
| **អាទិភាពទី៤៖ ការលើកទឹកចិត្តការចូលរួមពី** | ការផ្តួចផ្តើមក្រោមអាទិភាពនេះផ្តោតលើ ការជំរុញភាពជាដៃគូជាមួយមាតាបិតាអ្នកអាណាព្យាបាល ដៃគូអភិវឌ្ឍ និងសហគមន៍ ក្រសួងមានវត្ថុបំណងបង្កើតបណ្តាញគាំទ្រដ៏រឹងមាំ ដើម្បីពង្រឹងភាពជោគជ័យ និងការចូលរួមរបស់សិស្ស តាមរយៈការបង្កើតគណៈកម្មការ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| **មាតាបិតា អ្នកអាណាព្យាបាល និង សហគមន៍** | គ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់ថ្នាក់រៀន រួមមានការបង្កើតមូលនិធិស្ម័គ្រចិត្ត ដើម្បីគាំទ្រសកម្មភាពក្រៅម៉ោងសិក្សា ដូចជាកម្មវិធីសិក្សាក្រៅសាលា និងក្លឹបសិក្សា និងការលើកកម្ពស់ការចូលរួមរបស់គ្រួសារសិស្ស សហគមន៍ និងដៃគូក្នុងការជួសជុល និងសាងសង់អគារសិក្សា និងសកម្មភាពអប់រំ។ កិច្ចសហការរវាងភាគីពាក់ព័ន្ធជានាឱ្យសាលារៀនមានបរិយាកាសសិក្សាប្រកបដោយបរិយាបន្ន និងការគាំទ្រ។ |
| **អាទិភាពទី៥៖ ការជំរុញការអប់រំឌីជីថល** | អាទិភាពនេះ សង្កត់ធ្ងន់លើការរួមបញ្ចូលបច្ចេកវិទ្យាទៅក្នុងការសិក្សា ដើម្បីអភិវឌ្ឍជំនាញសំខាន់ៗសម្រាប់សកលលោកទំនើប។ គ្រូបង្រៀននឹងទទួលបានការបណ្តុះបណ្តាលការប្រើប្រាស់ឧបករណ៍ឌីជីថលប្រកបដោយប្រសិទ្ធភាព និងអនុញ្ញាតឱ្យមានការចូលរួម និងចែករំលែកបទពិសោធន៍សិក្សាថ្មីៗដល់សិស្ស។ តាមរយៈការលើកកម្ពស់អក្ខរកម្មឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យា ក្រសួងមានវត្ថុបំណងរៀបចំសិស្សសម្រាប់យុគសម័យឌីជីថល និងធានាថាសិស្សបំពាក់ដោយជំនាញ សម្រាប់ភាពជោគជ័យនាពេលអនាគត។ |
| **អាទិភាពទី៦៖ ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពក្នុងគ្រឹះស្ថានឧត្តមសិក្សា** | ការផ្តោតសំខាន់លើការលើកកម្ពស់គុណភាពនៃការបង្រៀន និងជំរុញនវានុវត្តន៍នៅសាកលវិទ្យាល័យ។ ការលើកកម្ពស់ការបណ្តុះបណ្តាលគ្រូ និងការបង្កើតភាពជាដៃគូជាមួយអាជីវកម្ម ដើម្បីផ្តល់ឱកាសដល់សិស្សសិក្សាមានគុណតម្លៃ។ តាមរយៈការបង្កើតមជ្ឈមណ្ឌលឧត្តមភាព ក្រសួងមានវត្ថុបំណងលើកកម្ពស់ឧត្តមភាពសិក្សា ការស្រាវជ្រាវ និងនវានុវត្តន៍ក្នុងគ្រឹះស្ថានឧត្តមសិក្សា។ |
| **អាទិភាពទី៧៖ ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព** | កិច្ចខិតខំប្រឹងប្រែង គឺដើម្បីបន្តលើកកម្ពស់គោលនយោបាយ ផែនការ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ការពិនិត្យតាមដាននិងវាយតម្លៃ អធិការកិច្ច ការគ្រប់គ្រងធនធានមនុស្ស ការអភិវឌ្ឍកម្មវិធីសិក្សា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការគាំទ្រគន្លងអាជីពគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ រួមបញ្ចូលទាំងការពង្រឹងវិធីសាស្ត្រគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ការកែលម្អដំណើរការរៀបចំផែនការ និងការគាំទ្រគន្លងអាជីពគ្រូបង្រៀន។ ក្រសួងមានវត្ថុបំណងធានាការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងការកែលម្អជាប់ជាប្រចាំនៅក្នុងប្រព័ន្ធអប់រំ ដែលនាំឱ្យសិស្សទទួលបានលទ្ធផលសិក្សាល្អប្រសើរ។ |
| **អាទិភាពទី៨៖ អភិវឌ្ឍការអប់រំកាយ និងកីឡា** | កិច្ចខិតខំប្រឹងប្រែងមានវត្ថុបំណងពង្រឹងសុខុមាលភាពរាងកាយ លើកកម្ពស់ការប្រកួតកីឡា និងលើកកម្ពស់សកម្មភាពហាត់ប្រាណទៀងទាត់សម្រាប់សុខភាព និងសាមគ្គីភាពសង្គម ស្របតាមពាក្យស្លោក «កីឡារស់ប្រកបដោយសុខដុមរមនាក្នុងសង្គមក្រោមម្លប់សន្តិភាព» និងចលនា «យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត»។ តាមរយៈកម្មវិធីអប់រំកាយ និងកីឡា (ក្នុងម៉ោង និងក្រៅម៉ោងសិក្សា) សិស្សអភិវឌ្ឍជំនាញជីវិតសំខាន់ៗ ដូចជា ការធ្វើការងារជាក្រុម ភាពធន់ និងវិន័យ ដែលរួមចំណែកដល់ការអភិវឌ្ឍរបស់ពួកគេ។ ក្រសួងនឹងខិតខំពង្រឹងគុណភាពអត្តពលិកជាតិ ដើម្បីប្រកួតប្រជែងគ្រប់កម្រិត និងលើឆាកអន្តរជាតិ។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ទន្ទឹមជាមួយគ្នានេះ អាទិភាពមួយទៀតគឺ «បច្ចេកវិទ្យាឌីជីថល» ដូចមានចែងក្នុងបញ្ចកោណទី៥ នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ក្នុងគោលបំណងបម្រើផលប្រយោជន៍ជាតិ និងឆ្លើយតបទៅនឹងសំណើ និងតម្រូវការរបស់ប្រជាពលរដ្ឋ ក៏ដូចជាឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ចនិងសង្គមកម្ពុជា ឆ្ពោះទៅរកការអភិវឌ្ឍធនធានមនុស្សប្រកបដោយភាពធន់ ព្រមទាំងភាពធន់នឹងវិបត្តិទាំងជំនាញក្នុងស្មារតីសហគ្រិនភាព នវានុវត្តន៍ និងក្រមសីលធម៌ និងគុណធម៌ខ្ពស់ ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសង្គម និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិស្ថានឆ្ពោះទៅរកការសម្រេចមហិច្ឆតានៃចក្ខុវិស័យកម្ពុជា ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។

សាកលវិទ្យាល័យជាតិគ្រប់គ្រង បានអភិវឌ្ឍមហាវិទ្យាល័យសេដ្ឋកិច្ច និងបច្ចេកវិទ្យាឌីជីថល ឱ្យស្របតាមនិន្នាការសេដ្ឋកិច្ច និងសង្គមឌីជីថល។ រួមទាំងការអភិវឌ្ឍផ្នែករឹង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងផ្នែកទន់ការអភិវឌ្ឍកម្មវិធីសិក្សាថ្មីស្របតាមបរិបទថ្មី។

ទាក់ទងនឹងបច្ចេកវិទ្យា វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាបានបង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈថ្មីសម្រាប់ថ្នាក់បណ្ឌិត បរិញ្ញាបត្រជាន់ខ្ពស់ វិស្វករ និងបរិញ្ញាបត្ររង និងបានបង្កើតកម្មវិធីសិក្សា សម្រាប់ការបណ្តុះបណ្តាលជំនាញថ្មីៗ ដូចជាវិស្វកម្ម វិទ្យាសាស្ត្រទិន្នន័យ ជាដើម។ ការដឹកជញ្ជូន និងប្រព័ន្ធគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញថាមពល ដំណើរការគ្រឿងអេឡិចត្រូនិក មេកានិក និងការវិភាគចំណីអាហារ។ វិស្វកម្មកម្មវិធី បញ្ញាសិប្បនិមិត្ត និងសន្តិសុខតាមអ៊ីនធឺណិត មនុស្សយន្ត និងស្វ័យប្រវត្តិកម្មឧស្សាហកម្ម និងការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ និរន្តរភាព អាជីវកម្ម និងវិទ្យាសាស្ត្ររូបវន្ត ដោយសហការជាមួយសាកលវិទ្យាល័យ ECAM LaSalle នៅប្រទេសបារាំង និងសាកលវិទ្យាល័យ Curtin នៅប្រទេសអូស្ត្រាលី ដូចជា រូបភាពកម្មវិធីសញ្ញាបត្រទ្វេ ១+៣ និងកម្មវិធី ២+៣ ដែលកម្មវិធីទាំងអស់នេះ បង្រៀនជាភាសាអង់គ្លេស។

## ២.១.៤ ការឆ្លុះបញ្ចាំងលើសន្និបាតអប់រំឆ្នាំ២០២៤

អនុសាសន៍នៃសន្និបាតអប់រំឆ្នាំ២០២៤ បានបង្ហាញនៅក្នុងតារាងខាងក្រោម ដែលបង្ហាញពីវិធានការគោលនយោបាយសំខាន់ៗចំនួន ១៥ ចំណុច ដើម្បីគាំទ្រដល់កំណែទម្រង់សាលារៀន។

| អនុសាសន៍ចំនួន ១៥ចំណុច នៅក្នុងសន្និបាតអប់រំឆ្នាំ ២០២៤ | ការឆ្លុះបញ្ចាំងនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨ |
|---|---|
| **ការពង្រឹងអភិបាលកិច្ច និង កំណែទម្រង់សាលារៀន** | អភិបាលកិច្ច សាលារៀនត្រូវបានពង្រឹង ដោយឈរលើកត្តាគន្លឹះចំនួន ៣គឺ៖ លទ្ធផលសិក្សារបស់សិស្ស ការដឹកនាំនិងគ្រប់គ្រង និងការចូលរួមរបស់មាតាបិតានិងសហគមន៍។ ការពង្រឹងអភិបាលកិច្ចសាលាមានវត្ថុបំណងបង្កើនប្រសិទ្ធភាព ស្វ័យភាព តម្លាភាព និងគណនេយ្យភាពរបស់សាលារៀនចំពោះសហគមន៍ ដោយចាប់ផ្តើមពីការពង្រឹងវិន័យ សណ្តាប់ធ្នាប់ និងអាកប្បកិរិយារបស់អ្នកគ្រប់គ្រងសាលារៀនជាមុនសិន បន្ទាប់មកគ្រូបង្រៀន សិស្ស និងមាតាបិតា។ សាលារៀនត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រងរឹងមាំ រួមទាំងក្រុមសិស្ស ជំនួយការសិស្ស ជំនួយការគ្រូបង្រៀន និង |



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| | |
|---|---|
| | ជានាគុណភាពនៃការអប់រំ និងតម្លាភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ ដែលជាមូលដ្ឋានគ្រឹះក្នុងការទាក់ទាញការចូលរួមរបស់សហគមន៍។ សាលារៀនត្រូវពង្រឹងសាមគ្គីភាពក្នុងសាលា និងទំនាក់ទំនងល្អជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ ទន្ទឹមនឹងនោះ សាលារៀនត្រូវយកចិត្តទុកដាក់លើសុខភាព សមត្ថភាព ជីវភាព និងគុណភាពរបស់បុគ្គលិក សិស្សានុសិស្ស និងសហគមន៍ ដើម្បីកែទម្រង់សាលារៀន អ្នកដឹកនាំ និងអ្នកគ្រប់គ្រងត្រូវ៖<br>**១) ពង្រឹងវិន័យ និងអប់រំសិស្សឱ្យស្រឡាញ់សាលា៖**<br>**នៅកម្រិតបឋមសិក្សា៖** រៀបចំឯកសណ្ឋាន និងសម្លៀកបំពាក់ស្អាត ការអប់រំ ណែនាំសិស្សនៅពេលគោរពទង់ជាតិ ដោយបង្ហាត់អំពីការតម្រង់ជួរ របៀបរបប ការហាត់កីឡា ការយកចិត្តទុកដាក់អំពីសុខភាពនិងសុខមាលភាពរបស់សិស្ស ការបណ្តុះមនសិការស្នេហាជាតិ ការធ្វើសមាធិ ការលេងភ្លេង ការបង្កើតក្រុមប្រឹក្សាកុមារ និងយុវជន ការផ្តល់រង្វាន់ និងការអនុវត្តទណ្ឌកម្មតាមបែបវិជ្ជមាន។<br>**នៅកម្រិតមធ្យមសិក្សា៖** រៀបចំបរិស្ថានសិក្សា ដែលគាំទ្រដល់ការសិក្សា ការផ្តល់ប្រឹក្សាអាជីព ការជួយដោះស្រាយបញ្ហាសិស្ស កម្មវិធីមិត្តអប់រំមិត្ត ការរៀបចំ ពិព័រណ៍ស្នាដៃសិស្ស ដើម្បីលើកទឹកចិត្តដល់ការសិក្សានិងស្វ័យសិក្សា ការបណ្តុះបំណិនសតវត្សរ៍ទី២១ និងការផ្តល់ឱកាសដល់សិស្សក្នុងការប្រកួតប្រជែងដើម្បីបញ្ចេញស្នាដៃ។<br>**២) ការងារជាមួយមាតាបិតា៖** នាយកសាលាត្រូវធ្វើការងារជាមួយមាតាបិតា ដើម្បីផ្តល់ការគាំទ្របន្ថែមដល់សិស្សដូចជា ការរៀបចំកម្មវិធីបំប៉ន ទស្សនកិច្ចសិក្សា ការប្រជុំជាប្រចាំ ការបង្កើតប្រព័ន្ធទំនាក់ទំនងជាមួយមាតាបិតា ជាពិសេសនៅពេលសិស្សអវត្តមាន និងការផ្សព្វផ្សាយលទ្ធផលសិក្សា។<br>**៣) ការងារជាមួយគ្រូបង្រៀន៖** សាលារៀនត្រូវការពារផលប្រយោជន៍របស់គ្រូ យកចិត្តទុកដាក់ដល់សុខទុក្ខរបស់បុគ្គលិក ការរៀបចំយន្តការស្វ័យគ្រប់គ្រង ការផ្តល់ការគាំទ្រដល់គ្រូបង្រៀន ការប្រើប្រាស់បច្ចេកវិទ្យា បន្ទប់ពិសោធន៍ ការផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ការបង្កើនគុណវុឌ្ឍិ ការស្រាវជ្រាវប្រតិបត្តិ ដើម្បីកែលម្អវិធីសាស្ត្របង្រៀន និងការផ្តល់ការលើកទឹកចិត្តតាមគ្រប់រូបភាព។<br>**៤) ការពង្រឹងការដឹកនាំ និងគ្រប់គ្រង៖** សាលារៀនត្រូវបង្កើត (១) គណៈកម្មការគ្រប់គ្រងសាលារៀន និងគ្រប់គ្រងថ្នាក់រៀន ការរៀបចំផែនការកែលម្អសាលារៀន ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ (២) ការបែងចែកតួនាទីភារកិច្ចដល់គណៈគ្រប់គ្រងតាមគោលការណ៍ ស្វ័យភាព និងការចុះកិច្ចសន្យាការងាររវាងគណៈគ្រប់គ្រងសាលារៀនជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន (៣) ការបង្កើនភាពជាម្ចាស់និងគណនេយ្យភាព (៤) ការបណ្តុះស្មារតី ពង្រឹងសមត្ថភាពខ្លួនឯងជាប្រចាំ (៥) ការគ្រប់គ្រងប្រកបដោយតម្លាភាព (៦) ការរៀបចំបរិស្ថានសាលារៀនស្អាត (៧)ការបង្កើតបណ្ណាល័យស្តង់ដានិងមានផាសុខភាពសម្រាប់ការអាន។ |
| **ការពង្រឹងវិន័យ សីលធម៌ និងឥរិយាបថសិស្ស** | គោលដៅនៃការអប់រំ គឺការលើកកម្ពស់វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទារបស់សិស្ស ជាពិសេសការអភិវឌ្ឍផ្នែកស្មារតី រាងកាយ សុខភាព វិន័យ សីលធម៌ ចំណេះដឹង បំណិន និងឥរិយាបថល្អ។ សាលារៀនត្រូវ៖<br>**១) ការអប់រំសិស្ស៖** បណ្តុះស្មារតីសិស្សឱ្យមករៀនទាន់ពេលវេលា ការបណ្តុះទម្លាប់ល្អដល់កុមារ (ភាពស្អាតនៃរាងកាយ ការស្លៀកពាក់ របៀបហូបអាហារ ការប្រើប្រាស់សម្ភារសិក្សា ការចូលបន្ទប់ទឹក ការលាងសម្អាតដៃ របៀបសំពះ សុភាពរាបសារ សេចក្តីក្លាហានក្នុងការនិយាយ និងទំនាក់ទំនងជាដើម) ការយល់ដឹងពីសិល្បៈ តន្ត្រី វប្បធម៌ និងបរិស្ថានជុំវិញ រួមទាំងការធ្វើសមាធិ ដើម្បីយល់ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | ហេតុផល ការអប់រំតាមបែបវិជ្ជមាន ការលើកទឹកចិត្តចំពោះ ឥរិយាបថល្អ និងមានសេចក្ដីក្លាហានក្នុងការទាក់ទងរវាងកុមារនិងកុមារ រវាងកុមារនិងរៀមច្បងឬចាស់ព្រឹទ្ធាចារ្យ មាតាបិតា លោកគ្រូ អ្នកគ្រូ និងការបង្កើតកម្មវិធីក្រៅម៉ោងសិក្សា ដើម្បីលើកកម្ពស់ការចូលរួមរបស់ព្រះសង្ឃក្នុងការលើកកម្ពស់សីលធម៌ និងចរិយាធម៌របស់សិស្ស។<br>២) **ការងារជាមួយគ្រូបង្រៀន៖** ពង្រឹងសីលធម៌ និងឥរិយាបថរបស់គ្រូឱ្យទៅជាគំរូ ដល់សិស្ស ការអភិវឌ្ឍវិធីសាស្ត្របង្រៀន របៀបនៃការសិក្សារៀនសូត្ររបស់សិស្ស ការយល់ដឹងអំពីភាសាទំនាក់ទំនង បរិស្ថានសិក្សាទាំងក្នុងបរិវេណ និងបរិស្ថានជុំវិញសាលារៀន។<br>៣) **បរិស្ថានសិក្សា៖** បង្កើតបរិស្ថានសាលារៀនស្អាត ការលើកកម្ពស់ អនាម័យ និង បរិស្ថានបៃតង ការអនុវត្តសកម្មភាពបន្ថែមទាំងក្នុងថ្នាក់និងក្រៅថ្នាក់ ការអប់រំសុខភាពសិក្សាដើម្បីបណ្ដុះទម្លាប់ល្អ វិន័យ សីលធម៌ និងឥរិយាបថ។ |
| **ការលើកកម្ពស់អាហារូបត្ថម្ភតាមសាលា-រៀន** | ការលើកកម្ពស់អាហារូបត្ថម្ភតាមសាលារៀន៖ កម្មវិធីផ្ដល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ បានដោះស្រាយបញ្ហាអសន្តិសុខស្បៀងក្នុងចំណោមសិស្ស ដោយធានាឱ្យសិស្សទទួលបានអាហារមួយពេលទៀងទាត់ និងមានជីវជាតិ។ ឧត្ដមានុវត្តន៍នៃកម្មវិធីនេះគឺ៖<br>១) **ការអប់រំប្រកបដោយសមធម៌៖** ដោយបានលើកកម្ពស់សុវត្ថិភាពស្បៀង អាហារូបត្ថម្ភ និងអនាម័យ ទឹកស្អាត ការលូតលាស់ខួរក្បាលនិងរាងកាយ ការផ្លាស់ប្ដូរទម្លាប់របស់សិស្សឱ្យបរិភោគអាហារមានតុល្យភាព សុខភាព និងសុខុមាលភាពរបស់សិស្ស ភាពឆ្លាតវៃ វិន័យ សាមគ្គីភាព ភាពក្លាហាន និងសីលធម៌ ការបណ្ដុះទម្លាប់ល្អ ការមករៀនទាន់ពេល ការធ្វើការជាក្រុម។ តាមរយៈកម្មវិធីនេះ លទ្ធផលសិក្សារបស់សិស្សកាន់តែល្អប្រសើរ អត្រាបោះបង់ការសិក្សា និងអត្រាត្រួតថ្នាក់ត្រូវបានកាត់បន្ថយ។<br>២) **ការផ្ដល់សន្តិសុខសង្គម៖** កាត់បន្ថយចំណាយរបស់មាតាបិតាលើការបរិភោគអាហារបានមួយពេល និងជួយបង្កើនជីវភាពគ្រួសារ។<br>៣) **ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន៖** យុទ្ធនាការទិញស្បៀងតាមសហគមន៍ បានជំរុញឱ្យកសិករតាមសហគមន៍ខិតខំដាំដំណាំតាមតម្រូវការក្នុងកម្រិតខ្នាតតូច និងបានបង្កើតទីផ្សារសម្រាប់កសិករក្នុងសហគមន៍ ការលើកកម្ពស់ការដាំដុះបន្លែ ការចិញ្ចឹមសត្វ និងការបង្កើតប្រភពចំណូលដល់កសិករ ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ ការគាំទ្រដល់វិស័យកសិកម្មក្នុងស្រុក និងពង្រឹងខ្សែសង្វាក់ផ្គត់ផ្គង់តាមមូលដ្ឋាន។ សាលារៀនមួយចំនួនបានជំរុញឱ្យមានការដាំដំណាំក្នុងសាលារៀន ដើម្បីអាចរកប្រាក់ចំណូលពីកម្មវិធីនេះផងដែរ។<br>កត្តាជានាដោគជ័យដល់ការអនុវត្តកម្មវិធីអាហារូបត្ថម្ភតាមសាលារៀន រួមមាន៖<br>– ការផ្លាស់ប្ដូរពីកម្មវិធីអាហារពេលព្រឹកបែបបុរាណទៅជាកម្មវិធីអាហារពេលព្រឹក ដោយប្រើប្រាស់កសិផលក្នុងសហគមន៍ តាមរយៈផ្សព្វផ្សាយ និងកៀរគរសហគមន៍ឱ្យចូលរួមវិភាគទានបន្ថែមដល់ចុងភៅ និងទិញសម្ភារផ្ទះបាយ<br>– សាលារៀនត្រូវរៀបចំទីតាំងឱ្យបានល្អ |

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | – សហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីផ្សព្វផ្សាយ និងហាមឃាត់ការលក់ដូរអាហារគ្មានសុវត្ថិភាពនៅក្បែរបរិវេណសាលារៀន<br>– សហការជាមួយអាជ្ញាធរ ដៃគូអភិវឌ្ឍ និងសហគមន៍ឱ្យជួយផ្តល់គ្រាប់ពូជដំណាំ និងបច្ចេកទេស ឬរបៀបនៃការដាំដុះដំណាំ<br>– ការយកចិត្តទុកដាក់ក្នុងការអនុវត្តកម្មវិធីអាហារតាមសាលារៀន ពីគណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ ដោយមានយន្តការអនុវត្តច្បាស់លាស់ និងអ្នកពាក់ព័ន្ធបានបំពេញតួនាទី និងភារកិច្ចប្រកបដោយការទទួលខុសត្រូវ<br>– សហគមន៍ចូលរួម និងគាំទ្រទាំងពេលវេលា សម្ភារ និងថវិកា តាមរយៈការផ្គត់ផ្គង់បន្លែ ត្រី សាច់ និងគ្រឿងទេស។ |
| **ការជំរុញការចូលរួមរបស់សហគមន៍តាមរយៈមូលនិធិសមធម៌** | ការជំរុញការចូលរួមរបស់សហគមន៍តាមរយៈមូលនិធិស្ម័គ្រចិត្ត៖ ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់គុណភាពអប់រំមានច្រើនរូបភាព។ ដើម្បីជានាបានភាពជោគជ័យ សាលារៀនត្រូវអនុវត្តដូចខាងក្រោម៖<br>– បង្កឱកាសឱ្យគ្រប់ភាគីពាក់ព័ន្ធសហការគ្នាក្នុងការជួយសិស្សឱ្យចេះរៀន និងជួយកែលម្អបរិស្ថានថ្នាក់រៀន និងសាលារៀន<br>– លើកទឹកចិត្តឱ្យសិស្ស គ្រូបង្រៀន និងមាតាបិតាឱ្យរួមគ្នាកំណត់កិច្ចការត្រូវធ្វើ ក្នុងការជួយសិស្ស និងសាលារៀន<br>– លើកទឹកចិត្តគ្រប់ភាគីពាក់ព័ន្ធក្នុងការជួយគ្រូបង្រៀនឱ្យមានទឹកចិត្តបង្រៀន និងគ្រប់គ្រងសិស្សឱ្យអាចរៀនបានកាន់តែប្រសើរ ឆ្លើយតបនឹងតម្រូវការរបស់សហគមន៍<br>– ប្រជុំផ្សព្វផ្សាយ និងកៀរគរធនធាននៅតាមសហគមន៍ |
| **ការបង្រៀននិងរៀនពេញមួយថ្ងៃ** | គោលការណ៍ណែនាំស្តីពីការរៀនពេញមួយថ្ងៃនឹងត្រូវដាក់ចេញឱ្យអនុវត្តនៅតាមសាលារៀនដែលមានសក្តានុពល ទាំងលទ្ធភាព អគារសិក្សា បន្ទប់រៀន និងគ្រូបង្រៀន ក្នុងវត្ថុបំណង៖<br>– សិស្សមានទំនុកចិត្តចំពោះសាលារៀនដែលមានសក្តានុពល ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព<br><br>ការលើកកម្ពស់គុណភាពអប់រំ និងការបង្កើតឱកាសសិក្សាវែងឆ្ងាយ ព្រមទាំងការបង្ការមិនឱ្យសិស្សយកពេលទៅប្រព្រឹត្តអំពើអបាយមុខផ្សេងៗ សាលារៀនមានការរីកចម្រើនខាងផ្នែកកែលម្អ បរិស្ថាន ការអនុវត្តកម្មវិធីសិក្សា បានគ្រប់ជ្រុងជ្រោយ ការអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗជាពិសេស ការលើកកម្ពស់អំណាន និងការរៀបចំសកម្មភាពក្រៅម៉ោងសិក្សា ដូចជា សិល្បៈ តន្ត្រី វប្បធម៌ គេហវិជ្ជា បណ្ណាល័យ ការអប់រំសីលធម៌ វិន័យ និងសម្មាធិ ការប្រើប្រាស់ធនធានសម្ភាររបស់សាលារៀន និងម៉ោងសិក្សាឱ្យអស់លទ្ធភាព<br>– ការកៀរគរសហគមន៍ឱ្យចូលរួមគាំទ្រ និងវិនិយោគលើវិស័យអប់រំ ចាប់ពីកម្រិតបឋមសិក្សា<br>– មាតាបិតាមានឱកាសពេញលេញ ក្នុងការប្រកបរបរចិញ្ចឹមជីវិត។ |

| | |
|---|---|
| | ដើម្បីពង្រឹងគុណភាពនៅកម្រិតបឋមសិក្សា ក្រសួងនឹងរៀបចំកែទម្រង់កម្មវិធីសិក្សាពីការរៀនមួយពេលទៅការរៀននិងបង្រៀនពេញមួយថ្ងៃ រៀបចំក្រុមធានាគុណភាពផ្ទៃក្នុង រៀបចំបុគ្គលិកសិក្សាឱ្យសមស្របតាមសមត្ថភាពជំនាញ រៀបចំកម្មវិធីសិក្សាផ្តោតលើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ចាត់ចែងនិងគ្រប់គ្រងសៀវភៅសិក្សាគោលឱ្យបានគ្រប់គ្រាន់ រៀបចំបន្ទប់រៀននិងថ្នាក់រៀនជាបណ្តើរៗឱ្យមានបច្ចេកវិទ្យា បង្កើនការបង្រៀនភាសាបរទេស និងការរៀបចំបរិស្ថានសាលារៀនទាំងមូលឱ្យក្លាយជាទីមេត្រី។ ឧត្តមានុវត្តន៍នៃការអនុវត្តការបង្រៀន និងរៀនពេញមួយថ្ងៃ មានដូចជា៖<br>– ការបង្រៀននិងរៀនពេញមួយថ្ងៃ តាមកម្មវិធីសិក្សាទំនើប ដោយបង្កើនម៉ោងសិក្សា ពង្រីកការអនុវត្តកម្មវិធី សិក្សានិងមុខវិជ្ជាសិក្សា លើកកម្ពស់ការអប់រំឌីជីថល ការបង្រៀនភាសាបរទេស និងការអប់រំស្នែមភាសាជាតិ ភាសាបរទេស កុំព្យូទ័រ រ៉ូបូទិក ។ល។<br>– មុនពេលចាប់ផ្តើមដំណើរការរៀនពេញមួយថ្ងៃ សាលារៀនត្រូវសិក្សាពីការចំណាយរបស់សិស្ស អគារសិក្សា ទីតាំងភូមិសាស្ត្រ ជំនួបជាមួយគ្រូ និងជំនួបជាមួយមាតាបិតា<br>– ការកំណត់មុខសញ្ញាចំណាយដូចជា បុគ្គលិករដ្ឋបាលសាលារៀន ការអភិវឌ្ឍសាលារៀន និងសន្សំទុក<br>– ការប្រជុំពិភាក្សារវាងគណៈកម្មការគ្រប់គ្រងសាលារៀនជាមួយគ្រូបង្រៀន ជាមួយមាតាបិតា និងអ្នកពាក់ព័ន្ធ ដើម្បីពន្យល់អំពីដំណើរការ និងលទ្ធផលរំពឹងទុក និងមានការឯកភាពគ្នា។ |
| **ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការអប់រំ** | ក្រសួងបាននិងកំពុងបន្តអភិវឌ្ឍ និងជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្ទែមនៃការអប់រំ ដើម្បីកសាងមូលធនមនុស្សសម្រាប់សេដ្ឋកិច្ចឌីជីថល តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការអប់រំនៅសាលារៀនជំនាន់ថ្មី។ អត្ថប្រយោជន៍នៃការអប់រំឌីជីថល៖<br>– សិស្សរៀនដោយខ្លួនឯង និងឆ្លាតជាងមុន<br>– សិស្សស្គាល់ពីបច្ចេកវិទ្យាឌីជីថល និងការប្រើប្រាស់<br>– ឱកាសសិក្សាទូលំទូលាយ និងសិស្សមានទំនួលខុសត្រូវ<br>– ការចូលរួមរបស់គ្រូបង្រៀន និងមាតាបិតាកាន់តែស៊ីជម្រៅ<br><br>វិធីសាស្ត្រសម្បូរបែបនៃការសិក្សាបច្ចេកវិទ្យាឌីជីថល រួមមាន៖<br>– ការរៀនសម្របខ្លួន ការកត់ចំណាំ និងល្បែងសិក្សា<br>– ការរៀនលាយបញ្ចូលគ្នា បច្ចេកវិទ្យាថ្នាក់រៀន ការរៀនបែបវិភាគ<br>– ការរៀនតាមប្រព័ន្ធអ៊ីនធឺណិត ទូរស័ព្ទ<br>– ការធ្វើពិសោធន៍តាមបែបឌីជីថល និងការធ្វើចំណោល<br><br>ដើម្បីជំរុញការប្រើប្រាស់ឌីជីថល ក្រសួងនឹងបន្ត៖<br>– អភិវឌ្ឍសមត្ថភាពគ្រូបង្រៀនជាប្រចាំលើវិធីសាស្ត្របង្រៀន និងការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាក្នុងការបង្រៀន |

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| | |
|---|---|
| | – បំពាក់សម្ភារបរិក្ខារបម្រើឱ្យការអប់រំឌីជីថលនៅទីចាត់ការ បន្ទប់រៀន បណ្ណាល័យ និងបន្ទប់កុំព្យូទ័រ<br>– លើកទឹកចិត្តសិស្ស និងគ្រូបង្រៀន ឱ្យចូលរួមដោយមិនគិតពីកត្តាបរាជ័យ<br>– សហការជាមួយក្រសួង និងក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត ដើម្បីភ្ជាប់សេវា ដល់សាលារៀន<br>– សហការជាមួយក្រសួងមានសមត្ថកិច្ច ក្នុងការបិទការផ្សព្វផ្សាយកម្មវិធីផ្សេងៗ ដែលរំខានសិស្សនៅលើឧបករណ៍ឌីជីថលរបស់ពួកគេ។ |
| **ការអនុវត្តកម្មវិធីសិក្សាបន្ថែមក្រៅម៉ោងសិក្សា** | ការបណ្តុះនូវបំណិនសម្បទាបន្ថែមដល់សិស្ស ដែលរួមមាន៖ (១) ចំណេះដឹងមូលដ្ឋានដូចជា មុខវិជ្ជាសំខាន់ៗនៅក្នុងកម្មវិធីសិក្សា (២) ប្រឹក្សាអាជីព និងបំណិនជីវិត (៣) កម្មវិធីអភិវឌ្ឍយុវជន<br>– ការបណ្តុះជំនាញបន្ថែម ភាពច្នៃប្រឌិត ការធ្វើការជាក្រុម ទំនាក់ទំនង និងមានចរិយាធម៌<br>– ការទទួលស្គាល់ស្នាដៃនិងស្មារតីលះបង់ ភាពជាគំរូរបស់យុវជន និងភាពជាអ្នកដឹកនាំ<br>– ការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា កម្មវិធីមុខជំនាញស្វែម អំណានក្នុងបណ្ណាល័យ សិល្បៈ កសិកម្ម អប់រំកាយកីឡា និងវប្បធម៌<br>ដូចនេះដើម្បីអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា សាលារៀនត្រូវ៖<br>– បង្កើតគណៈកម្មការគ្រប់គ្រងការអនុវត្តកម្មវិធី<br>– ជួបជាមួយអ្នកអាណាព្យាបាលសិស្ស<br>– ស្វែងរក និងទាក់ទងអង្គភាព ឬអង្គការដៃគូ សហគ្រិនភាព ឬសាលាបច្ចេកទេស ដើម្បីជួយគាំទ្រដល់ការអនុវត្ត<br>– បង្កើតរចនាសម្ព័ន្ធគ្រូប្រឹក្សាអាជីព និងជ្រើសរើសគ្រូអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា<br>– ផ្សព្វផ្សាយព័ត៌មានដល់សិស្ស និងអ្នកអាណាព្យាបាលនៅកម្មវិធីក្រៅម៉ោងសិក្សា<br>– ជ្រើសរើសសិស្សតាមកម្មវិធី ដែលពួកគេពេញចិត្ត។ |
| **សាលារៀនស្អាតក្នុងក្របខ័ណ្ឌយុទ្ធនាការសាលារៀនគ្មានសំរាម** | ការលើកកម្ពស់សុខភាពអនាម័យរបស់អ្នកអប់រំនិងអ្នកសិក្សា ការចូលរួមថែរក្សាបរិស្ថានសាលារៀន និងសហគមន៍ឱ្យមានភាពបៃតង តាមរយៈការអប់រំអំពីការទុកដាក់សំរាម ការញែកសំរាម ការកែច្នៃសំរាមឡើងវិញ ការអភិរក្សជីវចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងការបណ្តុះស្មារតីឱ្យស្រឡាញ់បរិស្ថាន ដើម្បីធានាឱ្យបាននូវសិស្សស្អាត ថ្នាក់រៀនស្អាត គ្រូបង្រៀនស្អាត សាលារៀនស្អាត និងសហគមន៍ស្អាត។<br>ដើម្បីធ្វើឱ្យសាលារៀនស្អាតគ្មានសំរាម គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន អ្នកពាក់ព័ន្ធត្រូវអនុវត្តវិធានការ៤ គឺ៖<br>**១) ចក្ខុវិស័យ និងការប្តេជ្ញាចិត្ត៖** គណៈគ្រប់គ្រងសាលារៀន និងបុគ្គលិកត្រូវមានការប្តេជ្ញាចិត្តខ្ពស់ មានស្មារតីការងារជាក្រុម ភាពជាម្ចាស់ និងចក្ខុវិស័យ ដើម្បីកែលម្អសាលារៀនស្របតាមស្តង់ដាសាលារៀនកុមារមេត្រី សាលាមេត្រីបរិស្ថាន និងសូចនាករស្តង់ដាអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | **២) ការចូលរួម៖** ព្រះសង្ឃ គ្រូបង្រៀន សិស្ស មាតាបិតា សហគមន៍ និងអាជ្ញាធរមូលដ្ឋានត្រូវចូលរួមគាំទ្រក្នុងគ្រប់រូបភាព។<br>**៣) ភាពជាអ្នកដឹកនាំ៖** សមត្ថភាពក្នុងការកៀរគរធនធាន ការបង្កើតជំនឿទុកចិត្ត ការគ្រប់គ្រងប្រកបដោយតម្លាភាព។<br>**៤) ការបង្កើតយន្តការគ្រប់គ្រង៖** ការចូលរួមរបស់ក្រុមប្រឹក្សាកុមារ ក្រុមប្រឹក្សាយុវជន និងបុគ្គលិកកសាង និងក្នុងការថែទាំបរិស្ថានសិក្សា។ |
| **មជ្ឈមណ្ឌលឧត្តមភាពនៅឧត្តមសិក្សា** | **១) ការបង្កើតមជ្ឈមណ្ឌលឧត្តមភាព៖** ដោយត្រូវវិនិយោគលើគ្រឹះស្ថានឧត្តមសិក្សា ដែលមានសក្តានុពល ដូចជាការកែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារសិក្សា អន្តេវាសិកដ្ឋាន មន្ទីរពិសោធន៍ កសិដ្ឋាន មជ្ឈមណ្ឌលឌីជីថល ដើម្បីប្រែក្លាយជាគ្រឹះស្ថានឧត្តមសិក្សាឈានមុខ និងអាចទទួលបានស្តង់ដាកម្រិតតំបន់ និងអន្តរជាតិ (University Ranking) និងប្រែក្លាយ គ្រឹះស្ថានទាំងនោះ ជាមជ្ឈមណ្ឌលធនធានសម្រាប់ប្រើប្រាស់រួមគ្នា។<br>**២) ការពង្រឹងអភិបាលកិច្ច និងសមត្ថភាពស្ថាប័ន៖** ដោយត្រូវធានាស្វ័យភាព គណនេយ្យភាព ប្រព័ន្ធធានាគុណភាពផ្ទៃក្នុង ប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវ ប្រព័ន្ធគ្រប់គ្រងទិន្នន័យឌីជីថល ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធអភិបាលកិច្ច និងការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា ដើម្បីផ្តល់ការទទួលស្គាល់គុណភាពអប់រំ ការកសាងផែនការយុទ្ធសាស្ត្រនិងផែនទីបង្ហាញផ្លូវ ការបញ្ចូលអ្នកមានសញ្ញាបត្រថ្នាក់បណ្ឌិតក្នុងក្របខណ្ឌមន្ត្រីរាជការ ការបង្កើតកម្មវិធីថ្នាក់ក្រោយបណ្ឌិត ការសិក្សាលើជំនាញពាក់ព័ន្ធនឹងការងារទាំងរយៈពេលខ្លី និងវែង (reskilling & upskilling) និងការរៀបចំប្រព័ន្ធវាយតម្លៃការបំពេញការងារផ្អែកលើសមិទ្ធកម្ម។<br>**៣) ការធ្វើទំនើបកម្មកម្មវិធីសិក្សា និងការពង្រឹងប្រសិទ្ធភាពនៃការបង្រៀន និងរៀន៖** ដោយត្រូវធ្វើទំនើបកម្ម និងការអភិវឌ្ឍកម្មវិធីសិក្សា ដោយផ្អែកលើលទ្ធផល (Outcome-Based Education Program–OBE) រួមទាំងការផ្តល់សិទ្ធិដល់គ្រឹះស្ថានឧត្តមសិក្សា ក្នុងការកែសម្រួល និងការអនុវត្តកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ការបញ្ចូលមុខវិជ្ជាថ្មីៗ និងការបង្កើតកម្មវិធីសិក្សាជំនាញថ្មី ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យាឌីជីថល និងបដិវត្តន៍ឧស្សាហកម្ម ៤.0 ដូចជា៖ បញ្ញាសិប្បនិម្មិត វិទ្យាសាស្ត្រទិន្នន័យ មេកាត្រូនិច បច្ចេកវិទ្យាព័ត៌មាន វិទ្យាសាស្ត្រកុំព្យូទ័រ បច្ចេកវិទ្យាអាហារ វិទ្យាសាស្ត្ររូបធាតុ និងគ្រឿងបង្កុំវិស្វកម្មអេឡិចត្រូនិច ស្វ័យប្រវត្តិកម្ម មុខវិជ្ជាវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ការបង្កើតប្រព័ន្ធគ្រប់គ្រងការសិក្សា (Learning Management System–LMS)។ ការវាយតម្លៃទទួលស្គាល់ គុណភាពកម្មវិធីសិក្សា (Program Accreditation) និងការរៀននិងបង្រៀន តាមរយៈប្រព័ន្ធឌីជីថល ការបង្កើតប្រព័ន្ធផ្ទេរក្រេឌីតការសិក្សា (Credit Transfer) ក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សា និងការផ្សារភ្ជាប់សាកលវិទ្យាល័យជាមួយកម្មវិធីអគារវៃឆ្លាត និងទីក្រុងវៃឆ្លាត ដោយសហការជាមួយក្រុមហ៊ុនក្នុង និងក្រៅប្រទេស។ |
| **ការអភិវឌ្ឍការអប់រំឧត្តមសិក្សាក្នុងបរិបទ** | គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្តល់ឱ្យនិស្សិតនូវសមត្ថភាពឌីជីថល និងជំនាញត្រិះរិះពិចារណា ដែលចាំបាច់សម្រាប់ភាពជោគជ័យក្នុងសតវត្សរ៍ទី២១។ នៅក្នុងន័យនេះ គ្រឹះស្ថានឧត្តមសិក្សាមានភារកិច្ចបង្កើតការអប់រំ ដែលរួមបញ្ចូលយុទ្ធសាស្ត្រសិក្សាតាមឌីជីថល លើកកម្ពស់ការច្នៃប្រឌិត និងសម្របសម្រួលការតភ្ជាប់ជាសកល ដើម្បីធានាថានិស្សិតត្រូវបានរៀបចំយ៉ាងល្អ សម្រាប់រួមចំណែក |

| | |
|---|---|
| **បច្ចេកវិទ្យាឌីជីថល** | ក្នុងការអភិវឌ្ឍសង្គមក្នុងយុគសម័យឌីជីថល។ គ្រឹះស្ថានឧត្តមសិក្សាត្រូវពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន និងពង្រឹងរចនាសម្ព័ន្ធនៃការសិក្សាតាមអនឡាញ បន្តការអភិវឌ្ឍវិជ្ជាជីវៈ និងពង្រឹងប្រព័ន្ធសុវត្ថិភាពទិន្នន័យឯកជនភាព។<br><br>**ការអប់រំឌីជីថលនៅកម្រិតឧត្តមសិក្សាបានធានា៖** ១)ភាពសម្បូរបែបនៃធនធានសម្រាប់ការរៀននិងបង្រៀន ២)ភាពងាយស្រួលនៃទំនាក់ទំនង កិច្ចសហការ និងការចូលរួម ៣)ភាពបត់បែននៃកាលវិភាគ និងការរៀនតាមលក្ខណៈបុគ្គល ៤)ការអភិវឌ្ឍការអប់រំឌីជីថល ៥)ការលើកកម្ពស់ជំនាញឌីជីថល ៦)ការបង្កើនការស្រាវជ្រាវ និងការច្នៃប្រឌិត និង ៧)ការគាំទ្រការអប់រំពេញមួយជីវិត។<br><br>ដើម្បីគាំទ្រដល់ការអប់រំឌីជីថលនៅកម្រិតឧត្តមសិក្សា ក្រសួងនឹង៖ ១)អភិវឌ្ឍហេដ្ឋា-រចនាសម្ព័ន្ធបច្ចេកវិទ្យា ២)ការធានាគុណភាព និងស្តង់ដា ៣)ការបត់បែន ទៅតាមការផ្លាស់ប្តូរបច្ចេកវិទ្យា ៤)ការធានាសុវត្ថិភាពទិន្នន័យឯកជនភាព ៥)ការពង្រឹង ភាពជាដៃគូជាមួយក្រុមហ៊ុន ៦)ការបន្តការអភិវឌ្ឍវិជ្ជាជីវៈ ៧)ការអភិវឌ្ឍបណ្តាញសាកលវិទ្យាល័យសាយប័រ (Cyber University Network) ដែលមានគ្រឹះស្ថានឧត្តមសិក្សារដ្ឋចំនួន ៦ និងគ្រឹះស្ថានឧត្តមសិក្សាឯកជនចំនួន២ ទាំងនៅក្នុងរាជធានីភ្នំពេញ និងនៅតាម បណ្តាខេត្តចូលរួម ដើម្បីពង្រឹងសមត្ថភាពសាស្ត្រាចារ្យសម្រាប់ការអនុវត្តការបង្រៀននិងរៀនតាមប្រព័ន្ធអនឡាញ។ |
| **ការអប់រំបរិយាបន្ននៅកម្ពុជា** | ដើម្បីធានាបាននូវការផ្តល់សេវាអប់រំ ពិសេសប្រកបដោយគុណភាព ក្រសួងនឹង៖<br>១) **ពង្រឹងវិទ្យាស្ថានជាតិអប់រំពិសេស និងនាយកដ្ឋានអប់រំពិសេស៖** ការរៀបចំគោលនយោបាយស្តីពីការអប់រំកុមារមានពិការភាព គោលនយោបាយស្តីពីការអប់រំបរិយាបន្ន ឯកសារជំនួយស្មារតីសម្រាប់គ្រូបង្រៀនវិទ្យាល័យអប់រំពិសេស ឯកសារជំនួយសម្រាប់ការកំណត់អត្តសញ្ញាណកុមារមានពិការភាពក្រោមអាយុ ៥ឆ្នាំ និងសម្របសម្រួលកិច្ចសហការជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់។<br>២) **ការបន្តវិនិយោគលើវិទ្យាល័យអប់រំពិសេសចំនួន ៦៖** ដើម្បីអនុវត្តកម្មវិធីអប់រំដល់កុមារមានពិការភាពនៅទូទាំងប្រទេស រួមទាំងកុមារខ្សោយសតិបញ្ញានិងអូទីស្សឹម និងការអនុវត្តកម្មវិធីសមាហរណកម្ម ដោយកុមារត្រូវរៀននៅគ្រឹះស្ថានសិក្សាសាធារណៈពាក់កណ្តាលថ្ងៃ និងនៅសាលារៀនអប់រំពិសេសពាក់កណ្តាលថ្ងៃទៀត។<br>៣) **ការផ្តល់ប្រាក់ឧបត្ថម្ភពិសេស៖** ចំនួន ៨ សែនរៀល លើបៀវត្សគ្រូបង្រៀន ដែលកើនឡើងជាលំដាប់ ដើម្បីថែរក្សាអ្នកឯកទេសខាងផ្នែកអប់រំពិសេស។<br>៤) **ការបន្តកិច្ចសហប្រតិបត្តិការអន្តរជាតិ៖** សហការជាមួយអង្គការគ្រួសារថ្មី ក្នុងការធ្វើសវនកម្មគុណភាពប្រចាំឆ្នាំ និងសហការជាមួយដៃគូអន្តរជាតិ ក្នុងការពិនិត្យត្រចៀក និងគាំទ្របច្ចេកទេស។<br><br>ក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តផ្តល់ការអប់រំពហុភាសានៅកម្រិតមត្តេយ្យសិក្សា និងបីឆ្នាំដំបូងសម្រាប់កុមារជនជាតិដើមភាគតិចនៅបឋមសិក្សា ក្នុងខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ ស្ទឹងត្រែង និងព្រះវិហារ ដោយសហការជាមួយអង្គការយូនីសេហ្វ និងអង្គការយែរះ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | **១) ការប្រើប្រាស់គំរូស្ពានចម្លង៖** ពីភាសាជនជាតិភាគតិច (ភាសាព្នង ការ៉ែត គ្រឹង ទំពួន ព្រៅ និង ចារ៉ាយ) ដើម្បីឱ្យពួកគេអាចរៀនជាភាសាជាតិទាំងស្រុង នៅថ្នាក់ទី៤។<br>**២) ផែនការសកម្មភាពស្តីពីការអប់រំពហុភាសា៖** ការកំណត់គោលការណ៍ស្តីពីការអនុវត្តកម្មវិធីអប់រំពីរភាសា ការរៀបចំឯកសារសម្រាប់បណ្តុះបណ្តាលគ្រូអប់រំពហុភាសា ឯកសារបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាអប់រំពហុភាសា ជាដើម។<br>៣) ការបញ្ចូលសាលាសហគមន៍ចូលជាគ្រឹះស្ថានសិក្សាសាធារណៈ៖ ផ្តល់ថវិកាដំណើរការសាលារៀន និងបញ្ចូលគ្រូជនជាតិដើមភាគតិចចំនួន ៥០នាក់ចូលក្នុងក្របខ័ណ្ឌរដ្ឋ ដើម្បីធានាឱ្យកុមារជនជាតិដើមភាគតិច ទទួលបានការអប់រំប្រកបដោយសមធម៌ បរិយាបន្ន និងឱកាសសិក្សាពេញមួយជីវិត ដើម្បីក្លាយជាមូលធនមនុស្ស។ |
| **មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត** | ដើម្បីជំរុញមជ្ឈមណ្ឌលសិក្សាសហគមន៍ឱ្យដំណើរការល្អ និងប្រែក្លាយជាមជ្ឈមណ្ឌលអប់រំពេញមួយជីវិត ទាមទារនូវកត្តាជាច្រើនរួមមាន៖<br>**១) ការបំពេញបន្ថែមលើកម្មវិធីសិក្សាសាលារៀនសាធារណៈ៖** ស្របតាមតម្រូវការជាក់ស្តែងរបស់យុវជន និងសិស្ស ដូចជាកម្មវិធីបណ្តុះបណ្តាលភាសាបរទេស បច្ចេកវិទ្យា ព័ត៌មានវិទ្យា ការបណ្តុះ-បណ្តាលជំនាញ និងការបើកវគ្គខ្លីៗសម្រាប់យុវជន និងសិស្សចំណេះទូទៅ ព្រមទាំងមានវិធីសាស្ត្រទាក់ទាញសិស្សឱ្យមករៀន។<br>**២) ការផ្សារភ្ជាប់កម្មវិធីបណ្តុះបណ្តាលជាមួយតម្រូវការជាក់ស្តែងក្នុងសហគមន៍៖** ការសិក្សាតម្រូវការទីផ្សារ ការបណ្តុះបណ្តាលជំនាញកសិកម្ម និងការរៀបចំកម្មវិធីប្រកបដោយភាព ច្នៃប្រឌិតនិងនវានុវត្តន៍ ដូចជាវគ្គខ្លីៗខាងផ្នែកគរុកោសល្យ សិប្បកម្មដែក ការផលិតវីដេអូ ការបណ្តុះបំណិនរកប្រាក់ចំណូលជាដើម។<br>**៣) ការចូលរួម និងការសហការ៖** ការបង្កើតគណៈកម្មការគ្រប់គ្រង ដែលសកម្ម និងមានមនសិការខ្ពស់ ដោយមានការចូលរួមពីយុវជនស្ម័គ្រចិត្ត និងការគាំទ្រពីនាយកដ្ឋានអប់រំក្រៅប្រព័ន្ធ និងអង្គការដៃគូ ដូចជាអង្គការ ឌីវីវី អន្តរជាតិ ព្រមទាំងធ្វើការអភិវឌ្ឍសមត្ថភាពគណៈកម្មការគ្រប់គ្រងឱ្យមានសមត្ថភាពពេញលេញទាំងជំនាញទន់ និងជំនាញរឹង។<br>**៤) ការធានានិរន្តរភាព៖** តាមរយៈការផ្តល់ថវិការដ្ឋ ការបង្កើតសកម្មភាពរកចំណូល ដើម្បីទ្រទ្រង់មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ការកៀរគរធនធានពីប្រភពផ្សេងៗ និងការលើកទឹកចិត្តដល់បុគ្គលិក។ |
| **ក្រុមប្រឹក្សាយុវជនកម្ពុជា ក្រុមប្រឹក្សាកុមារកម្ពុជា** | ដើម្បីធានាបាននូវការគ្រប់គ្រងសាលារៀន និងការរៀននិងការបង្រៀនប្រកបដោយគុណភាព និងប្រសិទ្ធភាព ក្រុមប្រឹក្សាយុវជន និងក្រុមប្រឹក្សាកុមារ ត្រូវចូលរួមលើកកម្ពស់៖ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| **និងការផ្លាស់ប្តូរឥរិយាបថជាវិជ្ជមាន** | ១) **ការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា៖** ការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌ កម្មវិធីមិត្តអប់រំមិត្ត យុទ្ធនាការលើកកម្ពស់ការយល់ដឹងពីសុខភាពបន្តពូជ និងការប្រយុទ្ធប្រឆាំងការប្រើប្រាស់សារធាតុញៀន។<br>២) **ការងារស្ម័គ្រចិត្ត៖** ដើម្បីលើកទឹកចិត្តឱ្យយុវជនចូលរួមក្នុងការងារសង្គម ហាត់ការ និងការបណ្តុះបំណិនបច្ចេកទេស។<br>៣) **ការបង្កើតក្លឹបសិក្សា៖** ការលើកកម្ពស់ស្វ័យសិក្សា និងការសិក្សារៀនសូត្រ ក្រៅម៉ោងសិក្សា។<br>៤) **ការបណ្តុះបំណិនសតវត្សរ៍ទី២១៖** ការចូលរួមក្នុងការប្រឡងប្រណាំង និងកម្មវិធីយុវជន ដើម្បីបង្កើនចំណេះដឹង បំណិនជីវិត បំណិនឌីជីថល បំណិនត្រិះរិះពិចារណា ការធ្វើការងារជាក្រុម និងបង្កើតទម្លាប់ និងឥរិយាបថល្អ ដែលមានភាពចាំបាច់សម្រាប់យុវជននៅក្នុងសង្គមបច្ចុប្បន្ន។ |
| **ការអនុវត្តសកម្មភាពអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថាន-សិក្សា** | ផ្សារភ្ជាប់ការអនុវត្តកម្មវិធីអប់រំកាយ និងកីឡាជាមួយការអនុវត្តស្តង់ដាសាលារៀនគំរូ៖<br>១) **កម្មវិធីក្រៅម៉ោងសិក្សា៖** ដាក់បញ្ចូលការអនុវត្តកម្មវិធីអប់រំកាយ និងកីឡា ទៅក្នុងកម្មវិធីកីឡាក្រៅម៉ោងសិក្សា និងការអប់រំសិស្សឱ្យយល់ពីសារៈសំខាន់នៃកីឡា ក្នុងការលើកកម្ពស់សុខភាពនិងជីវភាពរស់នៅ។<br>២) **ការរៀបចំកម្មវិធីសិក្សាថ្មី និងការលើកកម្ពស់គុណវុឌ្ឍិគ្រូកីឡា៖** ការរៀបចំកម្មវិធី សិក្សាទំនើបដោយសហការជាមួយអង្គការបេះដូងមាស និងការបណ្តុះបណ្តាលគ្រូកីឡា តាមរូបមន្តបរិញ្ញាបត្រ ឬ ១២+៤។<br>៣) **ការផ្សារភ្ជាប់៖** ការអប់រំកាយជាមួយនឹងកីឡាតាមគ្រឹះស្ថានសិក្សា និងកីឡាកម្រិតខ្ពស់ (ការលេងបាល់គ្រប់ប្រភេទ ការបង្កើតក្លឹបកីឡា)។<br>៤) **ការរៀបចំការប្រកួត៖** លើកទឹកចិត្តឱ្យសហព័ន្ធកីឡារៀបចំការប្រកួតកីឡា ដើម្បីជ្រើសរើសកីឡាករមានសក្តានុពល ឱ្យចូលក្នុងក្រុមកីឡាករថ្នាល និងកីឡាករជម្រើសជាតិ។ |
| **ការលើកកម្ពស់សុខភាពសិក្សានៅតាមសាលារៀន** | ការលើកកម្ពស់សុខភាពសិក្សា ដោយយកចិត្តទុកដាក់លើសុខភាពរបស់សិស្សតាមរយៈ៖<br>១) **ការលើកកម្ពស់សុខភាពរបស់អ្នកសិក្សានិងបុគ្គលិកអប់រំ៖** ការរៀបចំបន្ទប់សុខភាព ការផ្តល់សេវាពិនិត្យសុខភាព និងការផ្តល់ថ្នាំបង្ការ។ ការរៀបចំ **«បន្ទប់សុខភាពសិក្សាគ្រប់ជ្រុងជ្រោយ»** មុនគេនៅសាលាបឋមសិក្សាចតុមុខ និងសាលារៀនជាច្រើនទៀតបានយកបទពិសោធន៍នេះទៅអនុវត្តនៅសាលារៀនរបស់ខ្លួនជាបន្តបន្ទាប់។<br>២) **ការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ៖** បរិក្ខារលាងសម្អាតដៃ បង្គន់អនាម័យ និងការគ្រប់គ្រងកាកសំណល់។ គ្រឹះស្ថានសិក្សារដ្ឋ ១០០ ភាគរយ មានបង្គន់អនាម័យ។<br>៣) **ការលើកកម្ពស់អាហារូបត្ថម្ភ និងគុណភាពចំណីអាហារ៖** កម្មវិធីផ្តល់អាហាតាមសាលារៀន ការលើកកម្ពស់មីក្រូសារជាតិក្នុងចំណីអាហារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន។ |

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

| | |
|---|---|
| | ៤) **ការលើកកម្ពស់បរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងមេត្រីភាព៖** អនាម័យ បរិស្ថានស្អាត សួនផ្កា និងទីលានសម្រាប់អនុវត្តអប់រំកាយនិងកីឡា។<br>៥) **ការលើកកម្ពស់សន្តិសុខនិងសណ្តាប់ធ្នាប់ក្នុងគ្រឹះស្ថានសិក្សា៖** ការរក្សាសន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់ និងការបំពាក់ឧបករណ៍បង្ការការពារ។<br>៦) **ការលើកកម្ពស់ការអប់រំសុខភាព៖** ការអនុវត្តកម្មវិធីសិក្សា ២ម៉ោង ក្នុង១សប្តាហ៍ ការរៀបចំសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព និងការបណ្តុះបណ្តាលគ្រូមុខវិជ្ជាអប់រំសុខភាព។<br>៧)**ការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា៖** ក្រសួងបានសហការជាមួយក្រសួងសុខាភិបាល អង្គការសុខភាពពិភពលោក ព្រមទាំងដៃគូអភិវឌ្ឍផ្សេងទៀត ដោយរៀបចំជា «**គោលការណ៍ស្តង់ដាប្រតិបត្តិស្តីពី ការលើកកម្ពស់សុខភាពសិក្សាសម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅ**» នៅឆ្នាំ ២០២២។ |

## ២.៤ គោលការណ៍ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨

របៀបវារៈគោលនយោបាយនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ បង្ហាញនូវផ្នែកជាច្រើន ដូចជា ការគ្រប់គ្រងសាលារៀន ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ការវាយតម្លៃលទ្ធផលការសិក្សារបស់សិស្ស ការអប់រំឌីជីថលនិងបច្ចេកវិទ្យា និងកម្មវិធីសិក្សា។ ផ្នែកទាំងអស់នេះ ត្រូវបានរៀបចំដោយមានភាពបត់បែន ការជ្រើសរើសយុទ្ធសាស្ត្រឆ្លើយតបនឹងវត្ថុបំណង ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨ ទៅតាមទម្រង់ និងកម្រិតផ្សេងៗរបស់ប្រព័ន្ធអប់រំ។

ជាការពិត វិស័យអប់រំ រួមមាន ការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ រួមទាំងអនុវិស័យផ្សេងៗទៀត ត្រូវបានជំនួសដោយកម្មវិធីអាទិភាព។

- **វិស័យអប់រំមានមុខងារជាប្រព័ន្ធមួយទូលំទូលាយដូចខាងក្រោម៖**
  - ទម្រង់នៃរដ្ឋបាលអប់រំ គឺជាផ្នែកមួយនៃរដ្ឋបាលសាធារណៈ។ រដ្ឋបាលអប់រំ ជាអ្នកដឹកនាំវិស័យអប់រំ ប៉ុន្តែស្ថិតនៅក្រោមក្របខ័ណ្ឌគោលនយោបាយ និងការគ្រប់គ្រងរដ្ឋបាលសាធារណៈ។
  - ការអប់រំ គឺសំដៅបម្រើសេវាសាធារណៈ និងសាលារៀនជាផ្នែកមួយនៃសហគមន៍។ ដូច្នេះ សិស្ស គឺជាផ្នែកមួយនៃវិស័យអប់រំផង និងសហគមន៍ផង
  - តួអង្គអប់រំមានដៃគូជាច្រើន ទាំងកម្រិតជាតិ និងអន្តរជាតិ។

គោលការណ៍ណែនាំនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨ ផ្តោតលើសមាសភាគ ៣ផ្នែកសំខាន់ សម្រាប់ការអនុវត្តប្រព័ន្ធ មានដូចជា៖

- ទំនាក់ទំនងរវាងតួអង្គគ្រប់គ្រង និងតួអង្គផ្តល់សេវា
- គុណភាពនិងការបែងចែកជាតុចូល
- ទំនាក់ទំនងរវាងវិស័យសាធារណៈ និងដៃគូ

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

ពាក់ព័ន្ធនឹងទំនាក់ទំនងរវាងតួអង្គគ្រប់គ្រង និងតួអង្គផ្តល់សេវា ស្របតាមការណែនាំ និងអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំដូចខាងក្រោម៖

- **ស្វ័យភាព៖** គោលនយោបាយអប់រំគូសបញ្ជាក់ពីតម្រូវការសម្រាប់ស្វ័យភាពកាន់តែធំ។ ការងារនេះអនុវត្តដល់តួអង្គនៅក្នុងរដ្ឋបាលអប់រំ ជាពិសេសមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងតួរអង្គច្រើនពាក់ព័ន្ធ ជាពិសេសសាលារៀន។

«យុទ្ធសាស្ត្របញ្ចកោណ ចង្អុលបង្ហាញពីការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និងការរៀបចំផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាធនធានថវិកាសមស្រប សម្រាប់បំពេញមុខងារ និងអាទិភាពគោលនយោបាយ»។ ការងារដែលលេចធ្លោជាងគេ គឺការលើកកម្ពស់ការគ្រប់គ្រងតាមសាលារៀន តាមរយៈការអនុវត្តស្តង់ដាសាលារៀនគំរូ និងការបង្កើតសាលារៀនជំនាន់ថ្មី។ ស្វ័យភាពរបស់គណៈគ្រប់គ្រងសាលារៀន នឹងត្រូវបានពង្រឹងស្របតាមស្វ័យភាពរបស់សាលារៀនរៀងៗខ្លួន។ ជាងនេះទៅទៀត មជ្ឈមណ្ឌលឧត្តមភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សា នឹងទទួលបានអត្ថប្រយោជន៍ផ្នែកស្វ័យភាពកាន់តែច្រើនឡើង។

- **គណនេយ្យភាព៖** ជាក់ស្តែងនៅមន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា ទទួលបានស្វ័យភាពកាន់តែច្រើនឡើងៗ ជាមួយនឹងការទទួលខុសត្រូវថែមទៀតលើការប្រើប្រាស់ស្វ័យភាពនេះ។ យន្តការគណនេយ្យភាពជាច្រើន ដូចជា ការគ្រប់គ្រងសាលារៀន និងការវាយតម្លៃលទ្ធផលការសិក្សារបស់សិស្សនៅតែមាន ដែលជាគោលបំណងនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដើម្បីគាំទ្រកិច្ចការងារនេះ កាន់តែមានប្រសិទ្ធភាព និងប្រើប្រាស់មានលក្ខណៈជាប្រព័ន្ធ ដើម្បីឱ្យតួអង្គនានាមានទំនួលខុសត្រូវក្នុងការបំពេញការងារ។

«យុទ្ធសាស្ត្របញ្ចកោណ មានគោលបំណងរៀបចំ និងដាក់ឱ្យអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ និងក្រមប្រតិបត្តិក្នុងមុខងារសាធារណៈ និងពង្រឹងប្រសិទ្ធភាពនៃការធ្វើអធិការកិច្ច និងយន្តការសវនកម្ម»។ នៅក្នុងវិស័យអប់រំ កំណែទម្រង់នឹងពង្រឹងការវាយតម្លៃសាលារៀន តាមរយៈការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ការចូលរួមក្នុងកម្មវិធីសម្រាប់ការវាយតម្លៃសិស្សអន្តរជាតិ ការអនុវត្តតេស្តស្តង់ដា និងការបង្កើតប្រព័ន្ធព័ត៌មានសាលារៀន។

- **សមត្ថភាព និងវិជ្ជាជីវៈ៖** ដើម្បីឱ្យតួអង្គអប់រំនៅកម្ពុជាមានស្វ័យភាពប្រកបដោយប្រសិទ្ធភាព និងមានទំនួលខុសត្រូវ ចាំបាច់ត្រូវមានសមត្ថភាព (ត្រូវគិតដល់ស្ថាប័ន ឬអង្គភាព ដូចជា មន្ទីរអប់រំ យុវជន និងកីឡា ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀន) ឬជំនាញវិជ្ជាជីវៈ (ត្រូវគិតដល់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន ឬបុគ្គល)។ គោលការណ៍ទាំងនេះគឺជាចំណុចស្នូលនៃកំណែទម្រង់មុខងារសាធារណៈក្នុងវិស័យអប់រំ ដែលផ្តោតការយកចិត្តទុកដាក់សំខាន់លើការអភិវឌ្ឍសមត្ថភាពស្ថាប័ន (ត្រូវបានចាត់ទុកថាជាអាទិភាពក្នុងការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ) និងស្តីពីវិជ្ជាជីវៈរបស់នាយកសាលា និងគ្រូបង្រៀន។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដោយផ្សារភ្ជាប់ទៅនឹងគោលការណ៍ទាំងពីរនេះ យុទ្ធសាស្ត្របញ្ចកោណបានគូសបញ្ជាក់ពីសារៈសំខាន់នៃ «ការពង្រឹងប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សក្នុងមុខងារសាធារណៈផ្អែកលើគុណាធិបតេយ្យ»។ យុទ្ធសាស្ត្រនេះក៏ផ្ដោតសំខាន់លើវិជ្ជាជីវៈគ្រូបង្រៀនផងដែរ ដោយលើកជាសំណើនូវការ «ពង្រឹងគុណភាពនៃការបណ្ដុះបណ្ដាល និងវិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀន ព្រមទាំងការបន្តលើកកម្ពស់ជីវភាព និងគុណតម្លៃសង្គមរបស់បុគ្គលិកអប់រំនៅគ្រប់កម្រិត» និង «ដើម្បីបង្កើនសមត្ថភាព និងគុណវុឌ្ឍិរបស់គ្រូបង្រៀន ដោយលើកទឹកចិត្តគ្រូបង្រៀនឱ្យបន្តសិក្សាបន្ថែម និងសិក្សាស្រាវជ្រាវជាប្រចាំ ព្រមទាំងការទាក់ទាញនូវ គ្រូបង្រៀនដែលមានគុណវុឌ្ឍិខ្ពស់ និងឧត្តមានុវត្តន៍ជាក់ស្ដែង មកបង្រៀននៅតាមគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈនៅទូទាំងប្រទេស» ។ របៀបវារៈនៃកំណែទម្រង់ការអប់រំ គឺបានផ្ដោតការយកចិត្តទុកដាក់ស្រដៀងគ្នានឹងគោលការណ៍ខាងលើ និងបានផ្ដោតទៅលើការលើកទឹកចិត្ត និងការបណ្ដុះបណ្ដាលដល់គណៈគ្រប់គ្រងសាលារៀនផងដែរ។

គោលការណ៍ទាំងបីនេះគឺមានទំនាក់ទំនងគ្នា ដើម្បីឱ្យសាលារៀនកាន់តែមានស្វ័យភាពជាងមុន ដោយអាចធ្វើការសម្រេចចិត្ត និងការឆ្លើយតបដើម្បីកែលម្អលទ្ធផលរបស់សាលារៀនបានឆាប់រហ័ស។ បរិការណ៍នេះតម្រូវឱ្យសាលារៀនមាន "សមត្ថភាព" ព្រមទាំង ធនធាន សមត្ថកិច្ច និងកត្តាផ្សេងទៀត ពោលគឺគណៈគ្រប់គ្រងសាលារៀន និងបុគ្គលិកគឺចាំបាច់ត្រូវមានវិជ្ជាជីវៈពិតប្រាកដ និងមានទំនួលខុសត្រូវក្នុងការបំពេញការងារ។ តុល្យភាពរវាងគោលការណ៍ទាំងបីនេះគឺសារៈសំខាន់ណាស់ ដែលជំរុញឱ្យមាននូវយុទ្ធសាស្ត្រ និងកំណែទម្រង់ជាច្រើន និងជាផ្នែកមួយនៃរបៀបវារៈគោលនយោបាយពេលបច្ចុប្បន្ន។ គោលនយោបាយស្ដីពីគ្រូបង្រៀនបានគូសបញ្ជាក់អំពី ការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន ធ្វើឱ្យពួកគេមានស្វ័យភាព និងមានការទទួលខុសត្រូវកាន់តែច្រើនឡើង។

គោលការណ៍នៃ**គុណភាព និងការបែងចែកជាតុចូល** រួមមានកម្មវិធីសិក្សា និងសម្ភារបង្រៀន និងរៀន សម្ភារបរិក្ខារ ហេដ្ឋារចនាសម្ព័ន្ធ ដែលគាំទ្រដល់សិស្ស និងគ្រូបង្រៀនមានដូចខាងក្រោម៖

- **សមធម៌ និងបរិយាបន្ន៖** ធនធាន និងកម្មវិធីសាធារណៈគួរតែផ្ដល់ផលប្រយោជន៍មុនគេដល់ស្ថាប័ន សាលារៀន គ្រួសារ និងសិស្សានុសិស្សភាគច្រើនដែលមានតម្រូវការ ដោយមិនទុកចោលនរណាម្នាក់ឡើយ។ គោលការណ៍នេះមិនត្រឹមតែយកចិត្តទុកដាក់ចំពោះជាតុចូលនោះទេ ប៉ុន្តែត្រូវគ្រប់គ្រង និងមានការបែងចែកឱ្យបានល្អ ដើម្បីជានាសិទ្ធិទទួលបានការអប់រំសម្រាប់ទាំងអស់គ្នា ដោយមិនគិតពីភេទ អាយុ ពណ៌សម្បុរ ជាតិសាសន៍ ភាសា សាសនា និន្នាការនយោបាយ ឬស្ថានភាពមានពិការភាព។ ជាឧទាហរណ៍ ការគាំទ្រផ្នែកគរុកោសល្យ និងការត្រួតពិនិត្យសាលារៀន និងគ្រូបង្រៀន ដោយគិតគូរពីតម្រូវការផ្សេងៗ ទៅតាមបរិបទ និងក្រុមគោលដៅ។ គោលការណ៍នេះក៏ទាក់ទងនឹងវិធីដែលគ្រូបង្រៀនធ្វើទំនាក់ទំនងជាមួយសិស្ស។
- **បច្ចេកវិទ្យា៖** គុណភាព និងការផ្ដល់ជាតុចូល គាំទ្រដល់តួអង្គនានា និងទំនាក់ទំនង (អង្គភាពថ្នាក់កណ្ដាលដល់មូលដ្ឋាន និងសាលារៀន) ត្រូវបានកែលម្អតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

បែបទំនើប ជាពិសេសតាមរយៈបច្ចេកវិទ្យាឌីជីថល។ ទន្ទឹមនឹងនេះ ការប្រើប្រាស់បច្ចេកវិទ្យារំពឹងថានឹងជួយដល់ដំណើរការបង្រៀន និងការអនុវត្តកម្មវិធីសិក្សា ។

- **ភាពធន់៖** ការរីករាលដាលនៃជំងឺកូវីដ-១៩ និងការកើនឡើងនៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ បង្ហាញពីតម្រូវការសម្រាប់កសាងប្រព័ន្ធអប់រំ ដែលមានភាពធន់ មានសមត្ថភាពរៀបចំ និងទប់ស្កាត់និងវិបត្តិនានា និងដើម្បីស្តារឡើងវិញពីវិបត្តិទាំងនោះ។ ភាពធន់អាចបង្កើតបានតាមរយៈធនធាន និងការគាំទ្រដែលបង្កើតឱ្យមាននៅក្នុងប្រព័ន្ធទៅដល់សាលារៀន គ្រូបង្រៀន និងសិស្ស។ ភាពធន់ក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងសុខភាពសិស្ស ដែលជាអាទិភាពស្នូលសម្រាប់រដ្ឋាភិបាលផងដែរ។

**គោលការណ៍ទំនាក់ទំនងរវាងវិស័យសាធារណៈ និង "ដៃគូ"** រួមមាន៖ រដ្ឋបាលសាធារណៈ ក្នុងនោះក្រសួងអប់រំ យុវជន និងកីឡា ជាផ្នែកមួយ និងបណ្តាក្រសួងផ្សេងទៀតក៏មានតួនាទីក្នុងការអប់រំ និងការបណ្តុះបណ្តាលផងដែរ។ ដៃគូក្នុងស្រុក រួមមានអង្គការសង្គមស៊ីវិល ក្រុមយុវជន សហគ្រាសឯកជន និងដៃគូអភិវឌ្ឍ។ ដៃគូទាំងនោះមាននៅថ្នាក់ជាតិ ប៉ុន្តែក៏មាននៅថ្នាក់ក្រោមជាតិ និងសាលារៀនផងដែរ។ ទន្ទឹមនឹងនេះលក្ខណៈនៃទំនាក់ទំនង មានភាពខុសគ្នាទៅតាមចរិកលក្ខណៈនៃដៃគូនីមួយៗ។

- **ភាពជាដៃគូ៖** ទំនាក់ទំនងរវាងតួអង្គនានាដែលជាផ្នែកនៃវិស័យអប់រំ និងដៃគូវិស័យអប់រំផ្តល់អត្ថប្រយោជន៍ឱ្យគ្នាទៅវិញទៅមក។ ភាពជាដៃគូវិស័យអប់រំនឹងជួយពង្រឹងលើផ្នែកដែលតួអង្គនីមួយៗទទួលខុសត្រូវ និង ផ្តល់ឱកាសក្នុងការចូលរួម និងឆ្លើយតបទៅនឹងតម្រូវការ។ ការគាំទ្រពីដៃគូមានដូចជា ការរៀបចំកម្មវិធីពាក់ព័ន្ធ ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងផ្នែកស្មារតីដល់អង្គអប់រំ។
- **គណនេយ្យភាពសង្គម៖** នៅពេលដែលដៃគូផ្តល់ការគាំទ្រដល់អង្គអប់រំ បានផ្តល់ឱកាសដើម្បីអនុវត្តទម្រង់គណនេយ្យភាព ដោយត្រូវផ្តល់សិទ្ធិ ដើម្បីពិនិត្យមើលពីរបៀបដែលការគាំទ្រត្រូវបានប្រើប្រាស់ ជាងនេះទៅទៀត អំពីរបៀបដែលអង្គអប់រំអនុវត្តបេសកកម្មរបស់ខ្លួនកាន់តែទូលំទូលាយ។ គណនេយ្យភាពសង្គមបែបនេះគឺខុសពី "គណនេយ្យភាពការិយាធិបតេយ្យ" ដែលជាគោលការណ៍មួយក្នុងចំណោមគោលការណ៍ទាំងបី ដែលគ្រប់គ្រងទំនាក់ទំនងរវាងអង្គរដ្ឋបាល និងអង្គផ្តល់សេវាអប់រំ។ ឧទាហរណ៍នៃគោលការណ៍មួយមានរួចហើយនៅក្នុងគណនេយ្យភាពទ្វេទិសរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍដែលបានអនុវត្តក្នុងវិស័យអប់រំតាមរយៈក្រុមការងារវិស័យអប់រំថ្នាក់ក្រោមជាតិ។

ជំពូកទី៣ នឹងបង្ហាញពីកម្មវិធីអាទិភាពចំនួន៥ ដែលក្រសួងអប់រំ យុវជន និងកីឡា នឹងអនុវត្តក្នុងអំឡុងពេលឆ្នាំ២០២៤-២០២៨ ស្របតាមកំណែទម្រង់អាទិភាព និងណែនាំតាមគោលការណ៍ខាងលើ ដើម្បីដោះស្រាយបញ្ហាប្រឈមគន្លឹះៗដែលបានកំណត់ក្នុងកម្មវិធី អនុកម្មវិធីនីមួយៗ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

## ជំពូកទី ៣៖ ផែនការតាមកម្មវិធី និងអនុកម្មវិធី២០២៤-២០២៨

ជំពូកនេះបង្ហាញពីកម្មវិធីអាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់រយៈពេល ២០២៤-២០២៨ ស្របតាមអាទិភាពគោលនយោបាយរបស់ក្រសួង៖

**អាទិភាពគោលនយោបាយផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤ ២០២៨ ៖** ធានាឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ ត្រូវបានរៀបចំឡើងមាន ៥ កម្មវិធីអាទិភាព រួមមាន ៖

- **កម្មវិធីអាទិភាពទី១៖** កំណែទម្រង់សាលារៀន ដើម្បីឱ្យការចូលរៀនប្រកបគុណភាព សមធម៌ និងបរិយាបន្ន (ការអប់រំចំណេះទូទៅ)
- **កម្មវិធីអាទិភាពទី២៖** ការកែលម្អការចូលរៀន គុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា និងការស្រាវជ្រាវនិងនវានុវត្តន៍ (ការអប់រំនៅឧត្តមសិក្សា ការស្រាវជ្រាវ និងនវានុវត្តន៍)
- **កម្មវិធីអាទិភាពទី៣៖** ការលើកកម្ពស់ជំនាញសតវត្សរ៍ទី២១ សម្រាប់យុវជន (ការអប់រំក្រៅប្រព័ន្ធ ការសិក្សាពេញមួយជីវិត និងការអភិវឌ្ឍយុវជន)
- **កម្មវិធីអាទិភាពទី៤៖** ការអភិវឌ្ឍសកម្មភាពហាត់ប្រាណ ការអប់រំកាយ និងកីឡា (កីឡា)
- **កម្មវិធីអាទិភាពទី៥៖** ការលើកកម្ពស់ការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម (គោលនយោបាយ និងផែនការ ការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ការគ្រប់គ្រងធនធានមនុស្ស ការអប់រំគ្រូបង្រៀន និងការវាយតម្លៃផ្អែកលើសមិទ្ធកម្ម)

កម្មវិធីអាទិភាពនីមួយៗ មានអនុកម្មវិធីចន្លោះពី ២ ទៅ ៤ អនុកម្មវិធីសរុបមានចំនួន ១៦ ដែលអនុកម្មវិធីនីមួយៗ មានផលសម្រេចច្បាស់លាស់ ដូចបង្ហាញក្នុងផ្សាក្រោមខាងក្រោម៖

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ៣.១ រចនាសម្ព័ន្ធកម្មវិធីអាទិភាព អនុកម្មវិធី និងលទ្ធផលរំពឹងទុក

**គោលនយោបាយអាទិភាព៖** ធានាឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត។

**កម្មវិធីអាទិភាពទី១៖** កំណែទម្រង់សាលារៀនដើម្បីការចូលរៀនមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន

- **ការអប់រំកុមារតូច៖** កុមារអាយុ៣-៥ឆ្នាំ ចូលរៀនក្នុងកម្មវិធីអប់រំកុមារតូច និងត្រៀមខ្លួនចូលរៀនថ្នាក់ទី១ នៅអាយុ ៦ឆ្នាំ
- **ការអប់រំបឋមសិក្សា៖** កុមារទាំងអស់បានបញ្ចប់ថ្នាក់បឋមសិក្សា និងទទួលបានសមត្ថភាពល្អលើមុខវិជ្ជាគោល និងបំណិនជីវិត
- **ការអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស៖** យុវជនបានបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាដោយជោគជ័យ និងទទួលបានចំណេះដឹង ជំនាញ វិន័យ ក្រមសីលធម៌ និងអាកប្បកិរិយាសម្រាប់អនាគតដ៏ល្អ

**កម្មវិធីអាទិភាពទី២៖** ការកែលម្អការចូលរៀន គុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា និងការស្រាវជ្រាវនិងនវានុវត្តន៍

- **ការអប់រំឧត្តមសិក្សា៖** និស្សិតបញ្ចប់ការសិក្សាមានសមត្ថភាពឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច
- **ការស្រាវជ្រាវ និងនវានុវត្តន៍៖** លទ្ធផលនៃការស្រាវជ្រាវត្រូវបានផ្សារភ្ជាប់តម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ត្រូវបានប្រើប្រាស់ដោយគ្រឹះស្ថានឧត្តមសិក្សា និងឧស្សាហកម្ម

**កម្មវិធីអាទិភាពទី៣៖** ការលើកកម្ពស់ជំនាញសតវត្សរ៍ទី២១ សម្រាប់យុវជន

- **ការអប់រំក្រៅប្រព័ន្ធ និងការសិក្សាពេញមួយជីវិត៖** កុមារ យុវជន និងមនុស្សពេញវ័យ រួមទាំងអ្នកដែលមិនបានបញ្ចប់ការអប់រំក្នុងប្រព័ន្ធ ទទួលបានអត្ថប្រយោជន៍ពីកម្មវិធីបំណិនជីវិត និងកម្មវិធីបង្កើនប្រាក់ចំណូល ដើម្បីជីវិតកាន់តែល្អប្រសើរ
- **ការអភិវឌ្ឍយុវជន៖** យុវជនមានចំណេះដឹង ជំនាញ សីលធម៌ល្អ សុខភាពល្អ សមត្ថភាពគ្រប់គ្រាន់ និងជាពលរដ្ឋល្អ សម្រាប់សតវត្សរ៍ទី២១

**កម្មវិធីអាទិភាពទី៤៖** ការអភិវឌ្ឍសកម្មភាពហាត់ប្រាណ ការអប់រំកាយ និងកីឡា

- **សកម្មភាពហាត់ប្រាណ និងការអប់រំកាយ៖** ការអនុវត្តកម្មវិធីអប់រំកាយ និងកីឡាប្រកបដោយបរិយាបន្ន សិស្សានុសិស្សទទួលបានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា និងសកម្មភាពហាត់ប្រាណ និងលេងកីឡា នាំឱ្យប្រជាជនទទួលបាននូវកាយសម្បទារឹងមាំ និងសុខភាពល្អ
- **កីឡា៖** គ្រូបង្វឹក និងមន្ត្រីបច្ចេកទេសប្រកបដោយគុណវុឌ្ឍិកម្រិតអន្តរជាតិនៃប្រភេទកីឡា និងអត្តពលិក ដែលមានទេពកោសល្យ និងសមត្ថភាពខ្ពស់ និងអត្តពលិកដែលមានសក្តានុពល ទេពកោសល្យ និងកំណត់ត្រាគុណផលខ្ពស់ ចូលរួមក្នុងការប្រកួតដណ្តើមមេដាយថ្នាក់ជាតិ និងអន្តរជាតិ លើគ្រប់ប្រភេទកីឡាដោយជោគជ័យ

**កម្មវិធីអាទិភាពទី៥៖** ការលើកកម្ពស់ការគ្រប់គ្រងផ្តោតលើសមិទ្ធកម្ម

- **គោលនយោបាយ និងផែនការផ្អែកលើភស្តុតាង៖** ស្ថាប័ន និងបុគ្គលិកក្នុងប្រព័ន្ធអប់រំ ចេះវិភាគ និងប្រើប្រាស់ព័ត៌មាន ដើម្បីរៀបចំគោលនយោបាយ និងផែនការអប់រំពាក់ព័ន្ធ
- **ការគ្រប់គ្រងធនធានហិរញ្ញវត្ថុ៖** ការិយាល័យអប់រំនៅថ្នាក់កណ្តាល និងថ្នាក់រដ្ឋបាល និងសាលារៀន មានហិរញ្ញវត្ថុគ្រប់គ្រាន់ និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ដើម្បីអនុវត្តការងារ
- **ការគ្រប់គ្រងធនធានមនុស្ស**
  - **កិច្ចការបណ្តុះបណ្តាលគ្រូបង្រៀន៖** គ្រូបង្រៀនទាំងអស់នៅគ្រប់កម្រិតថ្នាក់មានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាល្អ ស្របតាមសតវត្សរ៍ទី២១
  - **អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពគ្រូបង្រៀន (កិច្ចការវិក្រឹតការ)៖** គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនទាំងអស់អភិវឌ្ឍបំណិនថ្មីតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
  - **ការអភិវឌ្ឍសមត្ថភាព និងគាំទ្រការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ៖** បុគ្គលិកអប់រំនៅតាមកម្រិតនៃរដ្ឋបាលអប់រំមានសមត្ថភាពអនុវត្តមុខងារប្រកបដោយ ផលិតភាពខ្ពស់ស្របតាមកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
  - **ការគ្រប់គ្រងបុគ្គលិក៖** បុគ្គលិកអប់រំអនុវត្តវិជ្ជាជីវៈប្រកបដោយផលិតភាព
- **ការវាយតម្លៃផ្អែកលើសមិទ្ធកម្ម៖** លទ្ធផលនៃការត្រួតពិនិត្យ និងវាយតម្លៃប្រព័ន្ធអប់រំ ការិយាល័យ និងសាលារៀន ណែនាំអ្នកដើរតួក្នុងវិស័យអប់រំឆ្ពោះទៅរកការកែលម្អការអនុវត្ត និងអភិបាលកិច្ចល្អ

តារាងខាងក្រោម គឺជាការសង្ខេបចំណុចដៅសំខាន់ៗ របស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨ ទៅតាមកម្មវិធីអាទិភាព និងអនុកម្មវិធី។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៣.២ សូចនាករសមិទ្ធកម្មគន្លឹះ និងចំណុចដៅសម្រាប់ឆ្នាំ ២០២៤-២០២៨

| លេខរៀង | សូចនាករសមិទ្ធកម្មគន្លឹះ | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨[2] |
|---|---|---|---|
| **កម្មវិធីទី១៖ កំណែទម្រង់សាលារៀន ដើម្បីការចូលរៀនមានគុណភាព ប្រកបដោយបរិយាបន្ន និងសមធម៌** | | | |
| ១.១ | ចំនួនសាលារៀនគំរូ | ១២០ | ១ ២០០ |
| ១.២ | ភាគរយសិស្សថ្នាក់ទី ១២ ទទួលបាននិទ្ទេស A, B, និង C | ១៩,៩% | ៣៥% |
| **កម្មវិធីទី២៖ កែលម្អការចូលរៀន គុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា និងការស្រាវជ្រាវនិងនវានុវត្តន៍** | | | |
| ២.១ | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (អាយុ១៨-២២ឆ្នាំ)[3] | ១៤,៧% | ២១,៨% |
| | ប្រុស | ១៥,១% | ២១,៩% |
| | ស្រី | ១៤,៣% | ២១,៨% |
| ២.២ | ចំនួនគម្រោងស្រាវជ្រាវ ដែលភ្ជាប់ជាមួយនឹងតម្រូវការទីផ្សារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ត្រូវបានប្រើប្រាស់ដោយគ្រឹះស្ថានឧត្តមសិក្សា និងវិស័យឧស្សាហកម្ម | N/A | ៤០ |
| **កម្មវិធីទី៣៖ លើកកម្ពស់ជំនាញសតវត្សរ៍ទី ២១ សម្រាប់យុវជន** | | | |
| ៣.១ | ចំនួនយុវជនបានបញ្ចប់កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន | ៨៣៥ | ១ ៤៣៦ |
| | យុវជន | ៧៥៩ | ១ ២៦០ |
| | ក្រៅប្រព័ន្ធ | ៧៦ | ១៧៦ |
| ៣.២ | ចំនួនយុវជន និងមនុស្សពេញវ័យបានបញ្ចប់ពីកម្មវិធីអភិវឌ្ឍន៍យុវជន និងមនុស្សពេញវ័យ (សាលារៀនគំរូ និងមជ្ឈមណ្ឌលគោលដៅ) | ១ ១៥០ | ២ ០៥០ |
| | យុវជន | N/A | ១ ៥៥០ |
| | ក្រៅប្រព័ន្ធ | N/A | ៥០០ |
| **កម្មវិធីទី៤៖ ការអភិវឌ្ឍសកម្មភាពហាត់ប្រាណ ការអប់រំកាយ និងកីឡា** | | | |
| ៤.១ | ចំនួនមេដាយដែលទទួលបានពីការប្រកួតកីឡាអន្តរជាតិក្នុងមួយឆ្នាំ | ១០០ | ១៥០ |
| ៤.២ | ចំនួនសាលារៀនគំរូបានអនុវត្តកម្មវិធីអប់រំកាយ និងកីឡា | N/A | ៥០០ |
| **កម្មវិធីទី៥៖ លើកកម្ពស់ការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម** | | | |
| ៥.១ | ភាគរយការទូទាត់ចំណាយថវិកាកម្មវិធី របស់ក្រសួងអប់រំ យុវជន និងកីឡា | ៩៥,០% | ៩៥,០% |
| ៥.២ | ចំនួនសាលារៀនដែលបានអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រង | N/A | ១ ២០០ |
| ៥.៣ | ចំនួនអ្នកឯកទេសអប់រំបានបណ្តុះបណ្តាល និងទទួលស្គាល់ | ៥ | ២០០ |

ផ្នែកខាងក្រោមនៃជំពូកនេះ បង្ហាញពីសនិទានកម្ម វត្ថុបំណង យុទ្ធសាស្ត្រ និងសកម្មភាពគោលចម្បងបានគ្រោងទុកនៅក្នុងអនុកម្មវិធីនីមួយៗ ព្រមទាំងមានសូចនាករ ទិន្នន័យឆ្នាំគោល ចំណុចដៅ ដែលនឹងត្រូវប្រើប្រាស់សម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធផលកម្រិតផលសម្រេច និងលទ្ធផលដែលបានរំពឹងទុក។

[2] នៅក្នុងជំពូកទី៣ ចំណុចដៅឆ្នាំ២០២៨ សំដៅឆ្នាំសិក្សា ២០២៧-២០២៨ ដែលមានលម្អិតនៅក្នុងតារាងឧបសម្ព័ន្ធ

[3] ឆ្នាំគោលសំដៅឆ្នាំសិក្សា២០២២-២០២៣ និងទិន្នន័យឆ្នាំគោល បានគណនាដោយប្រើប្រាស់ចំណោលប្រជាសាស្ត្រដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ ដែលប្រើនៅក្នុងចំណោលផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៣.៣ កម្មវិធីអាទិភាព១៖ កំណែទម្រង់សាលារៀនដើម្បីការចូលរៀនមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន

**កម្មវិធីអាទិភាពទី១**
**កំណែទម្រង់សាលារៀន ដើម្បីការចូលរៀនមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន**

**ការអប់រំកុមារតូច**
កុមារអាយុ៣-៥ឆ្នាំ ចូលរៀនក្នុងកម្មវិធីអប់រំកុមារតូច និងត្រៀមខ្លួនចូលរៀនថ្នាក់ទី១ នៅអាយុ ៦ឆ្នាំ

**ការអប់រំបឋមសិក្សា**
កុមារទាំងអស់បានបញ្ចប់ថ្នាក់បឋមសិក្សា និងទទួលបានសមត្ថភាពល្អលើមុខវិជ្ជាគោល និងបំណិនជីវិត

**ការអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស**
យុវជនបានបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាដោយជោគជ័យ និងទទួលបានចំណេះដឹង ជំនាញ វិន័យ ក្រមសីលធម៌ និងអាកប្បកិរិយាសម្រាប់អនាគតដ៏ល្អ

### ៣.៣.១ អនុកម្មវិធី៖ ១.១ ការអប់រំកុមារតូច

| លទ្ធផលរំពឹងទុករបស់អនុកម្មវិធី៖ កុមារអាយុ៣-៥ឆ្នាំ ចូលរៀនក្នុងកម្មវិធីអប់រំកុមារតូច និងត្រៀមខ្លួនចូលរៀនថ្នាក់ទី១ នៅអាយុ ៦ឆ្នាំ | | |
|---|---|---|
| សូចនាករផលសម្រេច | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
| ចំនួនសាលាមត្តេយ្យសិក្សាសម្រេចបានស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ | ១០ | ១០០ |
| ភាគរយកុមារចូលរៀននៅបឋមសិក្សាបានឆ្លងកាត់ការអប់រំកុមារតូច | ៧០,៤% | ៧៥,៦% |
| ប្រុស | ៦៩,៨% | ៧៥,៥% |
| ស្រី | ៧១,០% | ៧៥,៧% |

**បញ្ហាប្រឈមគន្លឹះៗ៖**

- ការចុះឈ្មោះកុមារអាយុ ៣-៥ ឆ្នាំនៅក្នុងអនុវិស័យអប់រំកុមារតូច មិនមានភាពប្រសើរឡើងទេ និងការគាំទ្រ និងការអភិវឌ្ឍសម្រាប់កម្មវិធី ១ ០០០ ថ្ងៃដំបូងរបស់កុមារនៅតែមិនពេញលេញ
- កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា និងកម្មវិធីក្រៅម៉ោងសម្រាប់មត្តេយ្យសិក្សាមិនទាន់ត្រូវបានអនុវត្តពេញលេញ
- ចំនួនបុគ្គលិកផ្នែកអប់រំកុមារតូចនៅមិនទាន់គ្រប់គ្រាន់ ហើយភាគច្រើនមិនទាន់មានគុណវុឌ្ឍិតាមតម្រូវការ
- កិច្ចសហប្រតិបត្តិការភាពជាដៃគូរដ្ឋ និងសហគមន៍ ត្រូវការបន្តពង្រឹងបន្ថែម។

ដើម្បីដោះស្រាយបញ្ហាប្រឈមគន្លឹះៗ ដែលបានបង្ហាញខាងលើ អនុកម្មវិធីការអប់រំកុមារតូចបានកំណត់វត្ថុបំណងចំនួន៣ ដូចខាងក្រោម៖

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

១. បង្កើនការចូលរៀននៅកម្រិតអប់រំកុមារតូចសម្រាប់ទាំងអស់គ្នា ដោយយកចិត្តទុកដាក់លើសមភាពយេនឌ័រ សមធម៌ និងបរិយាបន្ន
២. លើកកម្ពស់គុណភាពនៃកម្មវិធីអប់រំកុមារតូច
៣. ពង្រឹងប្រតិបត្តិការ និងការគ្រប់គ្រងការអប់រំកុមារតូច

យុទ្ធសាស្ត្រសំខាន់ៗ សម្រាប់បង្កើនការចូលរៀនប្រកបដោយសមធម៌ និងបរិយាបន្ន សម្រាប់កុមារអាយុក្រោម ៦ឆ្នាំ ត្រូវផ្តោតលើការពង្រីកថ្នាក់មត្តេយ្យសិក្សានៅតាមសាលាបឋមសិក្សាសាធារណៈ និងលើកកម្ពស់ការបង្កើតសាលាមត្តេយ្យសិក្សាសហគមន៍ ថ្នាក់មតេយ្យសិក្សានៅតាមរោងចក្រ និងសហគ្រាស។ ការបង្កើតសាលាមត្តេយ្យសិក្សាសហគមន៍ នឹងពង្រឹងការសិក្សាប្រកបដោយសមធម៌ ដោយធ្វើឱ្យប្រសើរឡើងនូវការចូលរៀននៅតំបន់ដាច់ស្រយាល។ យុទ្ធសាស្ត្រមួយទៀត គឺបង្កើនការចូលរៀន រួមមានលើកកម្ពស់កម្មវិធីគាំពារកុមារតូច សុខភាព និងអាហារូបត្ថម្ភ សម្រាប់មត្តេយ្យសិក្សាទាំងអស់ (រួមបញ្ចូលទាំងវិស័យឯកជន) និងពង្រឹងការអប់រំបរិយាបន្ន និងការអប់រំពហុភាសា នៅតាមតំបន់ជនបទ។ ជាមួយគ្នានេះ ការផ្លាស់ប្តូរឥរិយាបថសង្គម នឹងត្រូវផ្តោតលើការលើកកម្ពស់ការយល់ដឹងក្នុងសហគមន៍ អំពីសារៈសំខាន់នៃការអប់រំកុមារតូច និងបង្កើនការអប់រំឆ្លើយតបនឹងតម្រូវការ។

ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពនៃកម្មវិធីអប់រំកុមារតូច វិធានការអាទិភាពត្រូវបានកំណត់សម្រាប់កំណែទម្រង់សាលារៀន ដែលផ្តោតលើការអនុវត្តស្តង់ដាសាលាមត្តេយ្យសិក្សាគំរូ ការអភិវឌ្ឍកម្មវិធីអប់រំមាតាបិតា ការពង្រឹងការត្រួតពិនិត្យនិងវាយតម្លៃកម្មវិធីអភិវឌ្ឍន៍ និងគាំពារកុមារតូច។

ដើម្បីពង្រឹងប្រសិទ្ធភាព និងនិរន្តរភាពនៃប្រតិបត្តិការ និងការគ្រប់គ្រងអប់រំកុមារតូច យុទ្ធសាស្ត្រសំខាន់ៗបានកំណត់ដោយផ្តោតលើដំណើរការប្រតិបត្តិ និងរដ្ឋបាល ភាពជាដៃគូរដ្ឋ-សហគមន៍ សម្រាប់ការអប់រំកុមារតូច (តាមលទ្ធភាពដែលអាចធ្វើទៅបានដោយសហការជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់) រួមទាំងការប្រែក្លាយពីសាលាមត្តេយ្យសិក្សាសហគមន៍ស្តង់ដា ទៅជាសាលាមត្តេយ្យសិក្សាឧបសម្ព័ន្ធ និងបង្កើនភាពធន់នឹងអាកាសធាតុនៅតាមសាលាមត្តេយ្យសិក្សា។

យុទ្ធសាស្ត្រ និងសកម្មភាពគោល ដើម្បីជំរុញវត្ថុបំណងទាំងនេះ ត្រូវបានកំណត់ក្នុងតារាងខាងក្រោម៖

| **វត្ថុបំណងទី១៖ បង្កើនការចូលរៀននៅកម្រិតអប់រំកុមារតូចសម្រាប់ទាំងអស់គ្នា ដោយយកចិត្តទុកដាក់លើសមភាពយេនឌ័រ សមធម៌ និងបរិយាបន្ន** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| អត្រារួមនៃការសិក្សាអប់រំកុមារតូច (អាយុ ៣-៥ឆ្នាំ)[4] | ៤១,៨% | ៤៥,៤% |
| ប្រុស | ៤០,៨% | ៤៥,៣% |
| ស្រី | ៤២,៨% | ៤៥,៦% |

[4] ឆ្នាំគោលសំដៅឆ្នាំសិក្សា២០២២-២០២៣ និងទិន្នន័យឆ្នាំគោល បានគណនាដោយប្រើប្រាស់ចំណោលប្រជាសាស្ត្រដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ ដែលប្រើនៅក្នុងចំណោលផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | |
|---|---|---|
| អត្រាចូលរៀនកុមារអាយុ ៥ឆ្នាំ[5] | ៧០,៤% | ៧៥,៦% |
| ប្រុស | ៦៩,៨% | ៧៥,៥% |
| ស្រី | ៧១,០% | ៧៥,៧% |
| ភាគរយសាលាមត្តេយ្យសិក្សាសាធារណៈអនុវត្តកម្មវិធីផ្ដល់អាហារតាមសាលារៀន | N/A | ៣០,០% |
| ភាគរយសាលាមត្តេយ្យសិក្សាសាធារណៈមានស្តង់ដាទឹកស្អាត និងអនាម័យ និងបរិក្ខារផ្សេងៗទៀត (មត្តេយ្យសិក្សាដាច់ដោយឡែក) | | |
| កម្រិត ៣ | ៥,២% | ១៥,០% |
| បង្គន់អនាម័យ | ៩៩,៧% | ១០០% |
| ប្រអប់សង្គ្រោះបឋម | ៣៨,៤% | ១០០% |
| អគ្គិសនី | ៩៥,៨% | ១០០% |
| ចំនួនសាលាមត្តេយ្យសិក្សាបានអនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិច | ១៤២ | ១៥២ |
| ចំនួនគ្រូមត្តេយ្យសិក្សាបានទទួលបំប៉នសមត្ថភាពស្តីពីការអប់រំបរិយាបន្ន | ១ ៥០០ | ២ ៥០០ |
| ស្រី | ១ ២៣០ | ២ ០៣០ |
| ចំនួនសាលាមត្តេយ្យសិក្សាសហគមន៍ដែលមានទីតាំងនៅតំបន់រោងចក្រ | N/A | ៣០ |
| ចំនួនមណ្ឌលថែទាំកុមារតាមសហគមន៍ | N/A | ៣០ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** ពង្រីកសាលាមត្តេយ្យសិក្សាសាធារណៈ (រួមទាំងថ្នាក់មត្តេយ្យសិក្សានៅក្នុងសាលាបឋមសិក្សា) | **បទដ្ឋានគតិយុត្ត**<br>- រៀបចំឯកសារច្បាប់ ដើម្បីគាំទ្រដល់ដំណើរការបង្កើតសាលាមត្តេយ្យសិក្សាសាធារណៈ<br>- ផ្សព្វផ្សាយ និងអនុវត្តប្រកាសស្តីពីការបើកថ្នាក់មត្តេយ្យសិក្សានៅសាលាបឋមសិក្សាសាធារណៈ<br>- ផ្សព្វផ្សាយ និងអនុវត្តប្រកាសស្តីពីការប្រែក្លាយសាលាមត្តេយ្យសិក្សាសហគមន៍ទៅជាឧបសម្ព័ន្ធសាលាមត្តេយ្យសិក្សាសាធារណៈ ឬសាលាបឋមសិក្សា។ |

[5] ឆ្នាំគោលសំដៅឆ្នាំសិក្សា២០២២-២០២៣ និងទិន្នន័យឆ្នាំគោល បានគណនាដោយប្រើប្រាស់ចំណោលប្រជាសាស្ត្រដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ ដែលប្រើនៅក្នុងចំណោលផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | **ការពង្រីកបណ្តាញ**<br>- សាងសង់អគារសិក្សាថ្មី និងជួសជុលហេដ្ឋារចនាសម្ព័ន្ធមត្តេយ្យសិក្សាស្របតាមស្តង់ដា រួមទាំងហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុ<br>- រៀបចំថ្នាក់មត្តេយ្យសិក្សានៅសាលាបឋមសិក្សាស្របតាមស្តង់ដាមត្តេយ្យសិក្សា។ |
| **យុទ្ធសាស្ត្រទី២៖** បង្កើតសាលាមត្តេយ្យសិក្សាសហគមន៍ | **បទដ្ឋានគតិយុត្ត**<br>- រៀបចំឯកសារច្បាប់ ដើម្បីគាំទ្រដល់ប្រតិបត្តិការ និងដំណើរការនៃសាលាមត្តេយ្យសិក្សាសហគមន៍ រួមទាំងតំបន់ពោងចក្រ និងសហគ្រាស ។<br>**ការពង្រីកបណ្តាញ**<br>- ពិគ្រោះយោបល់ជាមួយថ្នាក់ក្រោមជាតិ ដើម្បីបង្កើតសាលាមត្តេយ្យសិក្សាសហគមន៍នៅគ្រប់ភូមិ ដោយប្រើប្រាស់ផែនការវិនិយោគឃុំ/សង្កាត់<br>- សាងសង់អគារមត្តេយ្យសិក្សា និងហេដ្ឋារចនាសម្ព័ន្ធនៃសាលាមត្តេយ្យសិក្សាសហគមន៍ រួមទាំងរចនាសម្ព័ន្ធធន់នឹងអាកាសធាតុ។<br>**ការបណ្តុះបណ្តាល និងការគាំទ្រគ្រូបង្រៀន**<br>- បណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សានៅក្នុងសាលាមត្តេយ្យសិក្សាសហគមន៍ រួមទាំងគ្រូបង្រៀននៅតំបន់ពោងចក្រ និងសហគ្រាស<br>- ជំនួយផ្នែកបច្ចេកទេស (ការបង្វឹក និងប្រឹក្សាយោបល់) សម្រាប់គ្រូបង្រៀននៅសាលាមត្តេយ្យសិក្សាសហគមន៍។ |
| **យុទ្ធសាស្ត្រទី៣៖** បង្កើតមជ្ឈមណ្ឌលថែទាំកុមារតាមសហគមន៍ (១០០០ថ្ងៃដំបូង) | **បទដ្ឋានគតិយុត្ត**<br>- រៀបចំឯកសារច្បាប់ ដើម្បីគាំទ្រដល់ប្រតិបត្តិការ និងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលថែទាំកុមារសហគមន៍នៅតំបន់ពោងចក្រ និងសហគ្រាស។<br>**ការពង្រីកបណ្តាញ**<br>- សាងសង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធជាមួយមជ្ឈមណ្ឌលថែទាំកុមារសហគមន៍ រួមទាំង រចនាសម្ព័ន្ធធន់នឹងអាកាសធាតុ។<br>**ការបណ្តុះបណ្តាល និងគាំទ្រដល់អ្នកថែទាំកុមារ**<br>- ជំនួយផ្នែកបច្ចេកទេស (ហ្វឹកហាត់ និងការណែនាំផ្ទាល់) សម្រាប់អ្នកថែទាំកុមារនៅក្នុងមជ្ឈមណ្ឌលថែទាំកុមារសហគមន៍នៅតំបន់ពោងចក្រ និងតំបន់សហគ្រាស |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - បណ្តុះបណ្តាលអ្នកថែទាំកុមារតូច និងអ្នកពាក់ព័ន្ធនៅក្នុងមណ្ឌលថែទាំកុមារសហគមន៍ រួមទាំងនៅតំបន់ពោងចក្រ និងតំបន់សហគ្រាស។ |
| **យុទ្ធសាស្ត្រទី៤៖** ពង្រឹង និងការពង្រីកការអប់រំបរិយាបន្នសម្រាប់មត្តេយ្យសិក្សា | **សម្ភារគរុកោសល្យ**<br>- ផ្សព្វផ្សាយ និងអនុវត្តផែនការសកម្មភាពអប់រំបរិយាបន្ន ២០២៤-២០២៨<br>- អនុវត្តផែនការសកម្មភាពអប់រំពហុភាសា ២០២៤-២០២៨<br>- អភិវឌ្ឍសម្ភារសិក្សា និងឧបករណ៍វាយតម្លៃសម្រាប់ការបង្រៀន និងរៀនសម្រាប់ការអប់រំពហុភាសា<br>- អភិវឌ្ឍឯកសារ និងសម្ភារអប់រំបរិយាបន្ន សម្រាប់ជួយសិស្សមានពិការភាពសិស្សដែលមានតម្រូវការពិសេស និងគ្រូបង្រៀន។<br>**ការអភិវឌ្ឍសមត្ថភាព និងការគាំទ្រ**<br>- កសាងសមត្ថភាពគ្រូបង្រៀន និងអ្នកពាក់ព័ន្ធលើការអប់រំពហុភាសា និងបរិយាបន្នសម្រាប់សាលាមត្តេយ្យសិក្សា រួមទាំងការអនុវត្តឯកសារ) វិក្រឹតការសម្រាប់ការអប់រំពហុភាសា និងការកែលម្អភាសាកំណើតរបស់គ្រូមត្តេយ្យសិក្សាពហុភាសា)<br>- ផ្តល់ជំនួយបច្ចេកទេសដល់គ្រូបង្រៀនក្នុងការបង្រៀន និងរៀនសម្រាប់ការអប់រំពហុភាសា និងបរិយាបន្ន។ |
| **យុទ្ធសាស្ត្រទី៥៖** ពង្រីកកម្មវិធីអាហារូបត្ថម្ភ និងសុខភាពសិក្សាតាមសាលារៀន | **សកម្មភាពនៅតាមសាលារៀន**<br>- ពង្រឹងការអនុវត្តកម្មវិធីទឹកស្អាត និងអនាម័យ នៅតាមសាលារៀនសុវត្ថិភាពចំណីអាហារ និងអាហារដែលមានសុខភាពល្អនៅក្នុងសាលារៀន រួមទាំងអនាម័យទូទៅ អនាម័យរាងកាយ អនាម័យមាត់ធ្មេញ ការលាងសម្អាតដៃ និងអាហារូបត្ថម្ភ<br>- អនុវត្តយុទ្ធនាការសាលារៀនស្អាត គ្មានសំរាម បរិស្ថានស្អាត គ្មានគ្រឿង-ស្រវឹង គ្មានគ្រឿងញៀន គ្មានថ្នាំជក់ និងមិនប្រើផលិតផលប្លាស្ទិក។ល។<br>- បង្កើតបន្ទប់ថែទាំសុខភាពដោយបំពាក់សម្ភារ និងឧបករណ៍ចាំបាច់ ក៏ដូចជាការផ្តល់ឧបករណ៍សង្គ្រោះបឋម និងឧបករណ៍ការពារជំងឺឆ្លង<br>- បណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សានូវចំណេះដឹងអំពីសុខភាពសិក្សា និងអាហារូបត្ថម្ភរបស់កុមារ។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | **ការពង្រីកសេវាសុខភាព**<br>- ពង្រីកការថែទាំសុខភាព ការអនុវត្តសុវត្ថិភាពក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ រួមមានទឹកជំនន់ ការកើនឡើងសីតុណ្ហភាព ជំងឺឆ្លងដែលចម្លងតាមដៃ<br>- ពង្រីកវិសាលភាពនៃការពិនិត្យសុខភាព រួមមានការពិនិត្យភ្នែក ការពិនិត្យត្រចៀក និងការស្តារនីតិសម្បទា និងការគណនាអាហារូបត្ថម្ភសម្រាប់អន្តរាគមន៍ដល់សិស្សលើសទម្ងន់ ឬកង្វះអាហារូបត្ថម្ភ<br>- សហការជាមួយមណ្ឌលសុខភាពមូលដ្ឋាន ដើម្បីពង្រីកការផ្តល់សេវាថែទាំសុខភាពបឋម ដូចជាការពិនិត្យសុខភាព ការផ្តល់ថ្នាំ សេវាប្រឹក្សាសុខភាពផ្លូវចិត្ត ការកំណត់អត្តសញ្ញាណសម្រាប់កុមារខ្វះអាហារូបត្ថម្ភកម្រិតមធ្យម និងធ្ងន់ធ្ងរ និងការស្តារនីតិសម្បទា ឬបញ្ជូនទៅកាន់មន្ទីរពេទ្យដើម្បីទទួលថ្នាំ និងជំនួយសម្រាប់អ្នកផ្ទុកជំងឺ និងមេរោគអេដស៍ ឬជំងឺរាងកាយផ្សេងទៀត។ |

| **វត្ថុបំណងទី២៖ លើកកម្ពស់គុណភាពនៃកម្មវិធីការអប់រំកុមារតូច** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនគ្រូបង្រៀនអប់រំកុមារតូច និងអ្នកថែទាំបានទទួលការបណ្តុះបណ្តាលស្តីពីការអនុវត្តកម្មវិធីសិក្សា (មត្តេយ្យសិក្សាសហគមន៍ និងមជ្ឈមណ្ឌលថែទាំកុមារតាមសហគមន៍ ក្នុងតំបន់រោងចក្រ) | N/A | ១៥០ |
| ចំនួនសាលាមត្តេយ្យសិក្សាសហគមន៍ដែលបំពេញតាមស្តង់ដាអប្បបរមាបានបញ្ចូលទៅជាសាលារៀនឧបសម្ព័ន្ធ | N/A | ២៨៨ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** អនុវត្តស្តង់ដាមត្តេយ្យសិក្សាគំរូ | **ការណែនាំ**<br>- បង្កើតយន្តការគាំទ្រសាលាមត្តេយ្យសិក្សាដើម្បីអនុវត្តស្តង់ដាមត្តេយ្យសិក្សាគំរូ<br>- រៀបចំឯកសារគាំទ្រ និងឯកសារណែនាំបច្ចេកទេសសម្រាប់ការអនុវត្តស្តង់ដាមត្តេយ្យសិក្សាគំរូ |

sala.moeys.gov.kh t.me/moeysnews youtube.com/moeyscambodia

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - រៀបចំ និងតម្រង់ទិសប្រព័ន្ធវាយតម្លៃស្តង់ដាសម្រាប់សាលាមត្តេយ្យសិក្សាគំរូ។<br>**ការបណ្តុះបណ្តាល និងការគាំទ្រគ្រូបង្រៀន**<br>- បណ្តុះបណ្តាលគ្រូស្តីពីការសិក្សាតាមរយៈការលេង<br>- បណ្តុះបណ្តាលគ្រូអំពីការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការបង្រៀន និងការរៀន<br>- ផ្តល់ការកសាងសមត្ថភាព និងជំនួយបច្ចេកទេសសម្រាប់ការអនុវត្តកម្មវិធីសិក្សា និងផែនការមេរៀន និងការអនុវត្តកម្មវិធីអប់រំផ្សេងៗទៀត ដូចជា៖ វិន័យ អារម្មណ៍សង្គម សីលធម៌ អាកប្បកិរិយា និងអាកប្បកិរិយាសម្រាប់ការអប់រំកុមារតូច។<br>**សម្ភារគរុកោសល្យ**<br>- បង្កើតសម្ភារសិក្សា និងបង្រៀន (រួមទាំងសម្ភារដែលផលិតក្នុងមូលដ្ឋាន និងសម្ភារដែលអាចបំពេញបានក្នុងមូលដ្ឋាន) សម្រាប់ប្រើប្រាស់ក្នុងថ្នាក់រៀន និងក្នុងបរិវេណ ខាងក្រៅ ជុំវិញនៅមត្តេយ្យសិក្សា<br>- លើកកម្ពស់ការប្រើប្រាស់ «ជ្រុងសិក្សា»<br>- បង្កើតកម្មវិធីដើម្បីគាំទ្រកុមារដែលមានការយឺតយ៉ាវក្នុងការអភិវឌ្ឍ និងកុមារមកពីសហគមន៍ជនជាតិដើមភាគតិច។ |
| **យុទ្ធសាស្ត្រទី២៖** លើកកម្ពស់ការអប់រំមាតាបិតា | **ការណែនាំ**<br>- រៀបចំគោលការណ៍ណែនាំប្រតិបត្តិស្តីពីការអប់រំមាតាបិតា រួមទាំងសារៈសំខាន់នៃការអប់រំកុមារតូច (កុមារា និងកុមារី កុមារដែលមានសមត្ថភាពខុសៗគ្នា) និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងអ៊ីនធឺណិតប្រកបដោយការទទួលខុសត្រូវ។<br>**ការបណ្តុះបណ្តាល និងការគាំទ្រ**<br>- បណ្តុះបណ្តាលបុគ្គលិកថ្នាក់ក្រោមជាតិ និងសាលារៀន លើការណែនាំ និងសៀវភៅណែនាំស្តីពីការអប់រំមាតាបិតា<br>- ជំនួយផ្នែកបច្ចេកទេស (ការបង្វឹក និងការបង្ហាត់បង្រៀន) លើការអនុវត្តការអប់រំមាតាបិតា។ |

| វត្ថុបំណងទី៣៖ ពង្រឹងប្រតិបត្តិការ និងការគ្រប់គ្រងលើការអប់រំកុមារតូច | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនសាលាមត្តេយ្យសិក្សាបានទទួលការណែនាំ និងបង្វឹកស្ដីពីស្ដង់ដាសាលារៀនគំរូ | N/A | ៣៦០ |
| ភាគរយគ្រូបង្រៀនបានទទួលការបំប៉នសមត្ថភាពស្ដីពីភាពធន់នឹងអាកាសធាតុ | N/A | ១០០% |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** ពង្រីកភាពជាដៃគូរដ្ឋ-សហគមន៍សម្រាប់ការអប់រំកុមារតូច | **ភាពជាដៃគូ និងការសហការ**<br>- បង្កើនការចូលរួម សកម្មភាព និងការរៃអង្គាសថវិកាពីគ្រប់ភាគីពាក់ព័ន្ធ ដើម្បីគាំទ្រដល់សាលារៀន<br>- ពង្រឹងកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍ និងសាលារៀន<br>- ពង្រឹងកិច្ចសហប្រតិបត្តិការបច្ចេកទេស និងភាពជាដៃគូវិនិយោគពហុវិស័យ<br>- កសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធក្នុងការជួយដល់សាលារៀន រួមទាំងការចុះឈ្មោះចូលរៀនរបស់កុមារ។ |
| **យុទ្ធសាស្ត្រទី២៖** លើកកម្ពស់ភាពធន់នឹងអាកាសធាតុនៅតាមមត្តេយ្យសិក្សា | **ការណែនាំ និងសម្ភារ**<br>- រៀបចំឯកសារណែនាំបច្ចេកទេស ដើម្បីគាំទ្រភាពធន់របស់សាលាចំពោះការប្រែប្រួលអាកាសធាតុ រួមទាំងផែនការបន្ទាន់<br>- បង្កើត និងផ្សព្វផ្សាយសម្ភារ IEC (ខិត្តប័ណ្ណ ផ្ទាំងរូបភាព វីដេអូ ឬសំឡេង (ទាក់ទងនឹងភាពធន់នឹងអាកាសធាតុ។<br>**ការបណ្ដុះបណ្ដាល និងការគាំទ្រ**<br>- បណ្ដុះបណ្ដាលបុគ្គលិកថ្នាក់ក្រោមជាតិ និងសាលារៀន លើឯកសារណែនាំ និងខ្លឹមសារចាំបាច់ ដើម្បីគាំទ្រភាពធន់នឹងការប្រែប្រួលអាកាសធាតុ<br>- ផ្ដល់ជំនួយផ្នែកបច្ចេកទេសនៅកម្រិតសាលារៀនលើភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| **យុទ្ធសាស្ត្រទី៣៖** ការពង្រឹងការត្រួតពិនិត្យ និងការវាយតម្លៃកម្មវិធីអប់រំកុមារតូច | **ការរៀបចំ និងការប្រើប្រាស់ឧបករណ៍**<br>- ធ្វើបច្ចុប្បន្នកម្មក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ<br>- វាយតម្លៃលើការអប់រំកុមារតូចជាប្រចាំ និងប្រជុំវាយតម្លៃប្រចាំឆ្នាំ<br>- វាយតម្លៃ ឬធ្វើការសិក្សាប្រចាំឆ្នាំរួមគ្នា ជាមួយអង្គការមិនមែនរដ្ឋាភិបាល ឬដៃគូអភិវឌ្ឍ នៅក្នុងតំបន់ ឬវិស័យ។<br>**ការបណ្តុះបណ្តាល និងការគាំទ្រ**<br>- បណ្តុះបណ្តាលបុគ្គលិកថ្នាក់ក្រោមជាតិ និងសាលារៀន ស្តីពីការពិនិត្យតាមដាន និងវាយតម្លៃ<br>- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសលើកម្មវិធីការពិនិត្យតាមដាន និងវាយតម្លៃនៃកម្មវិធីការអប់រំកុមារតូច។ |

### ៣.៣.២ អនុកម្មវិធី៖ ១.២ ការអប់រំបឋមសិក្សា

| **លទ្ធផលរំពឹងទុករបស់អនុកម្មវិធី៖ កុមារទាំងអស់បានបញ្ចប់ថ្នាក់បឋមសិក្សា និងទទួលបានសមត្ថភាពល្អលើមុខវិជ្ជាគោល និងបំណិនជីវិត** | | |
|---|---|---|
| **សូចនាករផលសម្រេច** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនសាលាបឋមសិក្សាសម្រេចបានស្តង់ដាសាលាបឋមសិក្សាគំរូ | ៤០ | ៩០០ |
| អត្រារួមនៃការសិក្សានៅបឋមសិក្សា[6] | ១១៥,២% | ១១៩,៣% |
| ប្រុស | ១១៧,០% | ១២១,៦% |
| ស្រី | ១១៣,៣% | ១១៦,៩% |
| អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា[7] | ៩២,០% | ១០៧,៦% |
| ប្រុស | ៨៩,៨% | ១១២,៣% |
| ស្រី | ៩៤,៤% | ១០២,៧% |

[6] ឆ្នាំគោលសំដៅឆ្នាំសិក្សា២០២២-២០២៣ និងទិន្នន័យឆ្នាំគោល បានគណនាដោយប្រើប្រាស់ចំណោលប្រជាសាស្ត្រដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ ដែលប្រើនៅក្នុងចំណោលផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨។

[7] ឆ្នាំគោលសំដៅឆ្នាំសិក្សា២០២២-២០២៣ និងទិន្នន័យឆ្នាំគោល បានគណនាដោយប្រើប្រាស់ចំណោលប្រជាសាស្ត្រដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ ដែលប្រើនៅក្នុងចំណោលផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨។



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

**បញ្ហាប្រឈមគន្លឹះៗ៖**

- លទ្ធផលតេស្តវាយតម្លៃថ្នាក់ជាតិសម្រាប់ថ្នាក់ទី៣ (ភាសាខ្មែរ និងគណិតវិទ្យា) នៅមិនទាន់បានល្អប្រសើរ
- ចំនួនគ្រូបង្រៀនលើសនៅតំបន់ទីប្រជុំជន និងខ្វះគ្រូបង្រៀននៅតាមតំបន់ជនបទ និងជួបការលំបាក
- គ្រូបង្រៀនមួយចំនួនមិនទាន់មានគុណវឌ្ឍិសមស្រប
- សមត្ថភាពគ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរវេន និងគ្រូបង្រៀនថ្នាក់គួប នៅមានកម្រិត
- ការបាត់ម៉ោងបង្រៀន និងរៀន ប្រហែល ២៧៩ ម៉ោង ស្មើនឹង ៣០ ភាគរយ (គោលការណ៍ណែនាំម៉ោងបង្រៀនចាប់ពី ៨៥០ ទៅ ១ ០០០ ក្នុងមួយឆ្នាំ)
- សិស្សថ្នាក់ទី១ ប្រមាណ ៣០ ភាគរយ មិនបានឆ្លងកាត់ការអប់រំកុមារតូច
- សិស្សបឋមសិក្សា ប្រមាណ ៣០ ភាគរយ មានជំងឺក្រិសក្រិន ដោយសារកង្វះអាហារូបត្ថម្ភ
- សិស្សចូលរៀនថ្នាក់ទី១ ប្រមាណ ២០ ភាគរយ មានអាយុលើសពី ៦ឆ្នាំ
- អត្រាត្រួតថ្នាក់នៅបឋមសិក្សា ប្រមាណ ៥,៩ ភាគរយ នៅឆ្នាំ២០២២ លើសពីចំណុចដៅ ៥ ភាគរយ
- អត្រាបោះបង់ការសិក្សាបានកើនឡើងដល់ ៧,៥ ភាគរយ នៅក្នុងសាលារៀនសាធារណៈក្នុងឆ្នាំ ២០២២។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ អនុកម្មវិធីអប់រំបឋមសិក្សាមានវត្ថុបំណងចំនួន៣៖

១. ធានាការចូលរៀនប្រកបដោយសមធម៌នៅកម្រិតបឋមសិក្សា

២. លើកកម្ពស់គុណភាពនៃការអប់រំនៅកម្រិតបឋមសិក្សា

៣. កែលម្អភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចសាលារៀន

ដើម្បីធានាបាននូវការចូលរៀនកម្រិតបឋមសិក្សាប្រកបដោយសមធម៌ ការផ្តោតសំខាន់លើការបង្កើនការចុះឈ្មោះចូលរៀន វត្តមាន និងការបញ្ចប់ការសិក្សា ជាពិសេសសម្រាប់កុមារដែលជួបការលំបាក និងកុមារដែលប្រឈមមុខនឹងការបោះបង់ការសិក្សា។ ទាំងអស់នេះអាចសម្រេចបានតាមរយៈការធ្វើយុទ្ធនាការប្រមូលកុមារចូលរៀន និងរក្សាកុមារឱ្យគង់វង្ស ការផ្តល់អាហារូបករណ៍ និងការផ្តល់មធ្យោបាយធ្វើដំណើរសម្រាប់កុមារដែលរស់នៅឆ្ងាយពីសាលារៀន។ ការគាំទ្រផ្នែកគរុកោសល្យ នឹងជួយដល់កុមារដែលមានតម្រូវការ ដើម្បីរក្សាកុមារឱ្យនៅសាលារៀន។ ការលើកកម្ពស់សុខភាព សុវត្ថិភាព និងអាហារូបត្ថម្ភនៅតាមសាលារៀន និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារបរិក្ខារ ធានាឱ្យមានការចូលរៀនប្រកបដោយសមធម៌ ក៏ដូចជាការលើកកម្ពស់គុណភាពនៃការអប់រំបឋមសិក្សាផងដែរ។

ការលើកកម្ពស់គុណភាពនៃការសិក្សា ទាមទារឱ្យសិស្សមានមូលដ្ឋានគ្រឹះរឹងមាំនៅថ្នាក់ដំបូង។ ដើម្បីលើកកម្ពស់មូលដ្ឋានគ្រឹះរបស់សិស្សលើការសិក្សាមុខវិជ្ជាគោលភាសាខ្មែរ និងគណិតវិទ្យា អនុវិស័យអប់រំបឋមសិក្សា ត្រូវលើកកម្ពស់សមត្ថភាពគ្រូបង្រៀនថ្នាក់ដំបូង តាមរយៈការប្រើប្រាស់កញ្ចប់កម្មវិធីសិក្សាថ្នាក់ដំបូងសម្រាប់ការកសាងសមត្ថភាពគ្រូបង្រៀន និងអ្នកពាក់ព័ន្ធ ហើយត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយអគ្គនាយកដ្ឋាន

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

បណ្តុះបណ្តាល និងវិក្រឹតការ ដើម្បីធានាថាកញ្ចប់សិក្សាថ្នាក់ដំបូង បានអនុវត្តនៅក្នុងគ្រឹះស្ថាន បណ្តុះបណ្តាលគ្រូបង្រៀន។

ដើម្បីបង្កើនភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចសាលារៀន នាយកដ្ឋានបឋមសិក្សា នឹងធ្វើការកសាងសមត្ថភាពគណៈគ្រប់គ្រងសាលារៀន តាមរយៈការបណ្តុះបណ្តាល និងការផ្តល់ជំនួយណែនាំជាប្រចាំ។ ដោយផ្អែកលើយុទ្ធសាស្ត្រទាំងនេះ គណៈគ្រប់គ្រងសាលារៀននឹងមានសមត្ថភាពដឹកនាំ និងគ្រប់គ្រងសាលារៀន ក្នុងផ្នែកវាយតម្លៃ ផែនការ ថវិកា បុគ្គលិក និងការបង្រៀននិងរៀន ដើម្បីធានាបាននូវស្វ័យភាព និងគណនេយ្យភាពរបស់សាលារៀន និងដើម្បីបំពេញតាមស្តង់ដាសាលារៀនគំរូ រួមទាំងការគ្រប់គ្រងមូលនិធិស្ម័គ្រចិត្តរបស់សាលារៀន។

ការអភិវឌ្ឍសាលារៀនតម្រូវឱ្យមានការចូលរួមពីសហគមន៍ អាជ្ញាធរមូលដ្ឋាន ឪពុកម្តាយ អ្នកអាណាព្យាបាល ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ។ នាយកដ្ឋានបឋមសិក្សានឹងបង្កើតយុទ្ធនាការគាំទ្រ និង ផ្តល់ព័ត៌មានដើម្បីផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការរួមចំណែករបស់សហគមន៍ រួមទាំងផលជះជាវិជ្ជមានលើការអភិវឌ្ឍសាលារៀន និងនិរន្តរភាពនៃការវិនិយោគ ព្រមទាំងការលើកកម្ពស់គុណភាពនៃការអប់រំ ដើម្បីគាំទ្រសិស្សអនុវត្តសកម្មភាពក្រៅម៉ោងសិក្សា ការបង្កើនម៉ោងសិក្សា អនាម័យ និងបរិស្ថានបៃតង។ល។

យុទ្ធសាស្ត្រ និងសកម្មភាពគោល ដើម្បីជំរុញវត្ថុបំណងទាំងនេះ បានកំណត់ក្នុងតារាងខាងក្រោម៖

| **វត្ថុបំណងទី១៖ ធានាការចូលរៀនប្រកបដោយសមធម៌នៅកម្រិតបឋមសិក្សា** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| អត្រាពិតចូលរៀនថ្មីនៅបឋមសិក្សា | ៨៩,៨% | ៩៦,៣% |
| ប្រុស | ៨៩,១% | ៩៥,៩% |
| ស្រី | ៩០,៥% | ៩៦,៨% |
| អត្រាគង់វង្សនៅបឋមសិក្សា | ៦៩,៥% | ៨០,០% |
| ប្រុស | ៨០,៣% | ៩០,៣% |
| ស្រី | ៦០,៤% | ៧០,៤% |
| ភាគរយកុមារចូលរៀនលើសអាយុ | ១៤,២% | ៦,៧% |
| ស្រី | ១២,៩% | ៥,៤% |
| ចំនួនសិស្សក្រីក្រនៅបឋមសិក្សាទទួលបានអាហារូបករណ៍ | ១៤៨ ៣៦២ | ១៤៨ ៩៥៧ |
| ចំនួនសាលាបឋមសិក្សាដែលផ្តល់ការអប់រំបរិយាបន្ន | ៧៥ | ១០០ |
| ចំនួនគ្រូបឋមសិក្សាដែលបានទទួលការបំប៉នស្តីពីការអប់រំបរិយាបន្ន | ៤ ០០០ | ៥ ៥០០ |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | |
|---|---|---|
| ចំនួនសាលាបឋមសិក្សាបានអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍ | N/A | ១ ១១៤ |
| ភាគរយសាលាបឋមសិក្សាសាធារណៈមានទឹកស្អាត អនាម័យ និងបរិក្ខារផ្សេងៗទៀត | | |
| កម្រិត ៣ | ៦,៩% | ១៣,០% |
| បង្គន់អនាម័យ | ៩៩,៩% | ១០០% |
| ប្រអប់សង្គ្រោះបឋម | ៥៧,៤% | ១០០% |
| អគ្គិសនី | ៨៩,១% | ១០០% |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** អនុវត្តវិធានការបង្កើនការចូលរៀន បន្តការសិក្សា និងបញ្ចប់ការសិក្សា ជាពិសេសសម្រាប់កុមារដែលជួបការលំបាក និងកុមារងាយនឹងបោះបង់ការសិក្សា | **ការលើកកម្ពស់ការយល់ដឹង**<br>- ធ្វើយុទ្ធនាការចុះឈ្មោះសិស្ស ដើម្បីទាក់ទាញកុមារចូលរៀនត្រឹមត្រូវតាមអាយុ និងទប់ស្កាត់ការបោះបង់ការសិក្សា<br>- លើកទឹកចិត្តឱ្យសាលារៀនធ្វើបច្ចុប្បន្នកម្មផែនទីសាលារៀន ដើម្បីកំណត់មុខសញ្ញាកុមារដល់អាយុចូលរៀនបឋមសិក្សា កុមារមានពិការភាព និងក្រុមកុមារជួបការលំបាក តាមរយៈកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន។<br>**ជំនួយហិរញ្ញវត្ថុ**<br>- ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ សិស្សពូកែ និងសិស្សមានពិការភាព<br>- ផ្តល់មធ្យោបាយធ្វើដំណើរដល់សិស្សានុសិស្សដែលរស់នៅឆ្ងាយពីសាលារៀន។<br>**ការគាំទ្រគរុកោសល្យ**<br>- អនុវត្តកម្មវិធីបង្រៀន និងរៀនថ្ងៃព្រហស្បតិ៍ និងកម្មវិធីក្រៅម៉ោងសិក្សាដើម្បីគាំទ្រសិស្សរៀនយឺត<br>- អនុវត្តកម្មវិធីពន្លឿនការសិក្សា សម្រាប់កុមារលើសអាយុ<br>- អនុវត្តសកម្មភាពគោលនយោបាយស្តីពីការការពារកុមារ នៅតាមសាលារៀន រួមទាំងការប្រើប្រាស់វិធានការវិន័យបែបវិជ្ជមាន<br>- បង្កើតក្លឹបសិក្សា ដើម្បីគាំទ្រសិស្សរៀនយឺត និងកែលម្អលទ្ធផលសិក្សារបស់សិស្ស<br>- រៀបចំទស្សនកិច្ចសិក្សារបស់សិស្សនៅតាមសហគមន៍ រមណីយដ្ឋាន និងកន្លែងប្រវត្តិសាស្ត្រ និងវប្បធម៌ ដើម្បីគាំទ្រដល់ការសិក្សាតាមបែបគម្រោង |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - ពង្រឹងសមត្ថភាពនៅកម្រិតសាលា ដើម្បីប្រើប្រាស់ទិន្នន័យពីប្រព័ន្ធគ្រប់គ្រងទិន្នន័យសិស្ស និងយុទ្ធសាស្ត្រវាយតម្លៃថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រសិស្សឱ្យកាន់តែប្រសើរ តាមរយៈការសិក្សាចម្រុះ<br>- អនុវត្តកម្មវិធីអប់រំបរិយាបន្ន សម្រាប់កុមារមានពិការភាព និងកុមារដែលមានតម្រូវការពិសេស<br>- អនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិច<br>- អនុវត្តសកម្មភាពគាំទ្រដើម្បីបំពេញតាមស្តង់ដាសាលារៀនគំរូ។ |
| **យុទ្ធសាស្ត្រទី២៖** លើកកម្ពស់សុខភាព សុវត្ថិភាព និងអាហារូបត្ថម្ភក្នុង និងតាមសាលាបឋមសិក្សា | **សកម្មភាពក្នុងសាលារៀន**<br>- ពង្រីកការផ្តល់អាហារដល់សិស្សសាលាបឋមសិក្សា ជាពិសេសកុមារដែលជួបការលំបាក តាមរយៈកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍<br>- ពង្រឹងការអនុវត្តកម្មវិធីទឹកស្អាត និងអនាម័យនៅតាមសាលារៀន<br>- កម្មវិធីស្តីពីសុវត្ថិភាពចំណីអាហារ និងអាហារដែលមានសុខភាពល្អនៅក្នុងសាលារៀន អនាម័យទូទៅ អនាម័យខ្លួនប្រាណ អនាម័យមាត់ធ្មេញ ការលាងសម្អាតដៃ ការអប់រំពីមេរោគអេដស៍/ជំងឺអេដស៍សុខភាពផ្លូវភេទគ្រប់ជ្រុងជ្រោយ និងការគ្រប់គ្រងការមករដូវរបស់ក្មេងស្រី<br>- បង្កើតបន្ទប់ថែទាំសុខភាពដោយបំពាក់សម្ភារ និងឧបករណ៍ចាំបាច់អប្បបរមា ក៏ដូចជាការផ្តល់ឧបករណ៍សង្គ្រោះបឋម និងឧបករណ៍ការពារសម្រាប់ជំងឺឆ្លង<br>- អនុវត្តយុទ្ធនាការសាលារៀនស្អាត គ្មានសំរាម បរិស្ថានស្អាត ការអប់រំពីមេរោគអេដស៍/ជំងឺអេដស៍ សុខភាពផ្លូវភេទគ្រប់ជ្រុងជ្រោយ សាលារៀនគ្មានគ្រឿងស្រវឹង គ្មានគ្រឿងញៀន គ្មានថ្នាំជក់ និងមិនប្រើប្រាស់ផលិតផលប្លាស្ទិក។ល។<br>**ការពង្រីកសេវាសុខភាព**<br>- ពង្រីកការអនុវត្តការថែទាំសុខភាព និងសុវត្ថិភាព ដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរួមមានទឹកជំនន់ ការកើនឡើងសីតុណ្ហភាព និងជំងឺឆ្លងដែលចម្លងដោយការប៉ះពាល់គ្នា |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - ពង្រីកវិសាលភាពនៃការពិនិត្យសុខភាព រួមមានការពិនិត្យភ្នែក និងការផ្តល់វ៉ែនតា ការស្តារគំហើញឡើងវិញ ការស្តារលទ្ធភាពស្តាប់ និងការគណនាអាហារូបត្ថម្ភ ដើម្បីធ្វើអន្តរាគមន៍ចំពោះកុមារលើសទម្ងន់ ឬកង្វះអាហារូបត្ថម្ភ<br>- ពង្រីកកម្មវិធីអប់រំសុខភាពយ៉ាងទូលំទូលាយ ស្របតាមស្តង់ដាសាលារៀនគំរូ<br>- សហការជាមួយមន្ត្រីសុខាភិបាលមូលដ្ឋាន ដើម្បីពង្រីកការផ្តល់សេវាថែទាំសុខភាពបឋម ដូចជាការពិនិត្យសុខភាព ការចាក់ថ្នាំបង្ការ ការផ្តល់សេវាសុខភាព និងជំនួយ សេវាប្រឹក្សា ការបញ្ជូនកុមារខ្វះអាហារូបត្ថម្ភ និងសេវាគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ ឬជំងឺផ្លូវកាយផ្សេងទៀត។<br>**ការបណ្តុះបណ្តាលគ្រូនិងការគាំទ្រ**<br>- ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីកម្មវិធីសុខភាពសិក្សាដល់មន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម និងបុគ្គលិកសាលាដែលទទួលខុសត្រូវលើកម្មវិធីអប់រំសុខភាព<br>- បើកវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់សៀវភៅសិក្សាសម្រាប់ការអប់រំសុខភាពចាប់ពីថ្នាក់ទី ១ ដល់ទី ៦<br>- បោះពុម្ពសៀវភៅអប់រំសុខភាពសម្រាប់គ្រូ និងសិស្សចាប់ពីថ្នាក់ទី ១ ដល់ទី ៦។ |
| **យុទ្ធសាស្ត្រទី៣៖** អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាលារៀនដែលធន់នឹងអាកាសធាតុ រួមទាំងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ស្របតាមស្តង់ដានៃសាលាបឋមសិក្សាគំរូ ដោយយកចិត្តទុកដាក់ ជាពិសេសចំពោះសាលារៀនខ្សត់ខ្សោយ និងជួបការលំបាក | **ហេដ្ឋារចនាសម្ព័ន្ធសាលារៀន**<br>- លើកកម្ពស់បរិស្ថានស្អាត បៃតង សុវត្ថិភាព និងអនាម័យ ដាំដើមឈើសម្រាប់ម្លប់ រៀបចំ និង/ឬសាងសង់សួនកុមារ អនុវត្តការគ្រប់គ្រងសំណល់ដែលមិនប៉ះពាល់ដល់បរិស្ថាន សួនបន្លែ និងសួនជីវចម្រុះ<br>- សាងសង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធសាលារៀន រួមមាន ទីចាត់ការសាលារៀន អគារសិក្សា បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ផ្ទះគ្រូបង្រៀន បង្គន់អនាម័យ ផ្ទះបាយ បន្ទប់បរិភោគអាហារ និងសម្ភារបរិក្ខារផ្សេងៗទៀត តាមគោលការណ៍បរិយាបន្ន និងអាចចូលប្រើប្រាស់បាន ជាពិសេសសាលារៀនដែលមិនទាន់ពេញលេញ និងមានការខ្វះខាត |

| | |
|---|---|
| | - តភ្ជាប់បណ្តាញអគ្គិសនី ទឹកស្អាត និងអ៊ីនធឺណិតនៅតាមសាលារៀន និងបំពាក់ឧបករណ៍ទំនើបៗនៅតាមថ្នាក់រៀន ដូចជា LCD, Smart TV, Smart Board ។ល។<br>**បរិក្ខារសាលារៀន**<br>- បង្កើតបណ្ណាល័យ បន្ទប់កុំព្យូទ័រ និងបន្ទប់កុំព្យូទ័រតាមស្តង់ដា<br>- សាងសង់ និងជួសជុលទីលានកីឡា រួមមាន អត្តពលកម្ម បាល់ទះ បាល់ទាត់ បាល់បោះ វាយសី ។ល។<br>- ពង្រីក និងពង្រឹងកម្មវិធីសាលារៀនដែលមិនប៉ះពាល់ដល់បរិស្ថាន ក្លឹបមិត្តភាពបរិស្ថាន សហគមន៍ស្អាត គ្មានថង់ប្លាស្ទិក ឬប្លាស្ទិកប្រើប្រាស់តែម្តង។ |

| វត្ថុបំណងទី២៖ លើកកម្ពស់គុណភាពនៃសិក្សានៅកម្រិតបឋមសិក្សា | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ភាគរយសាលារៀនដែលអនុវត្តអំណាន និងគណិតវិទ្យាថ្នាក់ដំបូង | | |
| ភាសាខ្មែរថ្នាក់ទី ១ | N/A | ១០០% |
| គណិតវិទ្យាថ្នាក់ទី១ | N/A | ១០០% |
| ភាសាខ្មែរថ្នាក់ទី ២ | N/A | ១០០% |
| គណិតវិទ្យាថ្នាក់ទី២ | N/A | ៨០,០% |
| ភាសាខ្មែរថ្នាក់ទី៣ | N/A | ៥០,០% |
| គណិតវិទ្យាថ្នាក់ទី៣ | N/A | ៣០,០% |
| ចំនួនសាលារៀនអនុវត្តសកម្មភាពក្រៅម៉ោងសិក្សាពីថ្នាក់ទី៤ ដល់ទី ៦ | N/A | ៦០០ |
| ភាគរយសាលាបឋមសិក្សាអនុវត្តក្របខ័ណ្ឌកម្មវិធីសិក្សាពេញលេញ | N/A | ៨៥,០% |
| ចំនួនគ្រូបង្រៀនបានទទួលការបណ្តុះបណ្តាលស្តីពី អំណាន និងគណិតវិទ្យាថ្នាក់ដំបូង(ថ្នាក់ទី ១-៣) | | |
| អំណានថ្នាក់ដំបូង | ១៦ ៣៤៣ | ៣០ ០០០ |
| គណិតវិទ្យាថ្នាក់ដំបូង | ៥ ១១៦ | ២០ ០០០ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
| --- | --- |
| **យុទ្ធសាស្ត្រទី១៖** ធ្វើបច្ចុប្បន្ន-កម្មកម្មវិធីសិក្សា និងសៀវភៅសិក្សា និងវិធីសាស្ត្របង្រៀន និងឯកសារគរុកោសល្យ រួមទាំងការអប់រំបរិយាបន្ន និងការប្រែប្រួលអាកាសធាតុ | **កម្មវិធីសិក្សា សៀវភៅសិក្សា និងវិធីសាស្ត្របង្រៀន**<br>- ធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល គោលការណ៍ណែនាំគរុកោសល្យសម្រាប់ការបង្រៀននិងរៀន និងក្របខ័ណ្ឌវាយតម្លៃ<br>- បង្កើនការបណ្តុះបណ្តាលគ្រូបង្រៀន និងអ្នកពាក់ព័ន្ធ លើការសិក្សាថ្នាក់ដំបូង (អំណាន និងគណិតវិទ្យាថ្នាក់ដំបូង)<br>- អភិវឌ្ឍសមត្ថភាពគ្រូបង្គោលថ្នាក់ជាតិ សម្រាប់មុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា និងវិធីសាស្ត្របង្រៀនមុខវិជ្ជាស្នែមដល់គ្រូបឋមសិក្សា និងអ្នកពាក់ព័ន្ធ<br>- ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា សៀវភៅសិក្សាអប់រំបច្ចេកទេស និងសម្ភារសិក្សាសម្រាប់ការអប់រំពហុភាសា<br>- អភិវឌ្ឍកម្មវិធីសិក្សា សៀវភៅសិក្សា និងសម្ភារសិក្សា និងឯកសារសម្រាប់ការអប់រំបរិយាបន្ន និងអប់រំពិសេស<br>- ពិនិត្យ និងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ<br>- ធ្វើបច្ចុប្បន្នកម្មឯកសារបង្រៀននិងរៀនសម្រាប់ការអប់រំបរិស្ថាន និងការប្រែប្រួលអាកាសធាតុសម្រាប់ថ្នាក់ទី ៤-៦ និងភ្ជាប់ជាមួយការបណ្តុះបណ្តាលគ្រូ<br>- ផ្សព្វផ្សាយកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និងឯកសារគរុកោសល្យទៅដល់គ្រប់សាលាបឋមសិក្សាសាធារណៈ និងឯកជន ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់<br>- បំប៉នសមត្ថភាពគ្រូបង្រៀនឱ្យមានបំណិនប្រើប្រាស់កម្មវិធីសិក្សា សៀវភៅសិក្សាគោល វិធីសាស្ត្របង្រៀន និងឯកសារគរុកោសល្យឱ្យបានទូលំទូលាយ<br>- បញ្ជ្រាបកម្មវិធីសិក្សាថ្នាក់បឋមសិក្សាពាក់ព័ន្ធនឹងគំនិតច្នៃប្រឌិតនិងការបង្កើតថ្មីៗ<br>**ផែនការសកម្មភាព**<br>- អភិវឌ្ឍ ផ្សព្វផ្សាយ និងអនុវត្តផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្នឆ្នាំ២០២៤-២០២៨ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - អភិវឌ្ឍ ផ្សព្វផ្សាយ និងអនុវត្តផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ឆ្នាំ២០២៤-២០២៨។ |
| **យុទ្ធសាស្ត្រទី២៖** បញ្ចូលការប្រើប្រាស់បច្ចេកវិទ្យា និងទូរគមនាគមន៍ និងព័ត៌មានសម្រាប់ការបង្រៀន និងរៀន ដើម្បីបង្កើតបរិយាកាសអំណោយផលសម្រាប់ការរៀន | **មាតិកាឌីជីថល**<br>- លើកកម្ពស់ការប្រើប្រាស់ខ្លឹមសារឌីជីថល ដែលក្រសួងអប់រំ យុវជន និងកីឡាបានផលិត និងផ្សព្វផ្សាយរួចហើយ<br>- ផលិតមាតិកាឌីជីថលសម្រាប់ការរៀនពីចម្ងាយសម្រាប់សិស្ស សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន។<br>**ជំនួយគ្រូ**<br>- អភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និងបុគ្គលិក ក្នុងការរៀបចំខ្លឹមសារមេរៀន ផលិតសម្ភារសិក្សា និងបង្រៀន និងប្រើប្រាស់ថ្នាក់ឌីជីថល ដើម្បីណែនាំការបង្រៀននិងរៀន។<br>**សាលាឌីជីថល**<br>- បង្កើត និងលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធព័ត៌មានសាលារៀន និងកម្មវិធីផ្សេងទៀត ដូចជាមជ្ឈមណ្ឌលធនធានអប់រំអេឡិចត្រូនិក មជ្ឈមណ្ឌលទិន្នន័យឌីជីថល សៀវភៅសិក្សាអេឡិចត្រូនិក និងសាលាឌីជីថល និងថ្នាលអភិវឌ្ឍសមត្ថភាព<br>- អនុវត្តយុទ្ធសាស្ត្រអប់រំឌីជីថលសម្រាប់សាលារៀន<br>- លើកទឹកចិត្តឱ្យសាលារៀនបង្កើតគេហទំព័រផ្លូវការ ប្រព័ន្ធផ្សព្វផ្សាយសង្គម និងផ្សព្វផ្សាយយ៉ាងទូលំទូលាយ។ |
| **យុទ្ធសាស្ត្រទី៣៖** លើកកម្ពស់កម្មវិធីសិក្សាបន្ថែម ដើម្បីលើកកម្ពស់សីលធម៌ និងឥរិយាបថរបស់គ្រូបង្រៀន និងសិស្ស | **កម្មវិធីបំណិនជីវិត និងឥរិយាបថ**<br>- អនុវត្តកម្មវិធីដើម្បីលើកកម្ពស់ការអប់រំអាកប្បកិរិយា ដោយលើកទឹកចិត្តសិស្ស និងគ្រូបង្រៀន ឱ្យអនុវត្តតាមគោលការណ៍អនាម័យ ឥរិយាបថគាំទ្របរិស្ថាន សីលធម៌ ឥរិយាបថ គោរពពេលវេលា និងសមាធិ<br>- អនុវត្តកម្មវិធីបំណិនជីវិតនៅតាមមូលដ្ឋាន<br>- អនុវត្តក្លឹបសាលារៀនសម្រាប់បរិស្ថាន ឬការប្រែប្រួលអាកាសធាតុ<br>- អភិវឌ្ឍឯកសារស្តីពីកម្មវិធីសិក្សាក្រៅម៉ោងសិក្សាពាក់ព័ន្ធនឹងសីលធម៌ សុជីវធម៌ ឯកសារណែនាំប្រតិបត្តិ និងឯកសារជំនួយផ្សេងទៀត<br>- បំប៉នសមត្ថភាពគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនលើការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | **ព្រឹត្តិការណ៍ និងសកម្មភាពអប់រំ**<br>- រៀបចំព្រឹត្តិការណ៍អប់រំសីលធម៌ និងផ្លូវចិត្ត ដោយនិមន្តព្រះសង្ឃ ឬព្រឹទ្ធាចារ្យមកធ្វើធម្មទេសនាអប់រំ<br>- បង្កើត និងដំណើរការសកម្មភាពអប់រំសិល្បៈ រួមមានចម្រៀង គំនូរ របាំតន្ត្រី។ល។ |

| **វត្ថុបំណងទី ៣៖ កែលម្អភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចសាលារៀន** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ភាគរយសាលាបឋមសិក្សាដែលមានគណៈកម្មការគ្រប់គ្រងសាលារៀនសកម្ម (ប្រជុំយ៉ាងតិច ៧ ដងក្នុងមួយឆ្នាំ) | N/A | ៥០% |
| ចំនួនសាលាបឋមសិក្សាបានទទួលការប្រឹក្សាគរុកោសល្យ និងបង្វឹកស្ដីពីស្ដង់ដាសាលារៀនគំរូ | N/A | ១ ២០០ |

| **យុទ្ធសាស្ត្រ** | **សកម្មភាពគោល** |
|---|---|
| **យុទ្ធសាស្ត្រទី១៖** ពង្រឹងសមត្ថភាពគណៈគ្រប់គ្រងសាលារៀន | **បទដ្ឋានគតិយុត្ត**<br>- ធ្វើបច្ចុប្បន្នភាពឯកសារច្បាប់ និងពង្រឹងនីតិវិធីសម្រាប់ការលើកកម្ពស់គណៈគ្រប់គ្រងសាលារៀន។<br>**ការរៀបចំការបណ្ដុះបណ្ដាល**<br>- ត្រួតពិនិត្យមុខងាររបស់បុគ្គលិកនៅកម្រិតសាលារៀន<br>- រៀបចំឯកសារសម្រាប់ការបណ្ដុះបណ្ដាលគណៈគ្រប់គ្រងសាលារៀន<br>- រៀបចំ និងកែលម្អឯកសារបណ្ដុះបណ្ដាល សម្រាប់នាយកកម្រង និងគណៈគ្រប់គ្រងសាលារៀន។<br>**ការបណ្ដុះបណ្ដាល**<br>- បណ្ដុះបណ្ដាលដល់នាយកកម្រង និងគណៈគ្រប់គ្រងសាលារៀន<br>- បណ្ដុះបណ្ដាលរយៈពេលមធ្យមដល់បុគ្គលិកអប់រំដែលមានបំណងចង់ក្លាយជានាយកសាលាបឋមសិក្សា។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| **យុទ្ធសាស្ត្រទី២៖** កែលម្អប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងមូលនិធិស្ម័គ្រចិត្តសម្រាប់សហគមន៍សាលារៀន | **បទដ្ឋានគតិយុត្ត និងគោលនយោបាយ**<br>- បង្កើតគោលនយោបាយ ឯកសារច្បាប់ ផែនការយុទ្ធសាស្ត្រ ផែនការប្រតិបត្តិ ដើម្បីប្រមូលការគាំទ្រផ្នែកហិរញ្ញវត្ថុ សម្ភារ និងបច្ចេកទេស។<br>**ការផ្សព្វផ្សាយ**<br>- ផ្សព្វផ្សាយពីសារៈសំខាន់ និងភាពចាំបាច់នៃការគាំទ្រសាលារៀនពីឪពុកម្ដាយ អ្នកអាណាព្យាបាល និងសហគមន៍។<br>**ការអភិវឌ្ឍសមត្ថភាព**<br>- អភិវឌ្ឍសមត្ថភាពរបស់នាយកសាលា គណៈកម្មការគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធលើការគ្រប់គ្រងមូលនិធិស្ម័គ្រចិត្តរបស់សាលារៀន<br>- តាមដាន វាយតម្លៃ និងផ្សព្វផ្សាយលទ្ធផលនៃការអនុវត្តមូលនិធិស្ម័គ្រចិត្តរបស់សាលារៀន។ |
| **យុទ្ធសាស្ត្រទី៣៖** បង្កើតសាលារៀនគំរូ និងសាលា-រៀនជំនាន់ថ្មី | **ការរៀបចំក្របខ័ណ្ឌឯកសារគតិយុត្ត**<br>- រៀបចំឯកសារគតិយុត្ត ដើម្បីគាំទ្រដល់ការបង្កើត និងដំណើរការសាលារៀនពេញមួយថ្ងៃ និងកម្មវិធីសិក្សាទំនើប ដោយមូលនិធិស្ម័គ្រចិត្ត និងសាលារៀនជំនាន់ថ្មី<br>- រៀបចំឯកសារគតិយុត្ត ដើម្បីគាំទ្រការអនុវត្តស្តង់ដាសាលារៀនគំរូ។<br>**ការជ្រើសរើសសាលារៀនគំរូ**<br>- ប្រមូល និងវិភាគទិន្នន័យអំពីសាលារៀនសក្តានុពលដែលមានថ្នាក់រៀន និងគ្រូបង្រៀនសមស្រប ដែលអាចប្រែក្លាយជាសាលារៀនពេញមួយថ្ងៃ និងអនុវត្តកម្មវិធីសិក្សាទំនើប និងក្លាយជាសាលារៀនជំនាន់ថ្មី<br>- ជ្រើសរើសសាលាបឋមសិក្សា ដោយមានការប្តេជ្ញាចិត្តខ្ពស់ពីគណៈគ្រប់គ្រងសាលារៀន សហគមន៍ គ្រូបង្រៀន និងអាជ្ញាធរមូលដ្ឋាន ដើម្បីអនុវត្តស្តង់ដាសាលារៀនគំរូ<br>- គាំទ្រសាលារៀនដែលមានលទ្ធភាពសម្រេចបាននូវស្តង់ដាសាលារៀនគំរូ និងបង្កើតសាលារៀនជំនាន់ថ្មី។<br>**ការលើកកម្ពស់ការយល់ដឹង និងការគាំទ្រ**<br>- លើកកម្ពស់ការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងលោកគ្រូអ្នកគ្រូ ដើម្បីគាំទ្រដល់ការបង្រៀននិងរៀនពេញមួយថ្ងៃ ការអនុវត្តកម្មវិធីសិក្សាទំនើប និងសាលារៀនជំនាន់ថ្មី |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - ផ្តល់ការគាំទ្រ និងតាមដានការអនុវត្តកម្មវិធីសិក្សា និងបង្រៀនពេញមួយថ្ងៃ ការអនុវត្តកម្មវិធីសិក្សាទំនើបដោយមូលនិធិសមធម៌ ស្ម័គ្រចិត្ត និងការបង្កើតសាលារៀនគំរូ និងសាលារៀនជំនាន់ថ្មី។ |
| **យុទ្ធសាស្ត្រទី៤៖** លើកកម្ពស់ភាពជាដៃគូរវាងសាលារៀន និងសហគមន៍ | **រចនាសម្ព័ន្ធ និងតួនាទី**<br>- បង្កើត និងកំណត់តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ដើម្បីចែករំលែកភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងនៅក្នុងសាលារៀន និងថ្នាក់រៀន<br>- ផ្សព្វផ្សាយគោលការណ៍អភិបាលកិច្ចសាលារៀន (តម្លាភាព និងគណនេយ្យភាព)<br>- បង្កើតក្រុមប្រឹក្សាភិបាលសាលារៀនសាកល្បងនៅ៖ (១) សាលារៀនជំនាន់ថ្មី (២) សាលារៀនពេញមួយថ្ងៃ (៣) ស្តង់ដាសាលារៀនគំរូ។<br>**ការលើកកម្ពស់ភាពជាដៃគូ**<br>- បង្កើតបណ្តាញជាមួយសហគមន៍ ឪពុកម្តាយ អ្នកអាណាព្យាបាល អាជ្ញាធរ និងម្ចាស់ជំនួយ ដើម្បីរួមចំណែកជាសម្ភារ ថវិកា ពេលវេលា និងបទពិសោធន៍ ដើម្បីអភិវឌ្ឍសាលារៀន<br>- លើកទឹកចិត្ត និងលើកកម្ពស់ការចូលរួមរបស់សហគមន៍ដោយការប្រគល់វិញ្ញាបនបត្រ ឬលិខិតថ្លែងអំណរគុណដល់អ្នកឧបត្ថម្ភអភិវឌ្ឍន៍សាលារៀន<br>- លើកកម្ពស់ភាពជាដៃគូសាធារណៈ និងសហគមន៍សម្រាប់ការអប់រំដោយមានការចូលរួមពីដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីចូលរួមក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន និងគាំទ្រការអភិវឌ្ឍ។<br>**ការគាំទ្រនិងការត្រួតពិនិត្យ**<br>- ពង្រឹងគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ដើម្បីប្រមូលធនធានពីសប្បុរសជន ម្ចាស់ជំនួយសហគមន៍ និងដៃគូអភិវឌ្ឍ<br>- លើកកម្ពស់ការចូលរួមរបស់សហគមន៍សម្រាប់ការអនុវត្ត និងតាមដានសកម្មភាពរបស់សាលារៀន ដើម្បីធានាភាពជាម្ចាស់ របស់សាលារៀន<br>- ផ្សព្វផ្សាយលទ្ធផលសិក្សារបស់សិស្សយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ។ |

### ៣.៣.៣ អនុកម្មវិធី៖ ១.៣ ការអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស

| លទ្ធផលរំពឹងទុករបស់អនុកម្មវិធី ៖ យុវជនបានបញ្ចប់ការសិក្សាថ្នាក់មធ្យមសិក្សាដោយជោគជ័យ និងទទួលបានចំណេះដឹង ជំនាញ វិន័យ ក្រមសីលធម៌ និងអាកប្បកិរិយា សម្រាប់អនាគតដ៏ល្អ | | |
|---|---|---|
| សូចនាករផលសម្រេច | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
| ចំនួនសាលាមធ្យមសិក្សាសម្រេចបានស្តង់ដាសាលាមធ្យមសិក្សាគំរូ | | |
| សាលាមធ្យមសិក្សាបឋមភូមិគំរូ | ១៥ | ៣០០ |
| សាលាមធ្យមសិក្សាទុតិយភូមិគំរូ | ៥៥ | ២០០ |
| អត្រារួមនៃការសិក្សានៅមធ្យមសិក្សា[8] | | |
| មធ្យមសិក្សាបឋមភូមិ | ៧២,៣% | ៨១,៤% |
| ប្រុស | ៦៧,៤% | ៧៩,៨% |
| ស្រី | ៧៧,៣% | ៨៣,១% |
| មធ្យមសិក្សាទុតិយភូមិ | ៤០,១% | ៤៩,១% |
| ប្រុស | ៣៥,៨% | ៤៧,២% |
| ស្រី | ៤៤,៦% | ៥១,១% |
| អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សា[9] | | |
| មធ្យមសិក្សាបឋមភូមិ | ៦០,៧% | ៦៨,៤% |
| ប្រុស | ៥៥,២% | ៦៥,៥% |
| ស្រី | ៦៦,៥% | ៧១,៤% |
| មធ្យមសិក្សាទុតិយភូមិ | ៣៥,១% | ៤៥,៦% |
| ប្រុស | ៣១,៥% | ៤២,៤% |
| ស្រី | ៣៨,៩% | ៤៨,៩% |
| ចំនួនសិស្សចុះឈ្មោះចូលរៀនអប់រំបច្ចេកទេស | ៣ ២៥៩ | ៦ ០០០ |

**បញ្ហាប្រឈមគន្លឹះៗ៖**

- លទ្ធផលសិក្សានៅមានកម្រិតទាប ជាមួយនឹងភាគរយសំខាន់ៗនៃសិស្សថ្នាក់ទី៨ ដែលកំពុងអនុវត្តក្រោមកម្រិតជំនាញមូលដ្ឋាន ក្នុងនោះ ផ្នែកសំណេរ (៧៩ ភាគរយ) ផ្នែករូបវិទ្យា (៦៨ ភាគរយ) ផ្នែកគណិតវិទ្យា (៤៣ ភាគរយ) និង ផ្នែកអំណាន (១៧ ភាគរយ)

[8] ឆ្នាំគោលសំដៅឆ្នាំសិក្សា២០២២-២០២៣ និងទិន្នន័យឆ្នាំគោល បានគណនាដោយប្រើប្រាស់ចំណោលប្រជាសាស្ត្រដែលបានបោះពុម្ពផ្សាយដោយដោយវិទ្យាស្ថានជាតិស្ថិតិ ដែលប្រើនៅក្នុងចំណោលផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨។

[9] ឆ្នាំគោលសំដៅឆ្នាំសិក្សា២០២២-២០២៣ និងទិន្នន័យឆ្នាំគោល បានគណនាដោយប្រើប្រាស់ចំណោលប្រជាសាស្ត្រដែលបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានជាតិស្ថិតិ ដែលប្រើនៅក្នុងចំណោលផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ពិន្ទុ PISA ជាមធ្យមសម្រាប់សិស្សអាយុ ១៥ ឆ្នាំ មានភាពប្រសើរឡើងលើផ្នែកគណិតវិទ្យា អំណាន និងវិទ្យាសាស្ត្រ រវាងឆ្នាំ២០១៧ ដល់ឆ្នាំ២០២២ ប៉ុន្តែមានតែ ១២ ភាគរយ (ផ្នែកគណិតវិទ្យា) ១០,៤ ភាគរយ (ផ្នែកវិទ្យាសាស្ត្រ) និង ៧,៩ ភាគរយ (ផ្នែកអំណាន) នៃសិស្សដែលសម្រេចបានកម្រិត ២ (ជំនាញមូលដ្ឋាន)
- សាលាមធ្យមសិក្សាចំណេះទូទៅភាគច្រើនមិនមានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បណ្ណាល័យ សម្ភារបង្រៀន និងអគ្គិសនីស្របតាមកម្មវិធីសិក្សា
- កង្វះមន្ត្រីជំនាញដែលមានសមត្ថភាពឆ្លើយតបនឹងកំណែទម្រង់អប់រំ
- សហគ្រាស កសិដ្ឋាន និងវិស័យឯកជន មិនទាន់ផ្តល់កិច្ចសហប្រតិបត្តិការពេញលេញទាក់ទងនឹងកម្មសិក្សា និងទស្សនកិច្ចសិក្សានៅឡើយ
- កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនថ្មី គោលការណ៍ស្នែម និងវិធីសាស្ត្រល្អៗផ្សេងទៀត ព្រមទាំងវិធីសាស្ត្រនៃការរៀបចំឯកសារប្រឡង មិនទាន់បានរៀបចំឱ្យបានទូលំទូលាយសម្រាប់គ្រូបង្រៀន
- អត្រារួមចូលរៀនថ្មីថ្នាក់ទី ៧ បានធ្លាក់ចុះពី ៨០ ភាគរយ ក្នុងឆ្នាំសិក្សា២០២១-២០២២ មកត្រឹម ៦៧ ភាគរយ ក្នុងឆ្នាំសិក្សា២០២២-២០២៣
- អត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា នៅមធ្យមសិក្សាបឋមភូមិបានកើនឡើងពីឆ្នាំសិក្សា ២០១៩-២០២០។ ការបោះបង់ការសិក្សាគឺបណ្តាលមកពីកត្តាសេដ្ឋកិច្ច ក៏ដូចជាកត្តាអប់រំ។

ដើម្បីដោះស្រាយបញ្ហាប្រឈមគន្លឹះៗដែលបានបង្ហាញខាងលើ និងសម្រេចបានវត្ថុបំណងអនុកម្មវិធីអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស រួមមានវត្ថុបំណងចំនួន៣៖

១. កែលម្អការចូលរៀន និងគង់វង្សក្នុងកម្រិតមធ្យមសិក្សាប្រកបដោយសមធម៌ និងបរិយាបន្ន

២. លើកកម្ពស់គុណភាពអប់រំស្របតាមជំនាញនៃសតវត្សរ៍ទី២១

៣. កែលម្អភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចសាលារៀន

ដើម្បីបង្កើនការចូលរៀន និងរក្សាសិស្សឱ្យនៅគង់វង្សក្នុងកម្រិតអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ក្រសួងនឹងពង្រីកបណ្តាញសាលាមធ្យមសិក្សាចំណេះទូទៅ និងបច្ចេកទេស ដោយផ្អែកលើការវិភាគលើតម្រូវការប្រជាសាស្ត្រ និងទីផ្សារការងារ ហើយនឹងបង្កើនការផ្តល់អាហារូបករណ៍សម្រាប់សិស្សក្រីក្រ និងជនងាយរងគ្រោះ និងសិស្សមានពិការភាព ដើម្បីធានាបានការចូលរៀនប្រកបដោយសមធម៌ និងគង់វង្សក្នុងកម្រិតអប់រំមធ្យមសិក្សាចំណេះទូទៅ និងបច្ចេកទេសនៅទូទាំងប្រទេស។ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្ភារបរិក្ខារ រួមទាំងសម្ភារបរិក្ខារសុខភាពសិក្សា ក៏នឹងជាយុទ្ធសាស្ត្រគន្លឹះសម្រាប់ការបង្កើនការចូលរៀន និងរក្សាសិស្សឱ្យបានគង់វង្សនៅកម្រិតមធ្យមសិក្សា។

ក្រសួងនឹងជំរុញការអប់រំបច្ចេកទេសដោយផ្តត់ផ្គង់សម្ភារសិក្សា ឧបករណ៍ និងការកែលម្អបរិយាកាសសាលារៀន និងថ្នាក់រៀន តាមរយៈការអនុវត្តជាក់ស្តែង ការសិក្សាពេញមួយថ្ងៃ និងសកម្មភាពក្រៅកម្មវិធីសិក្សា។ លើសពីនេះ ក្រសួងនឹងសហការជាមួយគ្រឹះស្ថានឧត្តមសិក្សា គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

និងសហគ្រាសវិស័យឯកជន ដើម្បីពង្រឹងការផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេស ដើម្បីទាក់ទាញនិងរក្សាសិស្ស-និស្សិតក្នុងការអប់រំបច្ចេកទេស។ តាមរយៈឱកាសសិក្សាផ្អែកលើការងារ កម្មសិក្សា ទស្សនកិច្ចសិក្សា និងការចែករំលែកបទពិសោធន៍ជាមួយភាគីពាក់ព័ន្ធ ក្រសួងសង្ឃឹមថាមានការចូលរួមពីយុវជនកាន់តែច្រើនក្នុងការអប់រំបច្ចេកទេស និងលើកកម្ពស់គុណភាពនៃការអប់រំបច្ចេកទេស។

ដើម្បីបង្កើនគុណភាពទូទៅនៃការអប់រំមធ្យមសិក្សាចំណេះទូទៅ ក្រសួងនឹងបង្កើនការយកចិត្តទុកដាក់លើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា និងភាសាបរទេស ដើម្បីឆ្លើយតបទៅនឹងក្របខ័ណ្ឌជំនាញនៃសតវត្សរ៍ទី២១។ កិច្ចការទាំងអស់នេះនឹងសម្រេចបានតាមរយៈការអនុវត្តកម្មវិធីសិក្សាថ្មី ព្រមទាំងការអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា និងភាពជាដៃគូដែលអនុញ្ញាតឱ្យសិស្សបង្កើន និងបង្ហាញការសិក្សារបស់ខ្លួន។ គុណភាពនៃការអប់រំបច្ចេកទេសក៏នឹងត្រូវបានកែលម្អ តាមរយៈបច្ចុប្បន្នភាពកម្មវិធីសិក្សា ដើម្បីបំពេញតម្រូវការទីផ្សារការងារ រួមទាំងការឆ្លើយតបទៅនឹងបច្ចេកវិទ្យាបៃតង និងជំនាញឌីជីថលផងដែរ។ សិស្ស (មធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស) នឹងទទួលបានការគាំទ្របន្ថែមក្នុងទម្រង់នៃការណែនាំ និងការប្រឹក្សារបស់សាលារៀន ដើម្បីបង្កើនការអប់រំ និងការអភិវឌ្ឍផ្ទាល់ខ្លួនរបស់ពួកគេ។

ក្រសួងក៏នឹងបន្តគាំទ្រវិធីសាស្ត្រថ្មី រួមទាំងឧបករណ៍ឌីជីថល ដែលសមស្របនឹងបរិបទសិក្សាថ្មី (ដូចជាការរៀនតាមបែបឌីជីថល ឬពីចម្ងាយ) តាមរយៈការអភិវឌ្ឍការណែនាំគរុកោសល្យសម្រាប់គ្រូបង្រៀន និងការបណ្តុះបណ្តាលបន្ថែមសម្រាប់គ្រូបង្រៀន ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពលើវិធីសាស្ត្របង្រៀនបែបឌីជីថល។

ក្រសួងនឹងកែលម្អ និងពង្រឹងអភិបាលកិច្ចសាលារៀន និងគណនេយ្យភាពតាមរយៈការកសាងសមត្ថភាពអនុវត្តការគ្រប់គ្រងសាលារៀននៅកម្រិតមធ្យមសិក្សា តាមរយៈបទដ្ឋានគតិយុត្ត ការបណ្តុះបណ្តាល ការគាំទ្រ និងការពិនិត្យតាមដាន និងវាយតម្លៃ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះនឹងបំពេញបន្ថែមនូវតម្រូវការចាំបាច់សម្រាប់ការបង្កើតសាលារៀនគំរូ និងសាលារៀនជំនាន់ថ្មី ដោយមានការគាំទ្រពីប្រព័ន្ធធានាគុណភាពឱ្យកាន់តែប្រសើរឡើង។ យុទ្ធសាស្ត្រដែលលើកឡើងនេះ មិនគ្រាន់តែឆ្លើយតបដោយផ្ទាល់ទៅនឹងបញ្ហាប្រឈមដែលមានស្រាប់នោះទេ ប៉ុន្តែក៏បំពេញនូវតម្រូវការអប់រំនាពេលបច្ចុប្បន្ន និងគោលនយោបាយអប់រំរបស់រាជរដ្ឋាភិបាលអាណត្តិថ្មីផងដែរ។

យុទ្ធសាស្ត្រ និងសកម្មភាពគោល ដើម្បីជំរុញវត្ថុបំណងទាំងនេះ ត្រូវបានកំណត់ក្នុងតារាងខាងក្រោម៖

| **វត្ថុបំណងទី១៖ កែលម្អការចូលរៀន និងគង់វង្សក្នុងកម្រិតមធ្យមសិក្សាប្រកបដោយសមធម៌ និងបរិយាបន្ន** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| អត្រាឆ្លងភូមិសិក្សា | | |
| បឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ | ៨៣,៧% | ៩០,០% |

| | | |
|---|---|---|
| ប្រុស | ៨១,៤% | ៨៧,៧% |
| ស្រី | ៨៥,៩% | ៩២,២% |
| មធ្យមសិក្សាបឋមសិក្សាទៅមធ្យមសិក្សាទុតិយភូមិ | ៧៧,៦% | ៨៥,០% |
| ប្រុស | ៧៤,១% | ៨១,៥% |
| ស្រី | ៨០,៦% | ៨៨,០% |
| អត្រាគង់វង្ស | | |
| មធ្យមសិក្សាបឋមភូមិ | ៤៤,៣% | ៥១,៨% |
| ប្រុស | ៤៩,៦% | ៥៧,១% |
| ស្រី | ៣៩,៦% | ៤៧,១% |
| មធ្យមសិក្សាទុតិយភូមិ | ២៥,១% | ៣២,៦% |
| ប្រុស | ២៦,៩% | ៣៤,៤% |
| ស្រី | ២៣,៣% | ៣០,៨% |
| ចំនួនសិស្សក្រីក្រនៅមធ្យមសិក្សាទទួលបានអាហារូបករណ៍ | | |
| មធ្យមសិក្សាបឋមភូមិ | ១០២ ៣៥៩ | ១១៩ ៩៦១ |
| ស្រី | ៦១ ៤១៥ | ៧១ ៩៧៦ |
| មធ្យមសិក្សាទុតិយភូមិ | ១១ ១៦៧ | ១៣ ១១៧ |
| ស្រី | ៦ ៧០០ | ៧ ៨៧០ |
| ការអប់រំបច្ចេកទេស | ៥០៨ | ៣ ០០០ |
| ស្រី | ៣០៤ | ១ ០៥០ |
| ភាគរយមធ្យមសិក្សាបឋមភូមិអនុវត្តក្របខ័ណ្ឌកម្មវិធីសិក្សាពេញលេញ | N/A | ៧០,០% |
| ចំនួនសាលាមធ្យមសិក្សាអនុវត្តកម្មវិធីសុខភាពសិក្សា | ៧០ | ៦៧៦ |
| ភាគរយសាលាមធ្យមសិក្សាសាធារណៈមានទឹកស្អាត អនាម័យ និងបរិក្ខារផ្សេងៗទៀត | | |
| មធ្យមសិក្សាបឋមភូមិ | | |
| កម្រិត ៣ | ២,៧% | ៤,០% |
| បង្គន់អនាម័យ | ៩៩,៩% | ១០០% |
| ប្រអប់សង្គ្រោះបឋម | ៤៥,៣% | ១០០% |
| អគ្គិសនី | ៩៥,៩% | ១០០% |
| មធ្យមសិក្សាទុតិយភូមិ | | |
| កម្រិត ៣ | ៦,៩% | ១២,០% |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | |
|---|---|---|
| បង្គន់អនាម័យ | ១០០% | ១០០% |
| ប្រអប់សង្គ្រោះបឋម | ៧៨,១% | ១០០% |
| អគ្គិសនី | ៩៩,១% | ១០០% |
| ចំនួនមនុស្សវ័យជំទង់ និងយុវជនដែលទទួលបានការបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបចំណេះដឹងអំពីការថែរក្សាសុខភាពទាំងក្នុងនិងក្រៅប្រព័ន្ធ (អាយុពី១៥ ដល់ ២២ឆ្នាំ) | ៥០០០ | ៣០០០០ |
| ចំនួនបុគ្គលិកអប់រំដែលបានចូលរួមវគ្គបណ្តុះបណ្តាលបញ្ជ្រាបយេនឌ័រ | ៣០០ | ១៨០០ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** អនុវត្តវិធានការបង្កើនការចូលរួម និងកែលម្អការចូលរៀន និងការរក្សាសិស្សឱ្យបន្តរៀននៅមធ្យមសិក្សាបឋមភូមិ ជាពិសេសសម្រាប់ក្រុមជួបការលំបាក និងងាយរងគ្រោះ | **ការពង្រីកនិងកែលម្អបណ្តាញ**<br>- បង្កើត និងពង្រីកមធ្យមសិក្សាបឋមភូមិតាមតម្រូវការ ដោយផ្អែកលើទីតាំង និងប្រជាសាស្ត្រ<br>- ផ្តល់គ្រូបង្រៀនមុខវិជ្ជាឯកទេសសម្រាប់គ្រឹះស្ថានមធ្យមសិក្សាទាំងអស់ស្របតាមតម្រូវការជាក់ស្តែង តាមរយៈការអនុវត្តការដាក់ពង្រាយគ្រូបង្រៀន និងគោលការណ៍ជ្រើសរើសគ្រូបង្រៀន<br>- បង្កើតប្រព័ន្ធគ្រប់គ្រងការសិក្សានៅវិទ្យាល័យចំណេះទូទៅ និងអប់រំ-បច្ចេកទេស។<br>**ជំនួយហិរញ្ញវត្ថុ**<br>- បង្កើនអាហារូបករណ៍ និងថវិកាសម្រាប់សិស្សក្រីក្រ និងងាយរងគ្រោះ<br>- បង្កើនការផ្តល់អាហារូបករណ៍សម្រាប់សិស្សមានពិការភាពនៅវិទ្យាល័យអប់រំពិសេស។ |
| **យុទ្ធសាស្ត្រទី២៖** ពង្រឹកភាពជាដៃគូរវាងមធ្យមសិក្សា និងឧត្តមសិក្សា និងគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ វិស័យឯកជន និងសហគ្រាស ដើម្បីពង្រឹងវគ្គបណ្តុះបណ្តាលបច្ចេកទេស | **ភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការ**<br>- ពង្រីកភាពជាដៃគូរវាងគ្រឹះស្ថានសិក្សា និងមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ វិស័យឯកជន និងសហគ្រាសសម្រាប់ការអភិវឌ្ឍជំនាញ<br>- ពង្រឹងកិច្ចសហការរវាងសាលារៀន និងភាគីពាក់ព័ន្ធ ដើម្បីកែលម្អការអភិវឌ្ឍសាលារៀន។<br>**ការផ្តល់ការបណ្តុះបណ្តាល**<br>- ផ្តល់សេវាបណ្តុះបណ្តាលជំនាញទាក់ទងនឹងមុខរបរខ្នាតតូច និងមធ្យម |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - លើកកម្ពស់ការអនុវត្តឱកាសការសិក្សាផ្អែកលើការងារ កម្មសិក្សា ទស្សនកិច្ចសិក្សា និងការចែករំលែកបទពិសោធន៍ជាមួយភាគីពាក់ព័ន្ធ។ |
| **យុទ្ធសាស្ត្រទី៣៖** កែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្ភារបរិក្ខារសម្រាប់គ្រឹះស្ថានមធ្យមសិក្សា និងសាលារៀន | **ហេដ្ឋារចនាសម្ព័ន្ធ**<br>- ពង្រីកហេដ្ឋារចនាសម្ព័ន្ធសម្រាប់មធ្យមសិក្សាបឋមភូមិ និងវិទ្យាល័យចំណេះទូទៅ និងការអប់រំបច្ចេកទេស ដោយអនុលោមតាមភាពធន់របស់សាលារៀន ការប្រែប្រួលអាកាសធាតុ បរិយាបន្ន និងផ្អែកលើតម្រូវការភូមិសាស្ត្រ និងប្រជាសាស្ត្រ<br>- សាងសង់អគារសិក្សា បណ្ណាល័យ អគារធនធាន កន្លែងលាងដៃ បន្ទប់ទឹក កន្លែងស្នាក់នៅរបស់គ្រូបង្រៀន អន្តេវាសិកដ្ឋាន កសិដ្ឋាន រោងជាង បន្ទប់ពហុបំណង និងទីលានកីឡា។<br>**សម្ភារបរិក្ខារ**<br>- កែលម្អ និងបំពាក់ឧបករណ៍អនាម័យ នឹងកន្លែងលាងសម្អាតដៃ ទឹកស្អាត និងបរិស្ថានសាលារៀន ស្របតាមគោលការណ៍ណែនាំអនុវត្តនៃលក្ខខណ្ឌអប្បបរមាស្ដីពីទឹកស្អាត និងអនាម័យ នៅតាមសាលារៀន<br>- ពង្រីកការប្រើប្រាស់បណ្តាញអគ្គិសនី និងអ៊ីនធឺណិត នៅតាមសាលារៀន<br>- ពង្រីកបន្ទប់សុខភាពសិក្សាសម្រាប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ<br>- ផ្តល់សម្ភារ និងឧបករណ៍សម្រាប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស រួមទាំងបន្ទប់កុំព្យូទ័រ មន្ទីរពិសោធន៍វិទ្យាសាស្ត្រ និងការផ្គត់ផ្គង់សម្ភារ បណ្ណាល័យស្តង់ដា និងថ្នាក់រៀនឆ្លាតវៃ ជាមួយនឹងឧបករណ៍សិក្សាទំនើបៗ។ |
| **យុទ្ធសាស្ត្រទី៤៖** លើកកម្ពស់សុខភាពសាលារៀននៅកម្រិតមធ្យមសិក្សា | **សកម្មភាពក្នុងសាលារៀន**<br>- ពង្រឹងការអនុវត្តស្តង់ដាទឹកស្អាត និងអនាម័យ នៅតាមសាលារៀន សុវត្ថិភាពចំណីអាហារ និងអាហារូបត្ថម្ភ រួមទាំងអនាម័យទូទៅ អនាម័យរាងកាយ អនាម័យមាត់ធ្មេញ និងការលាងសម្អាតដៃ ការអប់រំពីមេរោគអេដស៍/ជំងឺអេដស៍ សុខភាពផ្លូវភេទគ្រប់ជ្រុងជ្រោយ និងការគ្រប់គ្រងអនាម័យពេលមករដូវរបស់ស្ត្រី<br>- អនុវត្តយុទ្ធនាការសាលារៀនស្អាត គ្មានសំរាម បរិស្ថានស្អាត ការអប់រំពីមេរោគអេដស៍/ជំងឺអេដស៍ សុខភាពផ្លូវភេទគ្រប់ជ្រុងជ្រោយ  សាលារៀន |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | គ្មានគ្រឿងស្រវឹង គ្មានគ្រឿងញៀន គ្មានថ្នាំជក់ និងមិនប្រើប្រាស់ផលិតផលប្លាស្ទិក។ល។<br>- ពង្រីកបន្ទប់ថែទាំសុខភាពដោយបំពាក់នូវសម្ភារ និងឧបករណ៍ចាំបាច់អប្បបរមា ក៏ដូចជាការផ្តល់ឧបករណ៍សង្គ្រោះបឋម និងឧបករណ៍ការពារសម្រាប់ជំងឺរាតត្បាតសកល<br>- ផ្សព្វផ្សាយកម្មវិធីផ្តល់អាហារដល់សាលារៀនសម្រាប់មធ្យមសិក្សាបឋមភូមិ តាមរយៈការរៀបចំគោលការណ៍ណែនាំស្តីពីការផ្តល់អាហារតាមសាលារៀន និងលើកទឹកចិត្តឱ្យសាលារៀនស្ម័គ្រចិត្តអនុវត្តកម្មវិធីផ្តល់អាហារ<br>- ពង្រីកកម្មវិធីអប់រំសុខភាពយ៉ាងទូលំទូលាយ ស្របតាមស្តង់ដាសាលារៀនគំរូ<br>- អនុវត្តការអប់រំកាយ និងកីឡា ស្របតាមគោលការណ៍ណែនាំ។<br>**ការពង្រីកសេវាសុខភាព**<br>- លើកកម្ពស់វិសាលភាពអប់រំផ្លូវភេទដល់សិស្សានុសិស្ស និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសមភាពនិងសមធម៌យេនឌ័រ អំពើហិង្សាទាក់ទងនឹងយេនឌ័រ សុខភាពបន្តពូជនិងសុខភាពផ្លូវភេទ អាកប្បកិរិយាស្វែងរកសេវាសុខភាព ផែនការគ្រួសារ សុខភាពមាតានិងទារក និងអាហារូបត្ថម្ភ តាមរយៈសកម្មភាព យុទ្ធនាការ ប្រព័ន្ធសារព័ត៌មាន និងសិក្ខាសាលា តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលដើម្បីបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំឆ្នាំ២០២១-២០២៥ តាមរាជធានី ខេត្ត<br>- ពង្រីកវិសាលភាព នៃការពិនិត្យសុខភាព រួមទាំងការពិនិត្យភ្នែក ការស្តារឡើងវិញនូវគំហើញ ការស្តាប់ និងការព្យាបាល និងការគណនាសិស្សលើសទម្ងន់ ឬកង្វះអាហារូបត្ថម្ភ<br>- ពង្រីកការថែទាំសុខភាព សុវត្ថិភាពក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ រួមមានទឹកជំនន់ ការកើនឡើងសីតុណ្ហភាព ជំងឺឆ្លង<br>- សហការជាមួយមណ្ឌលសុខភាព ក្នុងការផ្តល់សេវាថែទាំសុខភាពបឋម ដូចជា ការពិនិត្យសុខភាព ឱសថ សេវាប្រឹក្សាសុខភាពផ្លូវចិត្ត និងការគាំទ្រសម្រាប់អ្នកផ្ទុកមេរោគអេដស៍ ឬជំងឺផ្សេងទៀត |

| | |
|---|---|
| | **ការបណ្តុះបណ្តាលគ្រូនិងការគាំទ្រ**<br>- ពង្រឹងសមត្ថភាពយុវជន តាមរយៈការអប់រំនិងការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងពង្រឹងភាពអង់អាចដល់យុវជននិងស្ត្រី តាមរយៈការលើកកម្ពស់ការចូលរួមជាមន្ត្រីរាជការក្នុងមុខតំណែង និងចូលរួមក្នុងកិច្ចការសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ តាមរយៈការជំរុញភាគីពាក់ព័ន្ធ ដូចជាគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព និងគណៈ-កម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ ឱ្យចូលរួមក្នុងសកម្មភាពនានា និងចូលរួមទទួលការបណ្តុះបណ្តាល តាមរយៈសកម្មភាពបង្កើនការបញ្ជ្រាបចំណេះដឹងស្តីពី ការថែរក្សាសុខភាពកម្រិតបុគ្គលិកអប់រំ និងសិស្សានុសិស្ស<br>- ពង្រីកវគ្គបណ្តុះបណ្តាលមន្ត្រីសុខភាពសិក្សាតាមសាលារៀនចាប់ពីថ្នាក់ខេត្តដល់គ្រឹះស្ថានសិក្សាស្តីពីការអប់រំសុខភាព<br>- បំប៉នគ្រូបង្រៀនពីរបៀបការប្រើប្រាស់សៀវភៅអប់រំសុខភាពពីថ្នាក់ទី៧ ដល់ទី១២<br>- បោះពុម្ពសៀវភៅអប់រំសុខភាព និងសៀវភៅណែនាំសម្រាប់គ្រូបង្រៀន និងសិស្សចាប់ពីថ្នាក់ទី៧ដល់ទី១២។ |

| **វត្ថុបំណងទី២៖ លើកកម្ពស់គុណភាពអប់រំស្របតាមជំនាញនៃសតវត្សរ៍ទី២១** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនសាលាមធ្យមសិក្សាអនុវត្តសកម្មភាពក្រៅម៉ោងសិក្សា | ១៥ | ១០០ |
| ចំនួនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស មានអនុស្សារណៈយោគយល់គ្នារវាងភាពជាដៃគូជាមួយសហគ្រាស | N/A | ៨ |

| **យុទ្ធសាស្ត្រ** | **សកម្មភាពគោល** |
|---|---|
| **យុទ្ធសាស្ត្រទី១៖** អនុវត្តកម្មវិធីសិក្សាថ្មី រួមទាំងការពង្រីកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា និងភាសាបរទេស ដើម្បីបំពេញក្របខ័ណ្ឌជំនាញនៃសតវត្សរ៍ទី ២១ | **កម្មវិធីសិក្សា និងសៀវភៅសិក្សា**<br>- ពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល និងឯកសារគរុកោសល្យផ្សេងទៀតសម្រាប់ការបង្រៀន និងរៀន (ព្រមទាំងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ បច្ចេកវិទ្យាបៃតង និងឌីជីភាវូបនីយកម្ម) និងបង្កើតក្របខ័ណ្ឌវាយតម្លៃកម្មវិធីសិក្សា |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - លើកកម្ពស់អក្ខរកម្មឌីជីថល និងអភិវឌ្ឍខ្លឹមសារ និងវេទិកាតាមរយៈការអនុវត្តប្រព័ន្ធគ្រប់គ្រងការសិក្សា<br>- បង្កើនការផ្គត់ផ្គង់សៀវភៅសិក្សាគោលសម្រាប់សិស្សថ្នាក់មធ្យមសិក្សាទុតិយភូមិទូទាំងប្រទេស<br>- ពង្រីកការបង្រៀនភាសាបរទេស<br>- អភិវឌ្ឍកម្មវិធីសិក្សា សៀវភៅសិក្សា និងសម្ភារសិក្សាជាអក្សរប្រៃយ៍ និងភាសាសញ្ញា<br>- អនុវត្តក្របខ័ណ្ឌ វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា នៅតាមសាលារៀន<br>- ផ្សព្វផ្សាយកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និងឯកសារគរុកោសល្យ ទៅដល់គ្រប់សាលាមធ្យមសិក្សាទូទាំងប្រទេស និងភាគីពាក់ព័ន្ធទាំងអស់<br>- បំប៉នសមត្ថភាពគ្រូបង្រៀនឱ្យមានបំណិនប្រើប្រាស់កម្មវិធីសិក្សា សៀវភៅសិក្សាគោល វិធីសាស្ត្របង្រៀន និងឯកសារគរុកោសល្យផ្សេងៗទៀត ឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព<br>- បញ្ជ្រាបកម្មវិធីសិក្សាកម្រិតមធ្យមសិក្សាពាក់ព័ន្ធនឹងគំនិតច្នៃប្រឌិត និងការបង្កើតថ្មី។<br>**កម្មវិធីសិក្សាបន្ថែម**<br>- បង្កើតសកម្មភាពក្រៅម៉ោងសិក្សា និងការអប់រំបំណិនជីវិត ការប្រឡងអំណាន ក្លឹបសិក្សាប្រកបដោយបរិស្ថាន/សកម្មភាពសិក្សា ការអប់រំសិល្បៈនៅមធ្យមសិក្សា ដើម្បីឆ្លើយតបទៅនឹងជំនាញសតវត្សរ៍ទី២១ ដូចជាការសរសេរកូដ ភាសា ក្លឹបសិក្សាទស្សនកិច្ចសិក្សា ការសិក្សាផ្អែកតាមការងារ និងបែបគម្រោង<br>- បន្តពង្រីក និងពង្រឹងក្លឹបសិក្សាសម្រាប់អនុវត្តសកម្មភាពក្រៅម៉ោងសិក្សានៅមធ្យមសិក្សា<br>- ពង្រីកកម្មវិធីមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា ចាប់ផ្តើមពីថ្នាក់ទី ៧ និងរួមទាំងការតម្រង់ទិសទៅរកការអប់រំស្វែម និងអាជីពនាពេលអនាគត<br>- ពង្រីកកម្មវិធីអប់រំបំណិនជីវិតមូលដ្ឋាន នៅកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - ពង្រីកការងារស្ម័គ្រចិត្តសម្រាប់សហគមន៍ខ្ញុំ នៅតាមមធ្យមសិក្សាទុតិយភូមិដែលបំពេញបន្ថែមទៅនឹងកម្មវិធីអប់រំបំណិនជីវិតមូលដ្ឋាន ដែលត្រូវអនុវត្តនៅតាមមធ្យមសិក្សាបឋមភូមិ។<br>**ភាពជាដៃគូ**<br>- សហការជាមួយក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងវិស័យឯកជន ដើម្បីរៀបចំសកម្មភាពក្នុងគោលបំណងលើកកម្ពស់ការអប់រំស្ទែម និងលើកកម្ពស់ទេពកោសល្យឌីជីថលនៅមធ្យមសិក្សា<br>- លើកកម្ពស់ការអប់រំបំណិនជីវិតមូលដ្ឋាន សកម្មភាពបរិស្ថាន និងអាកាសធាតុ និងភាពជាសហគ្រិននៅតាមមធ្យមសិក្សា តាមរយៈគម្រោងសហគមន៍ឈានមុខរបស់សិស្ស ជាពិសេសសិស្សស្រី រួមទាំងការអនុវត្តកម្មវិធីអប់រំបំណិនជីវិតមូលដ្ឋាន និងការងារស្ម័គ្រចិត្តសម្រាប់សហគមន៍ខ្ញុំ<br>- ផ្លាស់ប្តូរឧត្តមានុវត្តន៍ការអប់រំបំណិនជីវិតមូលដ្ឋាន តាមរយៈយុទ្ធសាស្ត្រភាពជាដៃគូ (សាលារៀននិងសាលារៀន និងខេត្ត និងខេត្ត)។<br>**ការគាំទ្រសិស្ស**<br>- ពង្រីកកម្មវិធីមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា និងកម្មវិធីត្រីវិស័យ ដើម្បីបង្កើនជំនាញសម្រាប់ការស្វែងរកការងារ និងគាំទ្រដល់ការអប់រំ និងការអភិវឌ្ឍផ្ទាល់ខ្លួនរបស់សិស្ស។<br>**ការគាំទ្រសាលារៀន**<br>- បន្តអនុវត្តស្វ័យវាយតម្លៃសាលារៀន និងឆ្លុះបញ្ចាំងសម្រាប់ការកែលម្អ<br>- ពង្រឹងគណៈកម្មការគ្រប់គ្រងសាលារៀន និងបុគ្គលិកអប់រំស្តីពីកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និងការវាយតម្លៃកម្មវិធីសិក្សា។ |
| **យុទ្ធសាស្ត្រទី២៖** ពង្រីកការអប់រំបច្ចេកទេស ដែលតម្រង់ទិសទៅរកអាជីព និងការបង្កើនប្រាក់ចំណូល | **ការគាំទ្រសិស្ស**<br>- បង្កើនចំនួនសិស្ស និងថវិកាអាហារូបករណ៍សម្រាប់ការអប់រំបច្ចេកទេស<br>- ផ្តល់ឱកាសសិក្សាផ្អែកលើការងារ កម្មសិក្សា និងដំណើរទស្សនកិច្ចសិក្សាសម្រាប់សិស្ស ដើម្បីធ្វើការក្នុងវិស័យឧស្សាហកម្ម |

- រៀបចំពិព័រណ៍សិស្សនៅវិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេស។

**ហេដ្ឋារចនាសម្ព័ន្ធ និងស្តង់ដា**

- ប្រែក្លាយសាលាមធ្យមសិក្សាទុតិយភូមិទៅជាវិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេស ដោយការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសាលារៀនឱ្យស្របតាមស្តង់ដាវិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេស
- បំពាក់ឧបករណ៍បច្ចេកទេសសម្រាប់ដំណើរការបង្រៀន និងរៀន
- បន្តអនុវត្តស្តង់ដាគ្រឹះស្ថានអប់រំបច្ចេកទេស។

**កម្មវិធីសិក្សា**

- អនុវត្តកម្មវិធីអប់រំសហគ្រិនភាព និងកម្មវិធីជំនាញបង្កើនប្រាក់ចំណូលនៅវិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេស
- ធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សាអប់រំបច្ចេកទេស និងសៀវភៅសិក្សាដើម្បីឱ្យស្របទៅនឹងទីផ្សារការងារ ក្នុងការឆ្លើយតបទៅនឹងបច្ចេកវិទ្យាបៃតង និងជំនាញឌីជីថល
- អភិវឌ្ឍ និងអនុវត្តកម្មវិធីសិក្សាផ្អែកលើការងារ
- ជំរុញការអនុវត្តជំនាញទន់ និងមូលដ្ឋានគ្រឹះផលិតកម្មនៅវិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេស
- អភិវឌ្ឍជំនាញថ្មីនៅវិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេស។

**គ្រូបង្រៀន**

- ជ្រើសរើសគ្រូបង្រៀនសម្រាប់ការអប់រំបច្ចេកទេស
- ផ្តល់ការបណ្តុះបណ្តាល ដើម្បីអភិវឌ្ឍសមត្ថភាពដល់គ្រូបង្រៀនអប់រំបច្ចេកទេស និងគ្រូឧទ្ទេស
- ប្រែក្លាយវិទ្យាស្ថានបច្ចេកវិទ្យាទៅជាវិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀនបច្ចេកទេស
- អភិវឌ្ឍឯកសារពាក់ព័ន្ធស្តីពីការអប់រំក្រមសីលធម៌ សុជីវធម៌ចរិយាធម៌ សុភាវធម៌ ឯកសារប្រតិបត្តិ និងឯកសារជំនួយស្មារតីដទៃទៀត ដើម្បីពង្រឹងការអនុវត្តកម្មវិធីសិក្សាឱ្យមានប្រសិទ្ធភាព
- បំប៉នសមត្ថភាពគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន ដើម្បីអនុវត្តកម្មវិធីក្រៅម៉ោងសិក្សា។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | **ភាពជាដៃគូ**<br>- សហការជាមួយវិស័យឯកជន ដើម្បីរៀបចំអនុស្សារណៈ-យោគយល់គ្នា សម្រាប់គាំទ្រដល់វិស័យសហគ្រិនភាព<br>- សហការជាមួយវិទ្យាស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សាកលវិទ្យាល័យ វិស័យឯកជន និងដៃគូអភិវឌ្ឍ ដើម្បីកំណត់តម្រូវការទីផ្សារការងារ<br>- ពង្រឹងកម្មវិធីកម្មសិក្សានិងទស្សនកិច្ចសិក្សារបស់សិស្សអប់រំបច្ចេកទេស។<br>**ការគ្រប់គ្រងព័ត៌មាន**<br>- បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ការអប់រំបច្ចេកទេស។ |
| **យុទ្ធសាស្ត្រទី៣៖** គាំទ្រដល់វិធីសាស្ត្រសិក្សាថ្មី រួមទាំងឧបករណ៍ឌីជីថល ដែលសមស្របនឹងបរិបទសិក្សាថ្មី | **ការណែនាំគរុកោសល្យ**<br>- អនុវត្តការរៀនពីចម្ងាយដោយប្រើសម្ភារដូចជាសន្លឹក កិច្ចការ និងទម្រង់ហ្គូហ្គល និងបញ្ចូលខ្លឹមសារមេរៀនទៅក្នុងតេឡេក្រាម<br>- អនុវត្តវិធីសាស្ត្របង្រៀនថ្មីដូចជា វិធីសាស្ត្របង្រៀនតាមបែបថ្នាក់រៀនត្រឡប់ ការសិក្សាផ្អែកលើការស្រាវជ្រាវ ការសិក្សាតាមបែបគម្រោង ការសិក្សាតាមបែបរិះរក ការសិក្សាផ្អែកលើបញ្ហា និងការសិក្សាតាមបែបបញ្ញត្តិ<br>- រៀបចំគោលការណ៍ណែនាំទូទៅ និងនីតិវិធីប្រតិបត្តិលើការអនុវត្តកម្មវិធីសិក្សាថ្មី<br>- ផ្សព្វផ្សាយកម្មវិធីតម្រង់ទិសសិក្សា (មគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សាតាមប្រព័ន្ធអនឡាញ)។<br>**ការបណ្តុះបណ្តាល**<br>- អភិវឌ្ឍសមត្ថភាពដោយមានការទទួលស្គាល់គ្រូឧទ្ទេសថ្នាក់ជាតិ ដើម្បីពង្រឹងការអនុវត្តកម្មវិធីសិក្សាថ្មី វិធីសាស្ត្របង្រៀន និងការផលិតសម្ភារបង្រៀន<br>- ដាក់ឱ្យអនុវត្តសម្រាប់មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យ ដើម្បីលើកកម្ពស់គុណភាពនៃការបង្រៀន និងរៀន។ |

| វត្ថុបំណងទី៣៖ កែលម្អភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចសាលារៀន | | |
|---|---|---|
| សូចនាករផលសម្រេច | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
| ចំនួនសាលារៀនដែលមានគណៈកម្មការគ្រប់គ្រងសាលារៀនសកម្ម (ប្រជុំយ៉ាងតិច ៧ដង ក្នុងមួយឆ្នាំ) | N/A | ១ ៩២៣ |
| ចំនួនសាលារៀនជំនាន់ថ្មី | ៧ | ២៥ |
| ចំនួនសាលាមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស | ១៩ | ២៥ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** អនុវត្តអភិក្រមការគ្រប់គ្រងនៅតាមកម្រិតសាលារៀន | **បទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំ**<br>- ធ្វើបច្ចុប្បន្នកម្មឯកសារគតិយុត្ត និងពង្រឹងការគ្រប់គ្រងសាលារៀន<br>- អភិវឌ្ឍឯកសារបណ្តុះបណ្តាលស្តីពី អភិបាលកិច្ចល្អសម្រាប់ពង្រឹងការផ្តល់សេវាអប់រំ<br>- បង្កើតក្រុមការងារលើកកម្ពស់ការគាំទ្រ ការអនុវត្ត ការងារគណនេយ្យភាពសង្គម និងអភិបាលកិច្ចសាលារៀននៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>- ផ្សព្វផ្សាយព័ត៌មានជាសាធារណៈស្តីពីគោលការណ៍អភិបាលកិច្ចនៅកម្រិតសាលារៀន<br>- រៀបចំគោលការណ៍ណែនាំសម្រាប់ការអនុវត្តតេស្តស្តង់ដានៅមធ្យម-សិក្សា។<br>**ការបណ្តុះបណ្តាល និងការគាំទ្រ**<br>- បង្កើតក្រុមបច្ចេកទេសមធ្យមសិក្សា និងក្រុមចុះជួយគាំទ្រដល់សាលារៀន<br>- រៀបចំ និងកែលម្អឯកសារបណ្តុះបណ្តាលសម្រាប់ប្រធានកម្រង និងបណ្តុះបណ្តាលគណៈគ្រប់គ្រងសាលារៀន<br>- ផ្តល់ការបណ្តុះបណ្តាលដល់ប្រធានក្រុមកម្រង និងគណៈគ្រប់គ្រងសាលារៀនដែលត្រូវបានតែងតាំង<br>- រៀបចំឯកសារវិក្រឹតការ សម្រាប់បណ្តុះបណ្តាលគណៈគ្រប់គ្រងសាលារៀន<br>- ធ្វើវិក្រឹតការយៈពេលមធ្យមដល់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន<br>- ជំរុញការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការអនុវត្តគន្លងអាជីពគ្រូបង្រៀន។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | **ការពិនិត្យតាមដាន និងវាយតម្លៃ**<br>- រៀបចំបណ្ណព័ត៌មានសាលារៀន<br>- អនុវត្តកំណែទម្រង់សាលារៀន តាមរយៈការពង្រឹងការពិនិត្យតាមដាន និងវាយតម្លៃ និងស្វ័យវាយតម្លៃសាលារៀន<br>- បន្តអនុវត្តការប្រឡងប្រណាំងជ្រើសរើសនាយកសាលាល្អ គ្រូបង្រៀនល្អ និងសាលារៀនល្អ<br>- ផ្តល់រង្វាន់ដល់គណៈគ្រប់គ្រងសាលារៀនដែលសម្រេចបាននូវចំណុចដៅនៃសូចនាករក្នុងកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ និងពិចារណាសម្រាប់គន្លងអាជីព<br>- ពិនិត្យឡើងវិញនូវមុខងារនៅកម្រិតសាលារៀន<br>- រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រដោះស្រាយបញ្ហាដែលបានរកឃើញតាមរយៈលទ្ធផលតេស្តវាយតម្លៃ ដើម្បីកែលម្អគុណភាពអប់រំ<br>- អនុវត្តស្តង់ដាសាលារៀនគំរូ និងស្វ័យវាយតម្លៃសាលារៀន។<br>**ភាពជាដៃគូ**<br>- អនុវត្តយុទ្ធសាស្ត្រភាពជាដៃគូរវាងសាលារៀននិងសាលារៀន និងខេត្តនិងខេត្ត<br>- ជំរុញការអភិវឌ្ឍការអប់រំមធ្យមសិក្សា តាមរយៈការស្វែងរកកិច្ចសហការភាពជាដៃគូវិនិយោគជាមួយវិស័យសាធារណៈ និងឯកជន និងដៃគូអភិវឌ្ឍ។ |
| **យុទ្ធសាស្ត្រទី២៖** បង្កើតសាលារៀនគំរូ និងសាលារៀនជំនាន់ថ្មី | **បទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំ**<br>- រៀបចំឯកសារគតិយុត្តសម្រាប់អនុវត្តសាលារៀនគំរូ និងសាលារៀនជំនាន់ថ្មី<br>- រៀបចំយន្តការគាំទ្ររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដើម្បីជួយដល់សាលារៀនគំរូ<br>- រៀបចំ «**គោលការណ៍ណែនាំស្តីពីសាលារៀនគំរូ**» ដើម្បីពង្រឹងសាលារៀនគំរូដែលមានស្រាប់ និងពង្រីកសាលាធម្មតាឱ្យក្លាយជាសាលារៀនគំរូ។<br>**ការគ្រប់គ្រងសាលារៀន**<br>- បង្កើនស្វ័យភាព និងសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅកម្រិតសាលារៀន តាមរយៈគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន និងតាមរយៈការកែលម្អសាលារៀន និងថ្នាក់រៀន ការរៀបចំផែនការ និងកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - បង្កើនការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល សិស្ស និងភាគីពាក់ព័ន្ធផ្សេងទៀតក្នុងការគ្រប់គ្រងសាលារៀន ដើម្បីផ្តល់ព័ត៌មាន ជួយគ្នាទៅវិញទៅមក និងអភិវឌ្ឍសាលារៀនគំរូ។<br>**គណនេយ្យភាពរបស់សាលារៀន**<br>- វាយតម្លៃសមត្ថភាពរបស់សិស្សតាមរយៈការធ្វើតេស្តប្រកបដោយតម្លាភាព គាំទ្រការបង្រៀននិងរៀន និងរៀបចំថ្នាក់រៀនដើម្បីជួយសិស្សរៀនយឺត ដោយផ្តោតលើសិស្សដែលមានអក្ខរកម្ម និងលេខនព្វន្តនៅមានកម្រិត<br>- កែលម្អគណនេយ្យភាពរបស់សាលារៀន តាមរយៈការប្រកាសលទ្ធផលប្រឡងជាសាធារណៈ លទ្ធផលប្រចាំឆ្នាំ ចំណូល និងចំណាយរបស់សាលារៀន និងស្តង់ដាសាលារៀនគំរូ។<br>**ភាពជាដៃគូ**<br>- លើកទឹកចិត្តសហគមន៍ឱ្យចូលរួមក្នុងការសាងសង់ និងជួសជុលអគារសិក្សា តាមរយៈការធ្វើអាទិភាពភាវូបនីយកម្មថវិកាជាតិសម្រាប់ការសាងសង់ផ្ទះគ្រូបង្រៀននៅតំបន់ដាច់ស្រយាល និងជួបការលំបាក។ |
| **យុទ្ធសាស្ត្រទី៣៖** ពង្រឹងការគាំទ្រ និងការត្រួតពិនិត្យសាលារៀន និងគណៈគ្រប់គ្រងសាលារៀន រួមមាន ស្វ័យ-វាយតម្លៃ និងការអភិវឌ្ឍក្របខ័ណ្ឌធានាគុណភាពអប់រំ | **ការអភិវឌ្ឍប្រព័ន្ធ**<br>- អភិវឌ្ឍ និងអនុវត្តក្របខ័ណ្ឌធានាគុណភាពសាលារៀន រួមទាំងតួនាទីរបស់ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ<br>- អភិវឌ្ឍប្រព័ន្ធបង្វឹក និងប្រឹក្សាយោបល់ សម្រាប់ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ<br>- រៀបចំសៀវភៅគណៈកម្មការគ្រប់គ្រងសាលារៀន<br>- រៀបចំតេស្តស្តង់ដាសម្រាប់កម្រិតសាលារៀន។<br>**ការបណ្តុះបណ្តាល**<br>- ផ្សព្វផ្សាយស្តីពីគោលការណ៍អភិបាលកិច្ចល្អសម្រាប់ពង្រឹងការផ្តល់សេវាអប់រំនៅកម្រិតសាលារៀន<br>- អភិវឌ្ឍសមត្ថភាពក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ<br>- អភិវឌ្ឍកម្មវិធីសិក្សាទំនើបសម្រាប់បណ្តុះបណ្តាលអធិការអប់រំ<br>- ផ្តល់ការបណ្តុះបណ្តាលដល់គ្រូឧទ្ទេស និងអធិការថ្នាក់ជាតិ ដើម្បីលើកកម្ពស់ការគ្រប់គ្រង និងការបំពេញការងារនៅសាលារៀនមធ្យមសិក្សា |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - អភិវឌ្ឍសមត្ថភាពគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងភាគីពាក់ព័ន្ធស្តីពីការអប់រំបរិយាបន្ននៅកម្រិតមធ្យមសិក្សា។<br>**ការធានាគុណភាព**<br>- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការអប់រំបរិយាបន្ននៅគ្រឹះស្ថានមធ្យមសិក្សា<br>- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្ត កម្មវិធីអភិបាលកិច្ចល្អគ្រឹះស្ថានមធ្យមសិក្សា<br>- ធ្វើអធិការកិច្ច ដើម្បីពង្រឹងគុណភាពអប់រំ<br>- ពង្រឹងអធិការកិច្ច តាមរយៈការអនុវត្តកម្មវិធីសិក្សា ដោយផ្តោតលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា<br>- អនុវត្តការធ្វើតេស្តវាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ<br>- ផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផលសិក្សាប្រចាំខែ ឆមាស និងប្រចាំឆ្នាំរបស់សិស្ស។ |
| **យុទ្ធសាស្ត្រទី៤៖** លើកកម្ពស់ភាពជាដៃគូរវាងសាលារៀន វិស័យឯកជន ដៃគូអភិវឌ្ឍ និងសហគមន៍ | **កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ**<br>- បង្កើនកិច្ចសហការរវាងសាលារៀន និងវិស័យឯកជន និងសហគមន៍ ដើម្បីផ្តល់កម្មសិក្សាដល់សិស្ស ក៏ដូចជាគ្រូឧទ្ទេសមកពីវិស័យឯកជន ដើម្បីបង្រៀនជំនាញបច្ចេកទេស នៅតាមសាលារៀន<br>- លើកទឹកចិត្តឱ្យវិស័យឯកជនផ្តល់ជាតុចូលដល់កម្មវិធីបណ្តុះបណ្តាល និងរៀបចំពិព័រណ៍ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យត្រូវទៅនឹងតម្រូវការពីវិស័យនានា<br>- លើកទឹកចិត្តដល់បុគ្គលដែលមានជំនាញ និងសមត្ថភាពតាមសហគមន៍ ដើម្បីចែករំលែកឧត្តមានុវត្តន៍នៅតាមសាលារៀន<br>- ពង្រឹងគណៈកម្មការគ្រប់គ្រងសាលារៀននៅមធ្យមសិក្សាបឋមភូមិ និងការចូលរួមរបស់មាតាបិតាក្នុងការអភិវឌ្ឍមធ្យមសិក្សាបឋមភូមិ<br>- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន និងដៃគូអភិវឌ្ឍ ក្នុងការវិនិយោគលើវិស័យអប់រំមធ្យមសិក្សា<br>- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីទប់ស្កាត់យុវជនទំនើង អំពើហិង្សា ការប្រើប្រាស់គ្រឿងញៀន បទល្មើសផ្សេងៗ ការលើកកម្ពស់សុវត្ថិភាព និងការអភិវឌ្ឍមធ្យមសិក្សា<br>- លើកកម្ពស់ភាពជាដៃគូរវាងវិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេស និងភាគីពាក់ព័ន្ធ និងវិស័យឯកជនដើម្បីគាំទ្រការអប់រំ។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៣.៤ កម្មវិធីអាទិភាពទី២៖ ការកែលម្អការចូលរៀន គុណភាព និងឆ្លើយតបនៃការអប់រំឧត្តមសិក្សា និងការស្រាវជ្រាវ និងនវានុវត្តន៍

**កម្មវិធីអាទិភាពទី២**
**ការកែលម្អការចូលរៀន គុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា និងការស្រាវជ្រាវនិងនវានុវត្តន៍**

**ការអប់រំឧត្តមសិក្សា**
និស្សិតបញ្ចប់ការសិក្សាមានសមត្ថភាពឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច

**ការស្រាវជ្រាវ និងនវានុវត្តន៍**
ផលិតផលចេញពីការស្រាវជ្រាវផ្សារភ្ជាប់នឹងតម្រូវការទីផ្សារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច

### ៣.៤.១ អនុកម្មវិធី២.១៖ ការអប់រំឧត្តមសិក្សា

**លទ្ធផលរំពឹងទុករបស់អនុកម្មវិធី៖ និស្សិតបញ្ចប់ការសិក្សាមានសមត្ថភាព ឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច**

| សូចនាករផលសម្រេច | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
|---|---|---|
| ភាគរយនិស្សិតបញ្ចប់ការសិក្សាពីកម្រិតបរិញ្ញាបត្រមានការងារធ្វើក្រោយបញ្ចប់ការសិក្សារយៈពេល១ឆ្នាំ | N/A | ៧៥,0% |

**បញ្ហាប្រឈមគន្លឹះៗ៖**

- ការចុះឈ្មោះចូលរៀននៅឧត្តមសិក្សាបានកើនឡើង ៣ ភាគរយ (១៥ ភាគរយ ក្នុងឆ្នាំ ២០២៣ ធៀបនឹង ១២ ភាគរយ ក្នុងឆ្នាំ ២០១៩) ដែលយុវជនមានអាយុចូលរៀននៅឧត្តមសិក្សាតែ ៦ភាគរយបានប្រឡងជាប់បាក់ឌុបនៅឆ្នាំ ២០២២។ ទោះបីមានអាហារូបករណ៍ត្រូវបាន ផ្តល់ជូននិស្សិតប៉ុន្តែអត្រាបោះបង់ការសិក្សាមានកម្រិតខ្ពស់ (៥៨ ភាគរយ) ដោយសារប្រាក់ឧបត្ថម្ភប្រចាំខែមានចំនួនតិចតួច សម្រាប់ការចំណាយរបស់និស្សិត និងទទួលបានតែនិស្សិតមួយចំនួនតូចប៉ុណ្ណោះ។ កត្តានេះ ទាមទារឱ្យមានយន្តការគាំទ្រនៅតាមគ្រឹះស្ថានឧត្តមសិក្សា ដើម្បីអាចរក្សានិស្សិត អាហារូបករណ៍
- គ្រឹះស្ថានឧត្តមសិក្សានៅ ខ្វះខាតហេដ្ឋារចនាសម្ព័ន្ធរឹង និងឌីជីថលចាំបាច់ ដើម្បីពង្រីកការចូលរៀន និងសមធម៌នៅឧត្តមសិក្សា

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ទោះបីជាកម្មវិធីអប់រំត្រូវបានកែសម្រួល និងបង្កើតថ្មីដោយផ្អែកលើក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ហើយសម្ភារបង្រៀន និងរៀនត្រូវបានកែលម្អ ដើម្បីជំរុញការងារប្រតិបត្តិក្នុងមន្ទីរពិសោធន៍ក៏ដោយ ប៉ុន្តែការកែលម្អកម្មវិធីអប់រំខាងលើត្រូវបានរៀបចំពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើ វិធីសាស្ត្រនិក្ខេបបទ និងពុំមានក្របខ័ណ្ឌអភិវឌ្ឍកម្មវិធីផ្អែកលើលទ្ធផល ដើម្បីផ្តល់ការណែនាំ ជាក់លាក់សម្រាប់រៀបចំកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និងវិធីសាស្ត្រវាយតម្លៃ
- គ្រឹះស្ថានឧត្តមសិក្សាបានចូលរួមក្នុងកម្មវិធីចល័តនិស្សិតអន្តរជាតិនៅអាស៊ី (AIMS Programme) ប៉ុន្តែបានបញ្ជូនតែនិស្សិតកម្ពុជាទៅសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សានៅក្រៅប្រទេសដោយពុំទាន់ មាននិស្សិតបរទេសមកសិក្សានៅក្នុងប្រទេសកម្ពុជា ដោយសារកម្មវិធីសិក្សាដែលប្រើប្រាស់ភាសាអង់គ្លេសជាមធ្យោបាយបង្រៀនមានចំនួនតិច
- គ្រឹះស្ថានឧត្តមសិក្សាសាធារណៈចំនួន ៥ និងឯកជនចំនួន ២ ប៉ុណ្ណោះដែលបានអនុវត្ត និងគ្រប់គ្រងការស្រាវជ្រាវ (ក្នុងចំនួនតិចតួច) និងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ចំនួន ៤ ប៉ុណ្ណោះដែលបានបង្កើតមជ្ឈមណ្ឌលឧត្តមភាព
- សមត្ថភាពគ្រប់គ្រង និងអនុវត្តប្រព័ន្ធដែលមានស្រាប់នៅតែជាបញ្ហានៅកម្រិតស្ថាប័ន ទាំងកម្រិតបច្ចេកទេស និងកម្រិតគ្រប់គ្រង
- ធនធាន និងបុគ្គលិកជំនាញពុំទាន់មានគ្រប់គ្រាន់ ដើម្បីដំណើរការប្រព័ន្ធ
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យពុំទាន់អាចផលិតរបាយការណ៍សម្រាប់ការសម្រេចចិត្តកម្រិតគោលនយោបាយ។

ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ការអប់រំឧត្តមសិក្សានៅកម្ពុជាមានការរីកចម្រើនគួរឲ្យកត់សម្គាល់ជាពិសេសលើការពង្រីកចំនួនគ្រឹះស្ថានឧត្តមសិក្សា ការចុះឈ្មោះចូលរៀន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធអេកូឡូស៊ីសម្រាប់ការស្រាវជ្រាវ ការអភិវឌ្ឍ និងអភិបាលកិច្ច។ ទោះបីមានការរីកចម្រើនគួរឱ្យកត់សម្គាល់ នៅមានបញ្ហាប្រឈមមួយចំនួន ដែលត្រូវដោះស្រាយ ដើម្បីលើកកម្ពស់គុណភាព ភាពឆ្លើយតបការស្រាវជ្រាវ និងអភិបាលកិច្ចនៅឧត្តមសិក្សា។ អាស្រ័យហេតុនេះ អនុកម្មវិធីឧត្តមសិក្សា មានវត្ថុបំណងចំនួន ៤ ដូចខាងក្រោម៖

១. បង្កើនការចុះឈ្មោះចូលរៀននៅឧត្តមសិក្សា ដោយផ្តោតលើសមធម៌

២. លើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃកម្មវិធីអប់រំ

៣. ពង្រឹងការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំ សម្រាប់កម្រិតកម្មវិធី ដើម្បីបំពេញបានតាមស្តង់ដាជាតិ ឬ/និងស្តង់ដាអន្តរជាតិ

៤. គាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីកែលម្អប្រព័ន្ធអភិបាលកិច្ច និងគ្រប់គ្រងកម្រិតស្ថាប័ន ឆ្ពោះទៅការអភិវឌ្ឍសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សាកម្រិតខ្ពស់

ការចូលរៀន និងសមធម៌ (ការចុះឈ្មោះចូលរៀនទាប)៖ ដើម្បីដោះស្រាយអត្រាចុះឈ្មោះចូលរៀនទាបនៅឧត្តមសិក្សា យុទ្ធសាស្ត្រចំនួនពីរគួរត្រូវបានអនុវត្ត។ យុទ្ធសាស្ត្រទីមួយ គឺលើកកម្ពស់ការចូលរៀន

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

និងសមធម៌ តាមរយៈការរៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែង និងពង្រីកកម្មវិធីអាហារូបករណ៍ ដោយផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែសមរម្យដល់និស្សិត និងយន្តការគាំទ្រ ដើម្បីកាត់បន្ថយអត្រាបោះបង់ការសិក្សារបស់និស្សិតអាហារូបករណ៍។ វិធានការមួយទៀត គឺបង្កើតវេទិកាឌីជីថលសម្រាប់កម្មវិធីស្នើសុំអាហារូបករណ៍របស់និស្សិត និងការបណ្តុះបណ្តាលជំនាញតាមរយៈកម្មវិធីភាពជាដៃគូរវាងគ្រឹះស្ថានឧត្តមសិក្សា និងសាលាមធ្យមសិក្សាចំណេះទូទៅ។ យុទ្ធសាស្ត្រទីពីរ គឺអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការបង្រៀន និងរៀន តាមរយៈការបង្កើតមជ្ឈមណ្ឌលឧត្តមភាព និងជួសជុល និងសាងសង់ថ្នាក់រៀន បន្ទប់ពិសោធន៍ និងអន្តេវាសិកដ្ឋានស្នាក់នៅ ព្រមទាំងពង្រីក និងដាក់ឱ្យប្រើប្រាស់ថ្នាលឌីជីថលសម្រាប់ការបង្រៀន និងរៀន។

កម្មវិធីសិក្សា៖ ដើម្បីកែលម្អកម្មវិធីសិក្សា ឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្រសួងនឹងធ្វើទំនើបកម្មកម្មវិធីសិក្សាដោយផ្អែកលើក្របខ័ណ្ឌស្តីពីការរៀបចំកម្មវិធីសិក្សាផ្អែកលើលទ្ធផល ស្របតាមស្តង់ដាជាតិ និងអន្តរជាតិ។ ដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រនេះ ក្រសួងនឹងរៀបចំគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និងវិធីសាស្ត្រវាយតម្លៃលទ្ធផលសិក្សា ធ្វើទំនើបកម្ម និងអនុវត្តកម្មវិធីសិក្សាជាអាទិភាព និងបង្កើតភាពជាដៃគូរវាងគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេស និងក្រៅប្រទេស ដើម្បីបង្កើនគុណភាពអប់រំនៅឧត្តមសិក្សាឱ្យស្របតាមស្តង់ដាជាតិ និងអន្តរជាតិ។

ប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង៖ គុណភាពអប់រំនៅឧត្តមសិក្សា មានភាពល្អប្រសើរឡើងក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ។ នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ក្រសួងបានបង្កើតប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង ដើម្បីជួយគ្រឹះស្ថានឧត្តមសិក្សាក្នុងការកែលម្អគុណភាពកម្មវិធីអប់រំសិក្សា និងការអភិវឌ្ឍសមត្ថភាពស្ថាប័ន។ ដើម្បីជួយគ្រឹះស្ថានឧត្តមសិក្សាដើម្បីបំពេញតាមស្តង់ដាជាតិ និងអន្តរជាតិ ក្រសួងនឹងបង្កើនភាពជាម្ចាស់សម្រាប់កម្រិតអ្នកគ្រប់គ្រង និងបុគ្គលិកបច្ចេកទេសដែលទទួលបន្ទុកប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង ដើម្បីដឹកនាំការអនុវត្តប្រព័ន្ធ តាមរយៈការធ្វើបច្ចុប្បន្នភាពឧបករណ៍វាយតម្លៃ គុណភាពអប់រំផ្ទៃក្នុងឱ្យស្របតាមស្តង់ដាធានាគុណភាពរបស់បណ្តាញសាកលវិទ្យាល័យអាស៊ាន (AUN-QA) ផ្តល់អំណាចដល់ថ្នាក់ដឹកនាំគ្រឹះស្ថានឧត្តមសិក្សា ដើម្បីដឹកនាំអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង និងផ្តល់ការបណ្តុះបណ្តាលសមត្ថភាពដែលត្រូវការដល់កម្មវិធីអប់រំគោលដៅ និងការិយាល័យឬផ្នែកធានាគុណភាពអប់រំផ្ទៃក្នុងរបស់គ្រឹះស្ថានឧត្តមសិក្សាដែលចូលរួម ដើម្បីធ្វើការស្វ័យវាយតម្លៃប្រចាំឆ្នាំ។ យុទ្ធសាស្ត្រមួយទៀត គឺបង្កើតកម្មវិធីភាពជាដៃគូជាមួយបណ្តាញសាកលវិទ្យាល័យអាស៊ាន និងទីភ្នាក់ងារធានាគុណភាពអប់រំផ្សេងទៀតៗ ដើម្បីកែលម្អប្រព័ន្ធធានាគុណភាព និងការទទួលស្គាល់គុណភាពអប់រំរបស់កម្ពុជា រួមទាំងការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពមន្ត្រីបច្ចេកទេសដើម្បីក្លាយជាមន្ត្រីវាយតម្លៃទាំងកម្រិតគ្រឹះស្ថាន និងកម្រិតក្រសួង។ តាមរយៈការបណ្តុះបណ្តាលនេះ គ្រឹះស្ថានឧត្តមសិក្សានឹងអាចត្រៀមខ្លួនរួចរាល់សម្រាប់ការវាយតម្លៃកម្មវិធីអប់រំដែលបានជ្រើសរើស និងបានកែលម្អ ដើម្បីបំពេញការទទួលស្គាល់កម្មវិធីកម្រិតតំបន់ (AUN-QA) និងអន្តរជាតិ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

អភិបាលកិច្ចអនុវិស័យ និងស្ថាប័ន៖ យុទ្ធសាស្ត្ររបស់អនុវិស័យ និងរបស់គ្រឹះស្ថានឧត្តមសិក្សា រួមទាំងប្រព័ន្ធគាំទ្រទាំងអស់ត្រូវបានរៀបចំ ដើម្បីកែលម្អប្រព័ន្ធអភិបាលកិច្ច និងគ្រប់គ្រងរបស់អនុវិស័យ និងគ្រឹះស្ថានឧត្តមសិក្សា។ ដើម្បីពង្រឹងប្រព័ន្ធនេះឆ្ពោះទៅរកអភិវឌ្ឍសមត្ថភាពស្ថាប័ន ក្រសួងនឹងបន្តកសាងសមត្ថភាពស្តីពីភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសម្រាប់អនុវិស័យ និងស្ថាប័ន តាមរយៈការផ្តល់អំណាចដល់អ្នកគ្រប់គ្រងរបស់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីធ្វើបច្ចុប្បន្នភាព និងអនុវត្តយុទ្ធសាស្ត្ររយៈពេលវែងរបស់គ្រឹះស្ថានឧត្តមសិក្សា ផ្តល់ការបណ្តុះបណ្តាលសមត្ថភាពបុគ្គលិកបង្គោលមកពីការិយាល័យពាក់ព័ន្ធ ដើម្បីដំណើរការប្រព័ន្ធ និងអនុវត្តកម្មវិធីវិនិយោគ អភិវឌ្ឍសមត្ថភាពនៅគ្រឹះស្ថានឧត្តមសិក្សា សម្រាប់ធ្វើការវាយតម្លៃកម្រិតស្ថាប័ន ដើម្បីរៀបចំរបាយការណ៍ស្វ័យវាយតម្លៃស្តីពីការអភិវឌ្ឍ សមត្ថភាពស្ថាប័ន និងផ្តល់ការគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សាធ្វើការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា។ យុទ្ធសាស្ត្រមួយទៀត គឺធ្វើទំនើបកម្មអភិបាលកិច្ច ប្រព័ន្ធគ្រប់គ្រងនៅអនុវិស័យ និងស្ថាប័នដោយបង្កើត និងកែសម្រួលបទបញ្ញត្តិទាក់ទងនឹងការអប់រំឧត្តមសិក្សា បង្កើត និងអនុវត្តថ្នាលអនឡាញ សម្រាប់ប្រព័ន្ធព័ត៌មានគ្រប់គ្រងឧត្តមសិក្សា រួមទាំងមុខងារគន្លឹះក្នុងការផ្តល់សេវារបស់អគ្គនាយកដ្ឋានឧត្តមសិក្សាតាមបែបឌីជីថល និងបង្កើតក្របខ័ណ្ឌលទ្ធផលស្តីពីអត្រាមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សា។

| វត្ថុបំណងទី១៖ បង្កើនការចុះឈ្មោះចូលរៀននៅឧត្តមសិក្សា ដោយផ្តោតលើសមធម៌ | | |
|---|---|---|
| សូចនាករផលសម្រេច | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
| ចំនួននិស្សិតទទួលបានអាហារូបករណ៍នៅឧត្តមសិក្សា | | |
| ក្នុងប្រទេស | ៧ ៥៣៣ | ៧ ៥៨៣ |
| ក្រៅប្រទេស | ៣៨៧ | ៤១០ |
| ចំនួននិស្សិតជំនាញក្នុងផ្នែកបច្ចេកវិទ្យាឌីជីថល | ៧៣៧ | ៩៣៧ |
| ប្រុស | ៤២៤ | ៥៣៩ |
| ស្រី | ៣១៣ | ៣៩៨ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** អនុវត្តវិធានការបង្កើនការចូលរៀនការអប់រំឧត្តមសិក្សាប្រកបដោយសមធម៌ | **ការលើកកម្ពស់ការយល់ដឹង**<br>- ផ្សព្វផ្សាយព័ត៌មានការអប់រំឧត្តមសិក្សា ដោយសហការជាមួយគ្រឹះស្ថានឧត្តមសិក្សា សាលាមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស និងអង្គភាពពាក់ព័ន្ធផ្សេងទៀត<br>- លើកកម្ពស់ក្របខ័ណ្ឌច្បាប់កម្មសិទ្ធិបញ្ញានៅឧត្តមសិក្សា។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | **អាហារូបករណ៍**<br>- បង្កើត និងប្រើប្រាស់ថ្នាលឌីជីថលសម្រាប់កម្មវិធីស្នើសុំអាហារូបករណ៍ (ជាពិសេសកម្មវិធីទូរស័ព្ទសម្រាប់ព័ត៌មានពីគ្រឹះស្ថានឧត្តមសិក្សា ព័ត៌មានអាហារូបករណ៍ (អាទិភាពនារី និស្សិតក្រីក្រ និស្សិតរស់នៅតំបន់ដាច់ស្រយាល និស្សិតមានពិការភាព និងនិស្សិតឆ្នើម) ពាក្យស្នើសុំអាហារូបករណ៍សិក្សានៅឧត្តមសិក្សា និងគន្លងអាជីព)<br>- បង្កើតកម្មវិធីអាហារូបករណ៍នៅក្នុងកម្មវិធីអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា (STEAM) នៅឧត្តមសិក្សា រួមទាំងប្រាក់ឧបត្ថម្ភប្រចាំខែសមរម្យសម្រាប់និស្សិត<br>- បង្កើនការចូលរៀនប្រកបដោយសមធម៌ចំពោះមុខជំនាញ STEAM ពាក់ព័ន្ធ នឹងការបន្សាំប្រែប្រួលអាកាសធាតុ និងវិធានការកាត់បន្ថយ រួមទាំងផ្នែកថាមពល សវនកម្មថាមពល និងមុខជំនាញទាក់ទងនឹងថាមពលផ្សេងទៀត និងផ្នែកកសិកម្មប្រកបដោយចីរភាព<br>- ពង្រឹងយន្តការដើម្បីកាត់បន្ថយអត្រាបោះបង់ការសិក្សារបស់និស្សិតអាហារូបករណ៍រាជរដ្ឋាភិបាល (អាចមានជាកម្មវិធីណែនាំ/ការតម្រង់ទិសលើមុខជំនាញកម្មវិធីប្រឹក្សា និងច្រកការងារ) ដើម្បីអាចឱ្យនិស្សិតបញ្ចប់បរិញ្ញាបត្រ និងដើម្បីបង្កើននិស្សិតបញ្ចប់ការសិក្សាអាចបន្តការសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់<br>- ការជ្រើសរើស និងគ្រប់គ្រងនិស្សិតអាហារូបករណ៍កម្ពុជា ទៅសិក្សានៅបរទេស<br>- ការទទួល និងគ្រប់គ្រងនិស្សិតអាហារូបករណ៍បរទេសដែលកំពុងសិក្សានៅកម្ពុជា។<br>**ការលើកកម្ពស់កម្មវិធីអប់រំ STEAM**<br>- ផ្តល់ការគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សា ក្នុងការបង្កើត និងអនុវត្តកម្មវិធីភាពជាដៃគូ STEAM ។<br>**ការលើកកម្ពស់បច្ចេកវិទ្យាឌីជីថល**<br>- បង្កើត និងកែសម្រួលកម្មវិធីបណ្តុះបណ្តាលលើមុខជំនាញផ្នែកបច្ចេកវិទ្យាឌីជីថល<br>- ការគាំទ្រការចុះឈ្មោះចូលរៀនលើមុខជំនាញផ្នែកបច្ចេកវិទ្យាឌីជីថល<br>- វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសម្រាប់បច្ចេកវិទ្យាឌីជីថល។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| **យុទ្ធសាស្ត្រទី២៖** អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការបង្រៀន និងរៀន | **ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការបង្រៀន និងរៀន**<br>- បង្កើតមជ្ឈមណ្ឌលឧត្តមភាពសម្រាប់បង្រៀន និងរៀន<br>- ផ្តល់ការគាំទ្រគ្រឹះស្ថានឧត្តមសិក្សា ក្នុងការជួសជុល និងសាងសង់ថ្នាក់រៀន បន្ទប់ពិសោធន៍ និងអន្តេវាសិកដ្ឋាន<br>- ពង្រីក និងប្រើប្រាស់ថ្នាលឌីជីថលសម្រាប់ការបង្រៀន និងរៀន។ |

**វត្ថុបំណងទី២៖ លើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃកម្មវិធីអប់រំ**

| សូចនាករផលសម្រេច | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
|---|---|---|
| ចំនួនកម្មវិធីអប់រំបានចូលរួមបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា | ៩ | ២៥ |
| ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានចូលរួមបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា | ៧ | ១៥ |
| ចំនួនកម្មវិធីអប់រំដែលធ្វើទំនើបកម្មស្របតាមក្របខ័ណ្ឌស្តីពីការរៀបចំកម្មវិធីអប់រំផ្អែកលើលទ្ធផល | N/A | ៤០ |
| ចំនួនកម្មវិធីអប់រំក្នុងផ្នែកបច្ចេកវិទ្យាឌីជីថល បានបង្កើត/និងកែសម្រួល | ១៦ | ២៨ |
| ចំនួននិស្សិតទទួលបានប្រយោជន៍ពីកម្មវិធីចល័តនិស្សិត | ៦ | ៣០ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** ធ្វើទំនើបកម្មកម្មវិធីសិក្សា ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច | **កម្មវិធីសិក្សា និងកម្មវិធីអប់រំ**<br>- បង្កើតក្របខ័ណ្ឌស្តីពីការរៀបចំកម្មវិធីអប់រំផ្អែកលើលទ្ធផល និងគោលការណ៍ណែនាំស្តីពីការរៀបចំកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និងវិធីសាស្ត្រវាយតម្លៃលទ្ធផលសិក្សា<br>- គាំទ្រគ្រឹះស្ថានឧត្តមសិក្សាអនុវត្តកម្មវិធីបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា<br>- ធ្វើទំនើបកម្ម និងអនុវត្តកម្មវិធីអប់រំអាទិភាព ដែលស្របតាមក្របខ័ណ្ឌ និងគោលការណ៍ណែនាំ<br>- បង្កើត និងអនុវត្តកម្មវិធីភាពជាដៃគូជាមួយ គ្រឹះស្ថានឧត្តមសិក្សាក្នុងស្រុក និងអន្តរជាតិ ដើម្បីបង្កើនគុណភាពកម្មវិធីអប់រំឱ្យឆ្លើយតបនឹងស្តង់ដាជាតិ និងអន្តរជាតិ។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | **បណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា**<br>- ផ្តល់ការគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីអនុវត្តបណ្តាញសាកលវិទ្យាល័យសាយប័រ។ |
| **យុទ្ធសាស្ត្រទី២៖** ជំរុញអន្តរជាតូបនីយកម្ម ដើម្បីលើកកម្ពស់គុណភាព និងភាពឆ្លើយតបនៅឧត្តមសិក្សា | **ការផ្លាស់ប្តូរនិស្សិត និងភាពជាដៃគូអន្តរជាតិ**<br>- បង្កើត និងអនុវត្តកម្មវិធីសញ្ញាបត្ររួមគ្នា (Joint Degree ) តាមរយៈការសហការភាពជាដៃគូជាមួយគ្រឹះស្ថានឧត្តមសិក្សាក្នុងតំបន់ និងអន្តរជាតិ<br>- ផ្តល់ការគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីបណ្តុះបណ្តាលកម្មវិធីអប់រំដែលប្រើប្រាស់ភាសាអង់គ្លេសជាមធ្យោបាយបង្រៀន<br>- បង្កើនការវិនិយោគលើកម្មវិធីចល័តនិស្សិតអន្តរជាតិនៅអាស៊ី ដើម្បីពង្រីកការផ្លាស់ប្តូរនិស្សិត<br>- បង្កើនការផ្លាស់ប្តូរនិស្សិត និងបុគ្គលិកអប់រំ (តាមរយៈការរៀបចំអនុស្សរណៈនៃការយោគយល់ និងកិច្ចព្រមព្រៀងទៅវិញទៅមករវាងរាជរដ្ឋាភិបាល និងគ្រឹះស្ថានឧត្តមសិក្សា) និងកិច្ចព្រមព្រៀងជាគោលការណ៍ (សកម្មភាពនយោបាយ/គំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល/ភាពជាដៃគូរវាងទីភ្នាក់ងារអន្តរជាតិ គ្រឹះស្ថានឧត្តមសិក្សាជាមួយក្រសួង)។ |
| **យុទ្ធសាស្ត្រទី៣៖** លើកកម្ពស់សមត្ថភាពគ្រូបង្រៀន ដើម្បីអនុវត្តកម្មវិធីអប់រំដែលធ្វើទំនើបកម្ម | **ការបណ្តុះបណ្តាល**<br>- អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ និងជំនាញបន្ថែម ដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពការងារនិងទទួលបន្ទុកមុខងារ ឬភារកិច្ចថ្មីដល់ក្រុមការងារបច្ចេកទេសពីអគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សា ក្នុងការរៀបចំកម្មវិធីសិក្សា វិធីសាស្ត្របង្រៀនថ្មី និងវិធីសាស្ត្រវាយតម្លៃលទ្ធផលសិក្សា<br>- បង្កើនការវិនិយោគដើម្បីអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈបុគ្គលិកអប់រំ។ |

| **វត្ថុបំណងទី៣៖ ពង្រឹងការអនុវត្តប្រព័ន្ធធានាគុណភាព សម្រាប់កម្មវិធីអប់រំ ដើម្បីបំពេញបានស្តង់ដាជាតិ និង/ឬអន្តរជាតិ** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនកម្មវិធីសិក្សាបានទទួលស្គាល់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | N/A | ២៨ |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | |
|---|---|---|
| ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានទទួលស្គាល់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | N/A | ៨៩ |
| ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានធ្វើស្វ័យវាយតម្លៃកម្មវិធីអប់រំផ្អែកលើប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង | N/A | ៤០ |
| ចំនួនកម្មវិធីអប់រំមានរបាយការណ៍ស្វ័យវាយតម្លៃដោយផ្អែកលើប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង | N/A | ៨០ |
| ចំនួនកម្មវិធីអប់រំបានទទួលស្គាល់គុណភាពអប់រំដោយទីភ្នាក់ងារក្នុងតំបន់ និងអន្តរជាតិ | ៣ | ៤០ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** បង្កើនភាពជាម្ចាស់ដល់គណៈ-គ្រប់គ្រង និងមន្ត្រីបច្ចេកទេសទទួលបន្ទុកប្រព័ន្ធធានាគុណភាពអប់រំ ដើម្បីដឹកនាំការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង | **ការពង្រឹងប្រព័ន្ធ**<br>- ការលើកកម្ពស់ការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងរបស់គ្រឹះស្ថានឧត្តមសិក្សា<br>- ផ្តល់អំណាចដល់អ្នកគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ក្នុងការដឹកនាំអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង<br>- ផ្តល់ការបណ្តុះបណ្តាលសមត្ថភាពចាំបាច់កម្រិតកម្មវិធីអប់រំ ដល់ការិយាល័យ/ផ្នែកធានាគុណភាពអប់រំផ្ទៃក្នុងនៃគ្រឹះស្ថានឧត្តមសិក្សាដែលចូលរួមក្នុងប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង ដើម្បីវាយតម្លៃកម្មវិធីប្រចាំឆ្នាំ<br>- ធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌស្តីពីធានាគុណភាពអប់រំផ្ទៃក្នុង ដោយសហការជាមួយបណ្តាញសាកលវិទ្យាល័យអាស៊ានផ្នែកធានាគុណភាព។ |
| **យុទ្ធសាស្ត្រទី២៖** បង្កើតភាពជាដៃគូជាមួយទីភ្នាក់ងារធានាគុណភាពអប់រំ ពាក់ព័ន្ធក្នុងតំបន់ និងអន្តរជាតិលើការកែលម្អប្រព័ន្ធធានាគុណភាព ការទទួលស្គាល់គុណភាពអប់រំ និងការបណ្តុះ-បណ្តាលភាពជាអ្នកដឹកនាំ | **ការអភិវឌ្ឍ និងពង្រឹងភាពជាដៃគូ**<br>- ដឹកនាំការបង្កើតភាពជាដៃគូអភិវឌ្ឍរវាងអគ្គនាយកដ្ឋានឧត្តមសិក្សា និងបណ្តាញសាកលវិទ្យាល័យអាស៊ាន (AUN-QA) ដើម្បីធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌស្តីពីធានាគុណភាពផ្ទៃក្នុងកម្ពុជា និងការវាយតម្លៃកម្មវិធីអប់រំឈានឆ្ពោះទៅរកការទទួលស្គាល់ក្នុងតំបន់<br>- សម្របសម្រួលជាមួយ AUN-QA និងគ្រឹះស្ថានឧត្តមសិក្សាគោលដៅលើការបណ្តុះបណ្តាលស្តីពីការវាយតម្លៃកម្មវិធីអប់រំ ការបង្ហាត់បង្ហាញ និងការចុះកម្មសិក្សា |



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| | |
|---|---|
| | - រៀបចំស្វ័យវាយតម្លៃកម្មវិធីអប់រំ ដើម្បីបញ្ជូនរបាយការណ៍វាយតម្លៃទៅ AUN-QA (គ្រឹះស្ថានឧត្តមសិក្សា)<br>- សម្របសម្រួលជាមួយ AUN-QA និង គ្រឹះស្ថានឧត្តមសិក្សាគោលដៅលើការវាយតម្លៃកម្មវិធីអប់រំសម្រាប់ការទទួលស្គាល់គុណភាព។ |
| **យុទ្ធសាស្ត្រទី៣៖** ពង្រឹងការធានាគុណភាពខាងក្រៅនៃគ្រឹះស្ថានឧត្តមសិក្សា | **គាំទ្រដល់ការទទួលស្គាល់**<br>- បំប៉នសមត្ថភាពការិយាល័យធានាគុណភាពផ្ទៃក្នុង ឬអង្គភាពនៃគ្រឹះស្ថានឧត្តមសិក្សាជាមួយនឹងសមត្ថភាពដែលត្រូវការ ដើម្បីធ្វើការវាយតម្លៃដោយខ្លួនឯងទាំងកម្រិតកម្មវិធី និងស្ថាប័ន<br>- វាយតម្លៃទាំងកម្មវិធី និងកម្រិតស្ថាប័ននៃគ្រឹះស្ថានឧត្តមសិក្សាសម្រាប់ការផ្តល់ការទទួលស្គាល់។ |

| **វត្ថុបំណងទី៤៖ គាំទ្រគ្រឹះស្ថានឧត្តមសិក្សាដើម្បីកែលម្អប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងឆ្ពោះទៅការអភិវឌ្ឍសមត្ថភាពស្ថាប័នកម្រិតខ្ពស់** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនគ្រឹះស្ថានឧត្តមសិក្សាបំពេញតាមស្តង់ដាការអភិវឌ្ឍសមត្ថភាពស្ថាប័ន | N/A | ២០ |
| ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានបញ្ចូលប្រព័ន្ធព័ត៌មានទៅក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងឧត្តមសិក្សា | ៤៩ | ៨០ |
| ចំនួនគ្រឹះស្ថានឧត្តមសិក្សាស្ថិតក្រោមឱវាទ និងក្រៅឱវាទក្រសួងអប់រំ យុវជន និងកីឡា រៀបចំការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា | ២៣ | ៨០ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** កសាងសមត្ថភាពភាពជាអ្នកដឹកនាំ និងគ្រប់គ្រងកម្រិតអនុវិស័យ និងស្ថាប័ន ដើម្បីរៀបចំ និងអនុវត្តប្រព័ន្ធគាំទ្រ | **ការអភិវឌ្ឍសមត្ថភាព**<br>- ផ្តល់អំណាចដល់អ្នកគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ដើម្បីដឹកនាំការរៀបចំ បច្ចុប្បន្នកម្ម និងការអនុវត្តយុទ្ធសាស្ត្ររយៈពេលវែងរបស់គ្រឹះស្ថាន កម្មវិធីវិនិយោគ និងប្រព័ន្ធ<br>- ផ្តល់ការបណ្តុះបណ្តាលសមត្ថភាពដែលត្រូវការដល់បុគ្គលិកស្នូលពីការិយាល័យពាក់ព័ន្ធដែលមានជំនាញដែលត្រូវការដើម្បីដំណើរការប្រព័ន្ធ និងអនុវត្តកម្មវិធីវិនិយោគ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - អភិវឌ្ឍសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សា ក្នុងការវាយតម្លៃកម្រិតស្ថាប័ន ដើម្បីផលិតរបាយការណ៍ស្វ័យវាយតម្លៃ ស្តីពីការអភិវឌ្ឍសមត្ថភាពស្ថាប័ន<br>- អនុវត្តការវាយតម្លៃផ្ទៀងផ្ទាត់ដោយអគ្គនាយកដ្ឋានឧត្តមសិក្សា<br>- ផ្តល់ការគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីអនុវត្តការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា។ |
| **យុទ្ធសាស្ត្រទី២៖** ធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងកម្រិតស្ថាប័ន | **បទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិ**<br>- បង្កើតប្រកាសអន្តរក្រសួង អនុក្រឹត្យស្តីពីគណៈគ្រប់គ្រងប្រតិបត្តិរបស់គ្រឹះស្ថានឧត្តមសិក្សា រួមបញ្ចូលការកំណត់អាណត្តិ<br>- រៀបចំ និងកែសម្រួលបទបញ្ញត្តិពាក់ព័ន្ធនឹងការអប់រំឧត្តមសិក្សា។<br>**ប្រព័ន្ធគាំទ្រ**<br>- បង្កើត និងអនុវត្តថ្នាលអនឡាញសម្រាប់ប្រព័ន្ធគ្រប់គ្រងព័ត៌មានឧត្តមសិក្សា រួមទាំងមុខងារគន្លឹះក្នុងការផ្តល់សេវាតាមបែបឌីជីថលរបស់អគ្គនាយកដ្ឋានឧត្តមសិក្សា<br>- បង្កើតក្របខ័ណ្ឌលទ្ធផលស្តីពីអត្រាមានការងារធ្វើរបស់និស្សិតបញ្ចប់ការសិក្សា។ |

### ៣.៤.២ អនុកម្មវិធី២.២៖ ការស្រាវជ្រាវ និងនវានុវត្តន៍

| **លទ្ធផលរំពឹងទុករបស់អនុកម្មវិធី៖ ផលិតផលចេញពីការស្រាវជ្រាវផ្សារភ្ជាប់នឹងតម្រូវការទីផ្សារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច** | | |
|---|---|---|
| **សូចនាករផលសម្រេច** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនលទ្ធផលនៃការស្រាវជ្រាវត្រូវបានផ្សារភ្ជាប់តម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រើប្រាស់ដោយគ្រឹះស្ថានឧត្តមសិក្សា និងឧស្សាហកម្ម | N/A | ៤០ |

**បញ្ហាប្រឈមគន្លឹះៗ៖**

- ចំនួនបុគ្គលិកអប់រំដែលមានសញ្ញាបត្របណ្ឌិត និងជំនាញស្រាវជ្រាវមានកម្រិតទាប (មានតែ ៨,៨ ភាគរយ ប៉ុណ្ណោះដែលមាន PhDs [MoEYS, ២០២៣; UNESCO, ២០១៥])
- ចំនួនអ្នកស្រាវជ្រាវនៅមានកម្រិតទាប (មានតែអ្នកស្រាវជ្រាវ ៥១,១៦ នាក់ ប៉ុណ្ណោះក្នុងមួយលាននាក់ [MISTI, ២០២៣; UNESCO, ២០១៥])

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

- មូលនិធិស្រាវជ្រាវជាតិមានកម្រិត (ការចំណាយសាធារណៈរបស់កម្ពុជាលើការស្រាវជ្រាវ និងការអភិវឌ្ឍ គឺត្រឹមតែ ០,១២ ភាគរយ នៃផ.ស.ស [MISTI, ២០២៣; UNESCO, ២០១៥])
- ការបោះពុម្ពផ្សាយស្រាវជ្រាវមានកម្រិតទាប (ជាប់ចំណាត់ថ្នាក់ទី ៨ ក្នុងអាស៊ាន) ហើយគំរូ/ផលិតផលស្រាវជ្រាវនៅគ្រឹះស្ថានឧត្តមសិក្សា មិនបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពសម្រាប់ការបំពេញតម្រូវការទីផ្សារ
- កន្លែងស្រាវជ្រាវ និងមន្ទីរពិសោធន៍មិនមានមុខងារពេញលេញទេ ហើយមានតែនៅក្នុងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈមួយចំនួនប៉ុណ្ណោះ
- គ្រឹះស្ថានឧត្តមសិក្សាសាធារណៈចំនួន ៤ ប៉ុណ្ណោះដែលបានបង្កើតមជ្ឈមណ្ឌលឧត្តមភាព ប៉ុន្តែទោះយ៉ាងណា នៅមិនទាន់បានអភិវឌ្ឍពេញលេញ ដើម្បីបំពេញតាមលក្ខខណ្ឌជាតិ
- គ្រឹះស្ថានឧត្តមសិក្សាសាធារណៈចំនួន ៦ប៉ុណ្ណោះ ដែលបានអនុវត្តប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវរបស់សាកលវិទ្យាល័យ ប៉ុន្តែនៅមានចំនួនតិចតួចទៅឡើយ ដែលបរិការណ៍នេះ បង្ហាញថាតម្រូវចាំបាច់សម្រាប់ការអភិវឌ្ឍក្របខ័ណ្ឌគ្រប់គ្រងការស្រាវជ្រាវឱ្យបានទូលំទូលាយនៅគ្រឹះស្ថានឧត្តមសិក្សា។

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ អនុកម្មវិធី២.២៖ ការស្រាវជ្រាវ និងនវានុវត្តន៍ នឹងផ្ដោតលើការសម្រេចបាននូវវត្ថុបំណងចំនួន៣ ដូចខាងក្រោម៖

១. លើកកម្ពស់ការវិនិយោគជាយុទ្ធសាស្ត្រ លើការអភិវឌ្ឍធនធានមនុស្ស ឆ្ពោះទៅកកម្រិតក្រោយបរិញ្ញាបត្រ

២. ជំរុញសកម្មភាពស្រាវជ្រាវ និងការបោះពុម្ពផ្សាយ

៣. បន្សីវាងគម្រោងស្រាវជ្រាវជាមួយនឹងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច

វត្ថុបំណងទី១ មានគោលបំណងដោះស្រាយបញ្ហាប្រឈមនានាទាក់ទងនឹងចំនួនបុគ្គលិកអប់រំដែលមានសញ្ញាបត្របណ្ឌិត។ ដើម្បីបង្កើនចំនួននេះ ក្រសួងនឹងធ្វើការពង្រីកចំនួនអាហារូបករណ៍ និងភាពជាដៃគូយុទ្ធសាស្ត្រសម្រាប់កម្មវិធីបណ្ឌិត ដើម្បីទាញយកអត្ថប្រយោជន៍ពីឱកាសនៅក្រៅប្រទេស ព្រមទាំងធ្វើទំនើបកម្មកម្មវិធីបណ្ឌិតរបស់ខ្លួន និងតម្រង់ទិសទៅរកតម្រូវការទីផ្សារ និងស្តង់ដាជាតិ និងអន្តរជាតិ។

ដើម្បីដោះស្រាយបញ្ហាប្រឈមនានាដែលទាក់ទងនឹងចំនួនអ្នកស្រាវជ្រាវនៅក្នុងគ្រឹះស្ថានឧត្តមសិក្សា និងផលិតភាពស្រាវជ្រាវមានកម្រិត ជាពិសេសទាក់ទងនឹងការបោះពុម្ពផ្សាយ អនុវិស័យឧត្តមសិក្សានឹងធ្វើការបន្ថែមដើម្បីផ្តល់ជំនួយលើការស្រាវជ្រាវ និងគាំទ្រគ្រឹះស្ថានឧត្តមសិក្សា ដើម្បីអនុវត្តគម្រោងស្រាវជ្រាវរួមគ្នាជាមួយដៃគូ (ក្នុងស្រុក និងអន្តរជាតិ)។ ប្រព័ន្ធអ្នកស្រាវជ្រាវក៏នឹងត្រូវបានបង្កើតឡើងសម្រាប់កម្មវិធីថ្នាក់បណ្ឌិត និងក្រោយបណ្ឌិតផងដែរ។ លើសពីនេះទៀត ប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវនឹងបានបង្កើតឡើងដើម្បីធ្វើទំនើបកម្មស្តីពីហិរញ្ញប្បទានស្រាវជ្រាវ និងអនុញ្ញាតឱ្យមានការតាមដានអ្នកស្រាវជ្រាវ និងគម្រោងដែលកំពុងដំណើរការ។ ការកសាងសមត្ថភាពសម្រាប់គ្រឹះស្ថានឧត្តមសិក្សា និងអ្នកស្រាវជ្រាវ និងការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងសង្គមវិទ្យាសាស្ត្រ ក៏នឹងរួមចំណែកដល់ការពង្រឹងចំនួនអ្នកស្រាវជ្រាវ និងផលិតភាពរបស់ពួកគេ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដើម្បីដោះស្រាយបញ្ហាប្រឈម ទាក់ទងនឹងការប្រើប្រាស់នៃផលិតផលស្រាវជ្រាវ ដើម្បីបំពេញតម្រូវការទីផ្សារ ក្រសួងនឹងគាំទ្រគ្រឹះស្ថានឧត្តមសិក្សាតាមរយៈការផ្តល់ជំនួយស្រាវជ្រាវ និងទម្រង់គាំទ្រផ្សេងទៀត ដោយផ្អែកលើរបៀបវារៈស្រាវជ្រាវជាតិ។ គ្រឹះស្ថានឧត្តមសិក្សា ក៏នឹងត្រូវបានគាំទ្រក្នុងការអភិវឌ្ឍភាពជាដៃគូជាមួយវិស័យឯកជន/ឧស្សាហកម្ម ដើម្បីបង្កើតគំរូផលិតផលដែលមានសក្តានុពល។ ការគាំទ្រគ្រឹះស្ថានឧត្តមសិក្សា ដើម្បីកសាងភាពជាដៃគូរវាងវិស័យឯកជនតាមរយៈវេទិកាស្រាវជ្រាវ និងចែករំលែកចំណេះដឹងផ្សេងៗ ដូចជាវេទិកា សន្និសីទ និងកម្មវិធីណែនាំក៏នឹងពង្រឹងការផលិតផលិតផលស្រាវជ្រាវសម្រាប់ពាណិជ្ជកម្មផងដែរ។

យុទ្ធសាស្ត្រ និងសកម្មភាពគោល ដើម្បីជំរុញវត្ថុបំណងទាំងនេះ បានកំណត់ក្នុងតារាងខាងក្រោម៖

| **វត្ថុបំណងទី១៖ លើកកម្ពស់ការវិនិយោគជាយុទ្ធសាស្ត្រ លើការអភិវឌ្ឍធនធានមនុស្ស ឆ្ពោះទៅកេកម្រិតក្រោយបរិញ្ញាបត្រ** | | |
|---|---|---|
| **សូចនាករផលសម្រេច** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួននិស្សិតថ្នាក់បណ្ឌិតបានបញ្ចប់ការសិក្សានៅក្នុងវិស័យអាទិភាពទទួលបានអាហារូបករណ៍ពី ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ | N/A | ២០ |
| ចំនួននិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់បានបញ្ចប់ការសិក្សាក្នុងវិស័យអាទិភាពទទួលបានអាហារូបករណ៍ពី ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ | N/A | ១៥០ |

| យុទ្ធសាស្ត្រ | សកម្មភាព |
|---|---|
| **យុទ្ធសាស្ត្រទី១៖** ពង្រីកគម្រោងអាហារូបករណ៍ និងភាពជាដៃគូយុទ្ធសាស្ត្រសម្រាប់កម្មវិធីក្រោយឧត្តមសិក្សា | **អាហារូបករណ៍**<br>- ផ្តល់អាហារូបករណ៍ថ្នាក់អនុបណ្ឌិត និងបណ្ឌិតរបស់រដ្ឋាភិបាលដល់សាស្ត្រាចារ្យ បុគ្គលិក និងសិស្សានុសិស្សនៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន<br>- ពង្រីកអាហារូបករណ៍ថ្នាក់អនុបណ្ឌិត និងបណ្ឌិត តាមរយៈគម្រោងវិនិយោគរបស់ក្រសួង។<br>**ភាពជាដៃគូ**<br>- គាំទ្រ គ្រឹះស្ថានឧត្តមសិក្សា លើការអភិវឌ្ឍ និងអនុវត្តកិច្ចសហការក្នុងស្រុក និងភាពជាដៃគូរវាង គ្រឹះស្ថានឧត្តមសិក្សា និងអ្នកពាក់ព័ន្ធ<br>- គាំទ្រគ្រឹះស្ថានឧត្តមសិក្សា លើការអភិវឌ្ឍ និងអនុវត្តកិច្ចសហការអន្តរជាតិ និងភាពជាដៃគូរវាងគ្រឹះស្ថានឧត្តមសិក្សា និងដៃគូបរទេស។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| **យុទ្ធសាស្ត្រទី២៖** ធ្វើទំនើបកម្មកម្មវិធីអនុបណ្ឌិត និងបណ្ឌិត ឆ្ពោះទៅរកតម្រូវការទីផ្សារ និងស្តង់ដាជាតិ និងអន្តរជាតិ និងការពង្រីកកម្មវិធីអនុបណ្ឌិត និងបណ្ឌិត | - គាំទ្រគ្រឹះស្ថានឧត្តមសិក្សាដែលមានសក្តានុពល ដើម្បីបង្កើតកម្មវិធីអនុបណ្ឌិត និងបណ្ឌិត ដើម្បីបំពេញរបៀបវារៈជាតិជាអាទិភាព<br>- គាំទ្រគ្រឹះស្ថានឧត្តមសិក្សា លើការបង្កើត និងអនុវត្តកម្មវិធីអនុបណ្ឌិត និងបណ្ឌិត ដែលភ្ជាប់ទៅនឹងឧស្សាហកម្ម<br>- គាំទ្រគ្រឹះស្ថានឧត្តមសិក្សា លើការបង្កើត និងអនុវត្តកម្មវិធីអនុបណ្ឌិត និងបណ្ឌិតរួមគ្នាជាមួយដៃគូជាតិ និងអន្តរជាតិ។ |

| **វត្ថុបំណងទី២៖ ជំរុញសកម្មភាពស្រាវជ្រាវ និងការបោះពុម្ពផ្សាយ** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនគម្រោងស្រាវជ្រាវដែលបានបញ្ចប់ | N/A | ១០០ |
| ចំនួនអត្ថបទស្រាវជ្រាវបានបោះពុម្ពក្នុងទិន្នានុប្បវត្តិជាតិ និងអន្តរជាតិឆ្លងកាត់ការត្រួតពិនិត្យដោយក្រុមអ្នកជំនាញ | N/A | ២០០ |
| ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានអនុវត្តទាំងស្រុងនូវក្របខ័ណ្ឌគ្រប់គ្រងការស្រាវជ្រាវ | N/A | ៣ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** លើកកម្ពស់គម្រោងស្រាវជ្រាវ និងភាពជាដៃគូយុទ្ធសាស្ត្រ ដើម្បីជំរុញវប្បធម៌ស្រាវជ្រាវ ជំនួយស្រាវជ្រាវ និងអាហារូបករណ៍ | **ការគាំទ្រការស្រាវជ្រាវ និងការតាមដាន**<br>- ផ្តល់ជំនួយស្រាវជ្រាវដល់ គ្រឹះស្ថានឧត្តមសិក្សា សាធារណៈ និងឯកជន<br>- បង្កើត និងអនុវត្តគម្រោងស្រាវជ្រាវសម្រាប់កម្មវិធីថ្នាក់បណ្ឌិត និងក្រោយបណ្ឌិត<br>- គាំទ្រគ្រឹះស្ថានឧត្តមសិក្សា ដើម្បីបង្កើត និងអនុវត្តគម្រោងស្រាវជ្រាវរួមគ្នាជាមួយដៃគូក្នុងស្រុក និងអន្តរជាតិ។ |
| **យុទ្ធសាស្ត្រទី២៖** ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវ ច្បាប់ និងក្របខ័ណ្ឌស្ថាប័ន | **ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន**<br>- រៀបចំប្រកាសអន្តរក្រសួងស្តីពីការផ្តល់មូលនិធិស្រាវជ្រាវ រួមទាំងការបង្កើតមូលនិធិស្រាវជ្រាវតាមស្ថាប័ន<br>- បង្កើត និងអនុវត្តក្របខ័ណ្ឌគ្រប់គ្រងការស្រាវជ្រាវសម្រាប់គ្រឹះស្ថានឧត្តមសិក្សា |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - គាំទ្រគ្រឹះស្ថានឧត្តមសិក្សា លើការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងការស្រាវជ្រាវ និងធ្វើទំនើបកម្មច្បាប់ហិរញ្ញវត្ថុស្រាវជ្រាវ និងគោលនយោបាយលើកទឹកចិត្តផ្ទៃក្នុង<br>- អភិវឌ្ឍ និងអនុវត្តការងារស្រាវជ្រាវ និងសាស្ត្រាចារ្យ<br>- លើកកម្ពស់ក្របខ័ណ្ឌច្បាប់កម្មសិទ្ធិបញ្ញានៅឧត្តមសិក្សា។ |
| **យុទ្ធសាស្ត្រទី៣៖** កសាងសមត្ថភាពសម្រាប់គ្រឹះស្ថានឧត្តមសិក្សា និងអ្នកស្រាវជ្រាវ ដើម្បីផលិតភស្តុតាងវិទ្យា-សាស្ត្រសម្រាប់ការបោះពុម្ព-ផ្សាយ និងផលិតផល | **ការកសាងសមត្ថភាព**<br>- គាំទ្រអ្នកស្រាវជ្រាវនៅ គ្រឹះស្ថានឧត្តមសិក្សា ដើម្បីបង្កើនសមត្ថភាពលើជំនាញបោះពុម្ពផ្សាយ និងកម្មវិធីលទ្ធផលស្រាវជ្រាវ<br>- គាំទ្រគ្រឹះស្ថានឧត្តមសិក្សា លើការបង្កើតទិនានុប្បវត្តិឆ្ពោះទៅរកស្តង់ដាជាតិ និងអន្តរជាតិ។ |
| **យុទ្ធសាស្ត្រទី៤៖** ពង្រឹងមជ្ឈមណ្ឌលស្រាវជ្រាវ និងសង្គមវិទ្យាសាស្ត្រ | **ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ សង្គមវិទ្យាសាស្ត្រ និងមជ្ឈមណ្ឌលឧត្តមភាព**<br>- បង្កើតអនុក្រឹត្យស្តីពីការបង្កើតសង្គមវិទ្យាសាស្ត្រ<br>- បង្កើត និងអនុវត្តមជ្ឈមណ្ឌលស្រាវជ្រាវជាតិ និងសង្គមវិទ្យាសាស្ត្រ<br>- ផ្តល់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវ និងសម្ភារបរិក្ខារដល់គ្រឹះស្ថានឧត្តមសិក្សា ដែលមានសក្តានុពល<br>- លើកទឹកចិត្ត និងគាំទ្រគ្រឹះស្ថានឧត្តមសិក្សា លើការបង្កើត និងអភិវឌ្ឍមជ្ឈមណ្ឌលឧត្តមភាព។ |

| **វត្ថុបំណងទី៣៖ បន្សីរវាងគម្រោងស្រាវជ្រាវជាមួយនឹងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច** | | |
|---|---|---|
| **សូចនាករផលសម្រេច** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនគម្រោងស្រាវជ្រាវទាក់ទងនឹងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចត្រូវបានបញ្ចប់ | N/A | ១០ |
| ចំនួនគម្រោងស្រាវជ្រាវដែលគាំទ្រដោយវិស័យឯកជនតាមរយៈមូលនិធិបរធនបាល | N/A | ២០ |
| ចំនួនមជ្ឈមណ្ឌលឧត្តមភាព | ៤ | ៧ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** លើកកម្ពស់គម្រោងស្រាវជ្រាវក្នុងវិស័យអាទិភាព | **ការផ្តល់ជំនួយលើការស្រាវជ្រាវ និងភាពជាដៃគូ**<br>- ផ្តល់ជំនួយស្រាវជ្រាវដល់ គ្រឹះស្ថានឧត្តមសិក្សា ដោយផ្អែកលើរបៀបវារៈស្រាវជ្រាវជាតិ និង/ឬអាទិភាព<br>- គាំទ្រដល់មន្ទីរពិសោធន៍នៅគ្រឹះស្ថានឧត្តមសិក្សា ដើម្បីបំពេញតាមស្តង់ដាជាតិ ឬអន្តរជាតិ<br>- គាំទ្រគ្រឹះស្ថានឧត្តមសិក្សា ដើម្បីបង្កើតផលិតផលគំរូដើមសម្រាប់ការស្រាវជ្រាវពាណិជ្ជកម្ម តាមរយៈភាពជាដៃគូជាមួយវិស័យឯកជន ឬឧស្សាហកម្ម។<br>**បទប្បញ្ញត្តិ និងគោលនយោបាយ**<br>- បង្កើតក្របខ័ណ្ឌច្បាប់ ដើម្បីសម្រួលដល់ការស្រាវជ្រាវពាណិជ្ជកម្ម។<br>- គាំទ្រគ្រឹះស្ថានឧត្តមសិក្សា ដើម្បីផលិតគោលនយោបាយហិរញ្ញប្បទានស្រាវជ្រាវ និងគោលការណ៍ណែនាំការគ្រប់គ្រងកន្លែងស្រាវជ្រាវសម្រាប់ពាណិជ្ជកម្មស្រាវជ្រាវ។ |
| **យុទ្ធសាស្ត្រទី២៖** គាំទ្រគ្រឹះស្ថានឧត្តមសិក្សា ដើម្បីកសាងភាពជាដៃគូជាមួយវិស័យឯកជន វេទិកាស្រាវជ្រាវ ឬចែករំលែកចំណេះដឹង | **វេទិកាស្រាវស្រាវ ឬការចែករំលែកចំណេះដឹង**<br>- បង្កើតវេទិកាសម្រាប់ការតភ្ជាប់ ឬកិច្ចសហប្រតិបត្តិការរវាងគ្រឹះស្ថានឧត្តមសិក្សា ឧស្សាហកម្ម ក្រុមហ៊ុនឯកជន និងអ្នកដទៃ<br>- បង្កើតវេទិកាចែករំលែកចំណេះដឹងស្រាវជ្រាវ (វេទិកា សន្និសីទ កម្មវិធីណែនាំ។ល។) |
| **យុទ្ធសាស្ត្រទី៣៖** លើកកម្ពស់ក្នុងការបង្កើតមជ្ឈមណ្ឌលឧត្តមភាពលើការស្រាវជ្រាវ | **ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពលើការស្រាវជ្រាវ**<br>- បង្កើតគោលការណ៍ណែនាំរបស់មជ្ឈមណ្ឌលឧត្តមភាពលើការស្រាវជ្រាវ<br>- ផ្តល់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវ និងសម្ភារបរិក្ខារដល់គ្រឹះស្ថានឧត្តមសិក្សា ដែលមានសក្តានុពលក្នុងការបង្កើតមជ្ឈមណ្ឌលឧត្តមភាពលើការស្រាវជ្រាវ<br>- គាំទ្រគ្រឹះស្ថានឧត្តមសិក្សា ដើម្បីបង្កើត និងអភិវឌ្ឍមជ្ឈមណ្ឌលឧត្តមភាព។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៣.៥ កម្មវិធីអាទិភាពទី៣៖ ការលើកកម្ពស់ជំនាញសតវត្សរ៍ទី២១ សម្រាប់យុវជន

**កម្មវិធីអាទិភាពទី៣**
**ការលើកកម្ពស់ជំនាញសតវត្សរ៍ទី២១ សម្រាប់យុវជន**

**ការអប់រំក្រៅប្រព័ន្ធ និងការសិក្សាពេញមួយជីវិត**
កុមារ យុវជន និងមនុស្សពេញវ័យ រួមទាំងអ្នកដែលមិនបានបញ្ចប់ការអប់រំក្នុងប្រព័ន្ធ ទទួលបានអត្ថប្រយោជន៍ពីកម្មវិធីបំណិនជីវិត និងកម្មវិធីបង្កើនប្រាក់ចំណូលដើម្បីជីវិតកាន់តែល្អប្រសើរ

**ការអភិវឌ្ឍយុវជន**
យុវជនមានចំណេះដឹង ជំនាញ សីលធម៌ល្អ សុខភាពល្អ សមត្ថភាពគ្រប់គ្រាន់ និងជាពលរដ្ឋល្អ សម្រាប់សតវត្សរ៍ទី២១

### ៣.៥.១ អនុកម្មវិធី ៣.១៖ ការអប់រំក្រៅប្រព័ន្ធ និងការសិក្សាពេញមួយជីវិត

**លទ្ធផលរំពឹងទុករបស់អនុកម្មវិធី៖ កុមារ យុវជន និងមនុស្សពេញវ័យ រួមទាំងអ្នកដែលមិនបានបញ្ចប់ការអប់រំក្នុងប្រព័ន្ធ ទទួលបានអត្ថប្រយោជន៍ពីកម្មវិធីបំណិនជីវិត និងកម្មវិធីបង្កើនប្រាក់ចំណូល ដើម្បីជីវិតកាន់តែល្អប្រសើរ**

| សូចនាករផលសម្រេច | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
|---|---|---|
| អត្រាអក្ខរកម្មមនុស្សពេញវ័យ (អាយុចាប់ពី ១៥ ឆ្នាំឡើងទៅ)[10] | ៨៤,៧% | ៩១,៥% |
| ប្រុស | ៨៩,៥% | ៩៦,៧% |
| ស្រី | ៨០,៣% | ៨៦,៧% |
| ចំនួនយុវជន និងមនុស្សពេញវ័យទទួលបានអត្ថប្រយោជន៍ពីកម្មវិធីបង្កើនប្រាក់ចំណូល | ៣ ៥៦៨ | ៥ ១៨៩ |
| ប្រុស | ១ ១០២ | ១ ៦០៣ |
| ស្រី | ២ ៤៦៦ | ៣ ៥៨៦ |
| ចំនួនមជ្ឈមណ្ឌលសិក្សាពេញមួយជីវិតគំរូ | ១ | ១០ |

**បញ្ហាប្រឈមគន្លឹះៗ**
**ការអប់រំក្រៅប្រព័ន្ធ និងការសិក្សាពេញមួយជីវិត**
- ការអនុវត្តក្របខ័ណ្ឌ និងយុទ្ធសាស្ត្រការអប់រំក្រៅប្រព័ន្ធមិនទាន់បានទូលំទូលាយ
- ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនមិនស្របតាមក្របខ័ណ្ឌបណ្តុះបណ្តាល របស់ការអប់រំក្រៅប្រព័ន្ធ

[10] ប្រភព៖ របាយការណ៍អង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជាឆ្នាំ២០២១

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

- ការគ្រប់គ្រងទិន្នន័យអប់រំក្រៅប្រព័ន្ធមិនទាន់បានគ្របដណ្តប់ទូលំទូលាយ និងគុណភាពនៃការអប់រំក្រៅប្រព័ន្ធភាពមិនទាន់ឆ្លើយតប
- ការចូលរួមរបស់អាជ្ញាធរ និងសហគមន៍ក្នុងការគាំទ្រការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធមិនទាន់ពេញលេញ
- ការអភិវឌ្ឍមជ្ឈមណ្ឌលសិក្សាសហគមន៍ ការផ្តល់ធនធានអប់រំក្រៅប្រព័ន្ធ និងកម្មវិធី ប្រែក្លាយពីមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលមានស្រាប់ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិតមិនទាន់បានអនុវត្តពេញលេញ
- ការគ្រប់គ្រងប្រព័ន្ធព័ត៌មានអប់រំក្រៅប្រព័ន្ធមិនទាន់បានអនុវត្តដល់កម្រិតក្រុង ស្រុក ខណ្ឌ
- កង្វះសៀវភៅសិក្សាគោលសម្រាប់ជំនាញមុខរបរងាយៗ និងសៀវភៅណែនាំសម្រាប់កម្មវិធីបង្កើនប្រាក់ចំណូល
- មិនមានប្រព័ន្ធសម្រាប់ការប្រមូលទិន្នន័យជាប្រចាំអំពីតម្រូវការជំនាញនៅតាមសហគមន៍
- កង្វះការអភិវឌ្ឍសមត្ថភាពសម្រាប់គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។

ដើម្បីដោះស្រាយបញ្ហាប្រឈមគន្លឹះៗដែលបានបង្ហាញខាងលើ អនុកម្មវិធីការអប់រំក្រៅប្រព័ន្ធ និងការសិក្សាពេញមួយជីវិតមានវត្ថុបំណងចំនួន៤ ដូចខាងក្រោម៖

១. បង្កើនលទ្ធភាពទទួលបានកម្មវិធីអប់រំក្រៅប្រព័ន្ធ និងសិក្សាពេញមួយជីវិតដោយយកចិត្តទុកដាក់ជាពិសេសចំពោះកុមារ យុវជន និងមនុស្សពេញវ័យ
២. ផ្តល់កម្មវិធីអប់រំក្រៅប្រព័ន្ធ និងសិក្សាពេញមួយជីវិត ស្របនឹងតម្រូវការអភិវឌ្ឍសហគមន៍
៣. បង្កើនលទ្ធភាពទទួលបានបំណិនជីវិត និងកម្មវិធីបង្កើនប្រាក់ចំណូល សម្រាប់កុមារ យុវជនក្រៅសាលា និងមនុស្សពេញវ័យ
៤. លើកកម្ពស់គុណភាព និងភាពពាក់ព័ន្ធនៃបំណិនជីវិត និងកម្មវិធីបង្កើនប្រាក់ចំណូល

ដើម្បីបង្កើនលទ្ធភាពទទួលបានកម្មវិធីអប់រំក្រៅប្រព័ន្ធ និងសិក្សាពេញមួយជីវិត ក្រសួងអប់រំ យុវជន និងកីឡា នឹងធ្វើការវិភាគអំពីតម្រូវការរបស់អ្នកសិក្សា ដើម្បីផ្តល់អាទិភាពដល់ទីតាំងសម្រាប់ផ្តល់អក្ខរកម្ម និងកម្មវិធីសមមូលបឋមសិក្សា និងមធ្យមសិក្សាអប់រំក្រៅប្រព័ន្ធ។ ក្រសួងនឹងពង្រីកសេវាអប់រំក្រៅប្រព័ន្ធ និងសិក្សាពេញមួយជីវិត ដោយផ្អែកលើការវិភាគ និងសហការជាមួយម្ចាស់រោងចក្រ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្តល់ជូនថ្នាក់រៀនដែលបង្រៀនផ្ទាល់ ក៏ដូចជាពង្រីកការផ្តល់សេវាឌីជីថលសម្រាប់អ្នកសិក្សាអប់រំក្រៅប្រព័ន្ធ និងសិក្សាពេញមួយជីវិត។

មជ្ឈមណ្ឌលសិក្សាសហគមន៍នឹងបន្តផ្លាស់ប្តូរទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ដែលនឹងផ្តល់នូវជម្រើសសិក្សា រួមមាន កម្មវិធីអប់រំក្រៅប្រព័ន្ធ បំណិនជីវិត និងកម្មវិធីបង្កើនប្រាក់ចំណូល។ ក្របខ័ណ្ឌវាយតម្លៃ និងសៀវភៅណែនាំស្តីពីការគ្រប់គ្រង និងប្រតិបត្តិការរបស់មជ្ឈមណ្ឌលសិក្សាពេញមួយជីវិតនឹងត្រូវបង្កើត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

កិច្ចខិតខំប្រឹងប្រែងនេះដើម្បីលើកកម្ពស់គុណភាព និងភាពពាក់ព័ន្ធនៃកម្មវិធីអប់រំក្រៅប្រព័ន្ធ រួមមានការបង្កើតក្របខ័ណ្ឌបណ្តុះបណ្តាលគ្រូសម្រាប់កម្មវិធីអក្ខរកម្ម និងសមមូល និងការធ្វើបច្ចុប្បន្នភាពកម្មវិធីអប់រំក្រៅប្រព័ន្ធ។ លើសពីនេះ យន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នឹងត្រូវបានបង្កើតឡើង ដើម្បីផ្តល់វិញ្ញាបនបត្រដល់អ្នកសិក្សា ដើម្បីទទួលស្គាល់លទ្ធផល និងសមត្ថភាពរបស់អ្នកសិក្សាគ្រប់កម្មវិធីអប់រំក្រៅប្រព័ន្ធ និងសិក្សាពេញមួយជីវិត។

ក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធ ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ និងសិក្សាពេញមួយជីវិត និងការកៀរគរធនធាន។ ចំណុចសំខាន់ដែលត្រូវយកចិត្តទុកដាក់ គឺការបង្កើតទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដើម្បីលើកកម្ពស់កម្មវិធីអប់រំក្រៅប្រព័ន្ធ និងសិក្សាពេញមួយជីវិត និងពង្រឹងក្រុមការងារបច្ចេកទេសអប់រំក្រៅប្រព័ន្ធ ដើម្បីគាំទ្រការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ និងសិក្សាពេញមួយជីវិត។

ម៉្យាងវិញទៀត សម្រាប់ការសិក្សាពេញមួយជីវិត ក្រសួងនឹងធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ ដើម្បីប្រមូល និងវិភាគទិន្នន័យជាប្រចាំ អំពីតម្រូវការជំនាញនៅតាមសហគមន៍ ដើម្បីបង្កើនការចូលរៀនក្នុងកម្មវិធីបំណិនជីវិត និងកម្មវិធីបង្កើនប្រាក់ចំណូលដល់យុវជនក្រៅសាលា និងមនុស្សពេញវ័យ។ ការធ្វើបច្ចុប្បន្នភាពទាំងនេះ នឹងផ្តល់ជាមូលដ្ឋានក្នុងការកំណត់អាទិភាពមុខជំនាញ ដែលឆ្លើយតបនឹងតម្រូវការរបស់អ្នកសិក្សា។ ក្រសួងនឹងពង្រីកការអនុវត្តកម្មវិធីបំណិនជីវិត និងកម្មវិធីបង្កើនប្រាក់ចំណូល តាមរយៈការប្រើប្រាស់បណ្តាញមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។

ដើម្បីបង្កើនគុណភាព និងភាពពាក់ព័ន្ធនៃកម្មវិធីបំណិនជីវិត និងកម្មវិធីបង្កើនប្រាក់ចំណូល ក្រសួងនឹងអភិវឌ្ឍសៀវភៅសិក្សាគោលសម្រាប់ជំនាញមុខរបរងាយៗ និងសៀវភៅណែនាំសម្រាប់កម្មវិធីបង្កើនប្រាក់ចំណូល។ ការកសាងសមត្ថភាពសម្រាប់គណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងអ្នកពាក់ព័ន្ធនៅតែជាអាទិភាព។

យុទ្ធសាស្ត្រ និងសកម្មភាពគោល ដើម្បីជំរុញវត្ថុបំណងទាំងនេះ មាននៅក្នុងតារាងខាងក្រោម៖

| **វត្ថុបំណងទី១៖ បង្កើនលទ្ធភាពទទួលបានកម្មវិធីអប់រំក្រៅប្រព័ន្ធ និងសិក្សាពេញមួយជីវិតដោយយកចិត្តទុកដាក់ ជាពិសេសចំពោះកុមារ យុវជន និងមនុស្សពេញវ័យ** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនអ្នកសិក្សានៅក្នុងកម្មវិធីអក្ខរកម្ម | ១៧ ៨៦១ | ១៨ ៣២៨ |
| ចំនួនអ្នកសិក្សានៅក្នុងកម្មវិធីសមមូល | ៨ ៣១០ | ៨ ៧០០ |
| ចំនួនអ្នកសិក្សានៅក្នុងកម្មវិធីចូលរៀនឡើងវិញ | ៥ ១១៤ | ៥ ៦០០ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** ពង្រីកកម្មវិធីអក្ខរកម្ម សមមូលបឋមសិក្សា និងមធ្យមសិក្សាអប់រំក្រៅប្រព័ន្ធ | **ការប្រើប្រាស់ទិន្នន័យ និងការវិភាគ**<br>- ធ្វើការប្រមូលព័ត៌មានអំពីតម្រូវការរបស់អ្នកសិក្សា<br>- កំណត់អាទិភាពទីតាំងថ្នាក់អក្ខរកម្ម សមមូលបឋមសិក្សា និងមធ្យមសិក្សាអប់រំក្រៅប្រព័ន្ធ។<br>**ការពង្រីកការផ្តល់ជូន**<br>- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយម្ចាស់រោងចក្រ សហគ្រាស និងអ្នកពាក់ព័ន្ធ<br>- ផ្តល់ការសិក្សាតាមគ្រប់រូបភាព រួមមានទាំងការរៀនផ្ទាល់ និងការរៀនតាមប្រព័ន្ធឌីជីថល។ |
| **យុទ្ធសាស្ត្រទី២៖** ផ្តល់កម្មវិធីចូលរៀនឡើងវិញនៅក្នុងតំបន់ដែលមានអត្រាបោះបង់ការសិក្សាខ្ពស់ | **ការប្រើប្រាស់ទិន្នន័យ និងការវិភាគ**<br>- កំណត់ និងផ្តល់អាទិភាពទីតាំងសម្រាប់កម្មវិធីចូលឡើងវិញដោយផ្អែកលើការវិភាគនៃតំបន់ដែលមានអត្រាបោះបង់ការសិក្សាខ្ពស់។<br>**ការពង្រីកការផ្តល់ជូន**<br>- ធ្វើការណែនាំតម្រង់ទិសដល់គ្រូបង្រៀនកម្មវិធីចូលរៀនឡើងវិញ<br>- បើកថ្នាក់ចូលរៀនឡើងវិញ។ |
| **យុទ្ធសាស្ត្រទី៣៖** ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ | - បង្កើតបណ្តាញជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធសម្រាប់លើកកម្ពស់កម្មវិធីអប់រំក្រៅប្រព័ន្ធ<br>- ពង្រឹងយន្តការនៃការអនុវត្តក្រុមការងារបច្ចេកទេសដើម្បីគាំទ្រដល់អនុវិស័យការអប់រំក្រៅប្រព័ន្ធ។ |

| **វត្ថុបំណងទី២៖ ផ្តល់កម្មវិធីអប់រំក្រៅប្រព័ន្ធ និងសិក្សាពេញមួយជីវិត ស្របនឹងតម្រូវការអភិវឌ្ឍសហគមន៍** | | |
|---|---|---|
| **សូចនាករផលលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនកម្មវិធីការសិក្សាពេញមួយជីវិតសម្រាប់ការអភិវឌ្ឍសហគមន៍ | ៧ | ៧ |
| ចំនួនមជ្ឈមណ្ឌលសិក្សាពេញមួយជីវិតបានបង្កើត | ៤ | ៣៣ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** អភិវឌ្ឍ និង/ឬការធ្វើបច្ចុប្បន្នភាព | **បង្កើតកម្មវិធីអប់រំក្រៅប្រព័ន្ធ និងសិក្សាពេញមួយជីវិតតាមសហគមន៍**<br>- ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា និងសម្ភារបង្រៀននិងរៀន |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| កម្មវិធីអប់រំក្រៅប្រព័ន្ធផ្អែកលើសហគមន៍ | - អភិវឌ្ឍកម្មវិធីសិក្សា កម្មវិធីសមមូលមធ្យមសិក្សាទុតិយភូមិអប់រំក្រៅប្រព័ន្ធ<br>- សាកល្បងកម្មវិធីសិក្សាដែលបានកែលម្អ<br>- កែប្រែ និងបោះពុម្ពកំណែថ្មី។ |
| **យុទ្ធសាស្ត្រទី២៖** ការផលិតសម្ភារបង្រៀននិងរៀនតាមឌីជីថល | **ការបង្រៀននិងរៀនតាមឌីជីថល**<br>- ផលិតវីដេអូបន្ថែមសម្រាប់ការបង្រៀននិងរៀន<br>- បង្កើត ឬធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងការសិក្សា។ |

| **វត្ថុបំណងទី៣៖ បង្កើនលទ្ធភាពទទួលបានបំណិនជីវិត និងកម្មវិធីបង្កើនប្រាក់ចំណូលសម្រាប់កុមារ យុវជនក្រៅសាលា និងមនុស្សពេញវ័យ** | | |
|---|---|---|
| សូចនាករលទ្ធផល | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
| ចំនួនអ្នកចូលរួមនៅក្នុងកម្មវិធីបណ្តុះបណ្តាលការសិក្សាពេញមួយជីវិត | ១០ ២៣៩ | ១៣ ០០០ |
| ចំនួនការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុកខណ្ឌ អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ | N/A | ៦៥ |

| យុទ្ធសាស្ត្រ | សកម្មភាព |
|---|---|
| **យុទ្ធសាស្ត្រទី១៖** អភិវឌ្ឍប្រព័ន្ធសម្រាប់ការប្រមូលទិន្នន័យជាប្រចាំលើតម្រូវការជំនាញនៅកម្រិតសហគមន៍ | **ការវិភាគ និងការប្រមូលទិន្នន័យ**<br>- ធ្វើបច្ចុប្បកម្មប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ<br>- បណ្តុះបណ្តាលបុគ្គលិកអប់រំក្រុង ស្រុក ខណ្ឌអំពីរបៀបប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធថ្មី<br>- ធ្វើការប្រមូលព័ត៌មាន និងវិភាគដើម្បីកំណត់តម្រូវការជំនាញសម្រាប់សហគមន៍។ |
| **យុទ្ធសាស្ត្រទី២៖** ពង្រីកវិសាលភាពកម្មវិធីបំណិនជីវិត និងកម្មវិធីបង្កើនប្រាក់ចំណូល | **លើកកម្ពស់ការយល់ដឹង**<br>- ធ្វើយុទ្ធនាការសហគមន៍ ដើម្បីលើកកម្ពស់ជំនាញ និងកម្មវិធីបង្កើនប្រាក់ចំណូល។<br>**ការអនុវត្តកម្មវិធី**<br>- អនុវត្តនិងធ្វើពិពិធកម្មកម្មវិធីបំណិនជីវិត និងបង្កើនប្រាក់ចំណូលដើម្បីបំពេញតម្រូវការសហគមន៍ដែលបានកំណត់<br>- សហការជាមួយរោងចក្រ សហគ្រាស ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិលសម្រាប់ការបណ្តុះបណ្តាលជំនាញ។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| **យុទ្ធសាស្ត្រទី៣៖** ផ្តល់កម្មវិធីបំណិនជីវិត និងបង្កើនប្រាក់ចំណូលឱ្យឆ្លើយតបទៅនឹងតម្រូវការសហគមន៍នៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍ និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត | **ហេដ្ឋារចនាសម្ព័ន្ធ និងបុគ្គលិកបង្រៀន**<br>- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅមជ្ឈមណ្ឌលសិក្សាសហគមន៍និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត<br>- ជ្រើសរើសគ្រូបង្រៀនសម្រាប់បណ្តុះបណ្តាលបំណិនជីវិត និងបង្កើនប្រាក់ចំណូល។<br>**ការអនុវត្តកម្មវិធី**<br>- ផ្តល់អាទិភាពលើការអនុវត្តការបណ្តុះបណ្តាលសម្រាប់មុខវិជ្ជាបង្កើនប្រាក់ចំណូល<br>- ផ្តល់ជំនាញមុខរបរងាយៗ។ |
| **យុទ្ធសាស្ត្រទី៤៖** ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ | **កិច្ចសហប្រតិបត្តិការ**<br>- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំជាមួយភាគីពាក់ព័ន្ធ<br>- ទស្សនកិច្ចសិក្សានៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិតជាមួយភាគីពាក់ព័ន្ធ ដើម្បីចែករំលែកឧត្តមានុវត្តន៍<br>- បង្កើនកិច្ចសហប្រតិបត្តិការជាមួយម្ចាស់រោងចក្រ សហគ្រាស ក្រុមហ៊ុន និងវិស័យឯកជន ដើម្បីគាំទ្រកម្មវិធីបំណិនជីវិត និងបង្កើនប្រាក់ចំណូល។ |
| **យុទ្ធសាស្ត្រទី៥៖** ប្រែក្លាយមជ្ឈមណ្ឌលសិក្សាសហគមន៍ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត | **ការវាយតម្លៃមជ្ឈមណ្ឌលសិក្សាសហគមន៍**<br>- ពិនិត្យ និងកែសម្រួលក្របខ័ណ្ឌវាយតម្លៃ មជ្ឈមណ្ឌលសិក្សាសហគមន៍<br>- អនុវត្តការវាយតម្លៃមជ្ឈមណ្ឌលសិក្សាសហគមន៍។<br>**ការប្រែក្លាយទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត**<br>- ជួសជុលមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលមានស្រាប់និងបំពាក់សម្ភារសិក្សា និងបង្រៀនជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល<br>- ផ្តល់កម្មវិធីសិក្សាចម្រុះ ដូចជាកម្មវិធីអប់រំក្រៅប្រព័ន្ធ កម្មវិធីបំណិនជីវិត និងកម្មវិធីបង្កើនប្រាក់ចំណូល។ |

| **វត្ថុបំណងទី៤៖ លើកកម្ពស់គុណភាព និងភាពពាក់ព័ន្ធនៃបំណិនជីវិត និងកម្មវិធីបង្កើនប្រាក់ចំណូល** | | |
|---|---|---|
| **សូចនាករផលលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងមជ្ឈមណ្ឌលសិក្សាសហគមន៍ បានទទួលការបណ្តុះបណ្តាលស្តីពីក្របខ័ណ្ឌកម្មវិធីសិក្សាបង្កើនប្រាក់ចំណូល | N/A | ៦០០ |
| ចំនួនសហគមន៍ដែលបានអនុវត្តកម្មវិធីការសិក្សាពេញមួយជីវិត | N/A | ៣៥០ |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** អភិវឌ្ឍ កម្មវិធីបំណិនជីវិត និងបង្កើនប្រាក់ចំណូល កម្មវិធីសិក្សា និងសម្ភារបង្រៀន និងរៀន | **ក្របខ័ណ្ឌកម្មវិធីសិក្សា**<br>- បង្កើតក្របខ័ណ្ឌកម្មវិធីសិក្សាបង្កើនប្រាក់ចំណូល<br>- ពង្រឹងកម្មវិធីសិក្សាសម្រាប់បំណិនជីវិត បំណិនបៃតង និងការបង្កើនប្រាក់ចំណូល ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមគោលដៅ និងតម្រូវការការងារ។<br>**សម្ភារគរុកោសល្យ**<br>- ពង្រឹងសម្ភារបង្រៀនសម្រាប់បំណិនជីវិត បំណិនបៃតង និងបង្កើនប្រាក់ចំណូល<br>- អភិវឌ្ឍសៀវភៅសិក្សា និងសៀវភៅណែនាំគ្រូសម្រាប់ជំនាញមុខរបរងាយៗសម្រាប់កម្មវិធីបង្កើនប្រាក់ចំណូល<br>- បោះពុម្ពសៀវភៅសិក្សា និងសៀវភៅណែនាំគ្រូ។ |
| **យុទ្ធសាស្ត្រទី២៖** ជំរុញការអនុវត្តក្របខ័ណ្ឌវាយតម្លៃមជ្ឈមណ្ឌលសិក្សាសហគមន៍ | **ការអភិវឌ្ឍក្របខ័ណ្ឌវាយតម្លៃ**<br>- ធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌការវាយតម្លៃ មជ្ឈមណ្ឌលសិក្សាសហគមន៍ដែលមានស្រាប់<br>- អនុវត្តសាកល្បងក្របខ័ណ្ឌការវាយតម្លៃដែលបានកែសម្រួលជាមួយមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលមានស្រាប់ ៣ ភាគរយ<br>- ធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌវាយតម្លៃដែលបានកែប្រែដោយផ្អែកលើការធ្វើតេស្តសាកល្បង។<br>**ក្របខ័ណ្ឌនៃការប្រើប្រាស់**<br>- វាយតម្លៃមជ្ឈមណ្ឌលសិក្សាសហគមន៍។ |
| **យុទ្ធសាស្ត្រទី៣៖** អភិវឌ្ឍសមត្ថភាពគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត | **ការអភិវឌ្ឍសមត្ថភាព**<br>- កសាងសមត្ថភាពគណៈ គ្រប់គ្រងលើការគ្រប់គ្រង និងប្រតិបត្តិការមជ្ឈមណ្ឌលសិក្សាសហគមន៍ និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត<br>- ធ្វើទស្សនកិច្ចសិក្សាទៅកាន់ មជ្ឈមណ្ឌលសិក្សាសហគមន៍ និងមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ដើម្បីចែករំលែកឧត្តមានុវត្តន៍ និងដំណោះស្រាយបញ្ហាប្រឈម។ |
| **យុទ្ធសាស្ត្រទី៤៖** បណ្តុះបណ្តាលបច្ចេកទេសដល់គ្រូបង្រៀនកម្មវិធីបំណិនជីវិត និងបង្កើនប្រាក់ចំណូល | **ការបណ្តុះបណ្តាល**<br>- អភិវឌ្ឍសៀវភៅណែនាំគ្រូបង្រៀនអំពីបំណិនជីវិត និងបង្កើនប្រាក់ចំណូល<br>- បើកវគ្គបណ្តុះបណ្តាលគ្រូបង្រៀនជ្រើសរើសថ្មី។ |

### ៣.៥.២ អនុកម្មវិធី ៣.២៖ ការអភិវឌ្ឍយុវជន

| លទ្ធផលរំពឹងទុករបស់អនុកម្មវិធី៖ យុវជនមានចំណេះដឹង ជំនាញ សីលធម៌ល្អ សុខភាពល្អ និងសមត្ថភាពពេញលេញ ដើម្បីក្លាយជាពលរដ្ឋល្អក្នុងសង្គម | | |
|---|---|---|
| សូចនាករផលសម្រេច | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
| ចំនួនយុវជនចូលរួមប្រកួតប្រជែងសមត្ថភាពថ្នាក់ជាតិ (គោលដៅសាលារៀនគំរូ) | N/A | ២ ៦៩០ |

**បញ្ហាប្រឈមគន្លឹះៗ**

- មន្ត្រីទទួលបន្ទុកការងារយុវជនជាច្រើននៅគ្រប់កម្រិតនៅមានតម្រូវការអភិវឌ្ឍសមត្ថភាពដើម្បីជានាការអនុវត្តគម្រោង និងការផលិតកម្មវិធីយុវជនប្រកបដោយគុណភាព ទោះបីជាមានជំនួយពីដៃគូពាក់ព័ន្ធក្នុងការរៀបចំកម្មវិធីយុវជនកន្លងមកក៏ដោយ
- ការសម្របសម្រួលការអនុវត្តកម្មវិធីយុវជនប្រកបដោយគុណភាពមិនទាន់សម្រេចបាន តាមលទ្ធផលដែលរំពឹងទុកនៅឡើយ
- មានការខ្វះខាតឧបករណ៍ សម្ភារៈ និងការផ្តត់ផ្គង់លើផ្នែកបច្ចេកវិទ្យា បច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់កម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការបណ្តុះបណ្តាលផ្សេងៗទៀតនៅតាមមជ្ឈមណ្ឌលយុវជន
- មជ្ឈមណ្ឌលយុវជនខេត្តមួយចំនួនមានដីតែគ្មានអគារ និងមជ្ឈមណ្ឌលមួយចំនួនផ្សេងទៀតរៀបចំវគ្គបណ្តុះបណ្តាលរបស់ខ្លួនដោយពឹងផ្អែកលើជំនួយពីដៃគូពាក់ព័ន្ធ។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ អនុកម្មវិធីយុវជនមានវត្ថុបំណងចំនួន២ ដូចខាងក្រោម៖

១. បណ្តុះបណ្តាលយុវជននូវចំណេះដឹង និងជំនាញ ដើម្បីមានអត្តចរិក និងសីលធម៌ល្អ តាមរយៈរចនាសម្ព័ន្ធ និងកម្មវិធីអភិវឌ្ឍយុវជននៅតាមសាលារៀន

២. ប្រមូលផ្តុំយុវជនឱ្យចូលរួមក្នុងកម្មវិធីអភិវឌ្ឍយុវជន។

ក្នុងការជំរុញការអភិវឌ្ឍជាតិ និងដោយចាត់ទុកពួកគេជាធនធានមនុស្ស ដែលមិនអាចកាត់ថ្លៃបាន ដើម្បីជំរុញប្រទេសជាតិឆ្ពោះទៅរកសង្គមដែលមានចំណេះដឹង និងវឌ្ឍនភាពសេដ្ឋកិច្ចសង្គមដ៏រឹងមាំ។ ដោយប្រកាន់ខ្ជាប់នូវក្រមសីលធម៌នៃ **"យុវជនមួយ មានជំនាញសំខាន់មួយ សម្រាប់ជីវិត"** យុវជនត្រូវបានជំរុញឱ្យចូលរួមការបណ្តុះបណ្តាលជំនាញចម្រុះជាច្រើនរួមមាន បច្ចេកវិទ្យា ចំណេះដឹងឌីជីថល ជំនាញបច្ចេកទេស ជំនាញវិជ្ជាជីវៈ ជំនាញភាពជាអ្នកដឹកនាំ និងទាំងជំនាញរឹង និងជំនាញទន់។ ជំនាញសំខាន់ៗទាំងនេះត្រូវបានពង្រឹងតាមរយៈការបញ្ជ្រាបគុណភាពដូចជា សុចរិតភាព ឥរិយាបថវិជ្ជមាន និងសីលធម៌ និងនាំយុវជនមានការរីកចម្រើនក្នុងនាមជាពលរដ្ឋដែលមានទំនួលខុសត្រូវក្នុងសតវត្សរ៍ទី២១។ តាមរយៈការជំរុញការ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ត្រៀមលក្ខណៈក្នុងស្រុក តំបន់ និងសកលសម្រាប់តម្រូវការទីផ្សារការងារ កម្ពុជាប្តេជ្ញាជានាឱ្យយុវជនរបស់ខ្លួនក្លាយជាអ្នករួមចំណែកប្រកបដោយប្រសិទ្ធភាពចំពោះវិបុលភាពក្នុងស្រុក និងវឌ្ឍនភាពអន្តរជាតិ។

ដើម្បីសម្រេចបាននូវវត្ថុបំណងខាងលើ អនុកម្មវិធីអភិវឌ្ឍយុវជនបានតម្រង់ទិសកម្មវិធីយុវជនឱ្យឆ្លើយតបទៅនឹងតម្រូវការនៃសតវត្សរ៍ទី២១។ កម្មវិធីយុវជនត្រូវបានអភិវឌ្ឍឱ្យមានលក្ខណៈបត់បែន ងាយស្រួលអនុវត្ត និងបំពេញបន្ថែមលើការសិក្សាក្នុងប្រព័ន្ធ ដើម្បីទាក់ទាញយុវជន កុមារ និងកាយរឹទ្ធិតាមរយៈការពង្រីកកម្មវិធីនិងការផ្សព្វផ្សាយ ការពង្រឹងនិងការអភិវឌ្ឍរចនាសម្ព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធការអភិវឌ្ឍយុវជន និងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធ។

កម្មវិធីយុវជននឹងត្រូវដាក់បញ្ចូលទៅក្នុងរចនាសម្ព័ន្ធយុវជននៅតាមសាលារៀន និងការផ្តល់ជូនការសិក្សាក្រៅម៉ោង ដើម្បីពង្រីកសេវាកម្មយុវជន និងធ្វើពិពិធកម្មកម្មវិធីយុវជន ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរសង្គម និងតម្រូវការយុវជន។ យុវជនត្រូវបានពង្រឹងសមត្ថភាពខ្លួន និងកៀរគរឲ្យចូលរួមតាមរយៈសកម្មភាព ឬកម្មវិធីផ្សេងៗ ដូចជា ការស្ម័គ្រចិត្ត ការជជែកពិភាក្សា ការកសាងក្រុម ការត្រិះរិះពិចារណា ភាពជាអ្នកដឹកនាំ ការប្រាស្រ័យទាក់ទង កាយរឹទ្ធិកម្ម សហគ្រិនភាព ការផ្លាស់ប្តូរយុវជនក្នុងស្រុក តំបន់ និងអន្តរជាតិ និងកម្មវិធីជាច្រើនផ្សេងៗទៀត។

លើសពីនេះ ដើម្បីធានាគុណភាព និងការផ្សព្វផ្សាយកម្មវិធី និងរចនាសម្ព័ន្ធនៃអនុកម្មវិធីយុវជន ត្រូវមានការចូលរួមរបស់សហគមន៍សាលារៀន និងកិច្ចសហការពីភាគីពាក់ព័ន្ធទាក់ទងនឹង ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុជាចាំបាច់។

យុទ្ធសាស្ត្រ និងសកម្មភាពគោល ដើម្បីជំរុញវត្ថុបំណងទាំងនេះ បានកំណត់ក្នុងតារាងខាងក្រោម៖

**វត្ថុបំណងទី១៖ បណ្តុះបណ្តាលយុវជនឱ្យមានចំណេះដឹង ជំនាញ ឥរិយាបថវិជ្ជមាន និងសីលធម៌ល្អ តាមរយៈកម្មវិធី និងយន្តការអភិវឌ្ឍយុវជននៅតាមសាលារៀន។**

| សូចនាករលទ្ធផល | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
|---|---|---|
| ចំនួនកុមារ និងយុវជន ចូលរួមក្នុងចលនាកាយរឹទ្ធិ | ១៧៥ ០០០ | ២០៥ ០០០ |
| ស្រី | ៨៨ ១៥០ | ១០០ ៦៥០ |
| ចំនួនក្រុមប្រឹក្សាយុវជន និងកុមារកម្ពុជាដែលដំណើរការ | | |
| ក្រុមប្រឹក្សាយុវជនកម្ពុជា | ៤១៩ | ៤៦៩ |
| ក្រុមប្រឹក្សាកុមារកម្ពុជា | ៤ ៧៣២ | ៦ ១៨២ |
| ចំនួនសាលារៀនគំរូបានអនុវត្តកម្មវិធីអភិវឌ្ឍន៍យុវជន | N/A | ១១០ |
| | | |



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** ការពង្រីកកម្មវិធីយុវជន | **ពិពិធកម្មកម្មវិធី**<br>- ពិពិធកម្មសកម្មភាពដើម្បីកសាងចំណេះដឹង និងជំនាញដែលជាតម្រូវការក្នុងសតវត្សរ៍ទី២១<br>- សម្រួចសកម្មភាពយុវជនដើម្បីទាក់ទាញចំណាប់អារម្មណ៍ផ្សេងៗ និងផ្តល់នូវបទពិសោធន៍ដ៏ល្អ<br>- បង្កើតឱកាសសម្រាប់យុវជនក្នុងការស្រាវជ្រាវ និងបង្កើតដំណោះស្រាយប្រកបដោយភាពបង្កើតថ្មី ដើម្បីជួយសហគមន៍ដោយប្រើប្រាស់មធ្យោបាយឌីជីថល តាមរយៈកម្មវិធី E-Gen<br>- បង្កើតកម្មវិធី អក្ខរកម្មឌីជីថល ដូចជា AI chatbot សម្រាប់យុវជនទូទាំងប្រទេស<br>- បង្កើតកម្មវិធីជំនាញសេដ្ឋកិច្ចមូលដ្ឋានសម្រាប់យុវជន។<br>**ការផ្សព្វផ្សាយកម្មវិធី**<br>- ពង្រឹងយុវជនឱ្យមានសមត្ថភាពពេញលេញទាំងចំណេះដឹង ជំនាញ និងបុគ្គលិកលក្ខណៈ តាមរយៈការលើកកម្ពស់កិច្ចសន្ទនាយុវជននៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់រៀន<br>- ជំរុញកាយរឹទ្ធិកម្មតាមរយៈកម្មវិធីអ្នកនាំសារសន្តិភាព និងកាយរឹទ្ធិសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ |
| **យុទ្ធសាស្ត្រទី២៖** ពង្រឹងរចនាសម្ព័ន្ធយុវជន (ក្រុមប្រឹក្សាកុមារកម្ពុជា ក្រុមប្រឹក្សាយុវជនកម្ពុជា និងកងឯកភាពកាយរឹទ្ធិ) | **ការគាំទ្ររចនាសម្ព័ន្ធ**<br>- បង្កើតគោលការណ៍ណែនាំសម្រាប់ការអនុវត្តការងារក្រុមប្រឹក្សាយុវជនកម្ពុជា<br>- ពង្រឹងរចនាសម្ព័ន្ធ (ប្រព័ន្ធល្បាត) របស់កងឯកភាពកាយរឹទ្ធិ ដោយការបំពាក់ និងវិនិយោគលើឯកសណ្ឋានកាយរឹទ្ធិសម្រាប់យុវជន និងអ្នកដឹកនាំមនុស្សពេញវ័យនៅសាលា និងសហគមន៍<br>- កែលម្អការអនុវត្តការងារក្រុមប្រឹក្សាកុមារ និងយុវជនកម្ពុជានៅតាមសាលាសាធារណៈ ដោយបង្កើតសៀវភៅណែនាំ ឃ្លីបវីដេអូអប់រំកាយរឹទ្ធិកម្ម ដើម្បីផ្សព្វផ្សាយនៅថ្នាក់សាលារៀន និងសហគមន៍។<br>**ការគាំទ្រសកម្មភាព**<br>- បញ្ចូលការងារក្រុមប្រឹក្សាកុមារ និងយុវជនកម្ពុជា និងកាយរឹទ្ធិកម្មទៅក្នុងសកម្មភាពក្រៅកម្មវិធីសិក្សាតាមស្តង់ដាសាលារៀនគំរូ។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី៣៖** កែលម្អគុណភាពនៃកម្មវិធីសិក្សាក្រៅម៉ោងសិក្សា តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល | **ការគាំទ្រសកម្មភាព**<br>- បញ្ចូលសកម្មភាពក្លឹបរបស់ក្រុមប្រឹក្សាយុវជនកម្ពុជា ជាសកម្មភាពក្រៅកម្មវិធីសិក្សា<br>- សមាហរណកម្មការចូលរួមរបស់ប្រជាពលរដ្ឋ និងការចូលរួមរបស់យុវជន ដើម្បីលើកកម្ពស់សមត្ថភាពសិស្ស និងរួមចំណែកក្នុងការអភិវឌ្ឍសាលារៀន<br>- បញ្ចូលខ្លឹមសារបច្ចេកទេស និងឌីជីថលទៅក្នុងកម្មវិធីកាយរឹទ្ធិកម្មដែលមានស្រាប់។<br>**ការកៀរគរធនធាន**<br>- កៀរគរធនធានបច្ចេកទេស និងហិរញ្ញវត្ថុ។ |
| **យុទ្ធសាស្ត្រទី៤៖** កិច្ចសហការជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធនៅក្នុង និងជុំវិញសាលារៀន | **ការធ្វើការងារជាមួយដៃគូ**<br>- សហការជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជនដើម្បីកែលម្អកម្មវិធីយុវជន<br>- សហការយ៉ាងជិតស្និទ្ធជាមួយសហគមន៍សាលារៀន<br>- កៀរគរធនធានពីភាគីពាក់ព័ន្ធ<br>- បង្កើតស្មារតីសហប្រតិបត្តិការសម្រាប់មន្ត្រីទទួលបន្ទុកការងារយុវជនតាមរយៈគោលនយោបាយ និងក្របខ័ណ្ឌបណ្តុះបណ្តាលធនធានមនុស្សពេញវ័យ ដើម្បីអ្នកដឹកនាំពេញវ័យបន្តចូលរួមជាមួយសិស្សានុសិស្ស និងសហគមន៍របស់ពួកគេ និងតាមរយៈការចូលរួមក្នុងវេទិកាអង្គការមិនមែនរដ្ឋាភិបាល និងសាជីវកម្ម ដែលភាគីពាក់ព័ន្ធអាចបង្ហាញគម្រោងរបស់ពួកគេទាក់ទងនឹងការអភិវឌ្ឍយុវជន ដើម្បីបន្សីគម្រោងជាមួយគ្នា។ |

**វត្ថុបំណងទី២៖ ប្រមូលផ្តុំយុវជនឱ្យចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍យុវជន។**

| សូចនាករលទ្ធផល | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
|---|---|---|
| ចំនួនកម្មវិធីអភិវឌ្ឍន៍យុវជនបានបង្កើត | N/A | ១២ |
| ចំនួនយុវជនចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍យុវជន | ២ ៣៨៥ | ៣ ៧៥០ |
| ចំនួនយុវជនបានចូលរួមក្នុងកម្មវិធីយុវជនអន្តរជាតិ | ១៧០ | ២៣០ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** ពង្រីកការគ្រប់ដណ្តប់នៃកម្មវិធីយុវជន ដោយយកចិត្តទុកដាក់លើ ស្វែម ឌីជីថល ការស្ម័គ្រចិត្ត សហគ្រិនភាព ភាពជាអ្នកដឹកនាំ និងជំនាញសតវត្សរ៍ទី២១ | **ការវាយតម្លៃស្តីពីតម្រូវការ**<br>- វាយតម្លៃតម្រូវការយុវជនសម្រាប់ការអភិវឌ្ឍជំនាញ និងសមត្ថភាព។<br>**ការពង្រីកការគ្រប់ដណ្តប់នៃកម្មវិធី**<br>- បង្កើតកម្មវិធីប្រកួតប្រជែងសមត្ថភាពយុវជនបន្ថែមទាក់ទងនឹង ស្វែម ឌីជីថល ស្ម័គ្រចិត្ត សហគ្រិនភាព<br>- ធ្វើបច្ចុប្បន្នភាព និងកែលម្អខ្លឹមសារនៃកម្មវិធីយុវជនដែលមានស្រាប់លើ ស្វែម ឌីជីថល ស្ម័គ្រចិត្ត សហគ្រិនភាព និងជំនាញសតវត្សរ៍ទី២១<br>- ពង្រឹងកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយដោយបង្កើតការចូលរួមនិម្មិតបន្ថែមទៀតនៅក្នុងកម្មវិធីបណ្តុះបណ្តាលយុវជន ការផ្សាយបន្តផ្ទាល់នៅលើវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម និងទូរទស្សន៍។<br>**ការគាំទ្រកម្មវិធី**<br>- ចូលរួមជាមួយរាជធានី-ខេត្តក្នុងការជ្រើសរើស បណ្តុះបណ្តាល បង្វឹក និងការអនុវត្តគម្រោងយុវជន<br>- បង្កើតក្របខ័ណ្ឌទទួលស្គាល់ការងារស្ម័គ្រចិត្ត។ |
| **យុទ្ធសាស្ត្រទី២៖** ពង្រីកកម្មវិធីផ្សព្វផ្សាយយុវជន | **ការពង្រីកកម្មវិធី**<br>- ពង្រីកកម្មវិធីយុវជនដោយផ្តោតលើគោលគំនិតនៃអាកប្បកិរិយាល្អ ភាពជាអ្នកដឹកនាំ និងជំនាញសតវត្សរ៍ទី២១។<br>**ឱកាសសម្រាប់យុវជន**<br>- ផ្តល់ឱកាស និងលទ្ធភាពកាន់តែប្រសើរឡើងដល់យុវជន ដើម្បីបង្ហាញអំពីស្ថានភាពជីវិតពិត តាមរយៈកម្មវិធីដូចជា អ្នកស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ ការជជែកដេញដោលយុវជនថ្នាក់ជាតិ E-Gen ការប្រកួត-ប្រជែងផែនការអាជីវកម្ម ដែលយុវជនកំណត់បញ្ហានៅក្នុងសហគមន៍របស់ពួកគេ និងបង្កើតដំណោះស្រាយប្រកបដោយគំនិតបង្កើតថ្មី ដែលមានគាំទ្រផ្នែកការបណ្តុះបណ្តាល និងការបង្វឹកពីអ្នកសម្របសម្រួលកម្មវិធី<br>- បង្កើតកម្មវិធីផ្លាស់ប្តូរយុវជនជាតិ និងអន្តរជាតិ។ |
| **យុទ្ធសាស្ត្រទី៣៖** លើកកម្ពស់គុណភាពនៃកម្មវិធីប្រកួត-ប្រជែងសមត្ថភាពយុវជន | **ការផលិតកម្មវិធី**<br>- សម្រួចកម្មវិធីបណ្តុះបណ្តាលទៅរកជំនាញបច្ចេកទេស និងឌីជីថលស្របតាមតម្រូវការទីផ្សារការងារ<br>- ពង្រឹងមាតិកា និងខ្លឹមសារកម្មវិធី តាមរយៈការវាយតម្លៃជាមួយដៃគូពាក់ព័ន្ធ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - បណ្ដុះបណ្ដាល និងការអភិវឌ្ឍគ្រូឧទ្ទេសលើមាតិកា និងខ្លឹមសារកម្មវិធីដែលបានកែលម្អ<br>- សិក្សា និងវាយតម្លៃអំពីផលជះនៃកម្មវិធី។<br>**ការអនុវត្តកម្មវិធី**<br>- ពង្រឹងការអនុវត្តកម្មវិធីយុវជន<br>- ពង្រឹងគុណភាពកម្មវិធីបណ្ដុះបណ្ដាលនៅមជ្ឈមណ្ឌលយុវជន។ |
| **យុទ្ធសាស្ត្រទី៤៖** អភិវឌ្ឍ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធយុវជន | **គ្រឿងបរិក្ខារនិងឧបករណ៍**<br>- ជួសជុលអគារមជ្ឈមណ្ឌលយុវជន<br>- កែលម្អ និងបំពាក់គ្រឿងបរិក្ខារនៅមជ្ឈមណ្ឌលយុវជន ដោយផ្អែកលើតម្រូវការប្រតិបត្តិការ និងសកម្មភាពអភិវឌ្ឍយុវជន។ |
| **យុទ្ធសាស្ត្រទី៥៖** សហការជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធរួមមានដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងតួអង្គក្នុងវិស័យឯកជន | **ការធ្វើការងារជាមួយដៃគូ៖**<br>- សហការជាមួយដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជនដើម្បីកែលម្អកម្មវិធីយុវជន<br>- កៀរគរធនធានពីភាគីពាក់ព័ន្ធ<br>- កសាងស្មារតីសហប្រតិបត្តិការសម្រាប់មន្ត្រីទទួលបន្ទុកការងារយុវជនតាមរយៈការចូលរួមនៅក្នុងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល និងសាជីវកម្ម និងគម្រោងទំនួលខុសត្រូវសង្គមនៃវិស័យឯកជន (CSR) និងតាមរយៈការចែករំលែកគុណតម្លៃស្នូល និងបទពិសោធរួមគ្នាក្នុងការអភិវឌ្ឍយុវជន។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៣.៦ កម្មវិធីអាទិភាពទី ៤៖ ការអភិវឌ្ឍសកម្មភាពហាត់ប្រាណ ការអប់រំកាយ និងកីឡា

**កម្មវិធីអាទិភាពទី ៤៖**

**ការអភិវឌ្ឍសកម្មភាពហាត់ប្រាណ ការអប់រំកាយ និងកីឡា**

**សកម្មភាពហាត់ប្រាណ និងការអប់រំកាយ៖**

ការអនុវត្តកម្មវិធីអប់រំកាយ និងកីឡាប្រកបដោយបរិយាបន្ន សិស្សានុសិស្សទទួលបានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា និងសកម្មភាពហាត់ប្រាណ និងលេងកីឡា នាំឱ្យប្រជាជនទទួលបាននូវកាយសម្បទារឹងមាំ និងសុខភាពល្អ។

**កីឡា៖**

គ្រូបង្វឹក និងមន្ត្រីបច្ចេកទេសប្រកបដោយគុណវុឌ្ឍិកម្រិតអន្តរជាតិនៃប្រភេទកីឡា និងអត្តពលិក ដែលមានទេពកោសល្យ និងសមត្ថភាពខ្ពស់ និងអត្តពលិកដែលមានសក្តានុពល ទេពកោសល្យ និងកំណត់ត្រាគុណផលខ្ពស់ ចូលរួមក្នុងការប្រកួតដណ្តើមមេដាយថ្នាក់ជាតិ និងអន្តរជាតិលើគ្រប់ប្រភេទកីឡាដោយជោគជ័យ។

### ៣.៦.១ អនុកម្មវិធី ៤.១៖ សកម្មភាពហាត់ប្រាណ និងការអប់រំកាយ

| លទ្ធផលរំពឹងទុករបស់អនុកម្មវិធី៖ ការអនុវត្តការអប់រំកាយ សកម្មភាពហាត់ប្រាណ និងកីឡា នាំឱ្យប្រជាជនទទួលបាននូវកាយសម្បទារឹងមាំ និងសុខភាពល្អ | | |
|---|---|---|
| **សូចនាករផលសម្រេច** | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
| ភាគរយប្រជាជនបានចូលរួមក្នុងសកម្មភាពហាត់ប្រាណ និងលេងកីឡានៅតាមទីប្រជុំជន | ២០,២% | ២៥% |

**បញ្ហាប្រឈមគន្លឹះៗ**

- តំបន់ហាត់ប្រាណ និងលេងកីឡានៅគ្រប់រាជធានី-ខេត្ត មិនទាន់ឆ្លើយតបនឹងតម្រូវការ
- សមត្ថភាពរបស់មន្ត្រីកីឡាមួយចំនួនទទួលបន្ទុកផ្នែកអប់រំកាយ និងកីឡា នៅមានកម្រិត និងមិនគ្រប់គ្រាន់លើផ្នែកការស្រាវជ្រាវ និងការអភិវឌ្ឍ
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងស្ថិតិកីឡាមិនទាន់បានអនុវត្តពេញលេញ
- ការអនុវត្តកម្មវិធីអប់រំកាយក្នុងម៉ោងសិក្សា និងកីឡាក្រៅម៉ោងសិក្សាអនុវត្តមិនទាន់បានពេញលេញ
- គ្រឹះស្ថានសិក្សាពុំទាន់មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់សម្រាប់អនុវត្តកម្មវិធីអប់រំកាយ និងកីឡា។

ដើម្បីដោះស្រាយបញ្ហាប្រឈមគន្លឹះៗដែលបានបង្ហាញខាងលើ អនុកម្មវិធីសកម្មភាពហាត់ប្រាណ និងការអប់រំកាយមានវត្ថុបំណងចំនួន១៖

១. ពង្រីកការអនុវត្តការអប់រំកាយក្នុងម៉ោងសិក្សា និងកីឡាក្រៅម៉ោងសិក្សាប្រកបដោយបរិយាបន្ន ប្រសិទ្ធភាពនិងគុណភាព

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

២. លើកកម្ពស់សុខុមាលភាពរបស់ប្រជាជនតាមរយៈការហាត់ប្រាណ ការអប់រំកាយ និងកីឡា ដើម្បីសុខភាព

ដើម្បីពង្រីកការអនុវត្តការអប់រំកាយ និងកីឡាប្រកបដោយបរិយាបន្នក្នុង និងក្រោយម៉ោងសិក្សា អគ្គនាយកដ្ឋានកីឡានឹងអភិវឌ្ឍបន្ថែមទៀតនូវកម្មវិធីសិក្សា និងសម្ភារបង្រៀន និងការរៀនប្រកបដោយបរិយាបន្ន រួមទាំងសៀវភៅសិក្សា និងវីដេអូសម្រាប់ការអប់រំកាយ និងកីឡាសម្រាប់ប្រើប្រាស់ក្នុងនិងក្រៅម៉ោងសិក្សា។ សម្ភារកីឡានឹងបែងចែកសម្រាប់កុមារី និងកុមារដែលមានសមត្ថភាពខុសៗគ្នា ដែលចូលរួមក្នុងសកម្មភាពអប់រំកាយ និងកីឡា ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងសមធម៌។ អគ្គនាយកដ្ឋានកីឡានឹងសហការជាមួយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ដើម្បីអភិវឌ្ឍសមត្ថភាពគ្រូអប់រំកាយ និងកីឡាឱ្យប្រើប្រាស់សៀវភៅសិក្សា និងវីដេអូប្រកបដោយប្រសិទ្ធភាព ក្នុងអំឡុងពេលអប់រំកាយ។ សេចក្តីណែនាំដើម្បីពង្រឹងការអនុវត្តសកម្មភាពអប់រំកាយក្នុងម៉ោងសិក្សា និងសកម្មភាពកីឡាក្រៅកម្មវិធីសិក្សាក៏នឹងដាក់ឱ្យអនុវត្តផងដែរ។ ការពង្រឹងសមត្ថភាពលើការស្រាវជ្រាវ និងធ្វើអង្កេតស្ថិតិពីសកម្មភាពហាត់ប្រាណ អប់រំកាយ និងកីឡា នឹងត្រូវធ្វើឡើងជាបន្តបន្ទាប់។

ដើម្បីលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនតាមរយៈការធ្វើលំហាត់ប្រាណ ការអប់រំកាយ និងកីឡា ដើម្បីសុខភាព អគ្គនាយកដ្ឋានកីឡានឹងរៀបចំ និងអនុវត្តកម្មវិធី ដើម្បីបំផុសគំនិតប្រជាជនឱ្យលេងកីឡាយ៉ាងហោចណាស់មួយ។ កម្មវិធីនេះនឹងត្រូវធ្វើឡើងតាមរយៈយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ ដែលលើកកម្ពស់អត្ថប្រយោជន៍ដល់សុខុមាលភាពទាក់ទងនឹងសកម្មភាពហាត់ប្រាណ និងកីឡា។

យុទ្ធនាការទាំងនេះក៏នឹងជំរុញការអភិរក្ស និងអភិវឌ្ឍកីឡាប្រពៃណី តាមរយៈការរៀបចំកីឡាសម្រាប់ទាំងអស់គ្នា ទិវាកីឡាអាស៊ាន ទិវាអាស៊ានហាត់ប្រាណដើម្បីសុខភាព និងទិវាអប់រំកាយជាតិក្នុងរាជធានី-ខេត្ត និងសហគមន៍។

អគ្គនាយកដ្ឋានកីឡាក៏នឹងរៀបចំបទដ្ឋានគតិយុត្ត និងផែនការយុទ្ធសាស្ត្រជាតិដើម្បីកំណត់ «**ឃុំមួយកន្លែងហាត់ប្រាណមួយ និងទីលានកីឡាមួយ**» នៅថ្នាក់រាជធានី-ខេត្ត ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ និងធ្វើការជាមួយអាជ្ញាធរសហគមន៍ ដើម្បីកៀរគរការវិនិយោគ សម្រាប់រៀបចំកន្លែងហាត់ប្រាណ និងសួនកុមារ។ កន្លែងហាត់ប្រាណ និងសួនកុមារទាំងនេះ នឹងត្រូវបានប្រើប្រាស់ សម្រាប់ការអប់រំកាយ និងសកម្មភាពកីឡារបស់សាលារៀន និងសហគមន៍។

ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្ត និងផ្តល់អាជ្ញាបណ្ណដល់វិស័យឯកជនដើម្បីបើកដំណើរការសាលាអប់រំកាយ និងកីឡា សាលាកីឡា បណ្ឌិត្យសភាកីឡា ដើម្បីចូលរួមជាមួយរដ្ឋាភិបាលក្នុងការអភិវឌ្ឍ

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

មូលធនមនុស្សប្រកបដោយប្រសិទ្ធភាព និងបំពេញតាមតម្រូវការចាំបាច់ក្នុងពន្លឿនការអភិវឌ្ឍជំនាញកីឡាជាតិ និងកីឡាកម្រិតខ្ពស់ស្របតាមស្តង់ដាតំបន់ និងអន្តរជាតិ។

យុទ្ធសាស្ត្រ និងសកម្មភាពគោល ដើម្បីជំរុញវត្ថុបំណងទាំងនេះ បានកំណត់ក្នុងតារាងខាងក្រោម៖

| **វត្ថុបំណងទី១៖ ពង្រីកការអនុវត្តការអប់រំកាយក្នុងម៉ោងសិក្សា និងកីឡាក្រៅម៉ោងសិក្សាប្រកបដោយបរិយាបន្ន ប្រសិទ្ធភាព និងគុណភាព** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនសាលារៀនគំរូដែលអនុវត្តការអប់រំកាយក្នុង និងក្រៅម៉ោងសិក្សា | ១២០ | ៥០០ |
| ចំនួនគ្រូអប់រំកាយ និងកីឡា បានបណ្តុះបណ្តាលអំពីរបៀបអនុវត្តការអប់រំកាយប្រកបដោយប្រសិទ្ធភាពនៅតាមសាលារៀន | N/A | ៧០០ |
| ចំនួនគ្រូអប់រំកាយ និងកីឡា បានទទួលការបណ្តុះបណ្តាលវិក្រឹតការប្រចាំឆ្នាំ | ១០០ | ២៧៥ |

| **យុទ្ធសាស្ត្រ** | **សកម្មភាពគោល** |
|---|---|
| **យុទ្ធសាស្ត្រទី ១៖** អភិវឌ្ឍកម្មវិធីសិក្សា និងសម្ភារបង្រៀន និងការរៀនរួមមានវីដេអូ សម្រាប់ការអប់រំកាយក្នុងម៉ោងសិក្សា និងកីឡាក្រៅម៉ោងសិក្សា ប្រកបដោយសមភាពយេនឌ័រ និងសមធម៌ | **កម្មវិធី**<br>- បង្កើតកម្មវិធីអប់រំកាយ និងកីឡាប្រកបដោយបរិយាបន្ននៅគ្រប់កម្រិត តាមរយៈការអភិវឌ្ឍស្តង់ដាសាលារៀនគំរូទាក់ទងនឹងការអប់រំកាយ និងកីឡា<br>- ពង្រឹងការអនុវត្តស្តង់ដាអប្បបរមាសម្រាប់អប់រំកាយ និងកីឡាក្នុងម៉ោងសិក្សា និងក្រៅម៉ោងសិក្សានៅសាលារៀនគំរូ<br>- អភិវឌ្ឍវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ទៅជាគ្រឹះស្ថានឧត្តមសិក្សា<br>- ពង្រឹង និងពង្រីកប្រព័ន្ធវិក្រឹតការ រួមទាំងប្រព័ន្ធវាយតម្លៃគុណភាព និងវាយតម្លៃគុណភាពស្ថាប័នចំពោះដំណើរការវគ្គវិក្រឹតការ<br>- ធ្វើការបណ្តុះបណ្តាល និងវិក្រឹតការជំនាញអប់រំកាយ និងកីឡា ក្នុងទម្រង់បង់ថ្លៃសិក្សា និងអាហារូបករណ៍សម្រាប់សិស្សថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់<br>- រៀបចំស្តង់ដាអប់រំកាយ និងកីឡាជាតិ។<br>**សម្ភារគរុកោសល្យ**<br>- ផលិត និងផ្សព្វផ្សាយវីដេអូសម្រាប់សិស្សទាំងអស់ (រួមទាំងសិស្សដែលងាយរងគ្រោះ) នៃសកម្មភាពអប់រំកាយ និងកីឡាសម្រាប់ប្រើប្រាស់ក្នុងម៉ោងសិក្សា |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - រៀបចំឧបករណ៍ដើម្បីតាមដាន និងវាយតម្លៃសកម្មភាពនៃការបង្រៀន និងរៀនមុខវិជ្ជាអប់រំកាយគ្រប់កម្រិត<br>- បណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា លើការអនុវត្តកម្មវិធីអប់រំកាយនៅសាលា។<br>**ការរៀបចំផែនការ**<br>- ផ្តល់អាជ្ញាបណ្ណ និងលើកទឹកចិត្តវិស័យឯកជនបើកសាលាអប់រំកាយ និងកីឡា សាលាកីឡា និងបណ្ឌិត្យសភាកីឡា។ |
| **យុទ្ធសាស្ត្រទី២៖** សហការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូ និងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ដើម្បីបង្កើតកម្មវិធីអប់រំគ្រូបង្រៀន និងពង្រឹងសមត្ថភាពគ្រូអប់រំកាយ និងកីឡា | **ការបណ្តុះបណ្តាល**<br>- តាមរយៈវគ្គខ្លីៗ បណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា (នៅតាមរាជធានី-ខេត្ត) ពីរបៀបអនុវត្តសៀវភៅសិក្សាអប់រំកាយ និងកីឡាឱ្យមានប្រសិទ្ធភាព<br>- អភិវឌ្ឍគ្រូបណ្តុះបណ្តាលដែលទទួលខុសត្រូវលើការធ្វើតេស្តកាយសម្បទានៅក្នុងសាលារៀន។<br>**សៀវភៅសិក្សា**<br>- បង្កើនគុណភាពក្នុងការអភិវឌ្ឍសៀវភៅអប់រំកាយ និងកីឡា។<br>**ការត្រួតពិនិត្យ និងការវាយតម្លៃ**<br>- តាមដាន និងវាយតម្លៃវិធីសាស្ត្របង្រៀនរបស់គ្រូអប់រំកាយ និងកីឡាដោយប្រើឧបករណ៍ដែលទើបបង្កើតថ្មី។ |
| **យុទ្ធសាស្ត្រទី៣៖** អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលផ្តល់លទ្ធភាពទទួលបានពេញលេញ និងសុវត្ថិភាពសម្រាប់ការអប់រំកាយ និងកីឡា ផ្អែកលើសមភាព-យេនឌ័រ សមធម៌ និងសិស្សដែលមានពិការភាព | **ការលើកកម្ពស់ការយល់ដឹង**<br>- ជំរុញឱ្យសាលាគរុកោសល្យមានបរិក្ខារសម្រាប់ការអប់រំកាយ និងកីឡាឱ្យស្របតាមស្តង់ដាសាលារៀនគំរូ<br>- លើកទឹកចិត្តអាជ្ញាធរមូលដ្ឋាន និងភាពជាដៃគូជាមួយផ្នែកឯកជនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធអប់រំកាយ និងកីឡា<br>- រៀបចំគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ដោយសុវត្ថិភាព និងការថែទាំហេដ្ឋារចនាសម្ព័ន្ធអប់រំកាយ និងកីឡាស្របតាមបទដ្ឋានបច្ចេកទេស។<br>**ហេដ្ឋារចនាសម្ព័ន្ធ**<br>- សាងសង់ ជួសជុល កែលម្អ និងថែទាំហេដ្ឋារចនាសម្ព័ន្ធអប់រំកាយ និងកីឡាក្នុងសាលាគរុកោសល្យ និងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា<br>- រៀបចំបន្ទប់ពិសោធន៍អប់រំកាយ និងកីឡានៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា។ |

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| | |
|---|---|
| | **ការបណ្ដុះបណ្ដាល**<br>- បណ្ដុះបណ្ដាលក្រុមបច្ចេកទេសថែរក្សាហេដ្ឋារចនាសម្ព័ន្ធអប់រំកាយ និងកីឡា។ |

| **វត្ថុបំណងទី២៖ លើកកម្ពស់សុខុមាលភាពរបស់ប្រជាជនតាមរយៈការហាត់ប្រាណ ការអប់រំកាយ និងកីឡាដើម្បីសុខភាព** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនប្រភេទកីឡាដែលបំផុសសកម្មភាពហាត់ប្រាណ និងលេងកីឡា ក្នុងទិវាកីឡាសម្រាប់ទាំងអស់គ្នា ទិវាកីឡាអាស៊ាន និងទិវាអាស៊ានហាត់ប្រាណដើម្បីសុខភាពល្អ | ១០ | ១៥ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** កែលម្អ និងអនុវត្តកម្មវិធីដើម្បីជំរុញទឹកចិត្តប្រជាជនម្នាក់ឱ្យលេងកីឡាយ៉ាងហោចណាស់មួយសម្រាប់ជីវិត | **ការផ្សព្វផ្សាយ**<br>- ផ្សព្វផ្សាយតាមរយៈគេហទំព័ររបស់ទស្សនាវដ្ដីកីឡា និងព្រឹត្តិបត្រព័ត៌មានអប់រំកាយ និងកីឡា។<br>- ផលិតវីដេអូ ផ្ទាំងរូបភាព បដា ផ្ទាំងប៉ាណូ និងស្លាកសញ្ញាសម្រាប់ការអប់រំកាយ និងកីឡា ហើយដាក់បង្ហាញជាសាធារណៈ។<br>- ជំរុញការអភិរក្ស និងការអភិវឌ្ឍកីឡាប្រពៃណី តាមរយៈការរៀបចំទិវាជាតិអប់រំកាយ ទិវាកីឡាសម្រាប់ទាំងអស់គ្នា ទិវាកីឡាអាស៊ាន ទិវាអាស៊ានហាត់ប្រាណ តាមរាជធានី-ខេត្ត និងសហគមន៍។<br>**កិច្ចសហប្រតិបត្តិការ**<br>- អនុវត្តសកម្មភាពអាស៊ាន ភាពជាដៃគូអាស៊ាន និងកិច្ចសហប្រតិបត្តិការអន្តរជាតិលើការអភិវឌ្ឍការអប់រំកាយ និងកីឡា<br>- សហការជាមួយប្រព័ន្ធផ្សព្វផ្សាយរដ្ឋ និងអ្នកបង្កើតមាតិកាល្បីៗលើប្រព័ន្ធទំនាក់ទំនងសង្គមដើម្បីជំរុញយុទ្ធនាការ និងកម្មវិធីជំរុញទឹកចិត្តប្រជាជនម្នាក់ឱ្យលេងកីឡាយ៉ាងហោចណាស់មួយសម្រាប់ជីវិត។<br>**ការស្រាវជ្រាវ**<br>- ស្រាវជ្រាវ ចងក្រង និងរក្សាទុកទិន្នន័យអប់រំកាយ និងកីឡាគ្រប់ប្រភេទ។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - ធ្វើការស្រាវជ្រាវលើផលប៉ះពាល់នៃការហាត់ប្រាណ ការអប់រំកាយ និងកីឡាលើសុខុមាលភាព និងសុខភាពរបស់ប្រជាជននៅរាជធានី-ខេត្ត និងសហគមន៍។ |
| **យុទ្ធសាស្ត្រទី២៖** លើកកម្ពស់ការធ្វើតេស្តកាយសម្បទាប្រជាជន | **ការបណ្តុះបណ្តាល**<br>- បណ្តុះបណ្តាលមន្ត្រីជំនាញតាមរាជធានី-ខេត្តលើការធ្វើតេស្តកាយសម្បទាប្រជាជន និងធ្វើការត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំ។<br>**ការផ្សព្វផ្សាយ**<br>- រៀបចំគោលការណ៍ណែនាំអំពីស្តង់ដាវាយតម្លៃតេស្តកាយសម្បទា និងប្រជាជន<br>- លើកទឹកចិត្តភាពជាដៃគូរដ្ឋ និងឯកជនក្នុងការអភិវឌ្ឍកម្មវិធីទូរស័ព្ទដៃស្តង់ដាវាយតម្លៃកាយសម្បទា (Fit Cambodia App)។<br>**ហេដ្ឋារចនាសម្ព័ន្ធ**<br>- សាងសង់ ជួសជុល កែលម្អ និងថែទាំសកម្មភាពហាត់ប្រាណ និងសម្ភារកីឡា និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសហគមន៍។ |

### ៣.៦.២ អនុកម្មវិធី ៤.២៖ កីឡា

**លទ្ធផលរំពឹងទុករបស់អនុកម្មវិធី៖** គ្រូបង្វឹក និងមន្ត្រីបច្ចេកទេសប្រកបដោយគុណវុឌ្ឍិកម្រិតអន្តរជាតិនៃប្រភេទកីឡា និងអត្តពលិក ដែលមានទេពកោសល្យ និងសមត្ថភាពខ្ពស់ និងអត្តពលិកដែលមានសក្តានុពលទេពកោសល្យ និងកំណត់ត្រាគុណផលខ្ពស់ ចូលរួមក្នុងការប្រកួតដណ្តើមមេដាយថ្នាក់ជាតិ និងអន្តរជាតិលើគ្រប់ប្រភេទកីឡាដោយជោគជ័យ។

| សូចនាករផលសម្រេច | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
|---|---|---|
| ចំនួនមេដាយក្នុងការប្រកួតកីឡាលក្ខណៈហ្គេម | ៣៩៥ | ១០ |

**បញ្ហាប្រឈមគន្លឹះៗ**

- សមត្ថភាពរបស់មន្ត្រីវិទ្យាសាស្ត្រកីឡា និងពេទ្យកីឡាទាំងបរិមាណ និងគុណភាពមិនឆ្លើយតបតម្រូវការ
- ការអនុវត្តវិទ្យាសាស្ត្រកីឡា និងវេជ្ជសាស្ត្រកីឡាតាមប្រភេទកីឡាដោយសហព័ន្ធកីឡាជាតិនៅមានកម្រិត
- កង្វះការវាយតម្លៃ និងតាមដានលក្ខណៈបច្ចេកទេសក្នុងពេលប្រកួតកីឡា ដោយផ្អែកលើឯកទេសកីឡា
- ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខារកីឡា សម្រាប់ការអនុវត្តវិទ្យាសាស្ត្រកីឡានៅមានកម្រិត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដើម្បីដោះស្រាយបញ្ហាប្រឈមគន្លឹះៗដែលបានបង្ហាញខាងលើ អនុកម្មវិធីកីឡាមានវត្ថុបំណងចំនួន ២ ដូចខាងក្រោម៖

១. ពង្រឹងសមត្ថភាពក្រុមកីឡាជាតិឱ្យបានល្អនៅលើឆាកអន្តរជាតិ។

២. អភិវឌ្ឍសមត្ថភាពគ្រប់គ្រងស្ថាប័ន និងសមត្ថភាពមន្ត្រីបច្ចេកទេសកីឡា ជាពិសេសស្ត្រីផ្នែកកីឡា។

ដើម្បីសម្រេចបាននូវវត្ថុបំណងទាំងនេះ អគ្គនាយកដ្ឋានកីឡានឹងបញ្ជូនមន្ត្រីជំនាញមកបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងវែងក្នុងវិស័យវិទ្យាសាស្ត្រកីឡា និងវេជ្ជសាស្ត្រកីឡា ហើយអញ្ជើញមន្ត្រីជំនាញផ្នែកវិទ្យាសាស្ត្រកីឡា និងវេជ្ជសាស្ត្រកីឡា មករៀបចំសិក្ខាសាលាដោយសហការជាមួយប្រទេសជាមិត្ត។

លើសពីនេះ កន្លែងហ្វឹកហាត់នឹងបំពាក់ឧបករណ៍ធ្វើតេស្តគុណភាពកីឡាទៅតាមប្រភេទកីឡា ស្របតាមវិទ្យាសាស្ត្រកីឡា។ អគ្គនាយកដ្ឋានក៏នឹងរៀបចំផែនការយុទ្ធសាស្ត្រជាតិដើម្បីកំណត់កន្លែងដែលត្រូវសាងសង់កីឡដ្ឋានសម្រាប់ហ្វឹកហាត់ (តំបន់ឆ្នេរ តំបន់ខ្ពង់រាប តំបន់បឹងទន្លេសាប និងតំបន់ទំនាបផ្សេងទៀត) និងធ្វើការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិដើម្បីបង្កើតផែនការអភិវឌ្ឍ និងកៀរគរក្រុមហ៊ុនវិនិយោគដើម្បី សាងសង់ និងកែលម្អកីឡដ្ឋាននៅថ្នាក់រាជធានី និងខេត្ត។

ការត្រៀមលក្ខណៈឆ្ពោះទៅព្រឹត្តិការណ៍ប្រកួតកីឡាយុវជនអាស៊ី លើកទី៥ឆ្នាំ២០២៩ ដើរតួនាទីសំខាន់ដើម្បីលើកកម្ពស់កិត្យានុភាពកម្ពុជាជាថ្មីតាមរយៈមហាព្រឹត្តិការណ៍កីឡា។

យុទ្ធសាស្ត្រ និងសកម្មភាពគោល ដើម្បីសម្រេចវត្ថុបំណងទាំងនេះ រួមមានក្នុងតារាងខាងក្រោម។

| **វត្ថុបំណងទី១៖ លើកកម្ពស់សមត្ថភាពក្រុមកីឡាជម្រើសជាតិ ក្រុមកីឡាថ្នាល និងក្រុមកីឡាជនមានពិការភាពឱ្យមានភាពលេចធ្លោនៅលើឆាកអន្តរជាតិ** | | |
|---|---|---|
| **សូចនាករលទ្ធផល** | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
| ចំនួនអត្តពលិកជាតិបានប្រមូលផ្តុំ | ៨៧៨ | ១ ២៥៦ |
| ចំនួនអត្តពលិកជាតិចូលរួមក្នុងការប្រកួតកីឡាថ្នាក់តំបន់ និងអន្តរជាតិ | ៤២៥ | ៥៥០ |
| ចំនួនកីឡាដែលមានសក្តានុពលសម្រាប់ជម្រើសជាតិកម្ពុជា | ២០ | ៣៥ |
| ចំនួនកីឡាប្រពៃណីដែលបានផ្សព្វផ្សាយនៅកម្ពុជា | ៤ | ៦ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** ផ្តល់កម្មវិធីបណ្តុះបណ្តាលលក្ខណៈវិទ្យាសាស្ត្រកីឡាប្រកបដោយ | **ឧបករណ៍កីឡា** |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| ប្រសិទ្ធភាពនៅទីតាំងជាតិ និងតំបន់ | - បំពាក់ឧបករណ៍ហ្វឹកហាត់សាច់ដុំ និងឧបករណ៍តេស្តសមត្ថភាពកីឡា ដល់មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡាដើម្បីវិភាគកាយសម្បទា និង សមត្ថភាពកីឡារបស់ក្រុមជម្រើសជាតិ<br>- ជួសជុល និងកែលម្អហេដ្ឋារចនាសម្ព័ន្ធកីឡាចាំបាច់ សម្រាប់ការ ហ្វឹកហាត់របស់អត្តពលិក ដែលមានគុណផលលំដាប់ខ្ពស់។<br>**ការបណ្តុះបណ្តាលនិងការគាំទ្រ**<br>- រៀបចំកម្មវិធីបណ្តុះបណ្តាលអ្នកឯកទេសវិទ្យាសាស្ត្រកីឡា និង វេជ្ជសាស្ត្រកីឡា<br>- ពង្រឹងសមត្ថភាពគ្រូបង្វឹក និងគ្រូជំនួយ ឱ្យដល់កម្រិតអន្តរជាតិ<br>- បង្កើនគុណភាព និងប្រសិទ្ធភាពប្រព័ន្ធវាយតម្លៃជ្រើសរើសអ្នកមាន ទេពកោលសល្យផ្នែកកីឡា ដើម្បីបណ្តុះបណ្តាលជាអត្តពលិក<br>- ជ្រើសរើសអត្តពលិកជាតិទៅហ្វឹកហាត់ក្នុង និងក្រៅប្រទេស<br>- រៀបចំរបបអាហារស្របតាមស្តង់ដានៃតម្រូវការថាមពលរបស់អត្តពលិក តាមប្រភេទកីឡា។ |
| **យុទ្ធសាស្ត្រទី២៖** រៀបចំការប្រកួតជាតិ និងអន្តរជាតិ ស្របតាមស្តង់ដា និងការចូលរួមក្នុងការប្រកួតអន្តរជាតិ | **ការរៀបចំប្រកួតកីឡាជាលក្ខណៈហ្គេម**<br>- រៀបចំការប្រកួតកីឡាជាតិសម្រាប់សិស្សានុសិស្សជារៀងរាល់ឆ្នាំ<br>- រៀបចំការប្រកួតកីឡាជាតិ និងប៉ារ៉ាហ្គេម ថ្នាក់ជាតិរៀងរាល់ពីរឆ្នាំម្តង<br>- សហការរៀបចំការប្រកួតជើងឯកជាតិ និងអន្តរជាតិ<br>- ធ្វើជាម្ចាស់ផ្ទះព្រឹត្តិការណ៍កីឡាសាកលវិទ្យាល័យអាស៊ានឆ្នាំ២០២៦ នៅកម្ពុជា<br>- ធ្វើជាម្ចាស់ផ្ទះព្រឹត្តិការណ៍កីឡាយុវជនអាស៊ីឆ្នាំ២០២៩ នៅកម្ពុជា។<br>**ការចូលរួមប្រកួតកីឡាជាលក្ខណៈហ្គេម**<br>- ចូលរួមការប្រកួតកីឡាសិស្សអន្តរជាតិ<br>- ចូលរួមការប្រកួតកីឡាជាលក្ខណៈហ្គេម និងអន្តរជាតិនានា។ |
| **យុទ្ធសាស្ត្រទី៣៖** រៀបចំ និងអនុវត្តផែនការជាតិ និងកម្មវិធីនានា ដើម្បីលើកកម្ពស់ការចូលរួមក្នុងការប្រកួតកីឡាកម្រិតអន្តរជាតិ | **ស្តង់ដាជាតិ**<br>- រៀបចំផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍អត្តពលិក។<br>**ការស្រាវជ្រាវ និងធ្វើផែនការ**<br>- បង្កើតប្រព័ន្ធវាយតម្លៃជ្រើសរើសអ្នកមានទេពកោសល្យផ្នែកកីឡា សម្រាប់ព្រឹត្តិការណ៍កីឡាសាកលវិទ្យាល័យអាស៊ានឆ្នាំ២០២៦ និង ព្រឹត្តិការណ៍កីឡាយុវជនអាស៊ីឆ្នាំ២០២៩ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| | - សិក្សា និងវិភាគពីចំណុចខ្លាំងរបស់ប្រទេសក្នុងតំបន់ ដែលដណ្តើមបានមេដាយច្រើន<br>- រៀបចំផែនការជាតិ ដើម្បីដណ្តើមមេដាយក្នុងការប្រកួតកីឡាអន្តរជាតិ។<br>**ការគាំទ្រ**<br>- អភិវឌ្ឍអត្តពលិកឆ្នើមតាមរយៈការលើកទឹកចិត្ត និងឱកាសបណ្តុះ-បណ្តាលទាំងក្នុង និងក្រៅប្រទេស។ |

**វត្ថុបំណងទី២៖ អភិវឌ្ឍសមត្ថភាពគ្រប់គ្រងស្ថាប័ន និងសមត្ថភាពមន្ត្រីបច្ចេកទេសកីឡា ជាពិសេសស្ត្រីក្នុងវិស័យកីឡា**

| សូចនាករលទ្ធផល | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
|---|---|---|
| ចំនួនគ្រូបង្វឹកបានបណ្តុះបណ្តាលតាមប្រភេទកីឡា | ៥៦២ | ៣៥០ |
| ចំនួនមន្ត្រីបច្ចេកទេសកីឡាបានបណ្តុះបណ្តាលតាមប្រភេទកីឡា | ៨៤០ | ១ ០៥០ |
| ចំនួនសហព័ន្ធកីឡាជាតិសម្រេចបានតាមស្តង់ដា | N/A | ៤៨ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| យុទ្ធសាស្ត្រទី១៖ បង្កើតក្របខ័ណ្ឌច្បាប់ និងបទដ្ឋានគតិយុត្តប្រកបដោយប្រសិទ្ធភាព ដើម្បីអនុវត្តគោលនយោបាយ តាមរយៈកិច្ចសហប្រតិបត្តិការ និងភាពច្បាស់លាស់អំពីទំនួលខុសត្រូវរបស់អ្នកពាក់ព័ន្ធសំខាន់ៗ | **ច្បាប់ និងបទដ្ឋានគតិយុត្ត**<br>- រៀបចំឯកសារច្បាប់ស្តីពីការអប់រំកាយ និងកីឡា ដូចជា អនុក្រឹត្យ ប្រកាស គោលការណ៍ណែនាំ។<br>- ផ្សព្វផ្សាយច្បាប់ស្តីពីអប់រំកាយ និងកីឡា និងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា ដល់ភាគីពាក់ព័ន្ធ។<br>- ការធ្វើផែនការរៀបចំផែនការមេ ដើម្បីត្រៀមការប្រកួតកីឡាយុវជនអាស៊ីឆ្នាំ២០២៩<br>- រៀបចំគោលការណ៍រួម សម្រាប់ការអភិវឌ្ឍកីឡា រវាងអង្គការរដ្ឋកីឡា សហព័ន្ធកីឡា និងអង្គការសង្គមវិជ្ជាជីវៈកីឡា។<br>**ការធ្វើផែនការ**<br>- រៀបចំផែនការសកម្មភាពគ្រប់ជ្រុងជ្រោយ ដើម្បីរៀបចំព្រឹត្តិការណ៍កីឡាសាកលវិទ្យាល័យអាស៊ានឆ្នាំ២០២៦<br>- រៀបចំផែនការគោល ដើម្បីត្រៀមការប្រកួតកីឡាយុវជនអាស៊ីឆ្នាំ២០២៩<br>- រៀបចំស្តង់ដាគ្រូបង្វឹកកីឡាជាតិ ដោយសហការជាមួយសហព័ន្ធកីឡាជាតិ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - វាយតម្លៃ និងទទួលស្គាល់សហព័ន្ធកីឡាជាតិ ដែលទទួលបានថវិកាគាំទ្រពីរដ្ឋ។ |
| **យុទ្ធសាស្ត្រទី២៖** អភិវឌ្ឍសមត្ថភាពមន្ត្រីគ្រប់គ្រង និងបច្ចេកទេស (គ្រូបង្វឹកអាជ្ញាកណ្ដាល ចៅក្រម និងមន្ត្រីការប្រកួត) ទទួលបន្ទុកអប់រំកាយ និងកីឡា។ | **ការបណ្ដុះបណ្ដាល**<br>- បង្កើនកម្រិតថ្នាក់វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណសម្រាប់គ្រូបង្វឹក អាជ្ញាកណ្ដាល ចៅក្រមក្នុងប្រភេទកីឡាសក្ដានុពល អាទិភាពខ្ពស់<br>- រៀបចំវគ្គបណ្ដុះបណ្ដាល សន្និសីទ សិក្ខាសាលា សម្រាប់គ្រូបង្វឹក ចៅក្រម អាជ្ញាកណ្ដាល និងលើកកម្ពស់ស្ត្រីក្នុងវិស័យកីឡា និងជនមានពិការភាព<br>- អភិវឌ្ឍសមត្ថភាពមន្ត្រីគ្រប់គ្រងទទួលបន្ទុកអនុវិស័យអប់រំកាយ និងកីឡា ជាពិសេសស្ត្រី និងជនមានពិការភាព<br>- រៀបចំសិក្ខាសាលា ស្ដីពីការអប់រំកាយ និងកីឡា និងស្ត្រីក្នុងវិស័យកីឡា<br>- បញ្ជូនមន្ត្រីគ្រប់គ្រង បុគ្គលិក មន្ត្រីកីឡា គ្រូបង្វឹក អាជ្ញាកណ្ដាល ចៅក្រម និងមន្ត្រីគ្រប់គ្រងការប្រកួត ជាពិសេសស្ត្រី និងជនមានពិការភាព ទៅចូលរួមវគ្គបណ្ដុះបណ្ដាល និងសន្និសីទនានា ទាំងក្នុងតំបន់ និងក្រៅប្រទេស<br>- បណ្ដុះបណ្ដាលគ្រូបង្គោលលើសកម្មភាពហាត់ប្រាណ និងការធ្វើតេស្តកាយសម្បទា។ |
| **យុទ្ធសាស្ត្រទី៣៖** អភិវឌ្ឍប្រព័ន្ធព័ត៌មានក្នុងការអប់រំកាយ និងកីឡា | **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខារឌីជីថល**<br>- លើកកម្ពស់កីឡាឌីជីថលគ្រប់កម្រិតនៃការប្រកួតកីឡាជាតិ<br>- ប្រើប្រាស់កម្មវិធីបច្ចេកវិទ្យាព័ត៌មានវិទ្យា និងឌីជីថលសម្រាប់ការបង្រៀន និងរៀន អប់រំកាយ និងកីឡា និងការបណ្ដុះបណ្ដាល<br>- បង្កើតកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងផ្នែកឯកជនក្នុងការបង្កើតកម្មវិធីទូរស័ព្ទសម្រាប់វាយតម្លៃកាយសម្បទាសិស្ស<br>- បង្កើតកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងផ្នែកឯកជនក្នុងការបង្កើតប្រព័ន្ធទិន្នន័យគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធកីឡា ក្លឹបកីឡា ក្លឹបហាត់ប្រាណ និងទីលានកីឡា<br>- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងស្ថិតិកីឡា<br>- រៀបចំប្រព័ន្ធចុះឈ្មោះការប្រកួតឌីជីថល<br>- បង្កើតប្រព័ន្ធចុះបញ្ជីគ្រូអប់រំកាយ និងកីឡា<br>- បំពាក់ និងថែទាំ និងធ្វើទំនើបកម្មឧបករណ៍មជ្ឈមណ្ឌលទិន្នន័យ។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | **ការបណ្តុះបណ្តាល**<br>- បណ្តុះបណ្តាលមន្ត្រីឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងការអប់រំកាយ និងកីឡា<br>- បញ្ជូនមន្ត្រីចូលរួមសិក្ខាសាលាលើប្រធានបទទាក់ទងនឹងរដ្ឋាភិបាលឌីជីថលនៅកម្ពុជា។ |

## ៣.៧ កម្មវិធីអាទិភាពទី៥៖ ការលើកកម្ពស់ការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម




### ៣.៧.១ អនុកម្មវិធី៥.១៖ ការរៀបចំគោលនយោបាយ និងផែនការផ្អែកលើភស្តុតាង

| លទ្ធផលរំពឹងទុករបស់អនុកម្មវិធី៖ ស្ថាប័ន និងបុគ្គលិកក្នុងប្រព័ន្ធអប់រំ ចេះវិភាគ និងប្រើប្រាស់ព័ត៌មាន ដើម្បីរៀបចំគោលនយោបាយ និងផែនការអប់រំពាក់ព័ន្ធ។ | | |
|---|---|---|
| សូចនាករផលសម្រេច | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
| ចំនួនសាលារៀនបានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ស្របតាមស្តង់ដាសាលារៀនគំរូ (គោលដៅសាលារៀនគំរូ) | N/A | ១ ២០០ |
| ភាគរយសៀវភៅស្ថិតិ និងសូចនាករអប់រំត្រូវបានផលិត និងផ្សព្វផ្សាយតាមឆ្នាំសិក្សា | ១០០% | ១០០% |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**បញ្ហាប្រឈមគន្លឹះៗ៖**

- ការវិភាគទិន្នន័យមិនបានគ្រប់គ្រាន់ រួមមាន លទ្ធផលវង្វាយតម្លៃ និងកង្វះភស្តុតាងក្នុងការរៀបចំគោលនយោបាយ និងការកំណត់សកម្មភាពដែលត្រូវកែលម្អ
- ការអនុវត្តគោលនយោបាយ និងបទប្បញ្ញត្តិទូទាំងប្រទេសត្រូវពង្រឹង

ដើម្បីដោះស្រាយបញ្ហាប្រឈមគន្លឹះៗខាងលើ អនុកម្មវិធីការរៀបចំគោលនយោបាយ និងផែនការផ្អែកលើភស្តុតាងមានវត្ថុបំណងចំនួន២ ដូចខាងក្រោម៖

១. ប្រមូល វិភាគ និងប្រើប្រាស់ព័ត៌មានបែបបរិមាណ និងគុណវិស័យដែលពាក់ព័ន្ធ
២. រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រតាមបរិបទ

ដើម្បីលើកកម្ពស់ការរៀបចំគោលនយោបាយ និងផែនការផ្អែកលើភស្តុតាង អនុកម្មវិធីនេះ ផ្តោតលើ៖ ទី១ សារៈសំខាន់នៃការវិភាគទិន្នន័យ និងភស្តុតាងដែលមាន (រួមទាំងការស្រាវជ្រាវ)។ ក្រសួងអប់រំ យុវជន និងកីឡា ប្រមូលទិន្នន័យច្រើន ប៉ុន្តែចាំបាច់ត្រូវយកចិត្តទុកដាក់បន្ថែមទៀតក្នុងការវិភាគ និងប្រើប្រាស់ភស្តុតាងក្នុងការរៀបចំគោលនយោបាយ។ ការរៀបចំគោលនយោបាយ និងផែនការអប់រំ ត្រូវមានការវិភាគព័ត៌មានតាមបែបគុណវិស័យ និងបរិមាណវិស័យដែលមានលក្ខណៈជាប្រព័ន្ធ ដើម្បីជួយដល់ប្រជាជនដែលជួបការលំបាក ក្រីក្រ និងងាយរងគ្រោះ។ ទី២ គោលនយោបាយ និងអន្តរាគមន៍ក្នុងវិស័យអាទិភាពផ្សេងៗនឹងត្រូវរៀបចំ រួមទាំងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ។ គោលនយោបាយ និងផែនការទាំងនេះនឹងផ្តោតលើបរិបទនៃប្រព័ន្ធអប់រំនៅកម្ពុជា។ ការរៀបចំមានលក្ខណៈសមស្របតាមបរិបទរបស់ប្រទេស តាមរយៈការគាំទ្រ និងការណែនាំដល់ការិយាល័យអប់រំដែលបានធ្វើវិមជ្ឈការ ក្នុងការបកស្រាយ និងការអនុវត្តគោលនយោបាយជាតិ ប្រកាស និងគោលការណ៍ណែនាំ។

ការរៀបចំគោលនយោបាយ និងផែនការផ្អែកលើភស្តុតាង តម្រូវឱ្យបុគ្គលិកអប់រំមានសមត្ថភាពក្នុងការវិភាគវិស័យអប់រំ ការបកស្រាយព័ត៌មានបែបបរិមាណវិស័យ និងគុណវិស័យ និងការរៀបចំគោលនយោបាយ។ អនុកម្មវិធីទី៥.៣ ស្តីពីការអភិវឌ្ឍសមត្ថភាព រួមមានអន្តរាគមន៍ក្នុងវត្ថុបំណងនេះផងដែរ។

យុទ្ធសាស្ត្រ និងសកម្មភាពគោល ដើម្បីជំរុញវត្ថុបំណងទាំងនេះ បានកំណត់ក្នុងតារាងខាងក្រោម៖

| **វត្ថុបំណងទី១៖ ប្រមូល វិភាគ និងប្រើប្រាស់ព័ត៌មានតាមបែបគុណវិស័យ និងបរិមាណវិស័យ** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| សុខដុមនីយកម្មថ្នាលប្រព័ន្ធព័ត៌មានគ្រប់គ្រង (ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធព័ត៌មាន | សុខដុមនីយកម្មប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | សុខដុមនីយកម្មប្រព័ន្ធព័ត៌មាន |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | |
|---|---|---|
| គ្រប់គ្រងឧត្តមសិក្សា ប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ) | ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស | គ្រប់គ្រងទាំងអស់ |
| ភាគរយសាលារៀនដែលប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | | |
| ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស | ៩៦,០% | ១០០% |
| ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ៧១,០% | ៩០,០% |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** កែលម្អការប្រមូលទិន្នន័យ ដោយពង្រឹង និងសុខដុមនីយកម្មប្រព័ន្ធ (EMIS, HRMIS, EFMS, SARMIS, ប្រព័ន្ធគ្រប់គ្រងឯកសារ) ដែលគ្របដណ្តប់លើវិស័យអប់រំទាំងមូល | **កែលម្អដំណើរការប្រមូលទិន្នន័យ**<br>- កែលម្អគុណភាពទិន្នន័យ និងភាពគ្រប់ជ្រុងជ្រោយ (បង្កើតទីកន្លែងផ្ទុកទិន្នន័យ ដោយផ្អែកលើក្របខណ្ឌគ្រប់គ្រងទិន្នន័យ របស់ EMIS ដើម្បីរក្សាទុកព័ត៌មានដែលទទួលបានពីប្រភពផ្សេងៗ)<br>- កំណត់ស្តង់ដានៃទិន្នន័យជំរឿនស្ថិតិនៅតាមសាលារៀន ស្របតាមក្រសួងស្ថាប័នពាក់ព័ន្ធ<br>- កែលម្អដំណើរការផ្ទៀងផ្ទាត់ទិន្នន័យ និងសុពលភាពទិន្នន័យនៅកម្រិតមូលដ្ឋាន។<br>**ការបណ្តុះបណ្តាល**<br>- រៀបចំសិក្ខាសាលាស្តីពី ការសរសេរកូដកម្មវិធី ការបង្កើត គេហទំព័រ និងកម្មវិធីប្រើប្រាស់តាមបច្ចេកវិទ្យាការគ្រប់គ្រងទិន្នន័យនៅថ្នាក់កណ្តាល និងការគ្រប់គ្រងទិន្នន័យតាមបណ្តាញ<br>- ទស្សនកិច្ចសិក្សានៅក្រៅប្រទេស។<br>**ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ និងប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ**<br>- អភិវឌ្ឍ ឬកែលម្អប្រព័ន្ធទិន្នន័យតាមអនឡាញរបស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ (ដាក់ឱ្យដំណើរការប្រព័ន្ធតាមដានការសិក្សារបស់សិស្ស និងប្រព័ន្ធព័ត៌មានគ្រប់គ្រង់គុណភាពអប់រំ និងសុខដុមនីយកម្ម OpenEMIS។<br>**ហេដ្ឋារចនាសម្ព័ន្ធ**<br>- រៀបចំហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីពង្រីកការប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំតាមអនឡាញ<br>- វាយតម្លៃសមត្ថភាពប្រព័ន្ធ Hardware និង Software<br>- ពង្រឹងយន្តការនៃការចុះបញ្ជីទ្រព្យសម្បត្តិ និងការផ្គត់ផ្គង់។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| **យុទ្ធសាស្ត្រទី២៖** បង្កើតផ្ទាំងគ្រប់គ្រងទិន្នន័យសម្រាប់ប្រព័ន្ធគ្រប់គ្រងព័ត៌មានទាំងអស់ | **វិភាគតម្រូវការរបស់អ្នកប្រើប្រាស់**<br>- រៀបចំផែនការសុខដុមនីយកម្ម និងកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ក្រសួងអប់រំ យុវជន និងកីឡា។<br>**សុខដុមនីយកម្មទិន្នន័យ**<br>- សិក្សាការភ្ជាប់ទំនាក់ទំនងគ្នានៃប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ជាមួយនឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យពីប្រភពផ្សេងទៀត<br>- រៀបចំគោលការណ៍ណែនាំពង្រីកការតភ្ជាប់ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ នៅថ្នាក់កណ្ដាល ជាមួយនឹង រាជធានី-ខេត្ត ដើម្បីមានភាពងាយស្រួលក្នុងការយកព័ត៌មានមកប្រើប្រាស់<br>- លើកកម្ពស់កម្មវិធីប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ដើម្បីផ្លាស់ប្ដូរទិន្នន័យជាមួយប្រព័ន្ធព័ត៌មានផ្សេងទៀតរបស់ក្រសួង ដោយផ្ដល់នូវភាពងាយស្រួល និងសុវត្ថិភាព<br>- បង្កើតទំនាក់ទំនងរវាងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ វេទិកាអភិវឌ្ឍសមត្ថភាព គន្លងអាជីពគ្រូបង្រៀន និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស។ |
| **យុទ្ធសាស្ត្រទី៣៖** វិភាគស៊ីជម្រៅលើទិន្នន័យ ទស្សនៈអប់រំ និងការសិក្សាស្រាវជ្រាវ | **យន្តការ និងស្តង់ដា**<br>- ពង្រឹងយន្តការ និងស្តង់ដានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានានូវសង្គតិភាព និងការយល់ដឹងដូចគ្នាលើវិធីសាស្ត្រស្ថិតិ<br>- រៀបចំ និងផ្សព្វផ្សាយឯកសារសំខាន់ពាក់ព័ន្ធនឹងការកំណត់ព័ត៌មានអំពីទិន្នន័យ ដំណើរការទិន្នន័យ និងវិធីសាស្ត្រប្រមូលទិន្នន័យ។<br>**ការប្រើប្រាស់ទិន្នន័យសម្រាប់ការវិភាគ**<br>- សម្របសម្រួលការអនុវត្តប្រព័ន្ធព័ត៌មានសាលា នៅកម្រិតសាលារៀន<br>- បង្កើតប្រព័ន្ធគ្រប់គ្រងបណ្ណាល័យ និងកម្មវិធីទូរស័ព្ទសម្រាប់ការអប់រំចំណេះទូទៅ<br>- បង្កើតគេហទំព័រអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់ធនធានមនុស្ស និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីផ្ដល់ព័ត៌មាន និងសម្របសម្រួលដល់មុខងារអភិវឌ្ឍធនធានមនុស្ស<br>- ពង្រឹងការប្រើប្រាស់ និងមុខងាររបស់ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស<br>- ធ្វើបច្ចុប្បន្នកម្មគេហទំព័រសម្រាប់ដាក់បញ្ចូលលទ្ធផល និងរបាយការណ៍ទៅក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ដូចជា បណ្ណព័ត៌មានសាលារៀន ប្រវត្តិសាលារៀន ផែនទីសិក្សា។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | **ការបណ្តុះបណ្តាល**<br>- បណ្តុះបណ្តាលលើវិធីសាស្ត្រកំណត់ព័ត៌មានអំពីទិន្នន័យ<br>- វិភាគទិន្នន័យតាមបែបគុណវិស័យ និងបរិមាណវិស័យ<br>- បណ្តុះបណ្តាលដល់ថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និង សាលារៀន ស្តីពីការគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ការវិភាគទិន្នន័យ ការមើលឃើញទិន្នន័យ ការបែងចែកទិន្នន័យ និងការរាយការណ៍។ |
| **យុទ្ធសាស្ត្រទី៤៖** ប្រើប្រាស់ព័ត៌មានវិភាគដើម្បីរៀបចំគោលនយោបាយ ជួយប្រជាជនក្រីក្រ និងងាយ-រងគ្រោះ និងគ្រឹះស្ថានសិក្សា និងតំបន់ដែលជួបការលំបាក | **ការបណ្តុះបណ្តាល**<br>- គាំទ្រការសម្របសម្រួល និងការអនុវត្តសាកល្បងគន្លងអាជីពគ្រូបង្រៀននៅតាមសាលារៀនគោលដៅ<br>- លើកកម្ពស់សមត្ថភាពក្នុងការវិភាគ និងការរាយការណ៍សម្រាប់ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្សដើម្បីបំពេញតម្រូវការរបស់អ្នកប្រើប្រាស់ជាពិសេសព័ត៌មានសាលា និងទិន្នន័យគ្រូលើស/គ្រូខ្វះ។<br>**ការប្រើប្រាស់ទិន្នន័យសម្រាប់រៀបចំគោលនយោបាយ**<br>- ពង្រីកការអនុវត្តផែនការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>- អភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនិងរៀបចំម៉ូឌីលសម្រាប់គន្លងអាជីពគ្រូបង្រៀន តាមរយៈប្រព័ន្ធប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស<br>- ពិនិត្យកែសម្រួលឡើងវិញនូវគោលការណ៍ណែនាំ និងយន្តការពង្រាយ និងដាក់ពង្រាយគ្រូបង្រៀន។<br>**ការរៀបចំវេទិការគោលនយោបាយ**<br>- រៀបចំសន្និសីទជាតិ និងវេទិកាគោលនយោបាយអប់រំ។ |

| វត្ថុបំណងទី២៖ រៀបចំគោលនយោបាយ និងផែនការតាមបរិបទ | | |
|---|---|---|
| សូចនាករលទ្ធផល | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
| ចំនួនគោលនយោបាយ និងយុទ្ធសាស្ត្រអន្តរាគមន៍បានធ្វើបច្ចុប្បន្នភាព និងបង្កើតឡើង | ២ | ៧ |
| ភាគរយសូចនាករផលសម្រេច និងសូចនាករលទ្ធផលតាមកម្មវិធី និង អនុកម្មវិធី នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨ សម្រេចតាមចំណុចដៅប្រចាំឆ្នាំ | ៧០% | ៨០% |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | |
|---|---|---|
| ចំនួនបុគ្គលិកអប់រំទទួលបានការបំប៉នស្តីពីផែនការអប់រំនៅថ្នាក់ក្រោមជាតិ និងសាលារៀន | N/A | ៣៩០ |
| របាយការណ៍ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការក្នុងវិស័យអប់រំ ត្រូវបានរៀបចំ | កែលម្អ ប្រព័ន្ធ (AMIS) | រៀបចំ របាយការណ៍ វិភាគប្រចាំឆ្នាំ |
| ក្របខ័ណ្ឌពិនិត្យតាមដាននិងវាយតម្លៃផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំឆ្នាំ២០២១-២០២៥ ត្រូវបានរៀបចំ | N/A | |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** អភិវឌ្ឍគោលនយោបាយអប់រំជាតិតាមវិស័យអាទិភាព (រួមមានអាហារតាមសាលា និងអាហារូបត្ថម្ភ សាលារៀនគំរូ និងសាលារៀនពេញមួយថ្ងៃ) | **ការរៀបចំវេទិកា**<br>- រៀបចំក្របខ័ណ្ឌគោលនយោបាយអប់រំជាតិ<br>- រៀបចំគោលនយោបាយស្តីពី អាហារូបករណ៍ ការគាំទ្រហិរញ្ញវត្ថុ និងកម្ចីសម្រាប់សិស្សនៅមធ្យមសិក្សា<br>- រៀបចំវិធានការគោលនយោបាយបង្កើតភាពធន់នឹងបម្រែបម្រួលអាកាសធាតុ<br>- រៀបចំយុទ្ធសាស្ត្រអប់រំឌីជីថលនៅតាមសាលារៀន<br>- រៀបចំគោលនយោបាយគាំទ្រគ្រឹះស្ថានបណ្តុះបណ្តាលគ្រូស្តីពីការទទួលស្គាល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>- សម្របសម្រួលការរៀបចំគោលនយោបាយប្រព័ន្ធព័ត៌មានសាលារៀន<br>- រៀបចំក្របខ័ណ្ឌស្តីពី សមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរបស់គ្រូបង្រៀន។<br>**ការពិនិត្យគោលនយោបាយឡើងវិញ**<br>- ពិនិត្យឡើងវិញលើគោលនយោបាយពាក់ព័ន្ធនឹងគ្រូបង្រៀនតាមទស្សនៈប្រៀបធៀបផ្អែកលើការស្រាវជ្រាវ។ |
| **យុទ្ធសាស្ត្រទី២៖** អភិវឌ្ឍការសិក្សានៅពេលបច្ចុប្បន្ន និងទៅអនាគត ផ្អែកលើនិន្នាការ និងផលប៉ះពាល់លើការអប់រំ (ឧ. និន្នាការប្រជាសាស្ត្រ សេដ្ឋកិច្ចសង្គម | **ការស្រាវជ្រាវគោលនយោបាយដើម្បីផ្តល់ព័ត៌មានដល់អ្នករៀបចំគោលនយោបាយ**<br>- ស្រាវជ្រាវអន្តរាគមន៍ក្នុងការលើកកម្ពស់ការអប់រំស្ទែម<br>- ស្រាវជ្រាវយុទ្ធសាស្ត្រក្នុងការរក្សាសិស្សនៅតាមសាលារៀន<br>- សិក្សាលើការលើកកម្ពស់ការអនុវត្តស្តង់ដាសាលារៀនគំរូ<br>- សិក្សាលើភាពធន់របស់ប្រព័ន្ធអប់រំ និងក្របខ័ណ្ឌគោលនយោបាយអប់រំ |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| និងទីផ្សារការងារ ការប្រែប្រួលអាកាសធាតុ តម្រូវការគ្រូបង្រៀន ការសាងសង់អគារសិក្សា សមត្ថភាពសាលារៀនបណ្តាញ។ល។) | - សិក្សាលទ្ធភាពក្នុងការបង្កើតផែនទីសិក្សាស្របតាមតម្រូវអប់រំនៅកម្រិតមូលដ្ឋាន<br>- អនុវត្តការស្រាវជ្រាវប្រតិបត្តិសម្រាប់ការរៀបចំគោលនយោបាយ។<br>**ការសិក្សានៅពេលអនាគត**<br>- វាយតម្លៃជាប្រចាំដើម្បីកំណត់ទីកន្លែងអាទិភាព ដូចជា សាលារៀនជួបការលំបាក សាលារៀនដែលមានសិស្សច្រើន សាលារៀនដែលរងផលប៉ះពាល់ដោយគ្រោះធម្មជាតិ ឬគ្រោះមហន្តរាយ<br>- សិក្សាផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើប្រព័ន្ធអប់រំ<br>- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធនៃគម្រោងថវិកាអាទិភាពរយៈពេល ៥ ឆ្នាំសម្រាប់ការជួសជុលហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់ថ្មី<br>- ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងធនធានមនុស្សស្តីពី ការលើសខ្វះ និងតម្រូវការគ្រូបង្រៀន<br>- ព្យាករណ៍តម្រូវការបុគ្គលិក។ |
| **យុទ្ធសាស្ត្រទី៣៖** រៀបចំ និងបោះពុម្ពសេចក្តីណែនាំប្រតិបត្តិនៅតាមវិស័យអាទិភាព | **ការរៀបចំសេចក្តីណែនាំប្រតិបត្តិ**<br>- រៀបចំគន្លងអាជីពគ្រូបង្រៀន<br>- រៀបចំកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>- រៀបចំកំណត់លក្ខណៈរបស់មជ្ឈមណ្ឌលឧត្តមភាព<br>- រៀបចំនីតិវិធីស្តីពីសុវត្ថិភាពរបស់កុមារ<br>- បង្កើតនិងការប្រព្រឹត្តទៅរបស់គណៈកម្មការគ្រប់គ្រងសាលាបឋមសិក្សា<br>- ប្រព័ន្ធកត់ត្រាការបណ្តុះបណ្តាល និងប្រព័ន្ធសិក្សាតាមក្រេឌីត<br>- រៀបចំផែនការប្រតិបត្តិស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់វិស័យអប់រំ។ |
| **យុទ្ធសាស្ត្រទី៤៖** គាំទ្រ និងណែនាំដល់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលបានធ្វើវិមជ្ឈការលើការយល់ដឹង និងការអនុវត្តគោលនយោបាយជាតិ ប្រកាស និងសេចក្តីណែនាំតាមតម្រូវការរបស់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ | **ព័ត៌មាន និងលើកកម្ពស់ការយល់ដឹង**<br>- ផ្តល់គោលនយោបាយ ប្រកាស និងសេចក្តីណែនាំពាក់ព័ន្ធដល់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន<br>- រៀបចំកម្មវិធីពិភាក្សាស្តីពី ផលប៉ះពាល់នៃគោលនយោបាយជាតិ ប្រកាស និងសេចក្តីណែនាំ ដល់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀនការបកស្រាយក្នុងស្រុក។<br>**ការយល់នៅកម្រិតមូលដ្ឋាន**<br>- វាយតម្លៃជាប្រចាំលើការអនុវត្តគោលនយោបាយ និងប្រកាសនៅរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ<br>- រៀបចំឯកសារគោលនយោបាយ ប្រកាស និងសេចក្តីណែនាំ ដើម្បី |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | គាំទ្រការអនុវត្តនៅកម្រិតមូលដ្ឋាន។ |
| **យុទ្ធសាស្ត្រទី៥៖** រៀបចំផែនការអប់រំ និងផែនការថវិកាលក្ខណៈជាប្រព័ន្ធនៅថ្នាក់កណ្តាល និងកម្រិតវិមជ្ឈការ ដោយឆ្លុះបញ្ចាំងអំពីគោលនយោបាយជាតិ | **ការបណ្តុះបណ្តាល**<br>- ពង្រឹងចំណេះដឹងអ្នករៀបចំគោលនយោបាយ អ្នកអប់រំ អ្នកសារព័ត៌មាន អ្នកផលិតមាតិកាតាមបណ្តាញសង្គម និងសាធារណជនលើប្រធានបទអំពីសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ ការបញ្ជ្រាបយេនឌ័រ អំពើហិង្សា និងបញ្ហាពាក់ព័ន្ធនានា តាមរយៈការរៀបចំនិងអនុវត្តក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំឆ្នាំ២០២១-២០២៥<br>- កសាងសមត្ថភាពថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈគ្រប់គ្រងសាលារៀន លើការអនុវត្តផែនការសាលារៀនឆ្លើយតបទៅនឹងស្តង់ដាសាលារៀនគំរូ<br>- អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំថ្នាក់រាជធានី-ខេត្ត និងក្រុង ស្រុក ខណ្ឌ លើការរៀបចំផែនការអប់រំផ្អែកលើលទ្ធផល (ឧ. ការប្រើប្រាស់សូចនាករសមិទ្ធកម្ម)។<br>**ការពិនិត្យឡើងវិញ**<br>- សិក្សាលើការអនុវត្តថវិកាក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ<br>- ពិនិត្យលើការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការគោលអភិវឌ្ឍសមត្ថភាព និងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៅថ្នាក់ជាតិ<br>- វិភាគលើហិរញ្ញវត្ថុ ដើម្បីគាំទ្រការសម្រេចចិត្ត និងការបែងចែកធនធាន។<br>**ការរៀបចំផែនការ**<br>- រៀបចំថវិកាស្របតាមគោលនយោបាយ និងអាទិភាពរបស់ក្រសួង ដោយពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រៀបចំយន្តការផ្តល់មូលនិធិសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅសាលារៀន<br>- រៀបចំផែនការ និងថវិកាតាមរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ស្របតាមថវិកាជាតិ<br>- រៀបចំផែនទីសិក្សា និងផែនការសាលារៀន<br>- បង្កើតឧបករណ៍វាយតម្លៃគុណភាពលើការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់រាជធានី-ខេត្ត។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| **យុទ្ធសាស្ត្រទី៦៖** ពង្រឹងការផ្សារភ្ជាប់ផែនការ និងថវិកា | - ពិនិត្យកែសម្រួលរចនាសម្ព័ន្ធកម្មវិធីរបស់ក្រសួង ក្នុងការរៀបចំផែនការថវិកាឆ្នាំ២០២៧ រួមជាមួយចំណាត់ថ្នាក់មុខងាររបស់រាជរដ្ឋាភិបាល (COFOG)<br>- បែងចែកប្រាក់ឈ្នួលរបស់គ្រូបង្រៀន និងចំណាយមូលធនតាមកម្មវិធី និងអនុកម្មវិធី។ |
| **យុទ្ធសាស្ត្រទី៧៖** ពង្រឹងក្រុមការងារបច្ចេកទេសចម្រុះសម្របសម្រួលបានល្អ និងមានប្រសិទ្ធភាពនៅថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ គាំទ្រ និងពិនិត្យតាមដានការអភិវឌ្ឍវិស័យអប់រំស្របតាមបរិបទវិមជ្ឈការ និងវិសហមជ្ឈការ | **ការគាំទ្រ**<br>- អភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងជំនួយសម្រាប់ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- លើកកម្ពស់ការអភិវឌ្ឍសមត្ថភាពមន្ត្រីថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ លើការសម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ<br>- គាំទ្រការអនុវត្តនិងការគ្រប់គ្រង និងផ្តល់យោបល់សម្រាប់ក្រុមការងារបច្ចេកទេសចម្រុះថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ។<br>**ការពិនិត្យតាមដាន និងវាយតម្លៃ**<br>- រៀបចំកិច្ចប្រជុំទៀងទាត់សម្រាប់ក្រុមការងារបច្ចេកទេសចម្រុះនៅថ្នាក់រាជធានី-ខេត្ត និងក្រុង ស្រុក ខណ្ឌ<br>- ពិនិត្យតាមដាន និងវាយតម្លៃប្រសិទ្ធភាពនៃការសម្របសម្រួលរបស់ក្រុមការងារបច្ចេកទេសចម្រុះ និងការអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងជំនួយ (AMIS) នៅថ្នាក់រាជធានី-ខេត្ត<br>- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី ឬគម្រោងដែលគាំទ្រដោយដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល។ |
| **យុទ្ធសាស្ត្រទី៨៖** លើកកម្ពស់កិច្ចព្រមព្រៀងសហប្រតិបត្តិការ និងភាពជាដៃគូវិនិយោគជាមួយវិស័យឯកជន (ឧ. សមាគមពាណិជ្ជកម្ម ក្រុមហ៊ុនឯកកម្មសិទ្ធ) | **ការគ្រប់គ្រងជំនួយដៃគូអភិវឌ្ឍ**<br>- ពិនិត្យ និងពង្រឹងយន្តការសម្របសម្រួលជំនួយ និងហិរញ្ញវត្ថុនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- រៀបចំអនុស្សរណៈនៃការយោគយល់ និងកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការអប់រំជាមួយដៃគូអន្តរជាតិ<br>- សម្របសម្រួល និងស្នើសុំជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍសម្រាប់នាយកដ្ឋានពាក់ព័ន្ធ និងសាកលវិទ្យាល័យក្នុងវិស័យអប់រំ។<br>**ការពិនិត្យតាមដានការអនុវត្តកិច្ចព្រមព្រៀងគម្រោង**<br>- បច្ចុប្បន្នកម្មការអនុវត្តកម្មវិធី និងប្រព័ន្ធព័ត៌មានគ្រប់គ្រងជំនួយ |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - សហការជាមួយវិស័យឯកជន ដើម្បីពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី ឬគម្រោង។ |

## ៣.៧.២ អនុកម្មវិធី៥.២៖ ការគ្រប់គ្រងធនធានហិរញ្ញវត្ថុ

| **លទ្ធផលរំពឹងទុករបស់អនុកម្មវិធី៖ ការិយាល័យអប់រំនៅថ្នាក់កណ្ដាល និងថ្នាក់ក្រោមជាតិ និងសាលារៀន មានហិរញ្ញវត្ថុគ្រប់គ្រាន់ និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ដើម្បីអនុវត្តការងារ។** | | |
|---|---|---|
| **សូចនាករផលសម្រេច** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ភាគរយចំណាយចរន្តរបស់ក្រសួងអប់រំ យុវជន និងកីឡា ធៀបនឹងចំណាយចរន្តរបស់រាជរដ្ឋាភិបាល[11] | ១៦,៤% | ១៧,៧% |

**បញ្ហាប្រឈមគន្លឹះៗ៖**
- ផ្ដោតលើការបែងចែកធនធានហិរញ្ញវត្ថុប្រកបដោយសមធម៌
- តម្រូវការថវិកាផ្អែកលើសមិទ្ធកម្ម និងការពិនិត្យតាមដាន និងវាយតម្លៃ។

ដើម្បីដោះស្រាយបញ្ហាប្រឈមគន្លឹះៗខាងលើ អនុកម្មវិធីការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព មានវត្ថុបំណងចំនួន៣៖

១. កៀរគរប្រភពថវិកាក្នុងប្រទេស និងក្រៅប្រទេស ក្នុងការផ្ដល់មូលនិធិដោយសមធម៌សម្រាប់ការអប់រំ

២. បែងចែកធនធានហិរញ្ញវត្ថុដោយសមធម៌ និងលើកកម្ពស់ការប្រើប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព

៣. ផ្ដល់សម្ភារ និងបរិក្ខារសមស្របដល់អង្គភាពថ្នាក់កណ្ដាល និងរាជធានី-ខេត្ត និងសាលារៀន។

ការអនុវត្តគោលនយោបាយ និងផែនការប្រកបដោយជោគជ័យ តម្រូវឱ្យមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ និងបែងចែកដោយសមធម៌នៅក្នុងប្រព័ន្ធអប់រំ។ អនុកម្មវិធីនេះបានលើកឡើងនូវយុទ្ធសាស្ត្រចំនួនដើម្បីកៀរគរប្រភពថវិកាក្នុងប្រទេស និងក្រៅប្រទេស រួមទាំងកិច្ចព្រមព្រៀងសហប្រតិបត្តិការ និងភាពជាដៃគូវិនិយោគជាមួយវិស័យឯកជន។

[11] ទិន្នន័យឆ្នាំគោលឆ្លុះបញ្ចាំងក្នុងចំណោលផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ ត្រូវបានគណនាផ្អែកលើផែនការប្រតិបត្តិ ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

ដោយផ្តោតសំខាន់លើការបែងចែកធនធានហិរញ្ញវត្ថុដោយសមធម៌។ ដើម្បីលើកកម្ពស់ការប្រើប្រាស់ហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព តម្លាភាពនៃការបែងចែកធនធាន និងគណនេយ្យភាពសាធារណៈលើលទ្ធផលនឹងត្រូវពង្រឹង។

យុទ្ធសាស្ត្រ និងសកម្មភាពគោលសំខាន់ៗ ដើម្បីសម្រេចវត្ថុបំណងទាំងនេះ មាននៅក្នុងតារាងដូចខាងក្រោម៖

| **វត្ថុបំណងទី១៖ កៀរគរប្រភពថវិកាពីក្នុងប្រទេស និងក្រៅប្រទេសសម្រាប់មូលនិធិអប់រំ** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនកម្មវិធី អនុកម្មវិធី បានដាក់បញ្ចូលប្រាក់បៀវត្ស និងចំណាយមូលធន | N/A | គ្រប់កម្មវិធី អនុកម្មវិធី |
| ចំនួនរាជធានី-ខេត្ត បានរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្លើយតបនឹងស្តង់ដាគុណភាព | N/A | ២៥ |
| ចំនួនរាជធានី-ខេត្ត បានរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំឆ្លើយតបនឹងស្តង់ដាគុណភាព | ១៤ | ២៥ |

| **យុទ្ធសាស្ត្រ** | **សកម្មភាពគោល** |
|---|---|
| **យុទ្ធសាស្ត្រទី១៖** កៀរគរកិច្ចសហប្រតិបត្តិការអន្តរជាតិតាមរយៈកិច្ចព្រមព្រៀងកិច្ចសន្យា និងកម្ចី | **ការរៀបចំគោលនយោបាយ**<br>- រៀបចំឯកសារទស្សនាទាន និងកិច្ចព្រមព្រៀងសហប្រតិបត្តិការដោយបង្ហាញពីលក្ខណៈនៃការរួមចំណែករបស់វិស័យឯកជន<br>- កំណត់តួនាទីរបស់វិស័យឯកជនដែលត្រូវអនុវត្ត<br>- រៀបចំធនធានដើម្បីគាំទ្រដល់ការលើកកម្ពស់កិច្ចព្រមព្រៀងសហប្រតិបត្តិការ។<br>**ទំនាក់ទំនងជាមួយវិស័យឯកជន**<br>- កំណត់ ស្វែងរក ជ្រើសរើសវិស័យឯកជន និងដៃគូវិនិយោគ ដែលពាក់ព័ន្ធ<br>- ពិភាក្សា និងពិគ្រោះយោបល់ជាមួយវិស័យឯកជន និងដៃគូវិនិយោគ<br>- បង្កើតភាពជាដៃគូជាមួយវិស័យឯកជន និងដៃគូវិនិយោគ។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| **យុទ្ធសាស្ត្រទី២៖** ពង្រឹងការរៀបចំផែនការថវិកាផ្អែកលើសមិទ្ធកម្ម | **ការរៀបចំផែនការថវិកា**<br>- កែលម្អការរៀបចំផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិល និងផែនការប្រតិបត្តិប្រចាំឆ្នាំនៅថ្នាក់ជាតិ ដោយផ្អែកលើសូចនាករសមិទ្ធកម្ម<br>- រៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មប្រចាំឆ្នាំរវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ |

| **វត្ថុបំណងទី២៖ ការបែងចែកដោយសមធម៌ និងលើកកម្ពស់ការប្រើប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ភាគរយចំណាយក្រៅបន្ទុកបុគ្គលិកធៀបនឹងចំណាយចរន្តរបស់ក្រសួងអប់រំ យុវជន និងកីឡា[12] | ២១,០% | ២៣,៤% |
| កិច្ចព្រមព្រៀងសមិទ្ធកម្មបានរៀបចំគ្រប់កម្មវិធី អនុកម្មវិធី | គ្រប់កម្មវិធី | គ្រប់កម្មវិធី អនុកម្មវិធី |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** បង្កើត ឬប្រើប្រាស់យន្តការដើម្បីធានានូវតម្លាភាពនៃការបែងចែកធនធាន និងគណនេយ្យភាពសាធារណៈផ្អែកលើលទ្ធផល | **ការគាំទ្រ**<br>- អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព<br>- ស្វែងរកដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតសម្រាប់ដំណើរការហិរញ្ញវត្ថុ និងការរាយការណ៍<br>- រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រហិរញ្ញវត្ថុ ដើម្បីណែនាំការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រសួង។<br>**របាយការណ៍ហិរញ្ញវត្ថុ និងគណនេយ្យ**<br>- បង្កើតប្រព័ន្ធពិនិត្យតាមដានគម្រោងហិរញ្ញប្បទានក្នុងស្រុក ដើម្បីកំណត់ពីភាពយឺតយ៉ាវក្នុងការអនុវត្តគម្រោង និងការចំណាយលើស<br>- រក្សាកំណត់ត្រាហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ និងមានតម្លាភាព<br>- រៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យ<br>- ធានាការអនុលោមតាមតម្រូវការរបាយការណ៍ហិរញ្ញវត្ថុ |

[12] ទិន្នន័យឆ្នាំគោលឆ្លុះបញ្ចាំងក្នុងចំណោលផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ ត្រូវបានគណនាផ្អែកលើផែនការប្រតិបត្តិ ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| | |
|---|---|
| | - ពិនិត្យតាមដានការអនុវត្តថវិកា និងការកែតម្រូវការតាមការចាំបាច់។ |
| **យុទ្ធសាស្ត្រទី២៖** កែលម្អការគ្រប់គ្រងហិរញ្ញវត្ថុនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងកម្រិតសាលារៀន | **ការវិភាគ**<br>- វិភាគការចំណាយលើដំណើរការសាលារៀន តាមប្រភេទ និងលក្ខណៈរបស់សាលារៀន<br>- វិភាគលើថវិកាដែលមាន និងការប្រើប្រាស់ថវិកានៅពេលបច្ចុប្បន្នរបស់សាលារៀន<br>- កំណត់ជម្រើសផ្សេងៗដោយប្រើរូបមន្តគណនា និងផលប៉ះពាល់នៃជម្រើសនីមួយៗ។<br>**ការអភិវឌ្ឍ និងការអនុវត្ត**<br>- កំណត់រូបមន្តគណនាផ្អែកតាមតម្រូវការ និងរៀបចំឯកសារភ្ជាប់<br>- រៀបចំសេចក្ដីណែនាំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសាលារៀន<br>- ផ្ដល់ភាពងាយស្រួលសម្រាប់ដំណើរការអនុវត្តមូលនិធិដំណើរការសាលារៀន<br>- បណ្ដុះបណ្ដាលបុគ្គលិកពាក់ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងសាលារៀន។ |

**វត្ថុបំណងទី៣៖ ផ្ដល់សម្ភារបរិក្ខារសមស្របសម្រាប់អង្គភាពនៅថ្នាក់កណ្ដាល រាជធានី-ខេត្ត និងសាលារៀន**

| សូចនាករលទ្ធផល | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
|---|---|---|
| ចំនួនសាលារៀនគំរូទទួលបានសម្ភារបរិក្ខារមូលដ្ឋាន | N/A | ៧៩២ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** អភិវឌ្ឍ និងផ្ដល់ហេដ្ឋារចនាសម្ព័ន្ធ អប់រំ (សំណង់ និងការជួសជុល) ដោយគិតគូរពីភាពធន់នឹងការប្រែប្រួលអាកាសធាតុ | - រៀបចំសៀវភៅណែនាំវាយតម្លៃស្តង់ដា PIM និងសៀវភៅណែនាំការអនុវត្តស្តង់ដា PIM<br>- ពង្រឹងយន្តការផ្គត់ផ្គង់សម្ភារផ្អែកតាមបញ្ជីសារពើភ័ណ្ឌ<br>- សាងសង់ និងជួសជុលគ្រឹះស្ថានសិក្សាគោលដៅ (បរិវេណសាលារៀន វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងសាលាគរុកោសល្យខេត្ត បរិវេណសាកលវិទ្យាល័យ)<br>- គាំទ្រការផ្ដល់ហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការតភ្ជាប់ និងបរិក្ខារផ្សេងៗនៅតាមគ្រឹះស្ថានសិក្សាគោលដៅ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - គាំទ្រការផ្តល់សម្ភារ និងបរិក្ខារសម្រាប់ការគ្រប់គ្រងសាលារៀន។ |
| **យុទ្ធសាស្ត្រទី២៖** ពិនិត្យតាមដាន និងវាយតម្លៃលើការថែទាំ ជួសជុល និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធអប់រំ | - បណ្តុះបណ្តាលគណៈគ្រប់គ្រងសាលារៀនស្តីពីសារៈសំខាន់នៃហេដ្ឋារចនាសម្ព័ន្ធអប់រំ ដើម្បីធានាបាននូវគុណភាព និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព<br>- បង្កើតយន្តការពិនិត្យតាមដាន និងវាយតម្លៃ និងការប្រើប្រាស់ទិន្នន័យដែលមានស្រាប់ ដើម្បីថែទាំ ជួសជុល និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធអប់រំ<br>- បណ្តុះបណ្តាលស្តីពីការចុះបញ្ជីសារពើភ័ណ្ឌសម្រាប់រាជធានី-ខេត្ត និងសាលារៀន<br>- ពង្រឹងយន្តការពិនិត្យតាមដាន និងវាយតម្លៃលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ<br>- បណ្តុះបណ្តាលគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនពីរបៀបថែរក្សាហេដ្ឋារចនាសម្ព័ន្ធឌីជីថល ប្រព័ន្ធគ្រប់គ្រងសាលារៀន និងបន្ទប់កុំព្យូទ័រក្នុងសាលារៀន។ |

### ៣.៧.៣ អនុកម្មវិធី៥.៣៖ ការគ្រប់គ្រងធនធានមនុស្ស

#### អនុកម្មវិធី៥.៣.១៖ កិច្ចការបណ្តុះបណ្តាលគ្រូបង្រៀន

| **លទ្ធផលរំពឹងទុករបស់អនុកម្មវិធី៖ គ្រូបង្រៀនទាំងអស់នៅគ្រប់កម្រិតថ្នាក់ មានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាល្អស្របតាមសតវត្សរ៍ទី២១។** | | |
|---|---|---|
| **សូចនាករផលសម្រេច** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនអាជ្ញាបណ្ណបង្រៀនបានចេញសម្រាប់គ្រូបង្រៀន | | |
| មត្តេយ្យសិក្សា | N/A | ៨០០ |
| បឋមសិក្សា | N/A | ៣ ០០០ |
| មធ្យមសិក្សាបឋមភូមិ | N/A | ១ ៣៥០ |
| មធ្យមសិក្សាទុតិយភូមិ | N/A | ៣ ០០០ |

**បញ្ហាប្រឈមគន្លឹះៗ៖**

- កង្វះគ្រូបង្រៀននៅតាមតំបន់មួយចំនួន នាំឱ្យមានការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរវេន និងគ្រូបង្រៀនថ្នាក់គួប
- កង្វះគ្រូបង្រៀននៅទូទាំងប្រទេស កង្វះគ្រូបង្រៀននៅទូទាំងខេត្ត និងកង្វះគ្រូបង្រៀនច្រើននៅតំបន់ជនបទ



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ចំនួនគ្រូបង្រៀនសរុបនៅបឋមសិក្សាបានធ្លាក់ចុះចាប់តាំងពីឆ្នាំ២០១៧ ទោះបីការចុះឈ្មោះចូលរៀនមានកំណើន
- គ្រូបង្រៀនជាច្រើនខ្វះចំណេះដឹង ជំនាញ និងឥរិយាបទ ស្របតាមសតវត្សរ៍ទី២១ ជាពិសេសទាក់ទងនឹងការបង្រៀនកម្មវិធីសិក្សាថ្មី និងការបង្រៀនតាមប្រព័ន្ធអេឡិចត្រូនិក និងជំនាញឌីជីថលផ្សេងទៀត។

ដើម្បីដោះស្រាយបញ្ហាប្រឈមគន្លឹះៗខាងលើ និងសម្រេចលទ្ធផលរំពឹងទុករបស់អនុកម្មវិធី អនុកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនមានវត្ថុបំណងចំនួន២៖

១. កែទម្រង់ និងពង្រឹងគោលនយោបាយអប់រំគ្រូបង្រៀន និងស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន

២. ពង្រឹងសាលាគរុកោសល្យ

ដើម្បីសម្រេចបានវត្ថុបំណងទី១ ក្រសួងនឹងផ្តោតលើការកែសម្រួលគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ ២០១៣ ស្របតាមបរិវត្តកម្មអប់រំ និងគោលការណ៍ណែនាំសម្រាប់គ្រូបង្រៀន និងគ្រូបង្រៀនជាប់កិច្ចសន្យា។ លើសពីនេះ ក្រសួងនឹងផ្តោតលើការអនុវត្តកំណែទម្រង់គ្រូបង្រៀនដែលលម្អិតនៅក្នុងផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន ២០២៤-២០៣០។ គណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន បង្កើតឡើងសម្រាប់វត្ថុបំណងខាងលើ។ ផែនការកែលម្អគុណភាពនៃការបង្រៀន ចាំបាច់ត្រូវកែទម្រង់ និងពង្រឹងសាលាគរុកោសល្យនៅទូទាំងប្រទេស។ ក្រសួងនឹងពង្រីក និងធ្វើឱ្យប្រសើរឡើងនូវបណ្តាញសាលាគរុកោសល្យរបស់ខ្លួន រួមទាំងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ហើយនឹងពង្រឹងមុខងាររបស់សាលាគរុកោសល្យ តាមរយៈការកសាងសមត្ថភាពលើការគ្រប់គ្រង និងគ្រូឧទ្ទេស និងតាមរយៈការកែលម្អប្រព័ន្ធធានាគុណភាពផ្ទៃក្នុងសម្រាប់សាលាគរុកោសល្យ។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃកម្មវិធីបណ្តុះបណ្តាលថ្មី ដែលជាសកម្មភាពសំខាន់មួយក្នុងអំឡុងពេលនៃការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពនៅតាមសាលាគរុកោសល្យ ដើម្បីអនុវត្តការបណ្តុះបណ្តាលគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។

ដើម្បីបង្កើនស្តង់ដា និងគុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន ក្រសួងនឹងពិនិត្យ និងកែលម្អស្តង់ដាសាលាគរុកោសល្យគំរូ ស្តង់ដាវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន ស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យ និងស្តង់ដានាយកសាលារៀន។ ក្រសួងនឹងអនុវត្តអាជ្ញាបណ្ណបង្រៀនវិជ្ជាជីវៈគ្រូបង្រៀនសម្រាប់គរុសិស្ស និងគរុនិស្សិត ដែលបញ្ចប់ការបណ្តុះបណ្តាលពីសាលាគរុកោសល្យ។ លើសពីនេះ ក្រសួងនឹងដាក់ឱ្យអនុវត្តកម្មវិធីណែនាំ កម្មវិធីគ្រូបង្រៀនចេញថ្មី ដើម្បីជួយសម្របសម្រួលដល់ការចាប់ផ្តើមអាជីពជាគ្រូបង្រៀន។ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិតនឹងត្រូវកែលម្អដោយផ្អែកលើក្របខ័ណ្ឌកម្មវិធីអប់រំគ្រូបង្រៀនឆ្នាំ២០២៣ និងត្រូវផ្តោតលើការបង្រៀន បរិយាបន្ន សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ការអប់រំពិសេស និងការអប់រំកាយ និងកីឡា។ ក្រសួងនឹងអនុវត្តការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនដល់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់។

យុទ្ធសាស្ត្រ និងសកម្មភាពគោលសំខាន់ៗ ដើម្បីសម្រេចវត្ថុបំណងទាំងនេះ មាននៅក្នុងតារាងដូចខាងក្រោម៖

| វត្ថុបំណងទី១៖ កែទម្រង់ និងពង្រឹងគោលនយោបាយអប់រំគ្រូបង្រៀន និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| គោលនយោបាយស្តីពីគ្រូបង្រៀនបានពិនិត្យ កែសម្រួល និងអនុម័ត ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ | ពិនិត្យ និងកែសម្រួល | អនុវត្ត |

| **យុទ្ធសាស្ត្រ** | **សកម្មភាពគោល** |
|---|---|
| **យុទ្ធសាស្ត្រទី១៖** អភិវឌ្ឍគោលនយោបាយ និងផែនការ ដើម្បីពង្រឹងការបណ្តុះបណ្តាលគ្រូបង្រៀន | **ការអភិវឌ្ឍគោលនយោបាយ**<br>- ពិនិត្យ និងកែលម្អគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០១៣ ឱ្យស្របតាមបរិវត្តកម្មអប់រំ (ត្រឹមឆ្នាំ២០២៥)<br>- រៀបចំក្របខ័ណ្ឌគោលនយោបាយគន្លងអាជីពគ្រូឧទ្ទេស និងសេចក្តីណែនាំសម្រាប់គ្រូឧទ្ទេស និងគ្រូបង្រៀនជាប់កិច្ចសន្យា(ត្រឹមឆ្នាំ២០២៦)។<br>**ការរៀបចំផែនការ**<br>- រៀបចំផែនការយុទ្ធសាស្ត្រកែទម្រង់ការបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា ឆ្នាំ២០២៤-២០២៨ (ត្រឹមឆ្នាំ២០២៤)<br>- អនុវត្តផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០។ |
| **យុទ្ធសាស្ត្រទី២៖** អភិវឌ្ឍ និងកែសម្រួលស្តង់ដាដែលមានស្រាប់ | **គោលការណ៍ណែនាំ និងស្តង់ដា**<br>- ពិនិត្យ និងកែលម្អស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនឆ្នាំ២០១៦ ស្តង់ដាសមត្ថភាពនាយកសាលាគរុកោសល្យឆ្នាំ២០១០ និងស្តង់ដានាយកសាលារៀនឆ្នាំ២០១៧ (ត្រឹមឆ្នាំ២០២៥)<br>- រៀបចំគោលការណ៍ណែនាំគោលនយោបាយ ដើម្បីគាំទ្រដល់ការទទួលស្គាល់ និងការវាយតម្លៃការរៀនសិក្សាពីមុន និង/ឬបទពិសោធវិជ្ជាជីវៈសម្រាប់ការផ្ទេរក្រេឌីតរវាងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន (ត្រឹមឆ្នាំ២០២៤)<br>- អនុវត្តអាជ្ញាបណ្ណវិជ្ជាជីវៈគ្រូបង្រៀនដល់គរុសិស្ស និងគរុនិស្សិតដែលបញ្ចប់ការបណ្តុះបណ្តាលនៅតាមសាលាគរុកោសល្យ ដើម្បីបំពេញសេចក្តីណែនាំស្តីពីការពង្រាយគ្រូបង្រៀនចាប់ពីឆ្នាំ២០២៤។ |

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| យុទ្ធសាស្ត្រទី៣៖ អភិវឌ្ឍ និងកែលម្អកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន | **ការអភិវឌ្ឍកម្មវិធីសិក្សា**<br>- អភិវឌ្ឍក្របខ័ណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ បរិញ្ញាបត្រ+១ ក្របខ័ណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនមត្តេយ្យសិក្សាតាមប្រព័ន្ធក្រេឌីត ១២+២ ក្របខ័ណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់ការអប់រំបរិយាបន្ន ១២+៤ និងក្របខ័ណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់ការអប់រំកាយ និងកីឡា ១២+៤ ចាប់ពីឆ្នាំ២០២៤<br>- ពិនិត្យឡើងវិញលើក្របខ័ណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំ ១២+៤ បរិញ្ញាបត្រ+២ និងកម្មវិធីបរិញ្ញាបត្រផ្នែកអប់រំកាយចាប់ពីឆ្នាំ២០២៤<br>- អភិវឌ្ឍក្របខ័ណ្ឌកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនដល់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ចាប់ពីឆ្នាំ២០២៥។ |
|---|---|

| វត្ថុបំណងទី២៖ ពង្រឹងសាលាគរុកោសល្យ | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោល្យនិងវិក្រឹតការដែលប្រែក្លាយជាវិទ្យាស្ថានគរុកោសល្យ | ២ | ៦ |
| ចំនួនគ្រូឧទ្ទេសនៅតាមសាលាគរុកោសល្យ ឆ្លើយតបនឹងស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស (បរិញ្ញាបត្រជាន់ខ្ពស់តាមជំនាញ) | ៣៩,០% | ៥០,០% |
| ចំនួនសាលាគរុកោសល្យ ឆ្លើយតបនឹងស្តង់ដាសាលាគរុកោសល្យគំរូ | N/A | ៧ |
| ចំនួនសាលាអនុវត្តន៍នៅតាមសាលាគរុកោសល្យក្លាយជាសាលារៀនគំរូ | N/A | ៧ |

| **យុទ្ធសាស្ត្រ** | **សកម្មភាពគោល** |
|---|---|
| **យុទ្ធសាស្ត្រទី១៖** ពង្រឹង និងពង្រីកបណ្តាញសាលាគរុកោសល្យ គ្រឹះស្ថានសិក្សា និងមហាវិទ្យាល័យ | **ការពង្រីកបណ្តាញ**<br>- ប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៤ ដែលមានស្រាប់ទៅជាវិទ្យាស្ថានគរុកោសល្យ<br>- ពង្រីកការបណ្តុះបណ្តាលគ្រូបង្រៀនមត្តេយ្យសិក្សាតាមប្រព័ន្ធ ១២+២ នៅតាមសាលាគរុកោសល្យ និងវិក្រឹតការដែលមានសក្តានុពល<br>- ប្រែក្លាយវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ទៅជាគ្រឹះស្ថានឧត្តមសិក្សា<br>- កែលម្អហេដ្ឋារចនាសម្ព័ន្ធនៅតាមសាលាគរុកោសល្យ។ |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី២៖** លើកកម្ពស់ជំនាញភាពជាអ្នកដឹកនាំ និងគុណវុឌ្ឍិ គណៈគ្រប់គ្រង គ្រូឧទ្ទេស គ្រូបង្រៀន សាលាគរុកោសល្យ និងសាលារៀន | **ការកែលម្អមុខងាររបស់សាលាគរុកោសល្យ**<br>- ពង្រឹងទំនាក់ទំនងរវាងសាលាគរុកោសល្យ និងសាលាអនុវត្តន៍<br>- អភិវឌ្ឍសមត្ថភាពគណៈគ្រប់គ្រង និងគ្រូឧទ្ទេសសាលាគរុកោសល្យ<br>- កែលម្អប្រព័ន្ធធានាគុណភាពផ្ទៃក្នុងនៅតាមសាលាគរុកោសល្យទាំងអស់<br>- អនុវត្តការបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+៤ និងបរិញ្ញាបត្រ+១ នៅតាមសាលាគរុកោសល្យ និងវិក្រឹតការ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគដែលមានសក្តានុពល<br>- កសាង និងពង្រឹងសមត្ថភាពសាលាគរុកោសល្យលើការអប់រំបរិយាបន្ន រួមទាំងការអភិវឌ្ឍមជ្ឈមណ្ឌលវប្បធម៌ និងភាសាជនជាតិដើមភាគតិច ឬការគាំទ្រការអប់រំពហុភាសា។<br>**ការអភិវឌ្ឍជំនាញភាពជាអ្នកដឹកនាំដល់គណៈគ្រប់គ្រង គ្រូឧទ្ទេស គ្រូបង្រៀន នៅតាមសាលាគរុកោសល្យ និងសាលារៀន**<br>- ដំឡើងគុណវុឌ្ឍិ និងផ្តល់នូវការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គណៈគ្រប់គ្រង គ្រូឧទ្ទេស និងគ្រូបង្រៀន។ |
| **យុទ្ធសាស្ត្រទី៣៖** អភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រូបង្រៀន | **ការពង្រឹងមូលដ្ឋានទិន្នន័យក្នុងការរៀបចំផែនការ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពសម្រាប់ការអភិវឌ្ឍគ្រូបង្រៀន**<br>- រៀបចំប្រវត្តិរូបរបស់គ្រូឧទ្ទេស បុគ្គលិកមិនបង្រៀន និងគរុសិស្ស គរុនិស្សិតនៅតាមសាលាគរុកោសល្យ<br>- បង្កើតប្រព័ន្ធគាំទ្រគ្រូឧទ្ទេស និងការវាយតម្លៃបុគ្គលិកអប់រំផ្សារភ្ជាប់នឹងការធានាគុណភាពផ្ទៃក្នុង។ |

**អនុកម្មវិធី៥.៣.២៖ អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពគ្រូបង្រៀន (កិច្ចការវិក្រឹតការ)**

| **លទ្ធផលរំពឹងទុករបស់អនុកម្មវិធី៖ គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន អភិវឌ្ឍបំណិនថ្មីតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ** | | |
|---|---|---|
| **សូចនាករផលសម្រេច** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ចំនួនគ្រូបង្រៀនឆ្លើយតបនឹងស្តង់ដាគុណវុឌ្ឍិជាតិ (យ៉ាងតិច១២+៤) | | |
| បឋមសិក្សា | ៥៩០ | ២ ៥៤០ |
| មធ្យមសិក្សា | ៣៧៩ | ១ ២៣០ |
| ចំនួនគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលលើការគ្រប់គ្រងសាលារៀន | ៩៥ | ៤៧៥ |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | |
|---|---|---|
| ចំនួនគណៈគ្រប់គ្រងសាលារៀនទទួលបានការបណ្តុះបណ្តាលលើការគ្រប់គ្រងសាលារៀន | ៧៩៧ | ៣ ៩៨៥ |
| ចំនួនគ្រូបង្រៀនបានអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំ | ១៤ ៣៩២ | ៣០ ១០០ |

**បញ្ហាប្រឈមគន្លឹះៗ៖**

- សមត្ថភាពបុគ្គលិកអប់រំតាមឯកទេសមិនគ្រប់គ្រាន់សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព
- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំនៅមិនទាន់មានប្រសិទ្ធភាព ជាពិសេសសម្រាប់បុគ្គលិកអប់រំនៅតាមការិយាល័យដែលបានធ្វើវិមជ្ឈការ និងគណៈគ្រប់គ្រងសាលារៀន
- គន្លងអាជីពគ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំបានបង្កើតឡើង ប៉ុន្តែមិនទាន់បានអនុវត្តពេញលេញដែលផលប៉ះពាល់នៅពេលបច្ចុប្បន្នកំពុងត្រូវបានស្រាវជ្រាវ វាយតម្លៃ និងចងក្រងជាឯកសារ។

ដើម្បីដោះស្រាយបញ្ហាប្រឈមគន្លឹះៗខាងលើ ក្រសួងអប់រំ យុវជន និងកីឡាមានវត្ថុបំណង៖

១. អនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពគ្រូបង្រៀន

ក្រសួងនឹងផ្តោតលើប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ តាមរយៈការពង្រឹងប្រព័ន្ធទទួលស្គាល់គុណភាពអប់រំ និងពង្រីកចំនួនអ្នកផ្តល់សេវាដែលត្រូវបានទទួលស្គាល់។ វេទិកាសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់ក្រសួងអប់រំ យុវជន និងកីឡា នឹងត្រូវបានកែលម្អផងដែរ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់គ្រូបង្រៀន និងផ្សារភ្ជាប់ទៅនឹងគន្លងអាជីពគ្រូបង្រៀន។ ប្រព័ន្ធបង្វឹក និងការណែនាំសម្រាប់គ្រូបង្រៀនចេញថ្មី និងគ្រូឧទ្ទេសនឹងត្រូវបានបង្កើតឡើងផងដែរ ដើម្បីឱ្យគ្រូបង្រៀន ឬគ្រូបង្រៀនចេញថ្មី អាចទទួលបានចំណេះដឹង និងការគាំទ្រលើវិជ្ជាជីវៈផ្អែកលើបទពិសោធ។ ប្រព័ន្ធព័ត៌មានគ្រប់គ្រងបុគ្គលិក នឹងត្រូវបានពង្រឹងសម្រាប់ប្រើប្រាស់ក្នុងការរៀបចំផែនការ និងការគ្រប់គ្រងនៅតាមសាលាគរុកោសល្យ សាលាអនុវត្តន៍ និងសាលាសហការ។ ចំណុចកែលម្អសំខាន់ៗ នឹងផ្តោតលើការរៀបចំប្រវត្តិរូបបុគ្គលិកអប់រំ និងគរុសិស្សគរុសិស្សនៅតាមសាលារៀនគរុកោសល្យ សម្រាប់ការគាំទ្រលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនាពេលអនាគត និងការអភិវឌ្ឍប្រព័ន្ធគាំទ្រគ្រូឧទ្ទេស និងការវាយតម្លៃបុគ្គលិកមិនបង្រៀន ដោយផ្សារភ្ជាប់ការធានាគុណភាពផ្ទៃក្នុង។

យុទ្ធសាស្ត្រ និងសកម្មភាពគោលសំខាន់ៗ ដើម្បីសម្រេចវត្ថុបំណងទាំងនេះ មាននៅក្នុងតារាងដូចខាងក្រោម៖

| **វត្ថុបំណងទី១៖ អនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពគ្រូបង្រៀន** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |

| | | |
|---|---|---|
| ចំនួនអ្នកឯកទេសអប់រំជាន់ខ្ពស់ផ្នែករៀបចំគោលនយោបាយ ផែនការ ស្ថិតិ កម្មវិធីសិក្សា វិធីសាស្ត្របង្រៀន ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អធិការកិច្ច និងវាយតម្លៃ | N/A | ១០០ |
| ចំនួនអ្នកឯកទេសអប់រំនៅគ្រឹះស្ថានសិក្សា និងគ្រឹះស្ថានបណ្តុះបណ្តាល (ផ្នែកមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា) | N/A | ២០០ |
| ចំនួនបុគ្គលិកអប់រំបានកត់ត្រានៅក្នុងប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ៥ ១៥៧ | ៥០ ០០០ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** រៀបចំកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈដល់បុគ្គលិកការិយាល័យអប់រំនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន | **ការវាយតម្លៃ**<br>- វិភាគប្រវត្តិរូបរបស់បុគ្គលិក (បទពិសោធ គុណវុឌ្ឍិ) ទាក់ទងនឹងបេសកកម្ម និងមុខងារ<br>- កំណត់តម្រូវការបណ្តុះបណ្តាល ការបង្វឹក ប្រឹក្សាគរុកោសល្យ និងទម្រង់នៃការអភិវឌ្ឍវិជ្ជាជីវៈផ្សេងៗ<br>- រៀបចំបញ្ជីកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈដែលមាន<br>- វាយតម្លៃតម្រូវការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំសម្រាប់អ្នកអប់រំ បច្ចេកទេស គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន។<br>**ការបង្កើត**<br>- ធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍធនធានមនុស្ស<br>- រៀបចំសំណើរសុំថវិកាសម្រាប់កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈ<br>- រៀបចំកម្មវិធីផ្តោតលើបញ្ហាឆ្លងវិស័យយេនឌ័រ និងការប្រែប្រួលអាកាសធាតុ សម្រាប់បុគ្គលិកគ្រប់គ្រងនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន<br>- រៀបចំផែនការអភិវឌ្ឍសមត្ថភាពលើបច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើនប្រសិទ្ធភាពការងារ ជាពិសេសការផ្តល់សិទ្ធិអំណាចលើយេនឌ័រក្នុងបច្ចេកវិទ្យាឌីជីថល។ |
| **យុទ្ធសាស្ត្រទី២៖** ពង្រឹងការអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពគ្រូបង្រៀន | **ការពង្រឹងប្រព័ន្ធ**<br>- ពង្រឹង និងពង្រីកប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រួមទាំងប្រព័ន្ធទទួលស្គាល់ និងការទទួលស្គាល់អ្នកផ្តល់សេវាអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>- ពង្រឹងយន្តការលើកកម្ពស់គន្លងអាជីពគ្រូបង្រៀនតាមរយៈប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - កែលម្អវេទិកាសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់ក្រសួង ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ផ្សារភ្ជាប់ជាមួយប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់ក្រសួង។ |
| **យុទ្ធសាស្ត្រទី៣៖** អភិវឌ្ឍ និងគាំទ្រការប្រើប្រាស់សៀវភៅណែនាំ និងគោលការណ៍ណែនាំសម្រាប់បុគ្គលិករដ្ឋបាល និងអ្នកគ្រប់គ្រងគ្រប់កម្រិត | **ការអភិវឌ្ឍ**<br>- រៀបចំបញ្ជីសារពើភ័ណ្ឌ និងវិភាគសម្ភារ សៀវភៅណែនាំ និងគោលការណ៍ណែនាំដែលមានសម្រាប់បុគ្គលិករដ្ឋបាល និងគ្រប់គ្រងអប់រំ ស្តីពីការអនុវត្តប្រកបដោយប្រសិទ្ធភាពលើមុខងារសំខាន់ៗ<br>- កែសម្រួល/ធ្វើបច្ចុប្បន្នភាព/រៀបចំសៀវភៅណែនាំ និងគោលការណ៍ណែនាំ<br>- រៀបចំក្របខ័ណ្ឌធានាគុណភាពអប់រំសម្រាប់នាយកដ្ឋានធានាគុណភាពអប់រំ រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន<br>- បង្កើតឧបករណ៍ស្វ័យវាយតម្លៃសាលារៀនផ្អែកតាមស្តង់ដាសាលារៀនគំរូ<br>- សុខដុមនីយកម្មសៀវភៅណែនាំអធិការកិច្ចប្រចាំសាលាឆ្លើយតបស្តង់ដាសាលារៀនគំរូ។<br>**ការគាំទ្រ**<br>- រៀបចំសិក្ខាសាលាស្តីពីការប្រើប្រាស់ឧបករណ៍ សៀវភៅណែនាំ និងសេចក្តីណែនាំស្តីពីការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃមុខងារសំខាន់ៗ<br>- រៀបចំយន្តការគាំទ្រដល់បុគ្គលិករដ្ឋបាល និងគ្រប់គ្រងថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន<br>- ធានានូវភាពងាយស្រួលក្នុងការចូលទៅប្រើប្រាស់ឯកសារពាក់ព័ន្ធ និងការគាំទ្រ<br>- ពង្រឹងការប្រើប្រាស់វេទិកាអភិវឌ្ឍសមត្ថភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ |
| **យុទ្ធសាស្ត្រទី៤៖** អនុវត្តកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | **ការបណ្តុះបណ្តាលវិជ្ជាជីវៈ**<br>- បណ្តុះបណ្តាលស្តីពីក្របខ័ណ្ឌធានាគុណភាពអប់រំដល់បុគ្គលិកអប់រំ គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀននៅថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន<br>- បណ្តុះបណ្តាលលើការវិភាគវិស័យអប់រំ ការបកស្រាយព័ត៌មានបរិមាណវិស័យ និងគុណវិស័យ និងការរៀបចំគោលនយោបាយ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - បណ្ដុះបណ្ដាលស្ដីពីម៉ូដែលវិភាគសម្រាប់គាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងរបាយការណ៍ពាក់កណ្ដាលអាណត្តិ ដើម្បីបង្កើនសមត្ថភាពរៀបចំផែនការអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- បណ្ដុះបណ្ដាលស្ដីពីបច្ចេកទេសនៃការប្រើប្រាស់ផែនទីសិក្សានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- រៀបចំកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- បណ្ដុះបណ្ដាលការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ស្ដីពីការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងបរិវត្តកម្មឌីជីថល<br>- ធ្វើបច្ចុប្បន្នកម្មវេទិកាអភិវឌ្ឍសមត្ថភាព ដើម្បីលើកកម្ពស់កម្មវិធីស្វ័យសិក្សា<br>- កម្មវិធីកសាងសមត្ថភាពលើបញ្ញាសិប្បនិមិត្ត ក្នុងការអប់រំ និងដំណោះស្រាយឌីជីថល ដើម្បីលើកកម្ពស់ការបង្រៀន និងការរៀន<br>- ផ្ដល់ឱកាសសិក្សាជាបន្តបន្ទាប់តាមរយៈព្រឹត្តិបត្រ វេទិកាអនឡាញ ឬបណ្ដាញទំនាក់ទំនងផ្ទៃក្នុង<br>- ចែករំលែកធនធាន អត្ថបទ និងការបង្រៀនទាក់ទងនឹងការអនុវត្តការងារដែលប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។<br>**ការសិក្សា**<br>- កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនសម្រាប់ថ្នាក់បរិញ្ញាបត្រ<br>- កម្មវិធីលើកកម្ពស់ភាពគុណវុឌ្ឍិគណៈគ្រប់គ្រងសម្រាប់ថ្នាក់អនុបណ្ឌិត<br>- កម្មវិធីក្រោយឧត្ដមសិក្សាសម្រាប់មន្ត្រីអប់រំ។ |
| **យុទ្ធសាស្ត្រទី៥៖** ណែនាំបុគ្គលិកចេញថ្មីឱ្យបានច្បាស់លាស់ និងការគ្រប់គ្រងក្នុងអំឡុងពេលសាកល្បងការងារ | **ការណែនាំ និងការត្រួតពិនិត្យ**<br>- រៀបចំសម្ភារសម្រាប់ការបណ្ដុះបណ្ដាល<br>- រៀបចំសិក្ខាសាលាតម្រង់ទិសសម្រាប់បុគ្គលិកថ្មី<br>- ពិនិត្យឡើងវិញនូវច្បាប់ និងបទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រងបុគ្គលិកក្រសួងអប់រំ<br>- អនុវត្តការប្រើប្រាស់ច្បាប់ និងបទប្បញ្ញត្តិ<br>- គាំទ្រការដាក់បញ្ចូលបច្ចេកវិទ្យាឌីជីថលសម្រាប់ការគ្រប់គ្រង ការងាររដ្ឋបាល និងការរៀបចំផែនការ<br>- បង្កើតធនធានអន្តរកម្មតាមអនឡាញ ដើម្បីបង្កើនការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - អនុវត្តកម្មវិធីណែនាំគ្រូបង្រៀនចេញថ្មី។ |
| **យុទ្ធសាស្ត្រទី៦៖** កែលម្អប្រព័ន្ធ ឬយន្តការគាំទ្រ | **ការបង្វឹក និងប្រឹក្សាយោបល់**<br>- បង្កើតប្រព័ន្ធបង្វឹក និងប្រឹក្សាយោបល់<br>- ពង្រឹងប្រព័ន្ធណែនាំនៅតាមសាលាគរុកោសល្យ និងកម្រិតសាលារៀន ដែលជាការជួបគ្នារវាងគ្រូឧទ្ទេសដែលមានបទពិសោធជាមួយគ្រូឧទ្ទេសចេញថ្មី។<br>**ការណែនាំគ្រូបង្រៀន**<br>- អនុវត្តកម្មវិធីណែនាំគ្រូបង្រៀនចេញថ្មីសម្រាប់គរុសិស្ស គរុនិស្សិតទើបបញ្ចប់ការបណ្តុះបណ្តាលពីសាលាគរុកោសល្យ។ |

**អនុកម្មវិធី៥.៣.៣៖ អភិវឌ្ឍសមត្ថភាព និងគាំទ្រការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**

**លទ្ធផលរំពឹងទុករបស់អនុកម្មវិធី៖ បុគ្គលិកអប់រំនៅតាមកម្រិតនៃរដ្ឋបាលអប់រំមានសមត្ថភាពអនុវត្តមុខងារប្រកបដោយផលិតភាពខ្ពស់ ស្របតាមកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**

| **សូចនាករផលសម្រេច** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
|---|---|---|
| ចំនួនអង្គភាពបានរៀបចំកិច្ចព្រមព្រៀងការបំពេញការងារ | | |
| ថ្នាក់កណ្តាល | N/A | ៥១ |
| ថ្នាក់រាជធានី-ខេត្ត | N/A | ២៥ |
| ថ្នាក់សាលារៀន | N/A | ១ ២០០ |

**បញ្ហាប្រឈមគន្លឹះ ៗ៖**

- ការអនុវត្តគោលនយោបាយ និងបទប្បញ្ញត្តិទូទាំងប្រទេសត្រូវពង្រឹង
- ក្របខ័ណ្ឌបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ និងនីតិវិធីនៃការអនុវត្តនានា ដើម្បីគាំទ្រការងារកំណែទម្រង់វិមជ្ឈការ និងវិសមជ្ឈការនៅមិនបានរៀបចំគ្រប់ជ្រុងជ្រោយ
- កំណែទម្រង់ចំនួន៣ រួមមាន កំណែរទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មិនទាន់មានសង្គតិភាពគ្នា ជាពិសេសក្របខ័ណ្ឌពេលវេលានៃការអនុវត្ត
- សមត្ថភាពបុគ្គលិកអប់រំទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិលើការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅមានកម្រិតទាប
- សមត្ថភាពរដ្ឋបាលក្រុង ស្រុក ខណ្ឌលើការគ្រប់គ្រង ចាត់ចែង អនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានផ្ទេរនៅមានកម្រិតទាប

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- មុខងាររចនាសម្ព័ន្ធមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត នៅមិនទាន់បានធ្វើបច្ចុប្បន្នភាពបន្ទាប់ពីការផ្ទេរមុខងារអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ខ្សែគណនេយ្យភាពរវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ គ្រឹះស្ថានសិក្សាសាធារណៈ ជាមួយមន្ទីរអប់រំ យុវជន និងកីឡា និងក្រសួងអប់រំ យុវជន និងកីឡា មិនទាន់មានភាពច្បាស់លាស់
- ការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងាររបស់អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋាន និងការិយាល័យពាក់ព័ន្ធនៅទាបនៅឡើយ នៅពុំទាន់មានការអនុវត្តថ្មី
- ការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងាររបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ/សង្កាត់ នៅមិនទាន់បានអនុវត្តស្របតាមឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃ
- ប្រព័ន្ធគ្រប់គ្រងកិច្ចការរដ្ឋបាលថ្នាក់ក្រោមជាតិនៅមិនទាន់បានធ្វើទំនើបកម្មស្របតាមបរិបទនៃការគ្រប់គ្រងរដ្ឋបាលឌីជីថល។

ដើម្បីដោះស្រាយបញ្ហាប្រឈមគន្លឹះខាងលើ អនុវកម្មវិធីនេះផ្តោតលើការអភិវឌ្ឍសមត្ថភាព និងគាំទ្រការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងវិស័យអប់រំ ដោយមានវត្ថុបំណងដូចខាងក្រោម៖

១. ធានាបាននូវភាពច្បាស់លាស់ និងកិច្ចព្រមព្រៀងលើតួនាទី និងភារកិច្ចរបស់តួអង្គផ្សេងៗ ប្រកបដោយប្រសិទ្ធភាព និងសមធម៌ ក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ

២. ពង្រឹងការអនុវត្តច្បាប់ និងការទទួលខុសត្រូវក្នុងការគាំទ្រ និងពិនិត្យតាមដានលើការអភិវឌ្ឍការអប់រំនៅថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន។

ការអនុវត្តគោលនយោបាយអប់រំប្រកបដោយជោគជ័យ ទាមទារឱ្យមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព រួមជាមួយបុគ្គលិកមានសមត្ថភាព ដោយកំណត់នូវតួនាទី និងភារកិច្ចច្បាស់លាស់នៅគ្រប់កម្រិតថ្នាក់។ តួនាទីរបស់តួអង្គពាក់ព័ន្ធ នឹងដើរតួនាទីសំខាន់នៅក្នុងរៀបចំ និងការអនុវត្តគោលនយោបាយអប់រំ ខណៈដែលក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

អនុកម្មវិធីអភិវឌ្ឍសមត្ថភាព និងគាំទ្រការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ផ្តោតលើការពិនិត្យឡើងវិញ និងបង្កើនការយល់ដឹងរបស់អ្នកពាក់ព័ន្ធ លើតួនាទី និងភារកិច្ចរបស់ពួកគេនៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលកំពុងបន្ត។ តម្រូវការសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងការគាំទ្រដើម្បីអនុវត្តកំណែទម្រង់ទាំងនេះនៅគ្រប់កម្រិត នឹងត្រូវកំណត់ និងដោះស្រាយ។ ដើម្បីបង្កើនគណនេយ្យភាពសង្គម ក្រសួងអប់រំ យុវជន និងកីឡានឹងពង្រឹងលើការអនុវត្តលិខិតបទដ្ឋានគតិយុត្ត និងស្ថាប័នចូលរួមគាំទ្រ និងពិនិត្យតាមដានការអភិវឌ្ឍការអប់រំ នៅតាមរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

យុទ្ធសាស្ត្រ និងសកម្មភាពគោលសំខាន់ៗ ដើម្បីសម្រេចវត្ថុបំណងទាំងនេះ មាននៅក្នុងតារាងខាងក្រោម៖

**វត្ថុបំណងទី១៖ ធានាឱ្យបានច្បាស់លាស់ និងការឯកភាពលើតួនាទី និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធ សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព និងសមធម៌ នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ។**

| សូចនាករលទ្ធផល | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
|---|---|---|
| ចំនួនមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត បានធ្វើការកែសម្រួលឡើងវិញ នូវតួនាទីនិងភារកិច្ច រចនាសម្ព័ន្ធ បន្ទាប់ពីការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាល ក្រុង ស្រុក ខណ្ឌ | N/A | ២៥ |
| ចំនួនគណៈគ្រប់គ្រងសាលារៀនបានទទួលការបំប៉នស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ | ២៣០ | ២ ៣០០ |
| ចំនួនបុគ្គលិកអប់រំនៅថ្នាក់ក្រុង ស្រុក ខណ្ឌ បានទទួលការបំប៉នស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ | N/A | ១ ០៤០ |
| ចំនួនថ្នាក់ដឹកនាំ បុគ្គលិកអប់រំក្រសួងអប់រំ យុវជន និងកីឡាបានទទួលការផ្សព្វផ្សាយអំពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | N/A | ៦០០ |
| ចំនួនបុគ្គលិកអប់រំនៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត បានទទួលការបណ្តុះបណ្តាលកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (ការផ្ទេរមុខងារ និងធនធាន នីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងអនុវត្តមុខងារ បុគ្គលិក ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងខ្សែគណនេយ្យភាព) | N/A | ២៤០ |
| ចំនួនរាជធានី-ខេត្ត ដែលបានរៀបចំឱ្យមានកិច្ចប្រជុំណែនាំបន្សុីគ្នាលើការងារ អប់រំរវាងរដ្ឋបាលរាជធានី-ខេត្ត មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ អំពីនីតិវិធីនៃការអនុវត្តមុខងារ ការងាររដ្ឋបាលអប់រំ ការគ្រប់គ្រង ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ ការគ្រប់គ្រងធនធានបុគ្គលិក ខ្សែគណនេយ្យភាព ការគាំទ្រ និងការពិនិត្យតាមដាននិងវាយតម្លៃ | N/A | ២៥ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** ពង្រឹងមុខងារ រចនាសម្ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិវិស័យអប់រំសម្រាប់ធានាការគាំទ្រដល់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ និងឃុំ/សង្កាត់ | **ការអភិវឌ្ឍ**<br>- ពិនិត្យតួនាទី និងការទទួលខុសត្រូវដែលមានស្រាប់ និងសម្ភារដែលមាននៅថ្នាក់រាជធានី ខេត្ត<br>- រៀបចំ និង/ឬ ធ្វើបច្ចុប្បន្នកម្មសៀវភៅណែនាំ និងសេចក្តីណែនាំ<br>- រៀបចំបទប្បញ្ញត្តិសម្រាប់ការអនុវត្តមុខងារអប់រំនៅកម្រិតផ្សេងៗគ្នា។<br>**ការពិនិត្យតាមដាន**<br>- វាយតម្លៃផលប៉ះពាល់នៃបទប្បញ្ញត្តិអប់រំ<br>- វាយតម្លៃប្រសិទ្ធភាពការងាររបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ស្តីពីការគ្រប់គ្រង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរ<br>- គ្រប់គ្រងវិវាទរបស់បុគ្គលិកអប់រំនៅក្នុងតុលាការ<br>- រៀបចំក្របខ័ណ្ឌគតិយុត្ត គោលការណ៍ណែនាំចំនួន២១ ស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ២១៣ អនក្រ.បកចុះថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ២០២៣ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>- ការពិនិត្យមើលឡើងវិញនូវមុខងារ សម្រាប់ជាមូលដ្ឋានក្នុងការកែសម្រួលតួនាទីភារកិច្ច ក្រសួង និងមន្ទីរ<br>- អនុក្រឹត្យ ស្តីពីតួនាទីភារកិច្ចក្រសួងអប់រំ យុវជន និងកីឡា<br>- ប្រកាសស្តីពីតួនាទី ភារកិច្ចមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត<br>- រៀបចំយន្តការគាំទ្រសម្រាប់តួអង្គនៅថ្នាក់កណ្តាល និងវិមជ្ឈការ/វិសហមជ្ឈការ<br>- រៀបចំឯកសារ និងបណ្តុះបណ្តាលដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធអំពីគោលការណ៍ បែបបទ និងនីតិវិធី នៃការអនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ<br>- រៀបចំយន្តការប្រព័ន្ធទំនាក់ទំនង (រំហូរការងារ ការទទួលខុសត្រូវ) រវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ<br>- រៀបចំនីតិវិធីរដ្ឋបាល នីតិវិធីហិរញ្ញវត្ថុ នីតិវិធីគ្រប់គ្រង<br>- រៀបចំកិច្ចប្រជុំតម្រង់ទិសនៅតាមរដ្ឋបាលរាជធានី-ខេត្តនីមួយៗ ដើម្បីបន្សុីគ្នាលើយន្តការនៃការអនុវត្តមុខងារអប់រំ យុវជន និងកីឡា |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - សម្របសម្រួល និងដោះស្រាយបញ្ហាមិនចុះសម្រុងការងារ និង/ឬ វិវាទការងាររវាងអង្គនីមួយៗនៅថ្នាក់ក្រោមជាតិ<br>- រៀបចំក្រុមការងារ និងយន្តការចុះពិនិត្យតាមដាន វាយតម្លៃ លើការអនុវត្តមុខងារដែលបានផ្ទេរជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ<br>- រៀបចំបង្កើត និងពង្រឹងឧបករណ៍នានាសម្រាប់ត្រួតពិនិត្យតាមដាន<br>- រៀបចំរបាយការណ៍ឆ្លុះបញ្ចាំងការអនុវត្ត និងផ្សព្វផ្សាយ<br>- វាយតម្លៃផលប៉ះពាល់នៃបទប្បញ្ញត្តិអប់រំ<br>- វាយតម្លៃការងារលើការគ្រប់គ្រង និងការអនុវត្តមុខងារអប់រំដែលបានផ្ទេរ<br>- រៀបចំនីតិវិធីសម្របសម្រួល និងគ្រប់គ្រងវិវាទរបស់បុគ្គលិកអប់រំនៅក្នុងតុលាការ<br>- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ អំពីនីតិវិធីសម្របសម្រួល និងគ្រប់គ្រងវិវាទរបស់បុគ្គលិកអប់រំនៅក្នុងតុលាការ (បុគ្គលិកអប់រំ មត្តេយ្យសិក្សា និងបឋមសិក្សាសាធារណៈ)<br>- ពិនិត្យនិងកែសម្រួលខ្លឹមសារលើកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋដើម្បីបន្សុីនឹងស្តង់ដាសេវារបស់សាលាបឋមសិក្សា<br>- រៀបចំយន្តការផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់សាលាបឋមសិក្សាតាមប្រព័ន្ធឌីជីថល<br>- ផ្សព្វផ្សាយកញ្ចប់ព័ត៌មានសាលាបឋមសិក្សា ដើម្បីលើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់ប្រជាពលរដ្ឋ<br>- បង្កើតក្រុមការងារលើកកម្ពស់ គាំទ្រការអនុវត្ត ការងារគណនេយ្យភាពសង្គមកម្រិតក្រុង ស្រុក ខណ្ឌ<br>- ពង្រឹងសកម្មភាពគណនេយ្យភាពសង្គម នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ។ |
| **យុទ្ធសាស្ត្រទី២៖** យល់ដឹងអំពីតួនាទី និងទំនួលខុសត្រូវរបស់តួអង្គនៅថ្នាក់កណ្តាល និងវិមជ្ឈការ/វិសហមជ្ឈការ | **ការផ្សព្វផ្សាយតួនាទី និងការទទួលខុសត្រូវ**<br>- រៀបចំសិក្ខាសាលាស្តីពីការប្រើប្រាស់សៀវភៅណែនាំ និងគោលការណ៍ណែនាំអំពីតួនាទី និងការទទួលខុសត្រូវ<br>- រៀបចំយន្តការគាំទ្រសម្រាប់តួអង្គនៅថ្នាក់កណ្តាល និងវិមជ្ឈការ និងវិសហមជ្ឈការ<br>- ធានានូវភាពងាយស្រួលក្នុងចូលទៅប្រើប្រាស់ឯកសារពាក់ព័ន្ធ និងការគាំទ្រ។ |

| | |
|---|---|
| **យុទ្ធសាស្ត្រទី៣៖** លើកកម្ពស់ការយល់ដឹងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍ និងវិស័យឯកជន លើតួនាទីក្នុងការគាំទ្រការអប់រំ និងការអភិវឌ្ឍសាលារៀន | **ការផលិតឯកសារ**<br>- រៀបចំសេចក្តីព្រាងស្តីពីតួនាទីសហគមន៍ និងវិស័យឯកជន<br>- រៀបចំឯកសារស្តីពីតួនាទី និងការទទួលខុសត្រូវសមស្របសម្រាប់សហគមន៍ និងវិស័យឯកជន។<br>**ការលើកកម្ពស់ការយល់ដឹង**<br>- រៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹង<br>- ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីផ្តល់ព័ត៌មានដល់សហគមន៍និងវិស័យឯកជន។ |

**វត្ថុបំណងទី២៖ ពង្រឹងអនុវត្តច្បាប់ និងការទទួលខុសត្រូវក្នុងការគាំទ្រ និងពិនិត្យតាមដានលើការអភិវឌ្ឍការអប់រំនៅថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន**

| សូចនាករលទ្ធផល | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
|---|---|---|
| ចំនួនរាជធានី-ខេត្ត មានក្រុមការងារបច្ចេកទេសចម្រុះកំពុងដំណើរការ | ១៦ | ២៥ |
| ចំនួនឯកសារគតិយុត្តបានរៀបចំប្រចាំឆ្នាំ | N/A | ១៧០ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** គាំទ្រគណៈកម្មការគ្រប់គ្រងសាលារៀន ក្រុង ស្រុក ខណ្ឌ និងរាជធានី-ខេត្ត ក្នុងការអនុវត្តតួនាទី | **ការផលិតឯកសារ**<br>- ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មសេចក្តីណែនាំពាក់ព័ន្ធលើតួនាទី និងការប្រព្រឹត្តទៅរបស់គណៈកម្មការគ្រប់គ្រងសាលារៀន<br>- ផ្តល់សេចក្តីណែនាំដល់សមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន។<br>**ការបណ្តុះបណ្តាល**<br>- ផ្តល់ឯកសារបណ្តុះបណ្តាលស្តីពីតួនាទី និងការប្រព្រឹត្តទៅរបស់គណៈកម្មការគ្រប់គ្រងសាលារៀន<br>- រៀបចំវគ្គបណ្តុះបណ្តាលខ្លីៗចូលរួមពីរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ។<br>**ការបង្វឹក និងប្រឹក្សាយោបល់**<br>- បង្វឹក និងប្រឹក្សាយោបល់ដល់បុគ្គលិកអប់រំ គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀននៅថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន លើការអនុវត្តក្របខ័ណ្ឌធានាគុណភាពអប់រំ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - បង្ហឹក និងប្រឹក្សាយោបល់លើអធិការកិច្ចផ្ទៃក្នុង ដោយផ្អែកលើស្តង់ដាសាលារៀនគំរូ<br>- បង្ហឹក និងប្រឹក្សាយោបល់លើស្តង់ដាសាលារៀនគំរូស្តីពីស្វ័យវង្វាយតម្លៃសាលារៀនពាក់ព័ន្ធនឹងសាលារៀនគំរូ<br>- បង្ហឹក និងប្រឹក្សាយោបល់លើស្តង់ដាសាលារៀនគំរូ ស្តីពីការបង្កើតក្លឹបបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ជាសកម្មភាពកម្មវិធីសិក្សាបន្ថែម<br>- បង្ហឹក និងប្រឹក្សាយោបល់ពីរបៀបពង្រឹងការអភិវឌ្ឍវិជ្ជាជីវៈ តាមរយៈវគ្គសិក្សាតាមអ៊ីនធឺណិត និងបើកទូលាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។ |
| **យុទ្ធសាស្ត្រទី២៖** កំណែទម្រង់អធិការកិច្ចអប់រំ ផ្តោតលើ ការកែលម្អសាលា-រៀន និងការអភិវឌ្ឍការអប់រំនៅតាមរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ | **ក្របខ័ណ្ឌការងារ**<br>- រៀបចំ និងផ្សព្វផ្សាយអនុក្រឹត្យស្តីពីតម្រូវការគុណវុឌ្ឍិ របស់អធិការ (ស្មើនឹងបរិញ្ញាបត្រជាន់ខ្ពស់)<br>- រៀបចំ និងផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការអនុវត្តអធិការកិច្ចផ្ទៃក្នុងនៅសាលារៀន ឆ្លើយតបស្តង់ដាសាលារៀនគំរូ<br>- រៀបចំ និងចេញសេចក្តីណែនាំស្តីពីការអនុវត្តការស្វ័យវាយតម្លៃសាលារៀន ឆ្លើយតបស្តង់ដាសាលារៀនគំរូ។<br>**ឧបករណ៍**<br>- ពិនិត្យឡើងវិញនូវរាល់ឧបករណ៍អធិការកិច្ច ឆ្លើយតបស្តង់ដាសាលារៀនគំរូ<br>- បង្កើតឧបករណ៍អធិការកិច្ចតាមប្រធានបទ។ |

### អនុកម្មវិធី៥.៣.៤៖ ការគ្រប់គ្រងបុគ្គលិក

| **លទ្ធផលរំពឹងទុករបស់អនុកម្មវិធី៖ បុគ្គលិកអប់រំនៅគ្រប់កម្រិតថ្នាក់ និងសាលារៀនមានធនធានមនុស្សគ្រប់គ្រាន់** | | |
|---|---|---|
| **សូចនាករផលសម្រេច** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ភាគរយមុខតំណែងបុគ្គលិកតែងតាំងគ្រប់គ្រាន់ស្របតាមលិខិតបទដ្ឋានគតិយុត្ត | ៥០,០% | ៦០,០% |
| ភាគរយបុគ្គលិកអប់រំជាស្ត្រីនៅតាមកម្រិតផ្សេងៗ | ១៨,០% | ២០,០% |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**បញ្ហាប្រឈមគន្លឹះៗ៖**

- ការបែងចែក និងការពង្រាយធនធានមនុស្សត្រូវបានកែលម្អ
- កង្វះធនធានមនុស្សដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាព
- ការពិពណ៌នាការងារ និងលក្ខខណ្ឌការងារត្រូវបានកែសម្រួលដោយយោងតាមការពិនិត្យឡើងវិញលើមុខងារ
- ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្សនៅមានកម្រិត
- សមភាពយេនឌ័រនៅក្នុងតួនាទីជាអ្នកគ្រប់គ្រងត្រូវបានលើកកម្ពស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ដើម្បីដោះស្រាយបញ្ហាប្រឈមៗខាងលើ អនុកម្មវិធីគ្រប់គ្រងបុគ្គលិកមានវត្ថុបំណងដូចខាងក្រោម៖

១. បង្កើនប្រសិទ្ធភាព និងសមធម៌ក្នុងការចែកចាយ ការដាក់ពង្រាយ និងការរក្សាធនធានមនុស្ស ដោយយកចិត្តទុកដាក់ជាពិសេសទៅលើតំបន់ជួបការលំបាក និងសមភាពយេនឌ័រ

ការអនុវត្តគោលនយោបាយ និងផែនការប្រកបដោយជោគជ័យ តម្រូវឱ្យមានធនធានមនុស្សដែលមានសមត្ថភាពខ្ពស់ និងបែងចែកដោយសមធម៌នៅក្នុងប្រព័ន្ធអប់រំ។ ដើម្បីធានាបាននូវការផ្តល់បុគ្គលិកអប់រំបានត្រឹមត្រូវ ឆ្លើយតបទៅនឹងតម្រូវការដែលបានកំណត់ ត្រូវធ្វើការកែលម្អផែនការជ្រើសរើសបុគ្គលិក ដោយផ្តោតការលើសមភាពយេនឌ័រ។

ការបែងចែកធនធានមនុស្សប្រកបដោយសមធម៌ គឺជាការចាំបាច់។ រូបមន្តក្នុងការផ្ទេរធនធានមនុស្សទៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងសាលារៀន នឹងត្រូវណែនាំ ដោយផ្អែកលើគោលការណ៍សមធម៌ ផែនការលើកទឹកចិត្ត ដើម្បីទាក់ទាញ និងរក្សាបុគ្គលិកនៅតំបន់ជួបការលំបាក។ ដើម្បីកែលម្អការប្រើប្រាស់ធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ត្រូវពង្រឹងតម្លាភាពនៃការបែងចែកធនធាន និងគណនេយ្យភាពសាធារណៈផ្អែកលើលទ្ធផល។

យុទ្ធសាស្ត្រ និងសកម្មភាពគោលសំខាន់ៗ ដើម្បីសម្រេចវត្ថុបំណងទាំងនេះ មាននៅក្នុងតារាងខាងក្រោម៖

| **វត្ថុបំណងទី១៖ បង្កើនប្រសិទ្ធភាព និងសមធម៌ក្នុងការចែកចាយ ការដាក់ពង្រាយ និងការរក្សាធនធានមនុស្ស ដោយយកចិត្តទុកដាក់ជាពិសេសទៅលើតំបន់ជួបការលំបាក និងសមភាពយេនឌ័រ** | | |
|---|---|---|
| សូចនាករលទ្ធផល | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
| ផលធៀបសិស្ស-គ្រូ[13] | | |
| បឋមសិក្សា | ៤៦:១ | ៤៩:១ |
| មធ្យមសិក្សា | ២៣:១ | ២៥:១ |

[13]ឆ្នាំគោលសំដៅឆ្នាំសិក្សា២០២២-២០២៣ ចំពោះទិន្នន័យឆ្នាំគោលត្រូវបានប្រើប្រាស់សម្រាប់ការធ្វើចំណោលផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ និងចំណុចដៅជាលទ្ធផលនៃការធ្វើចំណោល។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | |
|---|---|---|
| ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្សត្រូវបានអភិវឌ្ឍបន្ថែមទាក់ទងនឹងមុខងារការគ្រប់គ្រងធនធានមនុស្ស (ការសុំច្បាប់ ការគ្រប់គ្រងវត្តមាន ដំឡើងឋានន្តរស័ក្តិ ថ្នាក់) | ១០% | ៧០% |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** វាយតម្លៃតម្រូវការចាំបាច់ ដើម្បីកំណត់តម្រូវការជំនាញ | - វិភាគទិន្នន័យដែលមានស្រាប់ស្តីពីការផ្គត់ផ្គង់ និងតម្រូវការរបស់គ្រូបង្រៀននៅក្នុងសាលារៀនជួបការលំបាក<br>- សិក្សាតាមបែបគុណវិស័យលើសំណាកសាលារៀននៅសាលារៀនជួបការលំបាក<br>- ផ្តល់អនុសាសន៍សម្រាប់ប្រព័ន្ធលើកទឹកចិត្ត សេចក្តីណែនាំ និងយន្តការដែលបានកែសម្រួលសម្រាប់សាលារៀនជួបការលំបាក<br>- ពិនិត្យឡើងវិញលើការពណ៌នាការងារ និងលក្ខខណ្ឌការងារ<br>- ប្រព័ន្ធវាយតម្លៃការអនុវត្តការបំពេញការងារ។ |
| **យុទ្ធសាស្ត្រទី២៖** រៀបចំផែនការអភិវឌ្ឍធនធាន-មនុស្ស | - ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស<br>- រៀបចំផែនការធនធានមនុស្ស<br>- រៀបចំគោលការណ៍ណែនាំ និងផែនការសកម្មភាពក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងមុខតំណែងគ្រប់គ្រង<br>- ការអនុម័តសេចក្តីណែនាំស្តីពីសាលារៀនជួបការលំបាកនៅឆ្នាំ២០២៤<br>- ការអនុម័តយុទ្ធសាស្ត្រសម្រាប់កាត់បន្ថយការលើសខ្វះគ្រូបង្រៀន<br>- សហការជាមួយភាគីពាក់ព័ន្ធ ដើម្បីផ្តល់ធនធាន និងការគាំទ្របន្ថែម |
| **យុទ្ធសាស្ត្រទី៣៖** រៀបចំផែនការលើកទឹកចិត្ត ដើម្បីទាក់ទាញ និងរក្សាបុគ្គលិក | - ពិនិត្យឡើងវិញ និងជំរុញការអនុវត្តគោលការណ៍ណែនាំ និងយន្តការលើកទឹកចិត្តបុគ្គលិកបង្រៀននៅតំបន់ជួបការលំបាក<br>- រៀបចំផែនការអនុវត្តគន្លងអាជីពគ្រូបង្រៀន |
| **យុទ្ធសាស្ត្រទី៤៖** សម្រប-សម្រួលដំណើរការជ្រើសរើសបុគ្គលិកប្រចាំឆ្នាំនៅតាមកម្រិតនៃរដ្ឋបាលអប់រំ | - វិភាគបុគ្គលិកអប់រំដែលមានស្រាប់ និងកំណត់តម្រូវការ<br>- រៀបចំសំណើសុំកូតាជ្រើសរើសបុគ្គលិកអប់រំថ្មី<br>- សហការជាមួយក្រសួងមុខងារសាធារណៈ ដើម្បីត្រួតពិនិត្យដំណើរការប្រឡងជ្រើសរើសបុគ្គលិក។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៣.៧.៤ អនុកម្មវិធី៥.៤៖ ការវាយតម្លៃផ្អែកលើសមិទ្ធកម្ម

| លទ្ធផលរំពឹងទុករបស់អនុកម្មវិធី៖ លទ្ធផលនៃការពិនិត្យតាមដាន និងវាយតម្លៃប្រព័ន្ធអប់រំ នៅតាមការិយាល័យ និងសាលារៀន បង្ហាញដល់តួអង្គពាក់ព័ន្ធក្នុងវិស័យអប់រំឱ្យបានដឹងពីការអនុវត្តដែលល្អប្រសើរ និងអភិបាលកិច្ចល្អ។ | | |
|---|---|---|
| សូចនាករផលសម្រេច | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
| ចំនួនសាលារៀនគំរូបានអនុវត្តតេស្តស្តង់ដា | ១២០ | ៩០០ |
| ចំនួនសាលារៀនបានចុះអធិការកិច្ច | ១២០ | ៨០០ |

**បញ្ហាប្រឈមគន្លឹះៗ៖**

- ការវិភាគទិន្នន័យមិនបានគ្រប់គ្រាន់ រួមមានលទ្ធផលវាយតម្លៃ កង្វះភស្តុតាងក្នុងការរៀបចំគោលនយោបាយ និងការកំណត់សកម្មភាពកែលម្អ
- សមត្ថភាពបុគ្គលិកលើផ្នែកឯកទេសមិនទាន់គ្រប់គ្រាន់សម្រាប់ការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព
- ការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងាររបស់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងការិយាល័យពាក់ព័ន្ធនៅពុំទាន់មានការអនុវត្តនៅឡើយ

ដើម្បីដោះស្រាយបញ្ហាប្រឈមគន្លឹះៗខាងលើ អនុកម្មវិធីការវាយតម្លៃផ្អែកលើសមិទ្ធកម្មមានវត្ថុបំណងចំនួន៤ ដូចខាងក្រោម៖

១. កែលម្អការពិនិត្យតាមដាន និងវាយតម្លៃគោលនយោបាយ និងកម្មវិធីអប់រំ និងការប្រើប្រាស់សម្រាប់តម្រង់ទិសគោលនយោបាយ

២. កែលម្អរង្វាយតម្លៃ ការពិនិត្យតាមដាន និងវាយតម្លៃ អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសាលារៀន

៣. ដាក់ឱ្យអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្មនៅគ្រប់កម្រិត

៤. ពង្រឹងយន្តការគ្រប់គ្រងផ្ទៃក្នុងស្ថាប័នដើម្បីការអនុវត្តការងារជាប្រព័ន្ធមានភាពល្អប្រសើរ

ការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាព និងការអភិវឌ្ឍវិជ្ជាជីវៈ រួមជាមួយនឹងការផ្តោតលើគណនេយ្យភាពខ្ពស់។ ការពង្រឹងគណនេយ្យភាពទាមទារឱ្យមានយន្តការពិនិត្យតាមដាន និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព ដែលគ្របដណ្តប់លើគោលនយោបាយ និងផែនការ ព្រមទាំងការិយាល័យ និងសាលារៀន ដែលបង្ហាញដល់តួអង្គក្នុងប្រព័ន្ធអប់រំឆ្ពោះទៅរកគោលនយោបាយ និងសកម្មភាពកាន់តែមានប្រសិទ្ធភាព។ ឧបករណ៍បុព្វសិទ្ធិក្នុងការវាយតម្លៃការអនុវត្ត គឺការវាយតម្លៃការសិក្សាតាមស្តង់ដាជាតិ និងអន្តរជាតិ។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

ដើម្បីធានាបាននូវការអនុវត្តមានគណនេយ្យភាពសមស្រប កិច្ចព្រមព្រៀងសមិទ្ធកម្មត្រូវរៀបចំឡើង ដើម្បីណែនាំដល់ការិយាល័យ និងសាលារៀន ឆ្ពោះទៅរកការកែលម្អ និងតាមដានវឌ្ឍនភាពខ្លួន។ យន្តការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ដំណើរការប្រព័ន្ធកាន់ល្អប្រសើរ ជាពិសេសការិយាល័យសវនកម្ម និងអធិការកិច្ចនឹងត្រូវបានពង្រឹងផងដែរ។

យុទ្ធសាស្ត្រ និងសកម្មភាពគោលសំខាន់ៗ ដើម្បីសម្រេចវត្ថុបំណងទាំងនេះ មាននៅក្នុងតារាងខាងក្រោម៖

| វត្ថុបំណងទី១៖ កែលម្អការពិនិត្យតាមដាន និងវាយតម្លៃគោលនយោបាយ និងកម្មវិធីអប់រំ និងការប្រើប្រាស់សេចក្តីណែនាំគោលនយោបាយ។ | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃ សេចក្តីណែនាំ និងឧបករណ៍ផ្សេងៗបានធ្វើបច្ចុប្បន្នកម្ម | N/A | អនុវត្ត |
| ភាគរយសូចនាករកិច្ចព្រមព្រៀងសមិទ្ធកម្មកម្រិតកម្មវិធី អនុកម្មវិធីសម្រេចចំណុចដៅប្រចាំឆ្នាំ | N/A | ៨០% |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** អភិវឌ្ឍ និង/ឬគាំទ្រការបង្កើតប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ | **ការអភិវឌ្ឍ**<br>- ពិនិត្យឡើងវិញលើឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃនៃគោលនយោបាយ និងកម្មវិធីដែលមានស្រាប់<br>- បង្កើតប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើសមិទ្ធកម្ម<br>- បង្កើតក្របខ័ណ្ឌពិនិត្យតាមដាន និងវាយតម្លៃវិសាលភាពនិងទំនួលខុសត្រូវ។<br>**ការគាំទ្រ**<br>- បង្កើតឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃលើគោលនយោបាយ និងកម្មវិធី<br>- ចុះជួយបង្វឹក និងណែនាំដល់បុគ្គលិកអប់រំនៅតាមសាលារៀនដែលទទួលខុសត្រូវលើពិនិត្យតាមដាន និងវាយតម្លៃ។ |
| **យុទ្ធសាស្ត្រទី២៖** ផ្សព្វផ្សាយលទ្ធផលពិនិត្យតាមដាន និងវាយតម្លៃដែលបានវិភាគ ដើម្បីកំណត់បុគ្គលិកដែល | **ការរាយការណ៍**<br>- ពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំលើគោលនយោបាយស្តីពីផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងការអនុវត្តកម្មវិធី |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| ធ្វើការនៅកម្រិតផ្សេងៗនៃរដ្ឋបាលអប់រំ | - រៀបចំរបាយការណ៍ស្តីពីលទ្ធផលពិនិត្យតាមដាន និងវាយតម្លៃដោយមានអន្តរាគមន៍បន្ថែម<br>- ផ្សព្វផ្សាយរបាយការណ៍ដល់បុគ្គលិកពាក់ព័ន្ធ។ |
| **យុទ្ធសាស្ត្រទី៣៖** ប្រើប្រាស់ប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម ដើម្បីជំរុញការអនុវត្តនៅកម្រិតសាលារៀនឱ្យកាន់តែប្រសើរឡើង | **ការបង្កើត**<br>- កំណត់លក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃគ្រូបង្រៀនល្អ នាយកសាលារៀនល្អ សាលារៀនគំរូ និងសាលារៀនស្អាត<br>- កំណត់ជំហានក្នុងដំណើរការវាយតម្លៃ និងទំនួលខុសត្រូវ។<br>**ការអនុវត្ត**<br>- ជ្រើសរើស និងវាយតម្លៃគ្រូបង្រៀនល្អ នាយកសាលាល្អ សាលារៀនគំរូ និងសាលារៀនស្អាត ដើម្បីទទួលបានរង្វាន់<br>- ប្រារព្ធពិធីប្រគល់រង្វាន់ និងលើកកម្ពស់ការយល់ដឹងពីអ្នកទទួលរង្វាន់។ |
| **យុទ្ធសាស្ត្រទី៤៖** គាំទ្រការប្រើប្រាស់លទ្ធផលនៃការពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីផ្តល់ព័ត៌មានអំពីការរៀបចំ និងការអនុវត្តគោលនយោបាយឱ្យកាន់តែល្អប្រសើរនៅតាមកម្រិតរដ្ឋបាលអប់រំ | **ការវិភាគ**<br>- វិភាគលទ្ធផលនៃការពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីកំណត់មេរៀនស្តីពីគោលនយោបាយ និងការអនុវត្តកម្មវិធីមានភាពពាក់ព័ន្ធទៅនឹងកម្រិតផ្សេងៗនៃរដ្ឋបាលអប់រំ។<br>**ការណែនាំគោលនយោបាយ**<br>- ផ្តល់ការណែនាំដល់បុគ្គលិកអំពីរបៀបវិភាគលទ្ធផលនៃការពិនិត្យតាមដាន និងវាយតម្លៃ សម្រាប់ការរៀបចំគោលនយោបាយ និងកម្មវិធីឱ្យកាន់តែល្អប្រសើរ<br>- រៀបចំកម្មវិធីការងារជាមួយបុគ្គលិកនៅតាមកម្រិតរដ្ឋបាលអប់រំ ដើម្បីពិនិត្យមើលផលប៉ះពាល់គោលនយោបាយ និងពិភាក្សាអំពីរបៀបផ្លាស់ប្តូរដំណើរការ និងអន្តរាគមន៍ដែលមានស្រាប់។ |

**វត្ថុបំណងទី២៖ កែលម្អរង្វាយតម្លៃ ការពិនិត្យតាមដាន និងវាយតម្លៃ អង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសាលារៀន**

| សូចនាករលទ្ធផល | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
|---|---|---|
| ចំនួនអង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានចុះអធិការកិច្ចលើផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ | ៣៣ | ៥០ |
| | | |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** កែលម្អប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការបំពេញការងារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | **ការបង្កើត**<br>- ពិនិត្យយន្តការដែលមានស្រាប់ ដើម្បីពិនិត្យតាមដាន និងវាយតម្លៃនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- កំណត់សូចនាករសមិទ្ធកម្មគន្លឹះ ដាក់បញ្ចូលក្នុងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ<br>- រៀបចំយន្តការនៅក្នុងដំណើរការវាយតម្លៃ សម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។<br>**ការអនុវត្ត**<br>- លើកកម្ពស់ការយល់ដឹងដល់បុគ្គលិកអប់រំអំពីដំណើរការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងារ<br>- ពិនិត្យតាមដានការអនុវត្ត និងរៀបចំរបាយការណ៍ប្រចាំឆ្នាំ<br>- ពិភាក្សាលើរបាយការណ៍របកគំហើញ នៃការពិនិត្យតាមដាន និងវាយតម្លៃជាមួយបុគ្គលិកពាក់ព័ន្ធ<br>- សម្រិតសម្រាំង និងវាយតម្លៃគ្រូបង្រៀនល្អ នាយកសាលាល្អ សាលារៀនគំរូ និងសាលារៀនស្អាត ដើម្បីផ្តល់រង្វាន់។ |
| **យុទ្ធសាស្ត្រទី២៖** កែលម្អប្រព័ន្ធវាយតម្លៃ តាមដាន និងវាយតម្លៃការអនុវត្តរបស់សាលារៀន | **ការរៀបចំ**<br>- ពិនិត្យយន្តការដែលមានស្រាប់ ដើម្បីតាមដាន និងវាយតម្លៃការអនុវត្តរបស់សាលារៀន<br>- កំណត់សូចនាករសមិទ្ធកម្ម ដោយដាក់បញ្ចូលក្នុងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ<br>- រៀបចំយន្តការនៅក្នុងដំណើរការវាយតម្លៃ សម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃសាលារៀន។<br>**ការអនុវត្ត**<br>- រៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងជាមួយបុគ្គលិកអប់រំនៅសាលារៀន អំពីដំណើរការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងារ<br>- ពិនិត្យតាមដានការអនុវត្ត និងរៀបចំរបាយការណ៍ជាប្រចាំ<br>- វាយតម្លៃគុណភាពការរៀបចំផែនការសាលារៀន<br>- ពិភាក្សាអំពីរបាយការណ៍លទ្ធផលពិនិត្យតាមដាន និងវាយតម្លៃជាមួយបុគ្គលិកពាក់ព័ន្ធ។ |

| | |
|---|---|
| **យុទ្ធសាស្ត្រទី៣៖** គាំទ្រការរៀបចំ និងប្រើប្រាស់រង្វាយតម្លៃការសិក្សាតាមស្តង់ដាជាតិ | **ការរៀបចំរង្វាយតម្លៃ**<br>- បង្កើតធនាគារតេស្តស្តង់ដាដើម្បីបំពេញតាមស្តង់ដានៃរង្វាយតម្លៃការសិក្សាថ្នាក់ជាតិ<br>- ចុះជួយបង្វឹក និងណែនាំដល់បុគ្គលិក នៅតាមសាលារៀនស្តីពីការរៀបចំ និងអនុវត្តរង្វាយតម្លៃតាមសាលារៀន<br>- ចុះជួយបង្វឹក និងណែនាំដល់បុគ្គលិកនៅមន្ទីរអប់រំ យុវជន និងកីឡា ស្តីពីការរៀបចំ និងអនុវត្តរង្វាយតម្លៃតាមសាលារៀន<br>- បណ្តុះបណ្តាលគណៈកម្មការប្រឡង ស្តីពីការគាំទ្រការប្រឡងថ្នាក់ជាតិ<br>- រៀបចំការប្រឡងថ្នាក់ជាតិថ្នាក់ទី៩ និងទី១២ និងការប្រឡងសិស្សពូកែថ្នាក់ជាតិ<br>- អនុវត្តការវាយតម្លៃជំនាញបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដើម្បីកំណត់ផ្នែកដែលបុគ្គលិកអប់រំត្រូវការកែលម្អ និងប្រើប្រាស់លទ្ធផលដើម្បីកែសម្រួលកម្មវិធីបណ្តុះបណ្តាល និងផែនការអភិវឌ្ឍបុគ្គល។<br>**ការប្រើប្រាស់ការរង្វាយតម្លៃ**<br>- វិភាគលទ្ធផលរង្វាយតម្លៃការសិក្សាថ្នាក់ជាតិ ដើម្បីរៀបចំរបាយការណ៍<br>- ពង្រឹងការប្រើប្រាស់លទ្ធផលរង្វាយតម្លៃតាមសាលារៀន ដើម្បីកែលម្អការរៀបចំផែនការសាលារៀន និងវិធីសាស្ត្របង្រៀន និងរៀននៅកម្រិតសាលារៀន<br>- ផ្សព្វផ្សាយ និងប្រើប្រាស់លទ្ធផលរង្វាយតម្លៃការសិក្សាថ្នាក់ជាតិ ដើម្បីផ្តល់ជាព័ត៌មានសម្រាប់កែលម្អគុណភាពអប់រំ។ |
| **យុទ្ធសាស្ត្រទី៤៖** គាំទ្រការចូលរួមក្នុងការរង្វាយតម្លៃការសិក្សាតាមស្តង់ដាក្នុងតំបន់ និងអន្តរជាតិ | **ការរៀបចំរង្វាយតម្លៃ**<br>- បង្កើតធនាគារតេស្តស្តង់ដាដើម្បីបំពេញតាមស្តង់ដានៃរង្វាយតម្លៃការសិក្សាអន្តរជាតិ<br>- គ្រូបង្វឹក និងគ្រូណែនាំបុគ្គលិកអប់រំពាក់ព័ន្ធលើការអភិវឌ្ឍនិងការអនុវត្តការវាយតម្លៃតាមសាលារៀន ដើម្បីបំពេញតាមស្តង់ដានៃរង្វាយតម្លៃការសិក្សាអន្តរជាតិ<br>- អនុវត្តតេស្តរង្វាយតម្លៃថ្នាក់តំបន់ និងអន្តរជាតិ តាមវដ្ត ដើម្បីវាស់វែងលទ្ធផលសិក្សារបស់សិស្សនៅអប់រំចំណេះទូទៅ<br>- ជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនសិស្សឆ្នើមទៅចូលរួមប្រកួតនៅអូឡាំពិកអន្តរជាតិ។<br>**ការប្រើប្រាស់ការវាយតម្លៃ**<br>- វិភាគ និងផលិតរបាយការណ៍ជាតិតេស្តរង្វាយតម្លៃថ្នាក់តំបន់ និងអន្តរជាតិ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - ផ្សព្វផ្សាយ និងប្រើប្រាស់លទ្ធផលតេស្តវាយតម្លៃថ្នាក់តំបន់ និងអន្តរជាតិ ដើម្បីលើកកម្ពស់គុណភាពអប់រំ<br>- ពង្រឹងសាលារៀនឱ្យប្រើប្រាស់លទ្ធផលវាយតម្លៃតាមសាលារៀន ដើម្បីរៀបចំផែនការកែលម្អសាលារៀន និងកែលម្អវិធីសាស្ត្របង្រៀន និងរៀននៅសាលារៀន។ |

| វត្ថុបំណងទី៣៖ ដាក់ឱ្យអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្មនៅគ្រប់កម្រិត | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ភាគរយអង្គភាពនៅថ្នាក់កណ្តាលបានរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មជាមួយក្រសួង និងផ្តល់របាយការណ៍សមិទ្ធកម្មជាទៀងទាត់ | ៨៥,០% | ១០០% |
| ចំនួនកម្មវិធីបានចុះកិច្ចព្រមព្រៀងសមិទ្ធកម្មជាមួយក្រសួងអប់រំ យុវជន និងកីឡា (ប្រធានកម្មវិធី និងរដ្ឋមន្ត្រី) | N/A | ៥ |
| ចំនួនអង្គភាពនៅថ្នាក់កណ្តាល និងរាជធានី-ខេត្ត រៀបចំចុះកិច្ចព្រមព្រៀងសមិទ្ធកម្មជាមួយក្រសួង និងត្រូវបានពិនិត្យតាមដាន | | |
| អង្គភាពថ្នាក់កណ្តាល | N/A | ៥១ |
| រាជធានី-ខេត្ត | N/A | ២៥ |
| ចំនួនសាលារៀនបានរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន និងត្រូវបានពិនិត្យតាមដាន | ១២០ | ១ ២០០ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** ដាក់ឱ្យអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម | - លើកកម្ពស់ការយល់ដឹងរបស់បុគ្គលិកគ្រប់គ្រងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសាលារៀន អំពីវត្ថុបំណងនៃកិច្ចព្រមព្រៀងសមិទ្ធកម្ម<br>- ពង្រឹងសមត្ថភាពលើការរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មសម្រាប់បុគ្គលិកអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>- រៀបចំទម្រង់គំរូសម្រាប់កិច្ចព្រមព្រៀងសមិទ្ធកម្ម។ |
| **យុទ្ធសាស្ត្រទី២៖** ពិនិត្យតាមដានជាប្រចាំ និងរៀបចំរបាយការណ៍ស្តីពីការអនុវត្តនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ | - រៀបចំទម្រង់របាយការណ៍ និងការកំណត់អំពីតួនាទីរបស់អ្នកពាក់ព័ន្ធក្នុងការរៀបចំរបាយការណ៍<br>- បណ្តុះបណ្តាល និងណែនាំអំពីរបៀបការសរសេររបាយការណ៍សមិទ្ធកម្មដល់បុគ្គលិកពាក់ព័ន្ធ។ |



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

| | |
|---|---|
| និងសាលារៀន ដោយផ្អែកលើកិច្ចព្រមព្រៀងសមិទ្ធកម្ម | |
| **យុទ្ធសាស្ត្រទី៣៖** កំណត់ និងអនុវត្តសកម្មភាពស្របតាមកិច្ចព្រមព្រៀងសមិទ្ធកម្ម | - ផ្តល់ការណែនាំដល់បុគ្គលិកពាក់ព័ន្ធអំពីវិធីសាស្ត្រដើម្បីកំណត់សកម្មភាព<br>- រៀបចំកម្មវិធីពិភាក្សាលើការប្រើប្រាស់កិច្ចព្រមព្រៀងសមិទ្ធកម្មដើម្បីកំណត់សកម្មភាព<br>- គាំទ្របុគ្គលិកពាក់ព័ន្ធក្នុងការកំណត់ និងអនុវត្តសកម្មភាព។ |

| **វត្ថុបំណងទី៤៖ ពង្រឹងយន្តការគ្រប់គ្រងផ្ទៃក្នុងស្ថាប័នដើម្បីអនុវត្តការងារមានលក្ខណៈជាប្រព័ន្ធកាន់តែប្រសើរ** | | |
|---|---|---|
| **សូចនាករលទ្ធផល** | **ឆ្នាំគោល ២០២៣** | **ចំណុចដៅ ២០២៨** |
| ភាគរយអង្គភាពបានរងសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ | | |
| អង្គភាពថ្នាក់កណ្តាល | ៣០,០% | ៨០,០% |
| រាជធានី-ខេត្ត | ៤០,០% | ៨០,០% |
| សាលារៀន | ៣,០% | ៥,០% |
| ភាគរយអង្គភាពអនុវត្តតាមអនុសាសន៍សវនកម្មផ្ទៃក្នុង | ៦០,០% | ៨០,០% |
| ចំនួនអង្គភាពត្រូវបានចុះធ្វើអធិការកិច្ចប្រចាំឆ្នាំ | ៣៣៥ | ៥០០ |
| ចំនួនវិវាទត្រូវបានដោះស្រាយ | ១៣ | ១៥ |

| យុទ្ធសាស្ត្រ | សកម្មភាពគោល |
|---|---|
| **យុទ្ធសាស្ត្រទី១៖** អនុវត្តសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ដោយគោរពតាមច្បាប់ និងនីតិវិធី | - អនុវត្តសវនកម្មទៀងទាត់ដើម្បីធានាថាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គភាពដែលរងសវនកម្ម ត្រូវបានរៀបចំឡើងដើម្បីសម្រេចបាននូវគោលដៅ និងវត្ថុបំណងដែលបានកំណត់ និងគ្រោងទុក<br>- ពង្រឹងនីតិវិធីសវនកម្ម និងសមត្ថភាពសវនកម្មផ្ទៃក្នុង ស្របតាមមុខងារសវនកម្មដែលបានកំណត់<br>- ពង្រឹងគុណភាពនៃស្តង់ដារបាយការណ៍សវនកម្ម។ |
| **យុទ្ធសាស្ត្រទី២៖** ពង្រឹងអភិបាលកិច្ចនៃការគ្រប់គ្រងការអនុលោម និងការបំពេញការងាររបស់បុគ្គលិកអប់រំ | **ការធ្វើអធិការកិច្ច**<br>- ធ្វើអធិការកិច្ចជាផ្លូវការពីវិធីសាស្ត្រហានិភ័យ ករណីសង្ស័យ បុគ្គល រដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិសាធារណៈ នៅតាមគ្រឹះស្ថានសាធារណៈ និងឯកជន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| | - ពិនិត្យតាមដាន និងលើកសំណើសុំឆ្លើយតបនឹងករណីពាក់ព័ន្ធបុគ្គលរដ្ឋបាល ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ<br>- បង្កើតកម្មវិធីអធិការកិច្ចនៅតាមគ្រឹះស្ថានសិក្សាឯកជន<br>- ផ្សព្វផ្សាយរបាយការណ៍អធិការកិច្ច<br>- ប្រមូលព័ត៌មាន និងលើកវិធានការដោះស្រាយភាពមិនប្រក្រតីក្នុងវិស័យអប់រំ យុវជន និងកីឡា រួចដាក់ជូនគណៈគ្រប់គ្រងត្រួតពិនិត្យ និងសម្រេច<br>- ពិនិត្យវឌ្ឍនភាពនៃការធ្វើអធិការកិច្ចតាមអង្គភាព និងស្ថាប័នអប់រំដែលបានធ្វើអធិការកិច្ច ឬមិនប្រក្រតី។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ជំពូកទី៤៖ ការគណនាតម្រូវការ ការព្យាករថវិកា និងជម្រើសហិរញ្ញប្បទាន

ការអប់រំ និងការអភិវឌ្ឍធនធានមនុស្ស គឺជាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។ ការតម្រង់ទិសជាយុទ្ធសាស្ត្រនេះគឺត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០២៤ ដែលរួមបញ្ចូលក្នុងចំណោមអាទិភាពគន្លឹះៗ «ដើម្បីលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសនៅគ្រប់កម្រិត ដើម្បីផ្គត់ផ្គង់បុគ្គលិកការងារប្រកបដោយជំនាញខ្ពស់ឱ្យបានគ្រប់គ្រាន់ និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារ»។

កម្មវិធី និងអនុកម្មវិធីនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ប្រែក្លាយការតម្រង់ទិសគោលនយោបាយទាំងមូលឱ្យទៅជាសកម្មភាពជាក់ស្តែងដែលគ្របដណ្តប់លើការអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស ការអប់រំឧត្តមសិក្សា ការសិក្សាពេញមួយជីវិត ការអភិវឌ្ឍយុវជន និងការអប់រំកាយនិងកីឡា។ ដើម្បីវាយតម្លៃលទ្ធភាពហិរញ្ញវត្ថុនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័អប់រំ គឺចាំបាច់ត្រូវធ្វើការប៉ាន់ស្មានតម្រូវការថវិកាសម្រាប់ការអនុវត្តកម្មវិធី/អនុកម្មវិធី និងប្រៀបធៀបការចំណាយទាំងនេះធៀបនឹងធនធានហិរញ្ញវត្ថុដែលមានសម្រាប់រយៈពេល៥ឆ្នាំ។ គោលបំណងនៃជំពូកនេះ បង្ហាញអំពីការធ្វើចំណោលការចំណាយសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ការព្យាករថវិកាសម្រាប់កម្រិតផ្សេងៗ នៃរដ្ឋបាលអប់រំ និងយុទ្ធសាស្ត្រកៀរគរធនធានដើម្បីដោះស្រាយគម្លាតថវិកាតម្រូវការ។

ការធ្វើចំណោលនៅក្នុងជំពូកនេះ គឺផ្អែកលើម៉ូដែលវិភាគតម្រូវការអប់រំ ដែលបានរៀបចំឡើង ជាពិសេសសម្រាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ គោលបំណងសំខាន់នៃម៉ូដែលនេះ គឺដើម្បីសម្របសម្រួលកិច្ចសន្ទនាគោលនយោបាយ និងគាំទ្រដល់ការរៀបចំគោលនយោបាយអប់រំថ្នាក់ជាតិ និងយុទ្ធសាស្ត្រដែលមានភាពប្រទាក់ក្រឡាគ្នា ឆ្ពោះទៅរកការរៀបចំផែនការអប់រំប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងការចំណាយឱ្យចំគោលដៅ។ ម៉ូដែលវិភាគតម្រូវការអប់រំធ្វើជាជម្រើសគោលនយោបាយ ការកំណត់ផ្នែកបច្ចេកទេស និងឧបសគ្គផ្នែកហិរញ្ញវត្ថុមកពិចារណាដើម្បីធ្វើចំណោលតម្រូវការធនធាន និងលទ្ធភាពនាពេលអនាគត សម្រាប់ធ្វើជាមូលដ្ឋានក្នុងកិច្ចសន្ទនាគោលនយោបាយ។

ម្យ៉ាងវិញទៀត ម៉ូដែលវិភាគតម្រូវការអប់រំ រួមមាន ការធ្វើចំណោលនៃការចំណាយដើម្បីគាំទ្រដល់អន្តរាគមន៍ដែលបានគ្រោងទុក និងជាពិសេសការព្យាករថវិកាសម្រាប់វិស័យអប់រំទាំងមូល។ តាមរយៈការប្រៀបធៀបធ្វើចំណោលថវិកាចំណាយ និងការព្យាករថវិកា។ ម៉ូដែលវិភាគនេះអនុញ្ញាតឱ្យមានការប៉ាន់ស្មានគម្លាតថវិកា ដោយផ្តល់ជាព័ត៌មានក្នុងការកំណត់ជម្រើស នៃការកៀរគរធនធាន ដែលត្រូវបន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំនេះ។

ម៉ូដែលវិភាគតម្រូវការអប់រំអនុញ្ញាតឱ្យបង្កើត និងប្រៀបធៀបជម្រើសសេណារីយ៉ូនៃការចំណាយ និងហិរញ្ញប្បទានមានលក្ខណៈផ្សេងៗគ្នា និងជាពិសេស មានសារៈសំខាន់ក្នុងការបន្សឺចំណុចដៅគោលនយោបាយ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ជាមួយនឹងឧបសគ្គថវិកា។ តាមរយៈជំពូកនេះនឹងពិពណ៌នាឱ្យដឹងអំពីលទ្ធផលសម្រាប់ការធ្វើចំណោលចំពោះសេណារីយ៉ូនៃការចំណាយ និងហិរញ្ញប្បទានដែលចាត់ទុកជាការឆ្លុះបញ្ចាំងដ៏ប្រសើរបំផុតអំពីមហិច្ឆតានៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងការរំពឹងទុករបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការវិភាជន៍ថវិការបស់រាជរដ្ឋាភិបាលដល់វិស័យអប់រំរហូតដល់ឆ្នាំ២០២៨។

## ៤.១ ការព្យាករតម្រូវការថវិកានៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ

### ៤.១.១ សេណារីយ៉ូតម្រូវការថវិកា និងសម្មតិកម្មគន្លឹះៗ

ការព្យាករតម្រូវការថវិកា ចំបាច់ត្រូវផ្តោតលើចំណោលនៃការចុះឈ្មោះចូលរៀន ដោយផ្អែកលើ ចំណោលប្រជាសាស្ត្រ ចំណុចដៅគោលនយោបាយនៃការចូលរៀន និងលទ្ធផលសិក្សារបស់សិស្សនៅតាមកម្រិតសិក្សា ទម្រង់នៃការផ្តល់សេវាអប់រំ និងគោលដៅអប់រំ ព្រមទាំងការចូលរួមរបស់ប្រជាពលរដ្ឋ និងការអនុវត្តកម្មវិធីការអភិវឌ្ឍយុវជន និងការអប់រំកាយនិងកីឡា។ ការព្យាករត្រូវគិតគូរពីចំណុចដៅគោលនយោបាយផ្សារភ្ជាប់ទៅនឹងលិខិតបទដ្ឋានគតិយុត្តក្នុងការផ្តល់គុណភាពសេវាអប់រំ។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ កំណត់ចំណុចដៅទាក់ទងនឹងការចូលរៀនក្នុងការអប់រំកុមារតូច ការអប់រំកម្រិតមូលដ្ឋាន ការអប់រំបច្ចេកទេស ការអប់រំមធ្យមសិក្សាទុតិយភូមិ និងការអប់រំឧត្តមសិក្សា។ ផែនការនេះ រួមបញ្ចូលផងដែរនូវអន្តរាគមន៍ជាច្រើន ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំ។ បរិការណ៍នេះ បានឆ្លុះបញ្ចាំងនៅក្នុងការព្យាករថវិកាអប់រំក្នុងគោលដៅ ដើម្បីកាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា រួមទាំងការធ្វើចំណោលនៃការចុះឈ្មោះចូលរៀនតាមកម្រិតភូមិសិក្សា ពីឆ្នាំ២០២៤ ដល់ ២០២៨។ រូបភាពខាងក្រោមពិពណ៌នាអំពីការវិវត្តនៃអត្រារួមនៃការសិក្សាដែលបានព្យាករណ៍នៅតាមកម្រិតសិក្សា ដោយផ្តោតលើការប៉ាន់ស្មានចំណាយសម្រាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ យោងតាមការព្យាករនេះ ការអប់រំកម្រិតមូលដ្ឋានជាសាកល រហូតដល់ថ្នាក់ទី៩ នឹងសម្រេចបាននៅត្រឹមឆ្នាំ២០៣៥។

**រូបភាព ៤.១៖ ចំណោលអត្រារួមនៃការសិក្សា ២០២២-២០២៨ តាមភូមិសិក្សា**






youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដើម្បីឱ្យឆ្លើយតបនឹងការវិវត្តនៃការចុះឈ្មោះចូលរៀន ការព្យាករតម្រូវការថវិកាអប់រំផ្តោតលើចំណុចដៅដែលគ្របដណ្តប់លើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការរៀបចំសេចក្តីណែនាំនៅតាមសាលារៀន (ចំណុះថ្នាក់ ផលធៀបគ្រូ-ថ្នាក់ វេនសិក្សា។ល។) និងកម្រិតនៃការចូលរួមរបស់វិស័យឯកជនក្នុងការផ្តល់សេវាអប់រំ។ ចំណុចដៅសំខាន់ៗ ផ្សារភ្ជាប់ទៅនឹងការរៀបចំសេចក្តីណែនាំដែលប្រើប្រាស់ក្នុងការព្យាករតម្រូវការថវិកាមានដូចបង្ហាញខាងក្រោម។ តារាងនេះបង្ហាញពីការវិវត្តនៃការធ្វើចំណោលផ្នែកបុគ្គលិកបង្រៀន និងថ្នាក់រៀនតាមកម្រិតអប់រំសាធារណៈ និងឯកជន។

**តារាង ៤.១៖ សេណារីយ៉ូការព្យាករតម្រូវការថវិកា-ចំណុចដៅសំខាន់ៗទាក់ទងនឹងសេចក្តីណែនាំ**

| | | ឆ្នាំគោល ២០២២ | ចំណុចដៅ ២០២៨ |
|---|---|---|---|
| **សិស្សក្នុងមួយថ្នាក់** | | | |
| | មត្តេយ្យសិក្សា | ៣០ | ៣០ |
| | បឋមសិក្សា | ៣៣ | ៤០ |
| | មធ្យមសិក្សាបឋមភូមិ | ៤៦ | ៤៦ |
| | មធ្យមសិក្សាទុតិយភូមិ | ៤៥ | ៤៥ |
| **គ្រូបង្រៀនក្នុងមួយថ្នាក់** | | | |
| | មត្តេយ្យសិក្សា | ០,៦៦ | ០,៨៣ |
| | បឋមសិក្សា | ០,៧១ | ០,៨៧ |
| | មធ្យមសិក្សាបឋមភូមិ | ១,៩៧ | ១,៨៣ |
| | មធ្យមសិក្សាទុតិយភូមិ | ១,៩១ | ២,០៦ |
| **ភាគរយសាលារៀនបង្រៀនពីរវេន** | | | |
| | បឋមសិក្សា | ៦០,៩% | ៤៥,០% |
| | មធ្យមសិក្សា | ១៣,០% | ៨,៦% |
| **ភាគរយចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានសិក្សាឯកជន** | | | |
| | មត្តេយ្យសិក្សា | ១៣,៣% | ១៣,៣% |
| | បឋមសិក្សា | ៦,៥% | ៦,៥% |
| | មធ្យមសិក្សាបឋមភូមិ | ៥,៨% | ៥,៨% |
| | មធ្យមសិក្សាទុតិយភូមិ | ៧,១% | ៧,១% |
| | ឧត្តមសិក្សា | ៦៨,១% | ៦៨,១% |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## រូបភាពទី ៤.២៖ ចំណោលបុគ្គលិកបង្រៀនតាមភូមិសិក្សាសាធារណៈ និងឯកជន (២០២២-២០២៨)







## រូបភាពទី ៤.៣៖ ចំណោលបន្ទប់រៀនតាមភូមិសិក្សាសាធារណៈ និងឯកជន(២០២២-២០២៨)







ការជ្រើសរើសមន្ត្រីរាជការស៊ីវិលថ្មី កំណត់ដោយក្រសួងមុខងារសាធារណៈ ផ្អែកតាមការធ្វើចំណោលសន្មតថាការជ្រើសរើសមន្ត្រីរាជការថ្មីជាបុគ្គលិកគ្រូបង្រៀនប្រចាំឆ្នាំ (ប្រកបដោយគុណវុឌ្ឍិ) មានចំនួនថេរនៅឆ្នាំ២០២៣។ ផ្អែកតាមការព្យាករ គម្លាតរវាងតម្រូវការគ្រូបង្រៀនប្រចាំឆ្នាំ និងគ្រូបង្រៀនក្នុងក្របខ័ណ្ឌដែលមានស្រាប់ ត្រូវបានសន្មតថានឹងត្រូវបំពេញដោយការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា។ រូបភាពទី៤.៤ ការធ្វើចំណោលគ្រូបង្រៀន នៅមត្តេយ្យសិក្សាសាធារណៈ និងសហគមន៍ បឋមសិក្សា (គ្រូបង្រៀនជាប់កិច្ចសន្យា) និងមធ្យមសិក្សា (២០២២-២០២៨) ដែលមានផលប៉ះពាល់ដល់ការធ្វើចំណោលនៃការចំណាយបៀវត្ស។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

**រូបភាពទី ៤.៤៖ ការធ្វើចំណោលគ្រូបង្រៀន នៅមត្តេយ្យសិក្សាសាធារណៈ និងសហគមន៍ បឋមសិក្សា (គ្រូបង្រៀនជាប់កិច្ចសន្យា) និងមធ្យមសិក្សា (២០២២-២០២៨)**




ការព្យាកររួមបញ្ចូលទាំងការប៉ាន់ស្មានចំណាយ ដើម្បីសម្រេចនូវចំណុចដៅដែលបានកំណត់ដោយផ្សារភ្ជាប់ទៅនឹងអាទិភាពកំណែទម្រង់ទាំង ៨ចំណុច របស់ក្រសួងអប់រំ យុវជន និងកីឡា ដូចដែលបានបង្ហាញនៅក្នុងតារាង៤.២។ ការចំណាយប៉ាន់ស្មាននៅក្នុងយុទ្ធសាស្ត្រដែលបានជ្រើសរើសបានគូសបញ្ជាក់ក្នុងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ២០២៤-២០៣០ ក៏ត្រូវបានរួមបញ្ចូលផងដែរនៅក្នុងការព្យាករតម្រូវការថវិកាក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

**តារាង ៤.២៖ សេណារីយ៉ូការព្យាករតម្រូវការថវិកា - ចំណុចដៅសំខាន់ៗទាក់ទងនឹងកំណែទម្រង់អាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា**

| | | ឆ្នាំគោល ២០២៣ | ចំណុចដៅ ២០២៨ |
|---|---|---|---|
| **១. ការពង្រឹងអភិបាលកិច្ចសាលារៀន** | | | |
| ចំនួនសាលារៀនគំរូ | មត្តេយ្យសិក្សា | ១០ | ១០០ |
| | បឋមសិក្សា | ៤០ | ៩០០ |
| | មធ្យមសិក្សា | ៧០ | ៥០០ |
| ចំនួនសាលារៀនជំនាន់ថ្មី | មធ្យមសិក្សា | ៧ | ២៥ |
| **២. ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សា ឱ្យស្របតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស** | | | |
| ចំនួនសាលាបឋមសិក្សាដែលអនុវត្តការបង្រៀននិងរៀនពេញមួយថ្ងៃ | បឋមសិក្សា | ៩ | ៦០០ |
| **៣. ការយកចិត្តទុកដាក់លើសុខភាពសិក្សារបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន** | | | |
| ចំនួនសាលារៀនសាធារណៈដែលអនុវត្តកម្មវិធីអាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍ | មត្តេយ្យសិក្សា | ០ | ២០០ |
| | បឋមសិក្សា | ៤២៧ | ១ ១១៤ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | | |
|---|---|---|---|
| **៤. ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក ភាពជាដៃគូ រដ្ឋ និងសហគមន៍ ដើម្បីការអប់រំ** | | | |
| *កម្មវិធីអាហារូបករណ៍សិស្សក្រីក្រ* | | | |
| ចំនួនសិស្សទទួលផលពីកម្មវិធីអាហារូបករណ៍ប្រចាំឆ្នាំនៅ | បឋមសិក្សា | ១៤៨ ៣៦២ | ១៤៨ ៩៥៧ |
| | មធ្យមសិក្សាបឋមភូមិ | ១០២ ៣៥៩ | ១១៩ ៩៦១ |
| | មធ្យមសិក្សាទុតិយភូមិ | ១១ ១៦៧ | ១៣ ១១៧ |
| *ការពង្រីកការអប់រំក្រៅប្រព័ន្ធនៅតាមសាលារៀន* | | | |
| ចំនួនអ្នកចូលរួមនៅក្នុងកម្មវិធីបណ្ដុះបណ្ដាលការសិក្សាពេញមួយជីវិត | ការអប់រំក្រៅប្រព័ន្ធ | ១០ ២៣៩ | ១៣ ០០០ |
| ការពង្រីកកម្មវិធីយុវជន | | | |
| ចំនួនយុវជនចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍យុវជន | យុវជន | ២ ៣៨៥ | ៣ ៧៥០ |
| **៥. ការអប់រំឌីជីថល** | | | |
| ភាគរយសាលារៀនមានសម្ភារបរិក្ខារព័ត៌មាន បច្ចេកវិទ្យា និងសារទូរគមនាគមន៍ដំណើរការ | មធ្យមសិក្សា | ២៦,៧% | ១០០% |
| **៦. ការបង្កើតមជ្ឈមណ្ឌលឧត្ដមភាពនៅគ្រឹះស្ថានឧត្ដមសិក្សា** | | | |
| ការចុះឈ្មោះចូលរៀនថ្មីប្រចាំឆ្នាំនៅតាមគ្រឹះស្ថានឧត្ដមសិក្សាសាធារណៈ | ឧត្ដមសិក្សា | ៧ ០០០ | ៧ ០០០ |
| ចំនួនមជ្ឈមណ្ឌលឧត្ដមភាព | ឧត្ដមសិក្សា | ៤ | ៧ |
| **៧. ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព** | | | |
| ភាគរយគ្រូបង្រៀនមានគុណវុឌ្ឍិ | មត្តេយ្យសិក្សា | ៧២,៥% | ៨៦,៣% |
| | បឋមសិក្សា | ៧៦,៥% | ៨៨,៣% |
| | មធ្យមសិក្សាបឋមភូមិ | ៨៩,៦% | ៩៤,៨% |
| | មធ្យមសិក្សាទុតិយភូមិ | ៨៩,០% | ៩៤,៥% |
| ចំនួនវិទ្យាស្ថានគរុកោសល្យដំណើរការពេញលេញ | ការបណ្ដុះបណ្ដាលគ្រូបង្រៀន | ២ | ៦ |
| ភាគរយសាលាអនុវត្ត ឆ្លើយតបស្តង់ដាអប្បបរមា | ការអប់រំបច្ចេកទេស | ០% | ៨០% |
| ភាគរយសាលារៀនចំណេះទូទៅដែលអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ការបណ្ដុះបណ្ដាលគ្រូបង្រៀន | ០% | ៥០% |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | | |
|---|---|---|---|
| ភាគរយគ្រូបង្រៀនមានសញ្ញាបត្រវិញ្ញាបត្រ | ការបណ្ដុះបណ្ដាលគ្រូបង្រៀន | ៣០% | ៥០% |
| ចំនួនសាលាបឋមសិក្សារដ្ឋដែលធ្វើអធិការកិច្ចសាលារៀន | បឋមសិក្សា | - | ៨០០ |
| **៨. ការអភិវឌ្ឍការអប់រំកាយ និងកីឡា** | | | |
| ភាគរយសាលារៀនដែលអនុវត្តកម្មវិធីអប់រំកាយ | បឋមសិក្សា | ៧៤,២% | ៨៧,១% |
| | មធ្យមសិក្សា | ៧៧,៣% | ៨៨,៧% |

ការប៉ាន់ស្មានតម្លៃឯកតាដែលពាក់ព័ន្ធផ្អែកលើការវិភាគនៃការចំណាយថវិកានាពេលកន្លងមក និងការសិក្សាជាក់ស្ដែង ឬការប៉ាន់ស្មានដែលមិនបានគ្រោងទុកមុន ក្នុងករណីមានអន្តរាគមន៍ថ្មីៗចាំបាច់។ ឧទាហរណ៍ គោលការណ៍ណែនាំគោលនយោបាយផ្សេងៗ ស្ដីពីប្រាក់បំណាច់គ្រូបង្រៀន ត្រូវបានដាក់បញ្ចូលក្នុងការធ្វើចំណោលនេះផងដែរ ដែលជាការកំណត់ការប្រែប្រួលនៃតម្លៃឯកតាពាក់ព័ន្ធ (ឧះការដំឡើងបៀវត្សគ្រូបង្រៀន ៥,៤ ភាគរយ ជារៀងរាល់ឆ្នាំ និងផ្អែកលើគុណវុឌ្ឍិ និងបទពិសោធ)។

### ៤.១.២ លទ្ធផលការព្យាករតម្រូវការថវិកា

ការចំណាយសរុបសម្រាប់រដ្ឋបាលសាធារណៈ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨ បានប៉ាន់ស្មានមានចំនួន ២២ ០៤៥ ៥៣២ លានរៀល (៥ ០១៨ លានដុល្លារអាមេរិក) ក្នុងថ្លៃថេរឆ្នាំ២០២៣។ តម្រូវការថវិកាប្រចាំឆ្នាំកើនឡើងពី ៣ ៨៣១ ៥៩២ លានរៀល (៨៩៣លានដុល្លារសហរដ្ឋអាមេរិក) នៅឆ្នាំ២០២៤ រហូតដល់ ៤ ៩២៤ ១៥៧ លានរៀល (១ ០៩៨លានដុល្លារអាមេរិក) ក្នុងថ្លៃថេរឆ្នាំ២០២៨។ ចំណាយបៀវត្ស ៧៣,៧ ភាគរយ និងចំណាយមូលធន ៣,១ ភាគរយ នៃតម្រូវការថវិកាសរុប។

**តារាង ៤.៣៖ ការធ្វើចំណោលតម្រូវការហិរញ្ញវត្ថុ (ចំណាយប៉ាន់ស្មាន)**

| | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|---|
| ចំណោលតម្រូវការហិរញ្ញវត្ថុសរុប | | | | | | | | |
| *គិតជាលានរៀល ថ្លៃបច្ចុប្បន្ន* | ៣ ៥៧២ ៣១៩ | ៣ ៩១៩ ៩២៤ | ៤ ៣៩៤ ៨២៧ | ៤ ៧៨៥ ៣៦៣ | ៥ ១៤២ ២២៥ | ៥ ៥៧៩ ២៣៩ | **២៣ ៨២១ ៥៧៨** | ១០០% |
| *គិតជាលានរៀល ថ្លៃថេរឆ្នាំ២០២៣* | ៣ ៥៧២ ៣១៩ | ៣ ៨៣១ ៥៩២ | ៤ ១៨៩ ៣៧៣ | ៤ ៤៤៤ ៥១៨ | ៤ ៦៥៥ ៨៩២ | ៤ ៩២៤ ១៥៧ | **២២ ០៤៥ ៥៣២** | ១០០% |
| *គិតជាលានដុល្លារ ថ្លៃថេរឆ្នាំ២០២៣* | ៨៤១ | ៨៩៣ | ៩៦៥ | ១ ០១៣ | ១ ០៥០ | ១ ០៩៨ | **៥ ០១៨** | ១០០% |
| ចំណោលតម្រូវការហិរញ្ញវត្ថុ តាមប្រភេទនៃការចំណាយ (គិតជាលានរៀល ថ្លៃថេរ២០២៣) | | | | | | | | |
| ថវិកាចរន្ត | ៣ ៤០៧ ៩៥៤ | ៣ ៧៥៩ ៣៤០ | ៤ ០៤៧ ០៥១ | ៤ ២៧៤ ៥១១ | ៤ ៥១៥ ៣០៤ | ៤ ៧៧១ ៩៤២ | **២១ ៣៦៨ ១៤៩** | ៩៦,៩% |
| ប្រាក់បៀវត្ស | ២ ៦៩២ ៦៣៤ | ២ ៨៦៤ ៣៦០ | ៣ ០៥១ ៥១៧ | ៣ ២៤១ ០៦៥ | ៣ ៤៤២ ៦៤៦ | ៣ ៦៥៧ ៤៩៣ | **១៦ ២៥៧ ០៧៩** | ៧៣,៧% |
| មិនមែនប្រាក់បៀវត្ស | ៧១៥ ៣២០ | ៨៩៤ ៩៨១ | ៩៩៥ ៥៣៥ | ១ ០៣៣ ៤៤៦ | ១ ០៧២ ៦៥៩ | ១ ១១៤ ៤៤៩ | **៥ ១១១ ០៦៩** | ២៣,២% |
| ថវិកាមូលធន | ៦០ ១០៥ | ៧២ ២៥២ | ១៤២ ៣២១ | ១៧០ ០០៧ | ១៤០ ៥៨៨ | ១៥២ ២១៥ | **៦៧៧ ៣៨៣** | ៣,១% |



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

ការធ្វើចំណោលតម្រូវការហិរញ្ញវត្ថុ រៀបចំទៅតាមកម្មវិធី និងអនុកម្មវិធី នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ តារាងខាងក្រោមបង្ហាញពីចំណោលតម្រូវការថវិកាតាមកម្មវិធី/អនុកម្មវិធីតាមឆ្នាំនីមួយៗ និងសម្រាប់ការអនុវត្តក្នុងរយៈពេល៥ឆ្នាំ។

**តារាង ៤.៤៖ ការធ្វើចំណោលតម្រូវការហិរញ្ញវត្ថុ (ចំណាយប៉ាន់ស្មាន) តាមកម្មវិធី/អនុកម្មវិធី នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ (គិតជាលានរៀល ថ្លៃថេរឆ្នាំ២០២៣)**

| *ការប៉ាន់ស្មានថវិកា តាមកម្មវិធី និងអនុកម្មវិធី* | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|---|
| **សរុប** | ៣ ៥៧២ ៣១៩ | ៣ ៨៣១ ៥៩២ | ៤ ១៨៩ ៣៧៣ | ៤ ៤៤៤ ៥១៨ | ៤ ៦៥៥ ៨៩២ | ៤ ៩២៤ ១៥៧ | **២២ ០៤៥ ៥៣២** | ១០០% |
| **កម្មវិធី១** | *២ ៩៤១ ៨០៥* | *៣ ១៤៨ ៣២០* | *៣ ៣៥៥ ៧២៩* | *៣ ៥៥៩ ១១១* | *៣ ៧៤០ ១១២* | *៣ ៩៥៤ ៣៣២* | *១៧ ៧៥៧ ៦០៣* | ៨០,៥% |
| ១.១ ការអប់រំកុមារតូច | ១៩៧ ០៤៧ | ១៩៤ ៩៨៧ | ២៤៩ ៥៥៣ | ២៧៦ ២៥៦ | ២៥៧ ៨២៦ | ២៧៦ ៩៥៩ | ១ ២៥៥ ៥៨១ | ៥,៧% |
| ១.២ ការអប់រំបឋមសិក្សា | ១ ៤៩៣ ៦៨៥ | ១ ៥៤២ ៦១៩ | ១ ៥៦៣ ៩៧៨ | ១ ៥៧៨ ១៥០ | ១ ៥៨៧ ៩១២ | ១ ៥៩៦ ១៥៦ | ៧ ៨៦៨ ៨១៥ | ៣៥,៧% |
| ១.៣ ការអប់រំមធ្យមសិក្សាចំណេះទូទៅ និងបច្ចេកទេស | | | | | | | | |
| ការអប់រំមធ្យមសិក្សាចំណេះទូទៅ | ១ ១៦១ ៧៩០ | ១ ២៤១ ៦១៧ | ១ ៣២៧ ២៤៤ | ១ ៤៣៧ ៥៧៥ | ១ ៥៦៨ ១២៣ | ១ ៦៨៨ ៧៤៤ | ៧ ២៦៣ ៣០៤ | ៣២,៩% |
| ការអប់រំបច្ចេកទេស | ១២៩ ២៨៣ | ១៦៩ ០៩៦ | ២១៤ ៩៥៣ | ២៦៧ ១៣០ | ៣២៦ ២៥០ | ៣៩២ ៤៧៤ | ១ ៣៦៩ ៩០៣ | ៦,២% |
| **កម្មវិធី២** | *២២៩ ៦៣២* | *២៦៦ ៣១៣* | *២៨២ ៩៣៤* | *៣២២ ៥៨៦* | *៣៤០ ៤៦៤* | *៣៨១ ៩១៩* | *១ ៥៩៤ ២១៥* | ៧,២% |
| ២.១ ការអប់រំឧត្តមសិក្សា<br>២.២ ការស្រាវជ្រាវ និងនវានុវត្តន៍ | ២២៩ ៦៣២ | ២៦៦ ៣១៣ | ២៨២ ៩៣៤ | ៣២២ ៥៨៦ | ៣៤០ ៤៦៤ | ៣៨១ ៩១៩ | ១ ៥៩៤ ២១៥ | ៧,២% |
| **កម្មវិធី៣** | *៧១ ៤០៩* | *៨០ ៨៦៩* | *៩០ ៩៣២* | *១០១ ០២៦* | *១១១ ២៨៩* | *១២១ ៦៦២* | *៥០៥ ៧៧៧* | ២,៣% |
| ៣.១ ការអប់រំក្រៅប្រព័ន្ធ និងការសិក្សាពេញមួយជីវិត | ៥១ ៩៦០ | ៦១ ៨១៤ | ៧១ ៦៦៩ | ៨១ ៥៦៩ | ៩១ ៦២៣ | ១០១ ៧៨៥ | ៤០៨ ៤៦០ | ១,៩% |
| ៣.២ ការអភិវឌ្ឍយុវជន | ១៩ ៤៤៩ | ១៩ ០៥៥ | ១៩ ២៦៣ | ១៩ ៤៥៧ | ១៩ ៦៦៥ | ១៩ ៨៧៧ | ៩៧ ៣១៧ | ០,៤% |
| **កម្មវិធី៤** | *៦៩ ៨៧៨* | *៧០ ៥៥៣* | *៧១ ១០១* | *៧១ ៥១១* | *៧១ ៩០៩* | *៧២ ៣១០* | *៣៥៧ ៣៨៤* | ១,៦% |
| ៤.១ ការអប់រំកាយ និងកីឡា | ៦៩ ៨៧៨ | ៧០ ៥៥៣ | ៧១ ១០១ | ៧១ ៥១១ | ៧១ ៩០៩ | ៧២ ៣១០ | ៣៥៧ ៣៨៤ | ១,៦% |
| **កម្មវិធី៥** | *១៥៥ ៣៣៥* | *២៦៥ ៥៣៨* | *៣៨៨ ៦៧៨* | *៣៩០ ២៨៤* | *៣៩២ ១១៩* | *៣៩៣ ៩៣៤* | *១ ៨៣០ ៥៥៣* | ៨,៣% |
| ៥.១ គោលនយោបាយ និងផែនការផ្តែកលើភស្តុតាង<br>៥.២ ការគ្រប់គ្រងហរិញ្ញវត្ថុ<br>៥.៤ ការវាយតម្លៃផ្អែកលើសមិទ្ធកម្ម | ១២៨ ៧១៥ | ២៣៨ ៥២៤ | ២៣៩ ៥៩៤ | ២៤០ ៤៤៥ | ២៤១ ៤៣២ | ២៤២ ៤០២ | ១ ២០២ ៣៩៦ | ៥,៥% |
| ៥.៣ ការអប់រំគ្រូបង្រៀន | ២៦ ៦២០ | ២៧ ០១៤ | ១៤៩ ០៨៤ | ១៤៩ ៨៣៨ | ១៥០ ៦៨៧ | ១៥១ ៥៣២ | ៦២៨ ១៥៧ | ២,៨% |

## ៤.២ ការព្យាករថវិកាសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា

### ៤.២.១ សេណារីយ៉ូហិរញ្ញប្បទាន និងសម្មតិកម្មគន្លឹះៗ

ការព្យាករថវិកាសម្រាប់វិស័យអប់រំ ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ ផ្តោតលើចំណុចដូចខាងក្រោម៖

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ការព្យាករម៉ាក្រូសេដ្ឋកិច្ច (ផលិតផលក្នុងស្រុកសរុប) ដែលមាននៅលើគេហទំព័រមូលដ្ឋានទិន្នន័យទស្សនវិស័យសេដ្ឋកិច្ចពិភពលោក
- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤ ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ការបញ្ចេញសាច់ប្រាក់ជំនួយអភិវឌ្ឍន៍ផ្លូវការដែលបានគ្រោងទុក និងកិច្ចព្រមព្រៀងសហប្រតិបត្តិការក្រៅប្រទេសក្នុងវិស័យអប់រំនៅចន្លោះឆ្នាំ២០២៤ និងឆ្នាំ២០២៦
- ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា ២០២៤-២០២៦
- ច្បាប់ថវិកាឆ្នាំ២០២៣ និងឆ្នាំ២០២៤។

សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗដែលប្រើប្រាស់ក្នុងការព្យាករថវិកាដូចបានបង្ហាញខាងក្រោម។

**តារាង ៤.៥៖ សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ (ការធ្វើចំណោល) ដែលប្រើប្រាស់ក្នុងការព្យាករថវិកា**

| | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| **ផលិតផលក្នុងស្រុកសរុប** | | | | | | |
| គិតជាលានរៀល ថ្លៃបច្ចុប្បន្ន | ១៣១ ៣៨៧ ១៦៧ | ១៤២ ៦៦០ ២១៦ | ១៥៥ ៦២៩ ៧៧៦ | ១៧០ ១៤៤ ៣៩៧ | ១៨៥ ៤២៧ ៩២១ | ២០២ ២២៤ ៣៨៥ |
| គិតជាលានរៀល ថ្លៃថេរឆ្នាំ២០២៣ | ១៣១ ៣៨៧ ១៦៧ | ១៣៩ ៤៤៥ ៥០៩ | ១៤៨ ៣៥៤ ២០៩ | ១៥៨ ០២៥ ៥៩៤ | ១៦៧ ៨៩០ ៨២៦ | ១៧៨ ៤៨០ ៣៥៣ |
| គិតជាលានដុល្លារអាមេរិក ថ្លៃថេរឆ្នាំ ២០២៣ | ៣០ ៩៤៣ | ៣២ ៤៨៤ | ៣៤ ១៨៣ | ៣៦ ០១៥ | ៣៧ ៨៤៨ | ៣៩ ៧៩៧ |
| កំណើន ផ.ស.ស ជានាម (ណូមីណាល) | ៨,៧% | ៨,៦% | ៩,១% | ៩,៣% | ៩,០% | ៩,១% |
| អត្រាអតិផរណា | ៣,០% | ៣,០% | ៣,០% | ៣,០% | ៣,០% | ៣,០% |
| អត្រាកំណើន ផ.ស.ស ពិត | ៥,៦% | ៦,១% | ៦,៤% | ៦,៥% | ៦,២% | ៦,៣% |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារ) | ៤ ២៤៦ | ៤ ២៩៣ | ៤ ៣៤០ | ៤ ៣៨៨ | ៤ ៤៣៦ | ៤ ៤៨៥ |

ប្រភព: មូលដ្ឋានទិន្នន័យទស្សនវិស័យសេដ្ឋកិច្ចពិភពលោក ខែតុលា ឆ្នាំ២០២៣

ការព្យាករថវិការយៈពេលពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ បានគិតគូរពិចារណាហ្មត់ចត់ អំពីថវិកាដែលបានអនុម័តសម្រាប់ឆ្នាំ២០២៣ និងឆ្នាំ២០២៤ និងការព្យាករសម្រាប់ឆ្នាំ២០២៥-២០២៨។ ថវិកាសរុបរួមរបស់រាជរដ្ឋាភិបាលកម្ពុជា និងថវិកាសរុបរបស់រាជរដ្ឋាភិបាលសម្រាប់ការអប់រំឆ្នាំ២០២៣ និងឆ្នាំ២០២៤ ឆ្លុះបញ្ចាំងពីថវិកាជាតិដែលបានអនុម័ត សម្រាប់ថ្នាក់កណ្តាល មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ។

ការព្យាករសម្រាប់ឆ្នាំ ២០២៥-២០២៨ សន្មតថាថវិកាសរុបរបស់រាជរដ្ឋាភិបាលនឹងបន្តកើនឡើងក្នុងន័យជាក់ស្តែង អត្រាជាមធ្យមប្រចាំឆ្នាំដូចដែលបានសន្មតក្នុងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនៃគោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលគ្របដណ្តប់រយៈពេលពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៦ (៣,៣ ភាគរយប្រចាំឆ្នាំ)។ ជាការកត់សម្គាល់ថវិកាសរុបដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលសម្រាប់ឆ្នាំ២០២៤ គឺ ១១,២ ភាគរយ ខ្ពស់ជាងការរំពឹងទុកនៅក្នុងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានកែតម្រូវ តាមរយៈការស្តារ



t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

ឡើងវិញនូវកំណើនម៉ាក្រូសេដ្ឋកិច្ចមានលក្ខណៈវិជ្ជមានក្នុងឆ្នាំ២០២២ និង២០២៣។ អត្រាកំណើនដែលបានសន្មតនៃការចំណាយសរុបរបស់រដ្ឋាភិបាលនៅតែទាបជាងកំណើននៃចំណោល ផ.ស.ស (៦,៣ ភាគរយប្រចាំឆ្នាំ នៅឆ្នាំ២០២៣ ដល់ឆ្នាំ២០២៨) ស្របតាមគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា។

ថវិកាសរុបរបស់រដ្ឋាភិបាលដែលមានសម្រាប់វិស័យអប់រំសម្រាប់ឆ្នាំ ២០២៥-២០២៨ ត្រូវបានប៉ាន់ស្មានផ្អែកលើការវិវត្តនៃការចំណាយសរុបរបស់រដ្ឋាភិបាលដែលបានធ្វើចំណោល។ ការព្យាករសន្មតថា ភាគរយចំណាយថវិកាចរន្តរបស់រាជរដ្ឋាភិបាលកម្ពុជាលើវិស័យអប់រំនៅថេរក្នុងឆ្នាំ២០២៤ (១៥,៨ ភាគរយ) រហូតដល់ឆ្នាំ២០២៨។ ជម្រើសនេះ បានឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលបញ្ឈប់មិនឱ្យនិន្នាការធ្លាក់ចុះនៃភាគរយការចំណាយថវិកាចរន្តចាប់តាំងពីឆ្នាំ២០១៧មក និងធានាបាននូវកម្រិតនៃការវិនិយោគសាធារណៈនៅក្នុងវិស័យអប់រំ។ ការរួមចំណែករបស់ដៃគូអភិវឌ្ឍលើវិស័យអប់រំតាមរយៈថវិកាគាំទ្រ សម្រាប់ឆ្នាំ២០២៣ និង២០២៤ បានបង្ហាញព័ត៌មានក្នុងច្បាប់ថវិកាដែលបានអនុម័ត។ ការរួមចំណែកថវិកាពីក្រៅប្រទេសសម្រាប់ឆ្នាំ២០២៥ និង២០២៦ បានប៉ាន់ស្មានផ្អែកលើការសន្មតមាន ២៣,៥ ភាគរយ នៃការប្តេជ្ញាចិត្តនៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុបដែលបានគ្រោងទុកក្នុងវិស័យអប់រំ នឹងរំហូរថវិកាគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា (ថវិការួមចំណែកដូចឆ្នាំ២០២៣)។ ការព្យាករថវិកាមិនបានសន្មតអំពីការរួមចំណែកថវិកាពីក្រៅប្រទេសចំពោះថវិកាអប់រំក្នុងប្រទេសទេ នៅឆ្នាំ២០២៧ និង២០២៨។

យោងតាមច្បាប់ថវិកាដែលបានអនុម័តឆ្នាំ២០២៤ បានសង្កេតឃើញថា ថវិការបស់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ពីឆ្នាំ២០២៥ ដល់ឆ្នាំ២០២៨ បានសន្មតរួមបញ្ចូលជាមួយនិងការវិវត្តនៃបៀវត្សគ្រូបង្រៀននៅមត្តេយ្យសិក្សា បឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។ ដូចគ្នានេះដែរ ថវិការបស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត សម្រាប់ឆ្នាំ២០២៥-២០២៨ មានការប្រែប្រួលចាប់ពីឆ្នាំ២០២៤ ទន្ទឹមនឹងការវិវត្តនៃការធ្វើចំណោលបៀវត្សគ្រូបង្រៀននៅមធ្យមសិក្សា។

### ៤.២.២ លទ្ធផលការធ្វើចំណោល

ថវិកាសរុបរបស់រដ្ឋាភិបាលដែលធ្វើចំណោលសម្រាប់វិស័យអប់រំពីឆ្នាំ២០២៤ ដល់ឆ្នាំ២០២៨ មានចំនួន ១៩ ៩៦២ ៤៣២ លានរៀល ក្នុងថេរឆ្នាំ២០២៣ ក្នុងនោះ ៣២៥ ៦៧៣ លានរៀល ដែលជាថវិកាគាំទ្រដោយដៃគូអភិវឌ្ឍ (១,៦ ភាគរយនៃការព្យាករថវិកាសរុប)។ ថវិកាសរុបប្រចាំឆ្នាំសម្រាប់វិស័យអប់រំប្រែប្រួលពី ៣ ៨១៦ ០១១ លានរៀល ក្នុងឆ្នាំ២០២៤ ថ្លៃបច្ចុប្បន្ន ដល់ ៤ ២៥៧ ៩០៤ លានរៀល នៅឆ្នាំ២០២៨ ក្នុងលក្ខខណ្ឌធម្មតាដែលបង្ហាញពីការកើនឡើង ១៩,២ ភាគរយ តាមលក្ខខណ្ឌជាក់ស្តែង (អតិផរណាដែលរំពឹងទុកមានការថមថយ) ប្រៀបធៀបនឹងថវិកាឆ្នាំ២០២៣ (តារាង ៤.៦)។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## តារាង ៤.៦៖ ការព្យាករថវិកាសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា (២០២៤-២០២៨)

| | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | សរុប |
|---|---|---|---|---|---|---|---|
| **ការព្យាករថវិកាសរុបរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យអប់រំ** | | | | | | | |
| គិតជាលានរៀល ថ្លៃបច្ចុប្បន្ន | ៣ ៥៧២ ៣១៩ | ៣ ៨១៦ ០១១ | ៤ ០៥២ ០០៩ | ៤ ២៩៦ ០៩៥ | ៤ ៥៥២ ៣៧៤ | ៤ ៨២៤ ៣៥២ | ២១ ៥៤០ ៨៤១ |
| គិតជាលានរៀល ថ្លៃថេរ ឆ្នាំ២០២៣ | ៣ ៥៧២ ៣១៩ | ៣ ៧៣០ ០២១ | ៣ ៨៦២ ៥៨១ | ៣ ៩៩០ ០៩៩ | ៤ ១២១ ៨២៧ | ៤ ២៥៧ ៩០៤ | ១៩ ៩៦២ ៤៣២ |
| ថវិកាគាំទ្រពីខាងក្រៅ | ១៥៧ ៨៣៨ | ១៨០ ៦៣៥ | ៩៩ ៩៦៨ | ៤៥ ០៧១ | - | - | ៣២៥ ៦៧៣ |
| គិតជាលានដុល្លារអាមេរិក ថ្លៃថេរឆ្នាំ២០២៣ | ៨៤១ | ៨៦៩ | ៨៩០ | ៩០៩ | ៩២៩ | ៩៤៩ | ៤ ៥៤៧ |
| **ការព្យាករថវិកាតាមកម្រិតរដ្ឋបាលអប់រំ (គិតជាលានរៀល ថ្លៃថេរឆ្នាំ២០២៣)** | | | | | | | |
| ថវិកាថ្នាក់កណ្តាល | | ៤៥៣ ៨៧៦ | ៤០៨ ៣៦៥ | ៣៦២ ១៨៦ | ៣០៩ ០៣១ | ២៨១ ២៩៧ | ១ ៨១៤ ៧៥៥ |
| ថវិកាថ្នាក់រាជធានី-ខេត្ត | | ១ ៥៦៥ ៣០៨ | ១ ៦៨៣ ០៩៨ | ១ ៨០៣ ៩៤៤ | ១ ៩៤៩ ០៣៤ | ២ ០៨៧ ៤១២ | ៩ ០៨៨ ៧៩៦ |
| ថវិកាថ្នាក់ក្រុង ស្រុក ខណ្ឌ | | ១ ៧១០ ៨៣៧ | ១ ៧៧១ ១១៨ | ១ ៨២៣ ៩៦៩ | ១ ៨៦៣ ៧៦២ | ១ ៨៨៩ ១៩៥ | ៩ ០៥៨ ៨៨១ |

តារាង៤.៧ បង្ហាញពីការវិវត្តនៃសូចនាករថវិកាអប់រំសំខាន់ៗដែលបានធ្វើចំណោលក្នុងអំឡុងពេលការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំផ្អែកលើការព្យាករថវិកា។ សមាមាត្រនៃថវិកាអប់រំទាក់ទងនឹងចំណាយចរន្តសរុបរបស់រដ្ឋាភិបាលបានសន្មតនៅថេរត្រឹម ១៥,៨ ភាគរយ។ ផ្ទុយទៅវិញ បដិភាគនៃថវិកាសម្រាប់អប់រំលើការចំណាយសរុបរបស់រាជរដ្ឋាភិបាល គួរតែបង្កើនពី ៩,០ ភាគរយ នៅឆ្នាំ២០២៣ ដល់ ៩,២ ភាគរយ នៅឆ្នាំ២០២៨។ ថវិកាសរុបដែលបានធ្វើចំណោលលើវិស័យអប់រំមានចំនួនប្រមាណជា ៥១,០ ភាគរយ នៃការចំណាយរបស់រដ្ឋាភិបាលក្នុងវិស័យសង្គមកិច្ច ផ្អែកលើក្របខ័ណ្ឌចំណាយរយៈពេលមធ្យមចាប់ពីឆ្នាំ២០២៤-២០២៦ ថវិកាមានការកើនឡើងបន្តិចបន្តួច តាមការសង្កេតនៅឆ្នាំ២០២៣។ ទោះជាយ៉ាងណា តាមសេណារីយ៉ូហិរញ្ញប្បទាននេះ ស្របតាមគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចបច្ចុប្បន្ន ការអប់រំ និងការចំណាយសរុបរបស់រាជរដ្ឋាភិបាលដែលបានធ្វើចំណោលនឹងកើនឡើងក្នុងអត្រាទាបជាង ផ.ស.ស របស់ប្រទេសកម្ពុជា។ ជាលទ្ធផលថវិកាសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា នៃបដិភាគ ផ.ស.ស នឹងធ្លាក់ចុះពី ២,៧ ភាគរយ ក្នុងឆ្នាំ ២០២៣ មកនៅត្រឹម ២,៤ ភាគរយ នៅឆ្នាំ២០២៨ តាមរយៈការធ្វើចំណោល។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## តារាង ៤.៧៖ ការវិវត្តនៃសូចនាករថវិកាអប់រំសំខាន់ៗដែលព្យាករណ៍ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៨

| | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
|---|---|---|---|---|---|---|
| ការព្យាករថវិកាប្រចាំឆ្នាំរបស់ក្រសួង អ.យ.ក) គិតជាលានរៀល ថ្លៃថេរឆ្នាំ២០២៣ | ៣ ៥៧២ ៣១៩ | ៣ ៧៣០ ០២១ | ៣ ៨៦២ ៥៨១ | ៣ ៩៩០ ០៩៩ | ៤ ១២១ ៨២៧ | ៤ ២៥៧ ៩០៤ |
| កំណើនប្រចាំឆ្នាំពិត | - | ៤,៤% | ៣,៦% | ៣,៣% | ៣,៣% | ៣,៣% |
| ភាគរយនៃ ផ.ស.ស | ២,៧% | ២,៧% | ២,៦% | ២,៥% | ២,៥% | ២,៤% |
| ភាគរយនៃចំណាយសរុបរបស់រាជរដ្ឋាភិបាល | ៩,០% | ៩,១% | ៩,២% | ៩,២% | ៩,២% | ៩,២% |
| ភាគរយនៃចំណាយថវិកាចរន្តរបស់រាជរដ្ឋាភិបាល | ១៧,១% | ១៥,៨% | ១៥,៨% | ១៥,៨% | ១៥,៨% | ១៥,៨% |
| ភាគរយនៃចំណាយរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យសង្គមកិច្ច | ៥០,៦% | ៥០,៨% | ៥០,៩% | ៥០,៩% | ៥០,៩% | ៥០,៩% |

## ៤.៣ គម្លាតថវិកា និងយុទ្ធសាស្ត្រគៀរគរធនធាន

ការធ្វើចំណោលនៃការចំណាយសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ លើសពី ១០,៤ ភាគរយ នៃការព្យាករថវិការបស់ក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ឆ្នាំ២០២៤-២០២៨។ ម្យ៉ាងវិញទៀត តម្រូវការថវិកា ៩,៤ ភាគរយ នៅតែមិនទាន់ឆ្លើយតបនឹងការព្យាករទាំងនេះ។ នេះបង្ហាញពីគម្លាតថវិកាចំនួន ២ ០៨៣ ១០០ លានរៀល ឬ ៤៧២ លានដុល្លារអាមេរិក ថ្លៃថេរក្នុងឆ្នាំ២០២៣ នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំសម្រាប់រយៈពេល៥ឆ្នាំ (តារាង៤.៨)។

## តារាង៤.៨៖ គម្លាតថវិកាប៉ាន់ស្មានតាមឆ្នាំ និងថវិកាសរុប ២០២៤-២០២៨ (ថ្លៃថេរ ឆ្នាំ២០២៣)

| | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | សរុប |
|---|---|---|---|---|---|---|---|
| ការធ្វើចំណោលចំណាយ គិតជាលានរៀល | ៣ ៥៧២ ៣១៩ | ៣ ៨៣១ ៥៩២ | ៤ ១៨៩ ៣៧៣ | ៤ ៤៤៤ ៥១៨ | ៤ ៦៥៥ ៨៩២ | ៤ ៩២៤ ១៥៧ | ២២ ០៤៥ ៥៣២ |
| ការព្យាករថវិកា គិតជាលានរៀល | ៣ ៥៧២ ៣១៩ | ៣ ៧៣០ ០២១ | ៣ ៨៦២ ៥៨១ | ៣ ៩៩០ ០៩៩ | ៤ ១២១ ៨២៧ | ៤ ២៥៧ ៩០៤ | ១៩ ៩៦២ ៤៣២ |
| **គម្លាតថវិកា** | | | | | | | |
| គិតជាលានរៀល | - | -១០១ ៥៧១ | -៣២៦ ៧៩២ | -៤៥៤ ៤១៩ | -៤៣៤ ០៦៥ | -៦៦៦ ២៥៣ | -២ ០៨៣ ១០០ |
| គិតជាលានដុល្លារអាមេរិក | - | - ២៣,៧ | - ៧៥,៣ | - ១០៣,៦ | - ១២០,៤ | - ១៤៨,៦ | - ៤៧១,៥ |
| គម្លាតថវិកាជាភាគរយនៃការធ្វើចំណោលចំណាយ | - | - ២,៧% | - ៧,៨% | - ១០,២% | - ១១,៥% | - ១៣,៥% | - ៩,៤% |
| គម្លាតថវិកា ជាភាគរយនៃការព្យាករថវិកា | - | - ២,៧% | - ៨,៥% | - ១១,៤% | - ១៣,០% | - ១៥,៦% | - ១០,៤% |

ការចំណាយសំខាន់ៗដែលបានគ្រោងទុក មិនបានផ្ដល់ថវិកាបន្ថែមក្នុងករណីខ្វះខាតធនធាន ដូចនេះ ចាំបាច់ត្រូវកំណត់ និងស្វែងរកហិរញ្ញប្បទានផ្សេងៗ ដើម្បីបង្កើនធនធានសម្រាប់វិស័យអប់រំ អំឡុងពេល អនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

តារាង ៤.៩ បង្ហាញពីតម្រូវការប៉ាន់ស្មានថវិកាប្រចាំឆ្នាំ និងថវិកាសរុបសម្រាប់ការចំណាយមូលធន និងការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន២០២៤-២០៣០ដោយឡែក បានដាក់បញ្ចូលនៅក្នុងការធ្វើចំណោលនៃការចំណាយក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ សរុបមក មុខចំណាយទាំងពីរនេះមាន ៦៧,៤ ភាគរយ នៃគម្លាតថវិកាប៉ាន់ស្មានសរុប។ បរិការណ៍នេះ បានធ្វើការកែតម្រូវការសម្រេចចិត្តនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ក្នុងការបន្តការវិនិយោគសាធារណៈ សម្រាប់កែលម្អហេដ្ឋារចនាសម្ព័ន្ធអប់រំ យុវជន និងកីឡា និងកែទម្រង់ប្រព័ន្ធបណ្ដុះបណ្ដាលគ្រូបង្រៀន ដើម្បីឱ្យលទ្ធផលសិក្សារបស់សិស្សកាន់តែប្រសើរ។ ក្រសួងអប់រំ យុវជន និងកីឡា នឹងស្វែងរកហិរញ្ញប្បទានបន្ថែមសម្រាប់អន្តរាគមន៍ ដែលមានផលជះដល់ការចូលរៀន និងរៀនប្រកបដោយគុណភាព និងប្រសិទ្ធភាព។

**តារាង ៤.៩៖ តម្រូវការថវិកាសរុបដែលចំណាយសម្រាប់អន្តរាគមន៍បានជ្រើសរើស និងមិនមានថវិកាក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (គិតជាលានរៀល ថ្លៃថេរក្នុងឆ្នាំ២០២៣)។**

| | ២០២៥-២០២៨ |
|---|---|
| **ការចំណាយមូលធន** | ៦៧៧ ៣៨៣ |
| **ចំណាយមូលធនផ្សេងៗ** | ៦៦៧ ៣៨៣ |
| **ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន** | ៤៥៧ ៤១៣ |
| ចំណាយថវិកាមូលធននៃផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន | ២៦១ ០២២ |
| ចំណាយថវិកាចរន្ត | ១៩៦ ៣៩០ |
| **សរុប** | **១ ១៣៤ ७៩៦** |

ផ្នែកចំណាយនេះ បានគ្របដណ្ដប់ តាមរយៈការប្ដេជ្ញាចិត្តរបស់ជំនួយអភិវឌ្ឍន៍ផ្លូវការបច្ចុប្បន្ន ចំពោះវិស័យអប់រំសម្រាប់ឆ្នាំ២០២៤-២០២៦។ តារាងខាងក្រោមបង្ហាញពីការប្ដេជ្ញាចិត្តរបស់ជំនួយអភិវឌ្ឍន៍ផ្លូវការសរុបបានគ្រោងទុកសម្រាប់អនុវត្តដូចដែលបានរាយការណ៍នៅក្នុងមូលដ្ឋានទិន្នន័យសាធារណៈនៃជំនួយអភិវឌ្ឍន៍ផ្លូវការរបស់កម្ពុជា។ នៅផ្នែកទី២ ការព្យាករថវិកាសន្មតថាមានត្រឹមតែ ២៣,៥ ភាគរយ នៃការប្ដេជ្ញាចិត្តរបស់ជំនួយអភិវឌ្ឍន៍ផ្លូវការសរុប ដែលបានគ្រោងទុកសម្រាប់ឆ្នាំ២០២៤-២០២៦ នឹងបានអនុវត្តតាមរយៈថវិកាគាំទ្រ និងមិនបានសន្មតពីការរួមចំណែកថវិកាក្រៅប្រទេសដែលរំពឹងទុកនៅឆ្នាំ២០២៧ និង២០២៨ នោះទេ។

ចំនួនទឹកប្រាក់សរុបនៃការប្ដេជ្ញាចិត្តរបស់ជំនួយអភិវឌ្ឍន៍ផ្លូវការដែលបានគ្រោងទុកសម្រាប់វិស័យអប់រំរវាងឆ្នាំ២០២៤ និង២០២៦ មិនបានរំហូរចូលតាមរយៈថវិកាគាំទ្រសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ បានប៉ាន់ស្មានមានចំនួន ១ ៣៨៥ ១០៥ លានរៀល គិតថ្លៃថេរ ឆ្នាំ២០២៣ គិតជាគម្លាតថវិកា



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ប៉ាន់ស្មានស្មើនឹង ៥៤,១ ភាគរយ។ ការវិភាគបន្ថែមបានបង្ហាញថា បរិភាគពាក់ព័ន្ធនៃជំនួយអភិវឌ្ឍន៍ផ្លូវការក្នុងវិស័យអប់រំ មិនបានរំហូរចូលតាមរយៈថវិកាគាំទ្រ ដែលថវិកានេះជាថវិកាគាំទ្រជាក់ស្តែង ឬត្រូវពិនិត្យឡើងវិញ ដើម្បីគាំទ្រការអនុវត្តសកម្មភាព ដែលបានគ្រោងទុករបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ក្រសួងអប់រំ យុវជន និងកីឡា នឹងដើរតួនាទីយ៉ាងសកម្មក្នុងការអញ្ជើញដៃគូអភិវឌ្ឍឱ្យចូលរួមក្នុងការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មអំពីការប្តេជ្ញាចិត្តដែលបានគ្រោងទុករហូតដល់ឆ្នាំ២០២៨ ក្នុងគោលបំណងបង្កើនការរួមចំណែករបស់ខ្លួនក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

**តារាង ៤.១០៖ ការប្តេជ្ញាចិត្តរបស់ជំនួយអភិវឌ្ឍន៍ផ្លូវការដែលបានគ្រោងទុកក្នុងវិស័យអប់រំឆ្នាំ២០២៤-២០២៦ និងបរិភាគប៉ាន់ស្មាននៃជំនួយអភិវឌ្ឍន៍ផ្លូវការដែលរំហូរចូលតាមរយៈថវិកាគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា**

| | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | សរុប |
|---|---|---|---|---|---|
| គិតជាលានដុល្លារអាមេរិក ថ្លៃថេរឆ្នាំ២០២៣ | ១៥៨ | ១៨៣ | ១០៣ | ៤៧ | ៣៣៣ |
| គិតជាលានរៀល ថ្លៃបច្ចុប្បន្ន | ៦៧១ ២៩៣ | ៧៨៥ ៩៥៩ | ៤៤៦ ០១៩ | ២០៦ ៣៩០ | ១ ៤៣៨ ៣៦៧ |
| គិតជាលានរៀល ថ្លៃថេរ ឆ្នាំ២០២៣ | ៦៧១ ២៩៣ | ៧៦៨ ២៤៨ | ៤២៥ ១៦៨ | ១៩១ ៦៩០ | ១ ៣៨៥ ១០៥ |
| ថវិកាគាំទ្រ | ១៥៧ ៨៣៨ | ១៨០ ៦៣៥ | ៩៩ ៩៦៨ | ៤៥ ០៧១ | ៣២៥ ៦៧៣ |
| | *២៣,៥០%* | *២៣,៥០%* | *២៣,៥០%* | *២៣,៥០%* | *២៣,៥០%* |
| ផ្សេងៗ | ៥១៣ ៤៥៥ | ៥៨៧ ៦១៣ | ៣២៥ ២០០ | ១៤៦ ៦១៩ | ១ ០៥៩ ៤៣២ |
| | *៧៦,៥០%* | *៧៦,៥០%* | *៧៦,៥០%* | *៧៦,៥០%* | *៧៦,៥០%* |

យុទ្ធសាស្ត្រផ្សេងៗទៀត ដើម្បីកៀរគរធនធានហិរញ្ញវត្ថុបន្ថែមសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំរួមមាន៖

– រៀបចំ និងអនុវត្តផែនទីបង្ហាញផ្លូវគម្រោងហិរញ្ញប្បទានឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីកំណត់មធ្យោបាយបង្កើនការវិភាជន៍ថវិកាដល់វិស័យអប់រំ។ បរិការណ៍នេះ ពាក់ព័ន្ធនឹងកិច្ចសន្ទនាអន្តរវិស័យ ដើម្បីពិនិត្យមើលថាតើក្រសួងផ្សេងៗទៀត អាចសហការផ្តល់ហិរញ្ញប្បទានដល់ការចំណាយមួយចំនួនលើលក្ខខណ្ឌដែលទាក់ទងនឹងការទទួលខុសត្រូវ (ឧ. សុខភាពសិក្សា) ឬដើម្បីកំណត់ការវិភាជន៍ឡើងវិញនូវធនធានសារពើពន្ធដល់វិស័យអប់រំ។ កិច្ចការនេះ ត្រូវការកិច្ចសន្ទនាគោលនយោបាយនៅកម្រិតផ្សេងៗគ្នារបស់រាជរដ្ឋាភិបាល ការវិភាគសមត្ថភាពសារពើពន្ធនៅកម្រិតផ្សេងៗគ្នារបស់រដ្ឋបាលអប់រំ និងត្រូវរៀបចំកិច្ចព្រមព្រៀងសារពើពន្ធ ដើម្បីជំរុញការវិនិយោគក្នុងវិស័យអប់រំ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ស្វែងរកភាពជាដៃគូរវាងរដ្ឋ-ឯកជន ឱ្យកាន់តែសកម្ម ដើម្បីបំពេញបន្ថែមដល់ថវិការដ្ឋ និងលើកកម្ពស់គុណភាព ឈានទៅដល់ការផ្តួចផ្តើមគំនិតលើការងារអប់រំ ដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។
- ការបង្កើនប្រសិទ្ធភាព និងការលើកកម្ពស់សមធម៌នៃការរួមចំណែករបស់គ្រួសារសម្រាប់វិស័យអប់រំ។ ខណៈដែលកម្រិតនៃការរួមចំណែករបស់គ្រួសារមានសារៈសំខាន់ណាស់សម្រាប់វិស័យអប់រំនាពេលបច្ចុប្បន្ននេះ វិសាលភាពសម្រាប់ការបង្កើនការរួមចំណែកបន្ថែមទៀតនេះ ទំនងជាមានលក្ខណៈតូចចង្អៀត។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ថវិការួមចំណែកទាំងនោះឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព អាចធ្វើទៅបានប្រសិនបើរំហូរថវិកាចូលទៅតាមរយៈមូលនិធិសាលារៀន (ឧ. មូលនិធិស្ម័គ្រចិត្ត)។ ទន្ទឹមនឹងនេះ ត្រូវជានានូវការគាំពារសិទ្ធិប្រជាពលរដ្ឋដែលងាយរងគ្រោះផ្នែកសេដ្ឋកិច្ចផងដែរ។ អភិក្រមនេះ នឹងរក្សាបាននូវគោលការណ៍យុត្តិធម៌ និងសមធម៌សង្គម ដោយធានាថា ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុបានបែងចែកប្រកបដោយសមធម៌ និងរក្សាបាននូវការចូលរៀនសម្រាប់ទាំងអស់គ្នា។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

# ជំពូកទី៥៖ ក្របខ័ណ្ឌការពិនិត្យតាមដាន និងវាយតម្លៃ

ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃមានសារៈសំខាន់ចំពោះការអនុវត្តប្រកបដោយជោគជ័យនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ប្រព័ន្ធនេះ នឹងត្រូវប្រើប្រាស់ក្នុងគោលបំណងសំខាន់ពីរ៖ (១) ការត្រួតពិនិត្យលើការអនុវត្តដែលជាតួនាទីនៃ «ការពិនិត្យតាមដាន» និង (២) ធានាថាមេរៀនពិសោធន៍នៃការអនុវត្តផែនការកន្លងមក ដើម្បីកែលម្អយុទ្ធសាស្ត្រ និងសកម្មភាព ដែលជាគោលបំណងនៃ «ការវាយតម្លៃ»។

គ្រប់សកម្មភាពនៃការពិនិត្យតាមដាន និងវាយតម្លៃ រួមមាន៖ ការប្រមូលទិន្នន័យបរិមាណវិស័យ និងគុណវិស័យ។ នៅពេលមានការវិភាគបានល្អ នឹងនាំមកនូវការយល់ដឹងកាន់តែច្បាស់ពីសារសំខាន់របស់ទិន្នន័យ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ គូសបញ្ជាក់យ៉ាងទូលំទូលាយពីការប្រើប្រាស់លទ្ធផលនៃការពិនិត្យតាមដាន និងវាយតម្លៃ និងធានាថាលទ្ធផលទាំងនេះ នាំទៅដល់ការសិក្សាអំពីមូលហេតុសម្រាប់ការបំពេញការងារជាក់លាក់ និងពីរបៀបកែលម្អស្ថានភាពអប់រំ។

ផ្នែកទី១នៃជំពូកនេះ ពិពណ៌នាអំពីដំណើរការនៃការពិនិត្យតាមដាន ការវាយតម្លៃ និងការសិក្សាដែលនឹងត្រូវប្រើប្រាស់ក្នុងអំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ផ្នែកទី២ រៀបចំបញ្ជីតួអង្គសំខាន់ៗដែលត្រូវអនុវត្តតួនាទីក្នុងដំណើរការនេះ។ ផ្នែកចុងក្រោយ បង្ហាញពីសូចនាករសមិទ្ធកម្មគន្លឹះ សូចនាករផលសម្រេច និងសូចនាករលទ្ធផល។ សូចនាករសំខាន់ៗទាំងអស់នេះ នឹងពិនិត្យពីទិដ្ឋភាពទូទៅនៃ វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផ្តោតលើការផ្លាស់ប្តូរដ៏សំខាន់បំផុត។

## ៥.១ ដំណើរការ

ប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ បង្កើតឡើងផ្អែកលើយន្តការ និងឧបករណ៍ដែលត្រូវបានប្រើប្រាស់សម្រាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំមុន ដែលភាគច្រើនជាផ្នែកនៃទម្រង់ការងារធម្មតានៃរដ្ឋបាលអប់រំ។ គោលការណ៍គឺត្រូវពឹងផ្អែកលើយន្តការដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាព ជាជាងការបង្កើតយន្តការស្របគ្នា។

### ៥.១.១ ដំណើរការ និងយន្តការពិនិត្យតាមដាន

**ការពិនិត្យតាមដាននៅកម្រិតសាលារៀន៖** ការពិនិត្យតាមដានសកម្មភាពក្នុងការអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ចាប់ផ្តើមពីកម្រិតសាលារៀន។ សាលារៀនតម្រូវឱ្យរៀបចំ និងបញ្ជូនរបាយការណ៍សមិទ្ធកម្មទៅឱ្យការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យឡើងវិញ មុននឹងបញ្ជូនរបាយការណ៍ទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត សម្រាប់រក្សាទុកធ្វើអធិការកិច្ច។ សាលារៀនត្រូវបំពេញទិន្នន័យជំរឿនស្ថិតិសាលារៀនប្រចាំឆ្នាំលម្អិត និងបញ្ជូនទៅឱ្យនាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំនៅសប្តាហ៍ទីពីរបន្ទាប់ពីបើកបវេសនកាលនៃឆ្នាំសិក្សា និងទិន្នន័យជំរឿនសង្ខេបស្តីពីការចុះឈ្មោះចូលរៀន ការបោះបង់ការសិក្សា និងការផ្ទេរការសិក្សា ត្រូវប្រមូលនៅពាក់កណ្តាលឆ្នាំ និងចុងឆ្នាំ។

**ការពិនិត្យតាមដាននៅថ្នាក់ក្រុង ស្រុក ខណ្ឌ៖** យោងតាមអនុក្រឹត្យលេខ ២១៣ និងប្រកាសលេខ ១០៦៥ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមុខងារ និងបុគ្គលិកអប់រំទៅឱ្យរដ្ឋបាលក្រុង

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

ស្រុក និងខណ្ឌ ជាពិសេសមុខងារគ្រប់គ្រងអប់រំកុមារតូច បឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។ ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសលេខ ១០៦៥ រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានតួនាទី និងភារកិច្ចក្នុងការគ្រប់គ្រងត្រួតពិនិត្យ និងប្រើប្រាស់បុគ្គលិកអប់រំ ស្របតាមព្រះរាជក្រឹត្យស្តីពីសហលក្ខន្តិកៈដាច់ដោយឡែកស្តីពីក្របខ័ណ្ឌគ្រូបង្រៀនបឋមសិក្សា គ្រូបង្រៀនកម្រិតមូលដ្ឋាន និងគ្រូបង្រៀនកម្រិតឧត្តម និងព្រះរាជក្រឹត្យស្តីពីសហលក្ខន្តិកៈដាច់ដោយឡែកនៃគោលការណ៍ណែនាំបែបបទនិងនីតិវិធីរបស់បុគ្គលិកថ្នាក់ក្រោមជាតិ។ រដ្ឋបាលទាំងនេះក៏មានតួនាទីក្នុងការពិនិត្យតាមដានវាយតម្លៃ និងធ្វើអធិការកិច្ចនៃការអនុវត្តមុខងារគ្រប់គ្រងដែលបានធ្វើប្រតិភូកម្មដោយក្រសួងអប់រំ យុវជន និងកីឡា។

ជាគោលការណ៍ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទទួលខុសត្រូវចំពោះមុខងារដែលបានផ្ទេរ ឬប្រតិភូកម្មតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងកម្មវិធី។ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សហការការងារនេះ ជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការឃុំ/សង្កាត់។ ការិយាល័យអប់រំ យុវជន និងកីឡារដ្ឋបាលក្រុង ស្រុក ខណ្ឌ ទទួលបន្ទុកពិនិត្យតាមដានជាប្រចាំនូវការគាំទ្រនៅកម្រិតសាលារៀន លើការអនុវត្តសកម្មភាព គោលនយោបាយ ក៏ដូចជាសកម្មភាពប្រចាំថ្ងៃរបស់កម្មវិធី អនុកម្មវិធីរៀងៗខ្លួន។

**ការពិនិត្យតាមដានគោលនយោបាយ និងយុទ្ធសាស្ត្រ៖** នាយកដ្ឋានគោលនយោបាយ សហការជាមួយនាយកដ្ឋានពិនិត្យតាមដាននិងវាយតម្លៃ ដើម្បីពិនិត្យឡើងវិញពីវឌ្ឍនភាព និងផលប៉ះពាល់នៃការអនុវត្តគោលនយោបាយ។

**ការពិនិត្យតាមដានថវិកា និងសមិទ្ធកម្ម៖** នាយកដ្ឋានពិនិត្យតាមដាននិងវាយតម្លៃ សហការជាមួយនាយកដ្ឋានហិរញ្ញវត្ថុ ទទួលខុសត្រូវក្នុងការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី អនុកម្មវិធីនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ តាមរយៈផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិប្រចាំឆ្នាំ និងរៀបចំរបាយការណ៍សមិទ្ធកម្មនៅគ្រប់កម្រិត រួមមាន៖ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសាលារៀន។ របាយការណ៍សមិទ្ធកម្មរៀបចំឡើងជារៀងរាល់ត្រីមាសដើម្បី៖ ១) ពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាព ផលិតភាព និងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និង២) ពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព គណនេយ្យភាព តម្លាភាព និងការគ្រប់គ្រងនៃការចំណាយថវិកាសម្រាប់អង្គភាពថ្នាក់កណ្តាលរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ការអនុវត្តការពិនិត្យតាមដាន និងរបាយការណ៍ទាំងនេះ ផ្តល់ជាព័ត៌មានសម្រាប់រៀបចំសន្និបាតអប់រំនៅថ្នាក់រាជធានី-ខេត្ត និងថ្នាក់ជាតិ។

**សន្និបាតអប់រំថ្នាក់រាជធានី-ខេត្ត៖** ពិធីសន្និបាតអប់រំថ្នាក់រាជធានី-ខេត្ត ប្រារព្ធធ្វើឡើង ២ឬ៣ថ្ងៃមុនសន្និបាតថ្នាក់ជាតិ ជាធម្មតាប្រារព្ធធ្វើនៅខែមករា។ ចាប់តាំងពីឆ្នាំ២០១៤ មក រាជធានី-ខេត្តនីមួយៗបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី-ខេត្ត ដែលមានរចនាសម្ព័ន្ធស្រដៀងនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ជាតិផងដែរ។ សន្និបាតអប់រំថ្នាក់រាជធានី-ខេត្ត ពិនិត្យមើលពីវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី-ខេត្តរបស់ខ្លួន ការវិភាគទិន្នន័យថ្នាក់រាជធានី-ខេត្ត និងរបាយការណ៍ស្តីពីការអនុវត្តកម្មវិធី និងអនុកម្មវិធីធៀបនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ថ្នាក់រាជធានី-ខេត្ត ផែនការប្រតិបត្តិ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ប្រចាំឆ្នាំ និងរបាយការណ៍របស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ រួមបញ្ចូលរបាយការណ៍ស្តីពីថវិកាកម្មវិធី វិហ្វូរមូលនិធិដំណើរការសាលារៀន និងគាំទ្រដល់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។ របាយការណ៍ថ្នាក់រាជធានី-ខេត្ត ផ្តល់ជាមូលដ្ឋានសម្រាប់ការផ្លាស់ប្តូរ និងការកែសម្រួលផែនការការងារប្រចាំឆ្នាំនៅថ្នាក់រាជធានី-ខេត្ត និងផ្តល់ធាតុចូលដល់សន្និបាតអប់រំថ្នាក់ជាតិ។

**សន្និបាតអប់រំថ្នាក់ជាតិ៖** ពិធីសន្និបាតអប់រំថ្នាក់ជាតិ ប្រារព្ធធ្វើឡើងក្នុងខែមីនាជារៀងរាល់ឆ្នាំ។ អ្នកចូលរួមក្នុងសន្និបាតអប់រំមកពីគ្រប់កម្រិត (ថ្នាក់ជាតិ រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀន) និងមកពីក្រសួង/ស្ថាប័នផ្សេងៗរបស់រាជរដ្ឋាភិបាល ទីភ្នាក់ងារ វិស័យឯកជន ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរាជរដ្ឋាភិបាល។ សន្និបាតអប់រំនេះ ប្រារព្ធធ្វើឡើងដើម្បីពិភាក្សា និងពិគ្រោះយោបល់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ តាមរយៈការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ និងដើម្បីកំណត់ទិសដៅសម្រាប់ឆ្នាំសិក្សាខាងមុខ។ សន្និបាតអប់រំនេះ ពិនិត្យឡើងវិញពីវឌ្ឍនភាពនៃចំណុចដៅប្រចាំឆ្នាំធៀបនឹងចំណុចដៅដែលបានកំណត់នៅក្នុងសន្និបាតអប់រំកន្លងមក ដោយផ្សារភ្ជាប់នឹងទៅនឹងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

របាយការណ៍សន្និបាតអប់រំ បង្ហាញពីការវិភាគស៊ីជម្រៅអំពីបញ្ហាប្រឈម និងលើកវិធានការ ដើម្បីកែលម្អការបំពេញការងារអប់រំ។ របាយការណ៍នេះ ផ្តល់នូវអនុសាសន៍គន្លឹះៗ សម្រាប់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិកាក្នុងរយៈពេលមធ្យម និងផែនការប្រតិបត្តិប្រចាំឆ្នាំ។ របាយការណ៍នេះ ពឹងផ្អែកលើធាតុចូលនៃការវិភាគលម្អិតតាមកម្មវិធី និងអនុកម្មវិធី។ ឯកសារទាំងនេះ បានពិនិត្យឡើងវិញយ៉ាងហ្មត់ចត់លើការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនិងអនុកម្មវិធីនីមួយៗ ធៀបនឹងចំណុចដៅ ដែលបានព្រមព្រៀងនៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងម៉ាទ្រីកគោលនយោបាយ ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការការងារផ្សេងទៀតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការវិភាគទៅលើធាតុចូលរបស់សាលារៀន និងក្រុង ស្រុក ខណ្ឌ ដែលផ្តល់សម្រាប់សន្និបាតអប់រំថ្នាក់រាជធានី-ខេត្ត ទិន្នន័យប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ និងប្រព័ន្ធព័ត៌មានគ្រប់គ្រងគុណភាពអប់រំ ការស្រាវជ្រាវ និងការសិក្សាលទ្ធផលនៃការវាយតម្លៃការសិក្សារបស់សិស្ស របាយការណ៍ពិនិត្យតាមដាន និងទិន្នន័យ ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

សន្និបាតអប់រំផ្តល់ឱកាសដល់ក្រសួងអប់រំ យុវជន និងកីឡា បុគ្គលិកថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បណ្តាក្រសួងពាក់ព័ន្ធ វិស័យឯកជន និងដៃគូអភិវឌ្ឍ ដើម្បីកំណត់បញ្ហាប្រឈម និងផ្នែកនានាដាក់លាក់សម្រាប់ឆ្នាំខាងមុខ និងឯកភាពលើសកម្មភាពចាំបាច់មួយចំនួន និងលទ្ធផលរំពឹងទុកសម្រាប់ឆ្នាំសិក្សាបន្ទាប់។

## ៥.១.២ ដំណើរការ និងយន្តការវាយតម្លៃ

នាយកដ្ឋានផែនការ នឹងធ្វើការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៅឆ្នាំ២០២៦ និងការពិនិត្យឡើងវិញចុងក្រោយនៅឆ្នាំ២០២៨។ ការពិនិត្យឡើងវិញទាំងនេះ មានលក្ខណៈខុសប្លែកពីរបាយការណ៍ពិនិត្យតាមដានប្រចាំឆ្នាំ ក៏ដូចជារបាយការណ៍សន្និបាតអប់រំ និងរបាយការណ៍ផ្សេងៗ។

ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ ត្រូវបានរៀបចំឡើង ដើម្បីផ្តល់នូវការពិនិត្យស៊ីជម្រៅបន្ថែមទៀតអំពី លទ្ធផលដែលសម្រេចបាន និងបញ្ហាបានជួបប្រទះកន្លងមក។ ការពិនិត្យឡើងវិញពាក់កណ្តាល



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

អាណត្តិជួយសម្រេចថាតើត្រូវកែសម្រួលឡើងវិញនូវវត្ថុបំណង យុទ្ធសាស្ត្រ និងសកម្មភាព ដែលបានគ្រោងទុកសម្រាប់រយៈពេលអនុវត្តផែនការពាក់កណ្តាលអាណត្តិទៀត។ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំក្នុងឆ្នាំ២០២១ កន្លងមក មានការកែសម្រួលឡើងវិញនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ដូចគ្នានេះដែរ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការ យុទ្ធសាស្ត្រវិស័យអប់រំនៅឆ្នាំ២០២៦ នឹងអាចមានការកែសម្រួលដូចគ្នា ដែលនាំទៅរកការបន្សុីឡើងវិញនៃកម្មវិធី អនុកម្មវិធី សូចនាករ និងចំណុចដៅជាមួយនឹងអាទិភាពថ្មីៗរបស់ក្រសួង ជាពិសេស កំណែទម្រង់ គ្រូបង្រៀន កម្មវិធីសិក្សា បុគ្គលិក គោលនយោបាយ និងផែនការ (កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ)។ ការកែសម្រួលផែនការដែលអាចធ្វើទៅបាន នឹងត្រូវផ្អែកលើចំណោលតម្រូវការអប់រំដែលបានធ្វើបច្ចុប្បន្នភាព ជាមួយនឹងការព្យាករចំនួនប្រជាជន សិស្ស និងធាតុចូលផ្សេងទៀត នាំឱ្យមានការធ្វើបច្ចុប្បន្នកម្មតម្រូវការហិរញ្ញប្បទានសម្រាប់រយៈពេលដែលនៅសេសសល់នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

ការពិនិត្យឡើងវិញចុងក្រោយ ធ្វើឡើងក្នុងគោលបំណងពិនិត្យមើលការអនុវត្តផែនការទាំងមូលឱ្យបានទូលំទូលាយ ដើម្បីវាយតម្លៃលទ្ធផលរយៈពេលវែង ប្រកបដោយភាពឆ្លើយតប ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងចីរភាព ព្រមទាំងវិភាគពីមូលហេតុនៃលទ្ធផលដែលសម្រេចបាន និងលទ្ធផលដែលសម្រេចមិនបាន ហើយសិក្សាពីមេរៀនពិសោធន៍សម្រាប់កែសម្រួលគោលនយោបាយ និងការរៀបចំផែនការបន្ទាប់។ ជាពិសេស ត្រូវផ្តោតលើការវិភាគនិន្នាការនៅក្នុងសូចនាករសមិទ្ធកម្មគន្លឹះៗ។

ទាំងការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និងចុងក្រោយ ត្រូវរៀបចំដោយក្រុមការងារឯករាជ្យខាងក្នុង និងខាងក្រៅលើការអប់រំ និងការគ្រប់គ្រង។ បុគ្គលិកអប់រំ ដែលបានជ្រើសរើសក្នុងការផ្តល់ព័ត៌មានត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធទាំងអស់សម្រាប់ការពិនិត្យឡើងវិញនេះ។ ប្រភពព័ត៌មានសំខាន់ៗមានដូចជា របាយការណ៍ពិនិត្យតាមដានផ្សេងៗ ទិន្នន័យពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ការធ្វើសម្ភាសន៍ និងការពិភាក្សាជាក្រុមតាមមុខសញ្ញា។ ក្នុងករណីចាំបាច់ ការសិក្សាជាក់លាក់លើបញ្ហាប្រឈមដោយឡែកណាមួយ អាចត្រូវធ្វើឡើងក្នុងអំឡុងពេលនៃការពិនិត្យឡើងវិញប្រចាំឆ្នាំ។

### ៥.១.៣ ការប្រែក្លាយការពិនិត្យតាមដាននិងវាយតម្លៃទៅជាការរៀនសូត្រ

ការអនុវត្តការពិនិត្យតាមដាន និងវាយតម្លៃ និងរបាយការណ៍ផ្សេងៗ បង្កើតបាននូវព័ត៌មានដ៏សម្បូរបែបស្តីពីការវិវត្តនៃប្រព័ន្ធអប់រំ វឌ្ឍនភាពនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងសមិទ្ធផលនៃអាទិភាពគន្លឹះៗ។ ការអនុវត្តនេះ ក៏ផ្តល់ចំណេះដឹងអំពីមូលហេតុនៃវឌ្ឍនភាព និងមិនមានវឌ្ឍនភាពជាមួយនឹងកម្មវិធីផ្សេងៗ។

ក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តរៀបចំកម្មវិធីអង្គវិបស្សនាអប់រំប្រចាំឆ្នាំ ដែលគោលបំណងសំខាន់គឺដើម្បីឆ្លុះបញ្ចាំងពីមេរៀនពិសោធន៍តាមរយៈប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ។ អ្នកចូលរួមក្នុងអង្គវិបស្សនាអប់រំ រួមមាន៖ ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល។ កិច្ចពិភាក្សានៅអង្គវិបស្សនាអប់រំ ផ្តល់ឱកាសសម្រាប់ឆ្លុះបញ្ចាំងពីវឌ្ឍនភាពដែលបានអនុវត្តក្នុងវិស័យអប់រំ និងសម្រាប់គិតគូរពិចារណាលើផ្នែកសំខាន់ៗសម្រាប់ឆ្នាំខាងមុខ។

អង្គវិបស្សនានេះ មានការណែនាំតាមរយៈឯកសារដែលបានរៀបចំមុនកិច្ចប្រជុំ ដោយក្រុមការងារវិស័យអប់រំផ្សេងៗគ្នា និងឯកសារស្រាវជ្រាវដែលរៀបចំដោយអនុវិស័យ និងនាយកដ្ឋានជំនាញនានាតាមការព្រមព្រៀងដោយក្រុមការងារបច្ចេកទេសចម្រុះ។ លទ្ធផលនៃអង្គវិបស្សនា គឺជារបាយការណ៍ដែលផ្តល់នូវព័ត៌មានពីការរៀបចំផែនការ កម្មវិធី និងកិច្ចពិភាក្សានៅសន្និបាតអប់រំ។ អង្គវិបស្សនាអប់រំនីមួយៗ នឹងផ្តោតលើប្រធានបទគន្លឹះមួយ ឬមួយចំនួន ដែលចាំបាច់ ឬជាបញ្ហាកង្វល់។

## ៥.២ តួអង្គពាក់ព័ន្ធ

ប្រសិទ្ធភាពនៃប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ អាស្រ័យលើភាពច្បាស់លាស់ពីតួនាទី និងការទទួលខុសត្រូវរបស់តួអង្គផ្សេងៗ នៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងថ្នាក់រាជធានី-ខេត្ត។

ក្រសួងអប់រំ យុវជន និងកីឡា មានទំនួលខុសត្រូវជារួមសម្រាប់ការត្រួតពិនិត្យផ្នែកបច្ចេកទេសនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ការពិនិត្យតាមដាន និងវាយតម្លៃ។

ថ្នាក់ដឹកនាំនៃក្រសួងអប់រំ យុវជន និងកីឡា នឹងដឹកនាំការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និងចុងក្រោយ និងពិនិត្យឡើងវិញថាតើផែនការនេះរួមចំណែកក្នុងការសម្រេចលទ្ធផលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ឆ្លើយតបនឹងយុទ្ធសាស្ត្របញ្ចកោណយ៉ាងដូចម្តេច។ ថ្នាក់ដឹកនាំនៃក្រសួងអប់រំ យុវជន និងកីឡា ប្រជុំជាប្រចាំតាមរយៈគណៈកម្មការគ្រប់គ្រងកម្មវិធី ដើម្បីពិនិត្យឡើងវិញពីវឌ្ឍនភាពវិស័យអប់រំ។ លទ្ធផលនេះ នឹងបង្ហាញនៅសន្និបាតអប់រំប្រចាំឆ្នាំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** ទទួលខុសត្រូវគ្រប់កម្មវិធីទាំងអស់ និងមានការគាំទ្រដោយរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការទទួលបន្ទុក។ កម្មវិធីនីមួយៗត្រូវដឹកនាំ និងគ្រប់គ្រងដោយអគ្គនាយក និងមានការគាំទ្រពីអគ្គនាយករង។ អនុកម្មវិធីនីមួយៗត្រូវដឹកនាំ និងគ្រប់គ្រងដោយនាយកដ្ឋានជំនាញ និងមានការគាំទ្រពីក្រុមការងារអនុកម្មវិធី ដែលជាកម្លាំងជំរុញក្នុងការអនុវត្តគោលនយោបាយ និងក្របខ័ណ្ឌយុទ្ធសាស្ត្រ។

**នាយកដ្ឋានផែនការ** ទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តកម្មវិធី អនុកម្មវិធី ការរៀបចំឯកសារ និងឧបករណ៍ផ្សេងទៀត សម្រាប់ការរៀបចំរបាយការណ៍វឌ្ឍនភាពតាមកម្មវិធី និងអនុកម្មវិធីសម្រាប់ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និងចុងក្រោយនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ នាយកដ្ឋានផែនការក៏គាំទ្រក្រុមការងារសម្រាប់កម្មវិធី និងអនុកម្មវិធីនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំផងដែរ។

**នាយកដ្ឋានពិនិត្យតាមដាននិងវាយតម្លៃ** ទទួលខុសត្រូវក្នុងការណែនាំ និងតម្រង់ទិសស្តីពីក្របខ័ណ្ឌពិនិត្យតាមដានទាំងមូល។ នាយកដ្ឋាននេះ ក៏ទទួលបន្ទុកពិនិត្យតាមដានការអនុវត្តគោលនយោបាយ ផែនការ កម្មវិធី និងគម្រោងអភិវឌ្ឍន៍ក្នុងវិស័យអប់រំគ្រប់កម្រិត រៀបចំរបាយការណ៍ពិនិត្យតាមដានតាមកាលកំណត់ និងទទួលខុសត្រូវសំខាន់ក្នុងការរៀបចំសន្និបាតអប់រំថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត ព្រមទាំងធ្វើសេចក្តីសង្ខេបអនុសាសន៍ និងខ្លឹមសារនៃសន្និបាតអប់រំថ្នាក់រាជធានី-ខេត្ត សម្រាប់ជាធាតុចូលទៅក្នុងរបាយការណ៍សន្និបាតអប់រំថ្នាក់ជាតិ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**នាយកដ្ឋានគាំទ្រ** ផ្តល់ការគាំទ្រដល់បុគ្គលិកថ្នាក់រាជធានី-ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់ការអនុវត្តការពិនិត្យតាមដាន និងធ្វើរបាយការណ៍ពីកម្មវិធីនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី-ខេត្ត។

នាយកដ្ឋានចំនួន ៣ ផ្សេងទៀត មានទំនួលខុសត្រូវលើការងារអធិការកិច្ច និងសវនកម្មផ្ទៃក្នុង៖

**នាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ**

- ធ្វើការសិក្សាស្រាវជ្រាវ វិភាគ និងវាយតម្លៃលើគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពការងារអប់រំ យុវជន និងកីឡានៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន
- ធ្វើអធិការកិច្ចសាលារៀន លើលទ្ធផលសិក្សារបស់សិស្ស ការបង្រៀន និងរៀន ការចូលរួមរបស់សហគមន៍ ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន និងគណនេយ្យភាពរបស់សាលារៀននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន
- វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតអប់រំចំណេះទូទៅ នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន
- ពិនិត្យតាមដានវឌ្ឍនភាពគ្រឹះស្ថានសិក្សាដែលរងអធិការកិច្ច
- វាយតម្លៃ និងផ្តល់វិញ្ញាបនបត្របញ្ជាក់សមត្ថភាពកម្រិតសមមូលសម្រាប់មធ្យមសិក្សាចំណេះទូទៅ
- ធ្វើអធិការកិច្ច និងលើកសំណើដោះស្រាយករណីមិនប្រក្រតីស្របតាមដែនសមត្ថកិច្ច
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ។

**នាយកដ្ឋានអធិការកិច្ច និងបណ្តឹងតវ៉ា**

- ធ្វើអធិការកិច្ចក្នុងសមត្ថកិច្ចតាមការកំណត់របស់ក្រសួង ដើម្បីធានាបានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព គណនេយ្យភាព ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ធ្វើអធិការកិច្ចដោយផ្អែកលើអភិក្រមហានិភ័យ និងករណីសង្ស័យ នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ គ្រឹះស្ថានសាធារណៈ និងគ្រឹះស្ថានឯកជន
- ទទួល និងធ្វើអធិការកិច្ចតាមពាក្យបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល និងមជ្ឈដ្ឋានពាក់ព័ន្ធស្របតាមដែនសមត្ថកិច្ច
- ធ្វើរបាយការណ៍លទ្ធផលអធិការកិច្ចជូនអគ្គាធិការ ថ្នាក់ដឹកនាំក្រសួង ក្រសួងអធិការកិច្ច និងប្រមុខរាជរដ្ឋាភិបាល។

**នាយកដ្ឋានសវនកម្មផ្ទៃក្នុង**

- ពិនិត្យឡើងវិញអំពីភាពត្រឹមត្រូវ ភាពទាន់ពេលវេលា និងភាពច្បាស់លាស់នៃព័ត៌មានហិរញ្ញវត្ថុ និងកិច្ចសហប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រ ដើម្បីធានានូវអនុលោមភាពតាមគោលការណ៍ធ្វើផែនការ និងនីតិវិធីច្បាប់

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- វាយតម្លៃប្រសិទ្ធភាពនៃវិធីសាស្ត្រតាមបែបសេដ្ឋកិច្ច និងផលប៉ះពាល់វិជ្ជមានស្តីពីការប្រើប្រាស់ធនធាន
- ធ្វើសវនកម្មតាមប្រព័ន្ធបច្ចេកវិទ្យាតាមកាលកំណត់ និងវាយតម្លៃមូលដ្ឋានទិន្នន័យសំខាន់ៗ ដើម្បីធានាថាប្រព័ន្ធទាំងនេះដោះស្រាយគោលដៅ និងវត្ថុបំណងដែលរំពឹងទុក
- រៀបចំផែនការយុទ្ធសាស្ត្រសវនកម្មបីឆ្នាំរំកិល និងផែនការសវនកម្មប្រចាំឆ្នាំ ដោយផ្តោតលើដំណើរការមានហានិភ័យ
- ធ្វើសវនកម្មជាប្រចាំនៅអង្គភាពក្រោមឱវាទក្រសួង ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិការនានា សំដៅសម្រេចបាននូវគោលបំណងតាមការរំពឹងទុក ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- វាយតម្លៃដោយឯករាជ្យលើប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងអភិបាលកិច្ចល្អ
- ធ្វើរបាយការណ៍ផ្ទាល់ជូនរដ្ឋមន្ត្រី និងផ្តល់របាយការណ៍ប្រចាំឆ្នាំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ ក្រសួងអធិការកិច្ច និងអាជ្ញាធរសវនកម្មជាតិ។

**មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត** រៀបចំ និងពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី-ខេត្តរបស់ខ្លួន។ វឌ្ឍនភាពនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី-ខេត្ត ត្រូវរាយការណ៍ក្នុងអំឡុងពេលសន្និបាតអប់រំថ្នាក់រាជធានី-ខេត្ត បន្ទាប់ពីគោលការណ៍ណែនាំរបស់ក្រសួង។

**ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ** រៀបចំផែនការការងារប្រចាំឆ្នាំផ្អែកលើផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី-ខេត្ត និងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស។ ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ គាំទ្រការអនុវត្ត ការពិនិត្យតាមដាន និងផ្សព្វផ្សាយពីផែនការរបស់ក្រុង ស្រុក ខណ្ឌ ដល់សាលារៀន។

**សាលារៀន** ដែលមានការគាំទ្រពីគណៈកម្មការគ្រប់គ្រងសាលារៀន រៀបចំ អនុវត្ត និងពិនិត្យតាមដានវឌ្ឍនភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ហើយផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាព និងរបាយការណ៍ការចំណាយថវិកាកម្មវិធីទៅឱ្យការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ** មាននៅថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត គឺជាតួអង្គសំខាន់រួមមានទាំងក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍ។ ក្រុមការងារនេះ មានគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការរវាងដៃគូ ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផ្តល់នូវព័ត៌មានស្តីពីមូលនិធិភាពជាដៃគូ ផ្តល់ដំណឹងដល់សមាជិករបស់ខ្លួនអំពីកម្មវិធីកំណែទម្រង់សំខាន់ៗដែលគាំទ្រដោយដៃគូអភិវឌ្ឍ ដូចជា កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងផែនការអភិវឌ្ឍន៍ធនធានមនុស្ស។ ក្រុមការងារនេះ ពិនិត្យឡើងវិញរបាយការណ៍ស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការក្នុងអំឡុងពេលសន្និបាតអប់រំ និងអង្គវិបស្សនាអប់រំ និងពង្រឹងសមត្ថភាពតាមរយៈសិក្ខាសាលាបណ្តុះបណ្តាលប្រចាំឆ្នាំផងដែរ។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិ រៀបចំកិច្ចប្រជុំរៀងរាល់ត្រីមាស ដោយពិភាក្សាអំពីអាទិភាពគោលនយោបាយ ការអនុវត្តកំណែទម្រង់អប់រំ និងហិរញ្ញប្បទានសហប្រតិបត្តិការ។ ចំណែកឯក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី-ខេត្ត គាំទ្រដល់ការរៀបចំផែនការ ការរៀបចំថវិកា និងធ្វើរបាយការណ៍សម្រាប់សកម្មភាពរបស់រាជធានី-ខេត្ត តាមក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់រាជធានី-ខេត្ត។ ជាពិសេស ផ្តល់ធាតុចូលសម្រាប់រៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់រាជធានី-ខេត្ត ផែនការយុទ្ធសាស្ត្រថវិកា ការចំណាយថវិកាកម្មវិធី និងផែនការការងារប្រចាំឆ្នាំ។

## ៥.៣ សូចនាករពិនិត្យតាមដាន និងវាយតម្លៃ

ការបំពេញការងារនៃវិស័យអប់រំ ត្រូវពិនិត្យតាមដាននិងវាយតម្លៃតាមរយៈការត្រួតពិនិត្យជាប្រចាំនៃសូចនាករផលសម្រេច សូចនាករលទ្ធផលមួយចំនួន និងចំណុចដៅដែលបង្ហាញក្នុងជំពូកទី៣។ បរិការណ៍នេះនឹងផ្តល់ព័ត៌មានអំពីសមិទ្ធផលនៃវត្ថុបំណងជាក់លាក់របស់អនុកម្មវិធីនីមួយៗ។ អង្គភាពទទួលបន្ទុកលើការពិនិត្យតាមដាន វិធីសាស្ត្រគណនា និងប្រភពទិន្នន័យទាក់ទងនឹងសូចនាករនីមួយៗ មានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០២៤-២០២៨។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## ជំពូកទី៦៖ ការកំណត់ហានិភ័យចម្បងៗ និងជម្រើសកាត់បន្ថយ

ផែនការយុទ្ធសាស្ត្រនេះ មានវត្ថុបំណងប្រកបដោយមហិច្ឆតាមួយចំនួន និងយុទ្ធសាស្ត្រជាច្រើន ដែលត្រូវអនុវត្តឱ្យបានជោគជ័យ ដែលតម្រូវឱ្យមានការផ្លាស់ប្តូរយ៉ាងស៊ីជម្រៅក្នុងការគ្រប់គ្រងប្រព័ន្ធអប់រំ។ ម្យ៉ាងវិញទៀត ផែនការនេះ គឺមិនមែនថាមិនមានហានិភ័យនោះទេ។ ជំពូកនេះ ការកំណត់ហានិភ័យចម្បងៗ មានភាពច្បាស់លាស់ និងបានកំណត់នូវអន្តរាគមន៍មួយចំនួនរួចទៅហើយនៅក្នុងផែនការនេះ ដើម្បីជួយបញ្ចៀសការកើតឡើងនូវហានិភ័យទាំងនេះ និងជម្រើសកាត់បន្ថយបន្ថែមទៀត។

ជំពូកនេះ បានផ្សារភ្ជាប់យ៉ាងស្អិតរមួតទៅនឹងក្របខ័ណ្ឌពិនិត្យតាមដាននិងវាយតម្លៃ ការអនុវត្តការពិនិត្យតាមដាននិងវាយតម្លៃផ្សេងៗគ្នា មានគោលបំណងវាយតម្លៃថាតើមានវឌ្ឍនភាពឆ្ពោះទៅការអនុវត្តយុទ្ធសាស្ត្រ និងការសម្រេចបានវត្ថុបំណងដែរឬទេ។ ទន្ទឹមនឹងនេះ មានការយកចិត្តទុកដាក់ជាពិសេសលើហានិភ័យដែលគំរាមកំហែងដល់វឌ្ឍនភាព។ ប្រសិនបើវឌ្ឍនភាពមិនមានលក្ខណៈគ្រប់គ្រាន់ ឬមិនបានសម្រេច វិធានការកាត់បន្ថយនេះ ចាំបាច់ត្រូវពិនិត្យឡើងវិញ។ នេះគឺជាផ្នែកដ៏សំខាន់នៃផែនការយុទ្ធសាស្ត្រដែលនៅតែពាក់ព័ន្ធការសម្របទៅនឹងការផ្លាស់ប្តូរផ្នែកបរិស្ថាន និងមុខងារនៃវឌ្ឍនភាព។

### ៦.១ ហានិភ័យខាងក្រៅដែលជះឥទ្ធិពលដល់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ

- **ការប្រែប្រួលអាកាសធាតុ៖** ផលប៉ះពាល់មានការកើនឡើង និងញឹកញាប់ការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរ ជាពិសេស គ្រោះរាំងស្ងួត និងទឹកជំនន់ អាចមានផលវិបាកជាអវិជ្ជមានលើការចូលរៀន និងការសិក្សា។ ការប៉ាន់ស្មានមួយចំនួនបង្ហាញថា៖ ការអប់រំរបស់សិស្សកម្ពុជាប្រមាណ ១ ភាគរយ មានការរំខានជារៀងរាល់ឆ្នាំដោយសារទឹកជំនន់។ ទោះជាយ៉ាងណាក៏ដោយ ទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ និងការអប់រំមិនមានភាពច្បាស់លាស់។

ការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរ អាចមានផលប៉ះពាល់ដល់ប្រព័ន្ធអប់រំដោយផ្ទាល់ ធ្វើឱ្យជីវិត និងសុខុមាលភាពរបស់កុមារ និងគ្រូបង្រៀនស្ថិតក្នុងហានិភ័យ និងបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធអប់រំ និងប៉ះពាល់ដោយប្រយោល ទាក់ទងនឹងអសន្តិសុខស្បៀង ពលកម្មកុមារ និងការធ្វើចំណាកស្រុកដោយបង្ខំ។ យោងតាមមជ្ឈមណ្ឌលពិនិត្យតាមដានការផ្លាស់ទីលំនៅក្នុងស្រុកឆ្នាំ២០២៣ មានការផ្លាស់ទីលំនៅក្នុងស្រុកចំនួន ១៥ ០០០ នៅឆ្នាំ២០២១។ បន្ថែមពីលើនេះទៀត ទោះបីជាការប្រែប្រួលអាកាសធាតុ ជាបាតុភូតសកលក៏ដោយ មិនមែនប្រជាពលរដ្ឋទាំងអស់នឹងរងផលប៉ះពាល់ស្មើគ្នានោះទេ។ ផលវិបាកនៃអាកាសធាតុនឹងប៉ះពាល់ដល់សិស្សានុសិស្សនៅតាមតំបន់ងាយរងគ្រោះពីគ្រោះធម្មជាតិ និងគ្រួសារដែលមានចំណេះដឹងតិចក្នុងការដោះស្រាយបញ្ហា និងស្តារឡើងវិញពីគ្រោះមហន្តរាយ។

  - **ជម្រើសកាត់បន្ថយ៖** ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដាក់បញ្ចូលនូវវិធានការបន្សាំ មួយចំនួនរួចហើយ ដូចជា ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាលារៀនដែលធន់នឹងអាកាសធាតុ ការរៀបចំផែនការប្រតិបត្តិស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់វិស័យអប់រំ ក៏ដូចជាវិធានការ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ចីរភាពបរិស្ថានមួយចំនួន ដូចជាការបញ្ចូលមេរៀនការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សា។ ជាការចាំបាច់ ត្រូវពិនិត្យតាមដានការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃវិធានការទាំងនេះ និងវាយតម្លៃលទ្ធផល។ មេរៀនពិសោធន៍បន្ថែមទៀតពីការវាយតម្លៃនៃការអនុវត្ត និងប្រសិទ្ធភាពនៃផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពជាតិកន្លងមក ដែលផ្តោតលើការដាក់បញ្ចូលបញ្ហាការប្រែប្រួលអាកាសធាតុក្នុងវិស័យអប់រំ (ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុសម្រាប់ការអប់រំឆ្នាំ២០១៣ ផែនការសកម្មភាពការប្រែប្រួលអាកាសធាតុសម្រាប់ការអប់រំឆ្នាំ២០១៤-២០១៨)។ ការពិនិត្យឡើងវិញពីការទទួលខុសត្រូវ និងបន្ទាត់គណនេយ្យភាពសម្រាប់ការប្រែប្រួលអាកាសធាតុនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា អាចរួមចំណែកធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួល និងពង្រឹងភាពស៊ីសង្វាក់គ្នាក្នុងសកម្មភាពនានា ដើម្បីបង្កើនភាពធន់នៃប្រព័ន្ធអប់រំចំពោះការប្រែប្រួលអាកាសធាតុ។ ធនធានរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុជាភស្តុតាងបង្ហាញឱ្យឃើញពីការប្តេជ្ញាចិត្តក្នុងការចំណាយ ២,១ ភាគរយ នៃផលិតផលក្នុងស្រុកសរុបស្តីពីអាទិភាពសកល។

- **កំណើនផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំ៖** ការផ្តល់ហិរញ្ញប្បទានរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ គឺផ្អែកលើការប៉ាន់ស្មានកម្រិតណាមួយនៃកំណើនប្រចាំឆ្នាំនៃផលិតផលក្នុងស្រុកសរុប។ ខណៈដែលបដិភាគនៃថវិការបស់រាជរដ្ឋាភិបាលនៃផ.ស.ស មិនមានការកើនឡើង នាំឱ្យបដិភាគថវិកាអប់រំរបស់រាជរដ្ឋាភិបាលមិនប្រែប្រួលសម្រាប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ កំណើន ផ.ស.ស ប្រចាំឆ្នាំ ប៉ាន់ស្មានប្រហែល ៦ ភាគរយ នាំឱ្យមានការកើនឡើងគួរឱ្យកត់សម្គាល់សម្រាប់ថវិកាអប់រំ។ ការប៉ាន់ស្មាននេះ គឺផ្អែកលើបរិយាកាសសេដ្ឋកិច្ចសកលបច្ចុប្បន្ន ដែលមិនសូវមានសុទិដ្ឋិនិយមខ្លាំងលើកំណើនសេដ្ឋកិច្ច។ ខណៈដែលប៉ុន្មានឆ្នាំថ្មីៗនេះ បានបង្ហាញថា បរិយាកាសសកលមិនអាចទស្សន៍ទាយទុកជាមុនបានហើយ ផ.ស.ស រងផលប៉ះពាល់ មិនត្រឹមតែព្រឹត្តិការណ៍សេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរងការប៉ះទង្គិចពីអាកាសធាតុ ឬជំងឺរាតត្បាតផងដែរ។ កំណើន ផ.ស.ស ប្រចាំឆ្នាំយឺត នឹងនាំទៅរកការវិភាជន៍ធនធានដល់ការអប់រំតិចជាងការធ្វើចំណោលនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។
    - **ជម្រើសកាត់បន្ថយ៖** កំណើន ផ.ស.ស ពិត គួរតែពិនិត្យតាមដាន ហើយម៉ូដែលវិភាគតម្រូវការអប់រំត្រូវធ្វើបច្ចុប្បន្នកម្មជាមួយនឹងទិន្នន័យជាក់ស្តែង ដើម្បីពិនិត្យឡើងវិញពីសេណារីយ៉ូ ការធ្វើចំណោល និងការប៉ាន់ស្មានឡើងវិញនូវធនធានហិរញ្ញវត្ថុដែលមាន បន្ទាប់មកចំណុចដៅ និងតម្រូវការចំណាយណាខ្លះគួរតែកែតម្រូវ។ ការឆ្លើយតបទី១ ទៅនឹងការវិភាជន៍ធនធានដល់ការអប់រំកាន់តែតិច ត្រូវគិតពីអាទិភាពសំខាន់ និងអាទិភាពមិនសូវសំខាន់ ឬអាទិភាពមិនសូវបន្ទាន់ និងការផ្តល់ថវិកាដូចពិដានមុនៗ។ ការឆ្លើយតបទីពីរ ការបង្កើនមូលនិធិបម្រុងទុកដែលមានសារៈសំខាន់ដល់ការអប់រំ ក្នុងករណីមានវិបត្តិសេដ្ឋកិច្ច។ ការឆ្លើយតបនេះ នឹងកាន់តែមាន

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

លទ្ធភាពច្រើនក្នុងអំឡុងឆ្នាំដែលថវិកាអប់រំខ្ពស់ជាងការរំពឹងទុក ឬនៅពេលដែលមានការលំបាកក្នុងការអនុវត្តសកម្មភាពដែលបានគ្រោងទុក ឧទាហរណ៍ ដោយសារការដាក់ឱ្យអនុវត្តកម្មវិធីថ្មីៗមានការយឺតយ៉ាវ។ ការឆ្លើយតបចុងក្រោយ យុទ្ធសាស្ត្រចរចា ដូចគ្នានឹងជំពូកស្តីពីការចំណាយ និងហិរញ្ញប្បទានអប់រំ ស្នើឱ្យបំពេញគម្លាតដែលមានស្រាប់ក្នុងការផ្តល់ថវិកាអាចមានសារៈប្រយោជន៍ក្នុងបរិបទនេះ។

- **ប្រាក់ចំណូលគ្រួសារ៖** វិបត្តិសេដ្ឋកិច្ចមិនគ្រាន់តែគំរាមកំហែងដល់ប្រាក់ចំណូលរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ក៏គំរាមកំហែងដល់ប្រាក់ចំណូលគ្រួសារផងដែរ។ នាពេលបច្ចុប្បន្ន គ្រួសារបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការចំណាយសរុបនៃប្រព័ន្ធអប់រំភាគច្រើន តាមរយៈការចំណាយប្រាក់ដោយផ្ទាល់ដល់សាលារៀន។ ប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ច គ្រួសារក្រីក្របំផុតនឹងមិនមានលទ្ធភាពផ្តល់ប្រាក់សូម្បីតែការរួមចំណែកតិចតួចក្នុងប្រព័ន្ធអប់រំ។ ព័ត៌មាននៅកម្ពុជាបានបង្ហាញថា ការបញ្ជូនកូនទៅធ្វើការ គឺជាយុទ្ធសាស្ត្រដំណោះស្រាយដែលគ្រួសារប្រើប្រាស់ នៅពេលដែលប្រាក់ចំណូលរបស់ពួកគេរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ជាពិសេសការខូចខាតដំណាំ។
    - **ជម្រើសកាត់បន្ថយ៖** ផែនការយុទ្ធសាស្ត្របានដាក់បញ្ចូលរួចមកហើយនូវអន្តរាគមន៍ផ្សេងៗដើម្បីកាត់បន្ថយបន្ទុកគ្រួសារក្រីក្របំផុត ដោយបានរៀបចំបញ្ចីកម្មវិធីអាទិភាព រួមទាំងការផ្តល់អាហារូបករណ៍ មធ្យោបាយធ្វើដំណើរសម្រាប់កុមារដែលរស់នៅឆ្ងាយពីសាលារៀន និងជួយបង្រៀនសិស្សឱ្យចំមុខសញ្ញា ដែលត្រូវការជំនួយបន្ថែម ដើម្បីឱ្យពួកគេបន្តរៀន។ យុទ្ធសាស្ត្រលើកទឹកចិត្តមួយទៀត គឺមូលនិធិស្ម័គ្រចិត្តរបស់សាលារៀន៖ នៅក្នុងសហគមន៍សាលារៀនមាតាបិតាដែលមានជីវភាពធូរធារភាគច្រើន បានចូលរួមចំណែកដោយស្ម័គ្រចិត្ត ដើម្បីជួយដល់សិស្សក្រីក្របំផុត ២០ ភាគរយ មិនអាចមានលទ្ធភាពបន្តការសិក្សា។ ចាំបាច់ត្រូវពិនិត្យតាមដានជាប្រចាំ (យ៉ាងហោចណាស់ ត្រូវពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ) ការវិវត្តនៃសូចនាករបែងចែកភេទស្តីពី ការចុះឈ្មោះចូលរៀន ការចូលរួម និងការបំពេញការងារ ដើម្បីរកឱ្យឃើញនូវសញ្ញារំលឹកជាមុន ដែលមានការកើនឡើងនៃភាពខុសគ្នា។ ការអនុវត្តមូលនិធិស្ម័គ្រចិត្តរបស់សាលារៀន នៅតាមក្រុង ស្រុក ខណ្ឌ ឬរាជធានី-ខេត្ត (ពោលគឺការវិភាជន៍ធនធានបន្ថែមទៀតដល់សាលារៀនដែលខ្វះខាតបំផុតនៅតាមក្រុង ស្រុក ខណ្ឌ ឬក្រុង ស្រុក ខណ្ឌដែលខ្វះខាតបំផុតក្នុងរាជធានី-ខេត្ត) ដែលជាជម្រើសបន្ថែមគួរជាទីចាប់អារម្មណ៍ផងដែរ។

## ៦.២ ហានិភ័យខាងក្នុងដែលជះឥទ្ធិពលដល់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងការរៀបចំយុទ្ធសាស្ត្រក្នុងការអនុវត្ត

- **សាលារៀនគំរូ និងការកែលម្អគុណភាពប្រព័ន្ធទាំងមូល៖** អាទិភាពសំខាន់នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ គឺដើម្បីលើកកម្ពស់គុណភាពនៃប្រព័ន្ធអប់រំ និងលទ្ធផលការសិក្សារបស់សិស្ស។ យុទ្ធសាស្ត្រជាច្រើននឹងរួមចំណែកដល់ការកែលម្អនេះ៖ លទ្ធភាពមានធនធានកាន់តែច្រើន និងគុណភាពកាន់តែ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ខ្ពស់សម្រាប់សាលារៀន និងគ្រូបង្រៀន ព្រឹត្តិបត្រព័ត៌មានគ្រូបង្រៀនបានកែលម្អដំណើរការគាំទ្រ និងការត្រួតពិនិត្យកាន់តែរឹងមាំ ការសិក្សាពេញមួយថ្ងៃ ការគ្រប់គ្រងសាលារៀនកាន់តែមានប្រសិទ្ធភាព និងការប្រើប្រាស់លទ្ធផលវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកាន់តែប្រសើរ ដើម្បីបញ្ចូលទៅការរៀបចំគោលនយោបាយ។ ខណៈពេលដែលគោលបំណងរួម គឺដើម្បីធ្វើបរិវត្តកម្មប្រព័ន្ធសាលារៀនទាំងមូល យុទ្ធសាស្ត្រមួយចំនួន គឺផ្តោតលើក្រុមសាលាដែលបានជ្រើសរើស ដោយរំពឹងថានឹងប្រែក្លាយទៅជា «សាលារៀនគំរូ»។ ជាមហិច្ឆតា គឺសាលារៀនគំរូទាំងនេះនឹងជួយកំណត់នូវអន្តរាគមន៍នានាដែលមានចំណាយទាប អាចពង្រីកនៅទូទាំងប្រព័ន្ធ ហើយនឹងជួយបំផុសគំនិត និងជំរុញឱ្យសាលារៀនផ្សេងៗទៀត ឆ្ពោះទៅរកការបំពេញការងារកាន់តែប្រសើរឡើង។ ទោះជាយ៉ាង ហានិភ័យដែលអាចកើតមាននោះគឺ មានសាលារៀនតែមួយចំនួនប៉ុណ្ណោះឆ្លើយតបតាមស្តង់ដាសាលារៀនគំរូ ដែលផលប៉ះពាល់លើគុណភាពមិនមាន់មានសារៈសំខាន់ និងមិនទាន់សម្រេចបាននូវការផ្លាស់ប្តូរជាលក្ខណៈប្រព័ន្ធលើផ្នែកគុណភាព ដែលក្នុងនោះហានិភ័យនៃគម្លាតកាន់តែកើនឡើងរវាង «សាលារៀនគំរូ» ដែលទទួលបានជោគជ័យ និងសាលារៀនផ្សេងទៀត ។

- **ជម្រើសកាត់បន្ថយ៖** ចាំបាច់ត្រូវមានការពិនិត្យតាមដាននិងវាយតម្លៃឱ្យសមស្របនៃការវិវត្តការបំពេញការងាររបស់សាលារៀនទាំងអស់ និងផលប៉ះពាល់ពិសេសនៃការដាក់ឱ្យអនុវត្តស្តង់ដាសាលារៀនគំរូស្តីពីការកែលម្អការបំពេញការងារ និងលទ្ធផលសិក្សារបស់សិស្សនឹងត្រូវពិនិត្យ។ កិច្ចខិតខំប្រឹងប្រែង នឹងធានាថាមេរៀនពិសោធតាមរយៈការដាក់ឱ្យអនុវត្តស្តង់ដាសាលារៀនគំរូអាចបង្កើតបានផលវិជ្ជមានប្រកបដោយចីរភាពនៅតាមកម្រិតជាលក្ខណៈប្រព័ន្ធ។ ភស្តុតាងជាសកលចង្អុលបង្ហាញពីសារៈសំខាន់នៃការពង្រឹងអភិបាលកិច្ច និងភាពជាអ្នកដឹកនាំដែលបានណែនាំនៅថ្នាក់ក្រោមជាតិ និងទប់ស្កាត់នូវការលេចឡើងនៃវិសមភាព តាមរយៈការដោះស្រាយតម្រូវការរបស់សាលារៀន និងសហគមន៍ ដែលខ្វះខាតធនធានហិរញ្ញវត្ថុ មនុស្ស បច្ចេកទេស និងធនធានស្ថាប័ន ដើម្បីចូលរួមក្នុងការស្វ័យកែលម្អ។ ភស្តុតាងស្តីពីប្រសិទ្ធភាពនៃការដាក់ឱ្យអនុវត្តស្តង់ដាសាលារៀនគំរូ ដើម្បីលើកកម្ពស់ការកែលម្អសាលារៀនប្រកបដោយសមធម៌ និងកែលម្អការសិក្សារបស់សិស្ស គួរតែផ្តល់ព័ត៌មានត្រឡប់ទៅដល់ការរៀបចំគោលនយោបាយ។

- **ការគ្រប់គ្រងសាលារៀន និងសាលារៀនជួបការលំបាក៖** ផែនការយុទ្ធសាស្ត្រវិស័យអប់រំ គិតគូរពីការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាពកាន់ច្រើនទៀត ជាយុទ្ធសាស្ត្រគន្លឹះមួយ ដើម្បីកែលម្អគុណភាព និងអភិបាលកិច្ច។ បរិបកិារណ៍នេះ គឺស្របតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំកន្លងមក និងឆ្លុះបញ្ចាំងពីគុណភាពព័ត៌មាន ដែលបង្ហាញថាសាលារៀនមានការគ្រប់គ្រងបានល្អ នាំទៅរកការកែលម្អលទ្ធផលសិស្សកាន់តែប្រសើរ ដើម្បីសម្រេចបាននូវការគ្រប់គ្រងកាន់តែរឹងមាំថែមទៀត ទាល់តែសាលារៀនទទួលបានស្វ័យភាពមុខងារកាន់តែច្រើន។ ហានិភ័យដែលមានចំពោះយុទ្ធសាស្ត្រនេះ គឺមិនមែនសាលារៀនទាំងអស់ទទួលបានអត្ថប្រយោជន៍ដូចគ្នាពីស្វ័យភាពទេ ដោយសារសាលារៀន



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

មានលក្ខណៈស្ថានភាពផ្សេងៗគ្នាទាក់ទងនឹងសមត្ថភាព ធនធាន និងបរិបទ។ សាលារៀនដែលស្ថិតនៅក្នុងសហគមន៍ជួបការលំបាក និងងាយរងគ្រោះ ប្រហែលជាមិនអាចកែលម្អដោយខ្លួនឯងបានទេ ហើយវិសមភាពអាចនឹងកើនឡើង។

- **ជម្រើសកាត់បន្ថយ៖** ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ អាចឱ្យយើងដឹងពីហានិភ័យ។ ជាឧទាហរណ៍ កម្មវិធីសាលារៀនគំរូ ផ្ដោតលើការជំរុញសាលារៀនឱ្យមានសមត្ថភាពកាន់តែច្រើន និងមានស្វ័យភាពកាន់តែទូលំទូលាយ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ បានដាក់បញ្ចូលនូវយុទ្ធសាស្ត្រនានា ដែលមានគោលបំណងពង្រឹងការត្រួតពិនិត្យ និងការគាំទ្រដល់សាលារៀនដែលងាយរងគ្រោះ។ កិច្ចការសំខាន់នោះ គឺបុគ្គលិកអប់រំនៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ត្រូវបានលើកទឹកចិត្តឱ្យបំពេញការងារ ដោយសារបទពិសោធន៍បានបង្រៀនថា ជាធម្មតាសម្រាប់ការអនុវត្ត ក៏ដូចជាហេតុផលវិជ្ជាជីវៈ ការធ្វើការជាមួយសាលារៀនដែលមានដំណើរការល្អ គឺងាយស្រួលជាងសាលារៀនដែលដំណើរការមិនល្អ និងសាលារៀនដែលជួបការលំបាក។

- **សមត្ថភាពថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ៖** អ្វីដែលបានអនុវត្តចំពោះសាលារៀន គឺត្រូវអនុវត្តចំពោះរាជធានី-ខេត្ត និងក្រុង ស្រុក ខណ្ឌ ផងដែរ។ ការអនុវត្តនេះ ស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ស្វ័យភាពកាន់តែច្រើន ជាពិសេសនៅក្នុងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ។ ពិសេសជាងនេះទៀត គោលនយោបាយជាតិត្រូវសម្របទៅនឹងពិពិធកម្មនៃតថភាពនៅតាមមូលដ្ឋាន។ ហានិភ័យ គឺថា ផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់រាជធានី-ខេត្ត មិនសូវមានភាពប្រទាក់ក្រឡាគ្នានឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលអាចបង្កើនវិសមភាព ដោយសារសមត្ថភាពមានកម្រិតខុសៗគ្នាក្នុងការរៀបចំផែនការ ការអនុវត្តយុទ្ធសាស្ត្រ និងការគាំទ្រដល់សាលារៀននិងគ្រូបង្រៀន។
  - **ជម្រើសកាត់បន្ថយ៖** ផែនការយុទ្ធសាស្ត្រវិស័យអប់រំ បានដាក់បញ្ចូលអនុកម្មវិធីមួយ និងមានអន្តរាគមន៍ជាច្រើន ក្នុងគោលបំណងពង្រឹងសមត្ថភាពមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឧទាហរណ៍ តាមរយៈការអភិវឌ្ឍវិជ្ជាជីវៈ ការគាំទ្រ ការណែនាំ និងការផ្ដល់ធនធានចាំបាច់។ ប្រសិនបើក្នុងអំឡុងពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ប្រាកដណាស់ថា រាជធានី-ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ មួយចំនួនជួបប្រទះបញ្ហាប្រឈមធ្ងន់ធ្ងរជាងរាជធានី-ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ផ្សេងទៀត។ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតនឹងត្រូវធ្វើឡើង ដើម្បីលើកកម្ពស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងដំណើរការរៀបចំផែនការ និងការអនុវត្ត តាមរយៈការផ្ដល់នូវការគាំទ្រពិសេស និងការណែនាំជាប្រចាំ។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- **យេនឌ័រ៖** ផែនការយុទ្ធសាស្ត្រវិស័យអប់រំ មានយុទ្ធសាស្ត្រជាច្រើន ដើម្បីលុបបំបាត់ និងកាត់បន្ថយនិន្នាការនៃការកើនឡើងវិសមភាពយេនឌ័រក្នុងវិស័យអប់រំនៅប៉ុន្មានឆ្នាំចុងក្រោយនេះ តាមរយៈការបង្កើនវិសាលភាពនៃកម្មវិធីអាហារូបករណ៍ ការលើកកម្ពស់ការចូលរួមរបស់សិស្សស្រី ការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យារបស់សិស្សស្រី និងការខិតខំប្រឹងប្រែងបន្តដើម្បីបញ្ជ្រាបយេនឌ័រនៅក្នុងកម្មវិធីសិក្សាអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។ ទោះជាយ៉ាងណា យុទ្ធសាស្ត្រទាំងនេះ មិនអាចធានាថានឹងមានលទ្ធផលដូចការរំពឹងទុកនោះទេ។
    - **ជម្រើសកាត់បន្ថយ៖** ប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ នឹងផ្តល់ព័ត៌មានស្តីពីការវិវត្តនៃវិសមភាពយេនឌ័រ ដែលគួរតែប្រើប្រាស់ដើម្បីវាយតម្លៃ ថាតើយុទ្ធសាស្ត្រដែលបានរៀបចំឡើងកំពុងទទួលបានលទ្ធផលដូចការរំពឹងទុក ទាក់ទងនឹងការកាត់បន្ថយវិសមភាពយេនឌ័រ។ ការកែសម្រួលឡើងវិញនៃផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ២០២០-២០២៥ មានសារៈសំខាន់ ដើម្បីធ្វើបច្ចុប្បន្នកម្ម និងបន្សុីជាមួយនឹងអាទិភាព វត្ថុបំណង និងចំណុចដៅរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

# តារាងឧបសម្ព័ន្ធ

## តារាងឧបសម្ព័ន្ធទី១៖ សូចនាករសមិទ្ធកម្មគន្លឹះ

| ល.រ | សូចនាករសមិទ្ធកម្មគន្លឹះ | ឯកតា | ឆ្នាំគោល ២០២២/២៣ | ឆ្នាំសិក្សា ២០២៣/២៤ | ឆ្នាំសិក្សា ២០២៤/២៥ | ឆ្នាំសិក្សា ២០២៥/២៦ | ឆ្នាំសិក្សា ២០២៦/២៧ | ឆ្នាំសិក្សា ២០២៧/២៨ |
|---|---|---|---|---|---|---|---|---|
| កម្មវិធីទី១៖ កំណែទម្រង់សាលារៀន ដើម្បីទទួលបានការចូលរៀនមានគុណភាព ប្រកបដោយបរិយាបន្ន និងសមធម៌ | | | | | | | | |
| ១.១ | ចំនួនសាលារៀនគំរូ | # | ១២០ | ២៥០ | ៣៥០ | ៥០០ | ៨០០ | ១ ២០០ |
| ១.២ | ភាគរយសិស្សថ្នាក់ទី ១២ ទទួលបាននិទ្ទេស A, B, និង C | % | ១៩,៩% | ២៣,០% | ២៦,០% | ២៩,០% | ៣២,០% | ៣៥,០% |
| កម្មវិធីទី២៖ កែលម្អការចូលរៀន គុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា និងការស្រាវជ្រាវនិងនវានុវត្តន៍ | | | | | | | | |
| ២.១ | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (អាយុ ១៨-២២) | % | ១៤,៧% | ១៨,៩% | ១៧,១% | ១៨,៨% | ២០,១% | ២១,៨% |
| | ប្រុស | % | ១៥,១% | ១៧,៥% | ១៧,៤% | ១៨,៧% | ២០,២% | ២១,៩% |
| | ស្រី | % | ១៤,៣% | ២០,៣% | ១៦,៩% | ១៨,៩% | ២០,០% | ២១,៨% |
| ២.២ | ចំនួនគម្រោងស្រាវជ្រាវដែលភ្ជាប់ជាមួយនឹងតម្រូវការទីផ្សារ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច បានប្រើប្រាស់ដោយ គ្រឹះស្ថានឧត្តមសិក្សា និងឧស្សាហកម្ម | # | N/A | ២២ | ២៥ | ៣០ | ៣៤ | ៤០ |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **កម្មវិធីទី៣៖ ការលើកកម្ពស់ជំនាញសតវត្សរ៍ទី ២១ សម្រាប់យុវជន** | | | | | | | | |
| ៣.១ | ចំនួនយុវជនបានបញ្ចប់កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន | # | ៨៣៥ | ៨៥៩ (មិនរាប់បញ្ចូលក្រៅប្រព័ន្ធ) | ១ ០៧៥ | ១ ១៩៦ | ១ ៣១៦ | ១ ៤៣៦ |
| | យុវជន | # | ៧៥៩ | ៨៥៩ | ៩៥៩ | ១ ០៦០ | ១ ១៦០ | ១ ២៦០ |
| | ក្រៅប្រព័ន្ធ | # | ៧៦ | ៩៦ | ១១៦ | ១៣៦ | ១៥៦ | ១៧៦ |
| ៣.២ | ចំនួនយុវជន និងមនុស្សពេញវ័យបានបញ្ចប់ពីកម្មវិធីអភិវឌ្ឍន៍យុវជន និងមនុស្សពេញវ័យ (សាលារៀនគំរូ និងមជ្ឈមណ្ឌលគោលដៅ) | # | ១ ១៥០ | ១ ៨២០ | ១ ៣១៨ | ១ ៥៦២ | ១ ៨០៦ | ២ ០៥០ |
| | យុវជន | # | N/A | ៧០០ | ១ ១០០ | ១ ២៥០ | ១ ៤០០ | ១ ៥៥០ |
| | មនុស្សពេញវ័យ | # | N/A | ១២៤ | ២១៨ | ៣១២ | ៤០៦ | ៥០០ |
| **កម្មវិធីទី៤៖ ការលើកកម្ពស់សកម្មភាពហាត់ប្រាណ ការអប់រំកាយ និងកីឡា** | | | | | | | | |
| ៤.១ | ចំនួនមេដាយពីការប្រកួតកីឡាអន្តរជាតិ | # | ១០០ | ១០៤ | ១៣៩ | ១១០ | ១៤៦ | ១៥០ |
| ៤.២ | ចំនួនសាលារៀនគំរូបានអនុវត្តកម្មវិធីអប់រំកាយ និងកីឡា | # | N/A | ១៨០ | ២៥០ | ៣០០ | ៤០០ | ៥០០ |
| **កម្មវិធីទី៥៖ ការលើកកម្ពស់ការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម** | | | | | | | | |
| ៥.១ | ភាគរយការទូទាត់ចំណាយថវិកាកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា | % | ៩៥,០% | ៩៥,០% | ៩៥,០% | ៩៥,០% | ៩៥,០% | ៩៥,០% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៥.២ | ចំនួនសាលារៀនដែលបានអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រង | # | N/A | ២៥០ | ៣៥០ | ៥០០ | ៨០០ | ១ ២០០ |
| ៥.៣ | ចំនួនអ្នកឯកទេសអប់រំបានបណ្តុះបណ្តាល និងទទួលស្គាល់ | # | ៥ | ៦៤ | ៩៨ | ១៣២ | ១៦៦ | ២០០ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## តារាងឧបសម្ព័ន្ធទី២៖ សូចនាករផលសម្រេច

| សូចនាករ | ឯកតា | ឆ្នាំគោល ២០២២/២៣ | ឆ្នាំសិក្សា ២០២៣/២៤ | ឆ្នាំសិក្សា ២០២៤/២៥ | ឆ្នាំសិក្សា ២០២៥/២៦ | ឆ្នាំសិក្សា ២០២៦/២៧ | ឆ្នាំសិក្សា ២០២៧/២៨ |
|---|---|---|---|---|---|---|---|
| **កម្មវិធី ១៖ កំណែទម្រង់សាលារៀនដើម្បីការចូលរៀនមានគុណភាព ប្រកបដោយបរិយាបន្ន និងសមធម៌** | | | | | | | |
| **អនុកម្មវិធី ១.១៖ ការអប់រំកុមារតូច** | | | | | | | |
